ក្រសួងអប់រំ យុវជន និងកីឡា

សម្រាប់ឈក់

# វិទ្យាសាស្ត្រ

# គីមីវិទ្យា

## ១២



គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ

ក្រសួងអប់រំ យុវជន និងកីឡា

# គីមីវិទ្យា

## ថ្នាក់ទី ១២

បោះពុម្ពផ្សាយដោយ

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

អគារ ១៤៨ មហាវិថី ព្រះនរោត្តម ភ្នំពេញ

| | | |
|---|---|---|
| **គណៈកម្មការនិពន្ធ** | លោក សួន សុជាតិ<br>លោក ចាន់ ខេង | លោកស្រី អន កិត្យាស៊ី<br>លោក ម៉ី សុវណ្ណី |
| **វាយអត្ថបទ** | លោកស្រី ហាក់ ផាន្នី | |
| **វិចិត្រករ** | លោក តន់ ជាតិ | |
| **រៀបរៀង** | លោក ស៊ុន ប៊ុណ្ណា | |
| **រចនាទំព័រ** | លោក ហាក់ វណ្ណថា | |
| **គណៈកម្មការពិនិត្យ** | លោក ឡុង ឡាយ | លោកស្រី លី សុធឿន |
| **អ្នកឯកទេស** | លោក នេត បារ៉ុម | |

បានទទួលការអនុញ្ញាតឱ្យបោះពុម្ពផ្សាយពី ក្រសួងអប់រំ យុវជន និងកីឡា តាមប្រកាសលេខ ៣២០០ អយក.ប្រក. ចុះថ្ងៃទី ២៩ ខែ ធ្នូ ឆ្នាំ ២០០៩ ដើម្បីប្រើប្រាស់នៅតាមសាលារៀន ។

**ហាមថតចម្លងសៀវភៅនេះ**

រក្សាសិទ្ធិ ©

**គ្រឹះស្ថានបោះពុម្ពនិងចែកផ្សាយ**

បោះពុម្ពឆ្នាំ ២០១៨

ISBN 9-789-995-001-124

# អារម្ភកថា

សៀវភៅគីមីវិទ្យាសម្រាប់សិស្សថ្នាក់ទី 12នេះ គណៈកម្មការនិពន្ធបានតាក់តែងឡើង ដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់សិស្សនិងគ្រូ សម្រាប់រៀននិងបង្រៀនស្របតាមកម្មវិធីសិក្សាថ្មី ។

ខ្លឹមសារមេរៀននិងវិធីសាស្ត្រនៅក្នុងជំពូកនីមួយៗ អ្នកនិពន្ធបានរៀបចំដោយអនុលោមទៅតាមកម្មវិធីសិក្សាថ្មី ហើយបានពណ៌នា បកស្រាយពីច្បាប់ ទ្រឹស្តី ការពិសោធព្រមទាំងបង្ហាញពីតួនាទីនៃឧស្សាហកម្មគីមីក្នុងវិស័យសេដ្ឋកិច្ចនិងបរិស្ថាន ។ លើសពីនេះទៀត នៅចុងជំពូកនីមួយៗមានសំណួរ ពហុជ្រើសរើស បំពេញល្បះ សំណួរត្រិះរិះ និងលំហាត់ដែលស្របតាមលំនាំនៃការប្រឡងសញ្ញាបត្រមធ្យមសិក្សាបឋមភូមិនិងទុតិយភូមិ ។

គណៈកម្មការនិពន្ធសង្ឃឹមថា លោកគ្រូ អ្នកគ្រូ មិត្តអ្នកអានគ្រប់មជ្ឈដ្ឋាននិងជួយផ្តល់យោបល់ ជួយទិតៀនរិះគន់ស្ថាបនា ចំពោះកង្វះខាតនិងការភ្លាំងភ្លាតដែលអាចកើតមានឡើងទាំងផ្នែកខ្លឹមសារ បច្ចេកទេស និងគរុកោសល្យ ដើម្បីជួយកែលម្អសៀវភៅនេះឱ្យកាន់តែប្រសើរឡើងថែមទៀត ។

គណៈកម្មការនិពន្ធ

# បញ្ជីអត្ថបទ

ទំព័រ

ជំពូក1 : ស៊ីនេទិចគីមី ........ 1

1. ល្បឿនប្រតិកម្ម ........ 2

2. កត្តាជះឥទ្ធិពលលើល្បឿនប្រតិកម្ម ........ 8

ជំពូក2 : សមាសធាតុក្នុងសូលុយស្យុងទឹកនិងកម្លាំងអន្តរម៉ូលេគុល ........ 31

1. សមាសធាតុក្នុងសូលុយស្យុងទឹក ........ 32

2. កម្លាំងអន្តរម៉ូលេគុល ........ 42

ជំពូក3 : អាស៊ីតនិងបាស ........ 55

1. ទ្រឹស្តីអាស៊ីតនិងបាស ........ 56

2. ប្រតិកម្មអាស៊ីតនិងបាស ........ 70

3. សូលុយស្យុងទឹកនិង pH ........ 80

4. អត្រាកម្មអាស៊ីតបាស ........ 94

ជំពូក4 : លំនឹងគីមី ........ 107

1. ធម្មជាតិនៃលំនឹងគីមី ........ 108

2. ការរំកិលលំនឹង ........ 117

3. លំនឹងអាស៊ីត បាសនិងអំបិល ........ 132

ជំពូក5 : ឧស្ម័ន ........ 149

1. លក្ខណៈឧស្ម័ន ........ 150

2. ច្បាប់ឧស្ម័ន ........ 160

3. សមាសភាពម៉ូលេគុលឧស្ម័ន ........ 174

ជំពូក6 : គីមីសរីរាង្គ ........ 187

1. អេស្ទែ ខ្លាញ់និងប្រេង ........ 188

2. ស្រឡាយអាលីផាទិចអាសូត ........ 202

3. សមាសធាតុប្រហើរ ........ 220

4. កាបូនអ៊ីដ្រាតនិងលីពីត ........ 234

ជំពូក 1

# ស៊ីនេទិចគីមី



កាំជ្រួចដែលគេបាញ់ នៅពេលរាត្រីមានផ្កាភ្លើងពណ៌ចម្រុះ ។ ផ្កាភ្លើងទាំងនោះបានមកពីចំហេះសារធាតុជាច្រើនដែលក្នុងនោះមានលោហៈផងដែរ ។ រយៈពេលចំហេះនេះ គេអាចវាស់បានតាមរយៈពិសោធន៍ ។ ស៊ីនេទិចគីមី គឺសិក្សាពីការវិវត្តនៃប្រតិកម្មជាមួយនិងរយៈពេល ។

មេរៀនទី

# 1 ល្បឿនប្រតិកម្មគីមី

**ចប់មេរៀននេះ សិស្សអាច**

- ❑ ឱ្យនិយមន័យល្បឿនមធ្យមនិងល្បឿនខណៈកំណអង្គធាតុកកើត ។
- ❑ ឱ្យនិយមន័យល្បឿនមធ្យមនិងល្បឿនខណៈបំបាត់អង្គធាតុប្រតិករ ។
- ❑ គណនារកល្បឿនមធ្យមនិងល្បឿនខណៈនៃប្រតិកម្មគីមីតាមរយៈខ្សែកោង ។

ប្រតិកម្មគីមីដែលបានសិក្សានៅថ្នាក់មុនៗកន្លងមក អង្គធាតុកកើត គឺកើតឡើងភ្លាមៗ នៅពេលគេដាក់អង្គធាតុប្រតិកររលាយចូលគ្នា។ ប្រតិកម្មឱ្យជាកករ ប្រតិកម្មចំហេះ ... ជាប្រតិកម្មប្រព្រឹត្តទៅយ៉ាងរហ័ស ។ តែនៅថ្នាក់ទី 12 នេះ យើងនឹងសិក្សាពីប្រតិកម្មខ្លះៗ ដែលប្រព្រឹត្តទៅក្នុងរយៈពេលច្រើននាទី ច្រើនម៉ោង ឬច្រើនថ្ងៃ ទើបឱ្យកំណអង្គធាតុកកើត ។

ស៊ីនេទិចគីមី គឺសិក្សាពីល្បឿនវិវត្តន៍នៃប្រតិកម្មគីមី ។

## 1. កត្តាពេលក្នុងប្រតិកម្មគីមី

### 1.1. ប្រតិកម្មរហ័ស

ប្រតិកម្មរហ័ស គឺជាប្រតិកម្មដែលប្រព្រឹត្តទៅក្នុងរយៈពេលដ៏ខ្លីមួយ ។

***ឧទាហរណ៍ :*** ប្រតិកម្មសំយោគទឹក ប្រតិកម្មបំបែកសារធាតុផ្ទុះ ប្រតិកម្មអាស៊ីត-បាស ប្រតិកម្មឱ្យផលជាកករ ($Ag^{+}(aq) + Cl^{-}(aq) \longrightarrow AgCl(s)$) ។

### 1.2. ប្រតិកម្មយឺត

ប្រតិកម្មយឺតអាចតាមដានវាបានដោយវិញ្ញាណរបស់យើងឬដោយឧបករណ៍វាស់ក្នុងរយៈពេលច្រើននាទី ច្រើនម៉ោង... ។ ប្រតិកម្មយឺតជាកម្មវត្ថុក្នុងការសិក្សាស៊ីនេទិចគីមី ។




*រូបទី 1.1 កករពណ៌បៃតងនៃ $Fe(OH)_2$ ប្រែជាពណ៌ត្នោតនៃ $Fe(OH)_3$*

***ឧទាហរណ៍ :*** ដែក II អ៊ីដ្រុកស៊ីតប្លែងទៅជាដែក III អ៊ីដ្រុកស៊ីត កាលណាវាត្រូវខ្យល់ ។

$$2Fe(OH)_2(s) + \frac{1}{2}O_2(g) + H_2O(\ell) \longrightarrow 2Fe(OH)_3(s)$$

### 1.3. ប្រតិកម្មយឺតបំផុត

ប្រតិកម្មយឺតបំផុតជាប្រតិកម្មដែលប្រព្រឹត្តទៅក្នុងរយៈពេលច្រើនខែ ច្រើនឆ្នាំ។ ជាទូទៅប្រតិកម្មទាំងនោះ គេមិនអាចសិក្សាស៊ីនេទិចតីមីបានភ្លាមៗនោះទេ ។

***ឧទាហរណ៍ :*** ប្រតិកម្មបំបែកទឹកអុកស៊ីសែន $H_2O_2(aq) \longrightarrow H_2O(\ell) + \frac{1}{2}O_2(g)$ ។

## 2. ល្បឿនប្រតិកម្ម

ការធ្វើចំណែកថ្នាក់ប្រតិកម្មយឺត លឿន និងយឺតបំផុតមានលក្ខណៈមិនសូវច្បាស់លាស់ទេ ។ គេមិនអាចប្រៀបធៀបឬវិភាគទៅលើល្បឿនវិវត្តនៃប្រតិកម្មបានត្រឹមត្រូវ ។ ដើម្បីកំណត់ល្បឿនប្រតិកម្មឱ្យបានត្រឹមត្រូវ គេអាចលើកឡើងសញ្ញាណពីរគឺល្បឿនកំណអង្គធាតុកកើតនិងល្បឿនបំបាត់អង្គធាតុប្រតិករ ។

### 2.1. ល្បឿនកំណអង្គធាតុកកើត

ក. ពិសោធន៍



***រូបទី 1.2 តាមវិធានកាម៉ាទឹកអុកស៊ីសែនអាចរងរេដុកម្មដោយអ៊ីយ៉ុង $I^-$***

យើងសិក្សាពីប្រតិកម្មរវាងទឹកអុកស៊ីសែន ( $H_2O_2$ ) និងអ៊ីយ៉ុងអ៊ីយ៉ូឌួ ( $I^-$ ) ។ សមីការតុល្យការប្រតិកម្ម :

$$H_2O_2(aq) + 2H^+(aq) + 2I^-(aq) \longrightarrow I_2(aq) + 2H_2O(\ell)$$

អង្គធាតុប្រតិករជាអង្គធាតុគ្មានពណ៌ ។ នៅពេលប្រតិកម្មគេសង្កេតឃើញ សូលុយស្យុងប្រែជាពណ៌ត្នោត ដោយសារមានកំណអ៊ីយ៉ូត ( $I_2$ ) ។



***រូបទី 1.3 ក. ល្បាយសូលុយស្យុងនៅខណៈ $t = 0$***
***ខ. ល្បាយសូលុយស្យុងនៅខណៈ $t = 70s$***

បរិមាណអ៊ីយ៉ូតកកើត កើនឡើងទៅតាមពេល ។ ការស្គាល់បរិមាណ $n_{I_2}$ និងកំហាប់អ៊ីយ៉ូត $[I_2]$ នៅខណៈនីមួយៗនាំឱ្យគេអាចសង់ក្រាបដូច(រូបទី 1.4) ។

តាងចំណុច $M_1$ និង $M_2$ នៅលើក្រាប $[I_2] = f(t)$ ។ ចំណុច $M_1$ ត្រូវនឹងខណៈ $t_1$ និងកំហាប់ $[I_2]_1$ ។ ចំណុច $M_2$ ត្រូវនឹងខណៈ $t_2$ និងកំហាប់ $[I_2]_2$ ។



***រូបទី 1.4 បម្រែបម្រួលកំហាប់អ៊ីយ៉ូតទៅតាមពេល***

ខ. ល្បឿនមធ្យមកំណអ៊ីយ៉ូត $I_2$

ល្បឿនមធ្យមកំណអ៊ីយ៉ូត $I_2$ នៅចន្លោះពេល $t_1$ និង $t_2$ គឺជាផលធៀបរវាងបម្រែបម្រួលកំហាប់ $I_2$ និងរយៈពេល $t_2 - t_1$ : $V_m(I_2)_{t_1,t_2} = \frac{[I_2]_2 - [I_2]_1}{t_2 - t_1}$ ឬ $V_m(I_2)_{t_1,t_2} = \frac{\Delta[I_2]}{\Delta t}$

$\Delta[I_2] = [I_2]_2 - [I_2]_1$ និង $\Delta t = t_2 - t_1$

បំណកស្រាយតាមក្រាប : ល្បឿនមធ្យមកំណ $I_2$ នៅចន្លោះពេល $t_1$ និង $t_2$ មានតម្លៃស្មើនិងមេគុណប្រាប់ទិសនៃខ្នាត់$M_1M_2$ លើខ្សែកោង $[I_2] = f(t)$ ត្រង់ចំណុចអាប់ស៊ីស $t_1$ និង $t_2$ ។

ជាទូទៅ : បើតាង P ជាអង្គធាតុកកើតនៅពេលប្រតិកម្ម ល្បឿនមធ្យមកំណអង្គធាតុកកើត P នៅចន្លោះពេល $t_1$ និង $t_2$ តាងដោយទំនាក់ទំនង : $V_m(P)t_1, t_2 = \frac{\Delta[P]}{\Delta t}$

គេនិយមតាងខ្នាតល្បឿនមធ្យមកំណគិតជា: $mol \cdot L^{-1}s^{-1}$ $mol \cdot L^{-1}min^{-1}$ និង $mol \cdot L^{-1}h^{-1}$ ។

***ឧទាហរណ៍ :*** តាមរយៈក្រាបនៅក្នុង(រូបទី 1.4) ។ ចូរកំណត់រកល្បឿនមធ្យមកំណអ៊ីយ៉ូតនៅចន្លោះពេល $t_1 = 50s$ និង $t_2 = 100s$ ។

***ចម្លើយ :***

$$V_m(I_2)_{t_1,t_2} = \frac{[I_2]_2 - [I_2]_1}{t_2 - t_1} = \frac{9.5 \times 10^{-3} - 7.2 \times 10^{-3}}{100 - 50} = 4.6 \times 10^{-5} mol \cdot L^{-1}s^{-1}$$ ។

គ. ល្បឿនខណៈកំណអ៊ីយ៉ូត$I_2$

និយមន័យ : ល្បឿនខណៈ កំណឌីអ៊ីយ៉ូត គឺជាលីមីតនៃល្បឿនមធ្យម កាលណាចន្លោះពេល $\Delta t = t_2 - t_1$ ខិតទៅរកសូន្យ ។ ល្បឿនខណៈនេះជាញឹកញាប់ត្រូវបានគេហៅថាល្បឿនកំណ $I_2$ នៅខណៈ $t_1$ ។ គេតាង ល្បឿនខណៈកំណអ៊ីយ៉ូតនៅខណៈ $t_1$ ដោយ : $V(I_2)_{t_1}$ ។

$$V(I_2)_{t_1} = \lim_{(t_2 - t_1) \to 0} \frac{[I_2]_2 - [I_2]_1}{t_2 - t_1} = \lim_{\Delta t \to 0} \frac{\Delta[I_2]}{\Delta t}$$ ក្នុងលីមីតនេះ គេស្គាល់ថាជាតម្លៃដេរីវេនៅខណៈ $t_1$ នៃអនុគមន៍ $[I_2] = f(t)$ ។ $V(I_2)_{t_1} = \left(\frac{d[I_2]}{dt}\right)t_1$ ។

បំណកស្រាយតាមក្រាបៈ កាលណា $t_2$ ខិតមករក $t_1$ ចំណុច $M_2$ ខិតមករក $M_1$ ហើយខ្នាត់ $M_1M_2$ ទៅជាបន្ទាត់ប៉ះនៃខ្សែកោងត្រង់ចំណុច $M_1$ ។ ដូច្នេះល្បឿនកំណអ៊ីយ៉ូតនៅខណៈ $t_1$ ជាតម្លៃមេគុណប្រាប់ទិសនៃបន្ទាត់ប៉ះខ្សែកោង $[I_2] = f(t)$ ត្រង់ចំណុច $M_1$ អាប់ស៊ីស $t_1$ (រូបទី 1.4) ។

ជាទូទៅ : បើតាង P ជាអង្គធាតុកកើតនៅពេលប្រតិកម្ម ល្បឿនខណៈកំណអង្គធាតុកកើត P នៅខណៈ $t$ : $V(P)_t = \left(\frac{d[P]}{dt}\right)t$ ។

***ឧទាហរណ៍ :*** តាមរយៈខ្សែកោង $[I_2] = f(t)$ (រូបទី 1.4) ។ ចូរកំណត់រកល្បឿនខណៈកំណអ៊ីយ៉ូតនៅខណៈ $t = 50s$ ។

***ចម្លើយ :***

សង់បន្ទាត់ប៉ះនៃខ្សែកោងត្រង់ចំណុច $M_1$ ហើយរកមេគុណប្រាប់ទិសរបស់វា ។ គេជ្រើសរើសចំណុច $T_1$ និង $T_2$ នៅលើបន្ទាត់ប៉ះឱ្យបានឆ្ងាយពីគ្នាបន្តិចដើម្បីឱ្យមានភាពជាក់លាក់ ។

$$V(I_2)_{50} = \frac{[I_2]_2 - [I_2]_1}{t_2 - t_1} = \frac{10 \times 10^{-3} - 5 \times 10^{-3}}{80 - 22} = \frac{5 \times 10^{-3}}{58}$$

$$V(I_2)_{50} = 8.62 \times 10^{-5} mol \cdot L^{-1} s^{-1}$$ ។

## 2.2. ល្បឿនបំបាត់អង្គធាតុប្រតិករ

កំណអ៊ីយ៉ូតនៅពេលប្រតិកម្មនាំឱ្យមានការបាត់បង់អ៊ីយ៉ុងអ៊ីយ៉ូឌួ $I^-$ និងទឹកអុកស៊ីសែន ។ ការស្គាល់បរិមាណ $n_{I^-}$ និងកំហាប់ $[I^-]$ នៅខណៈនីមួយៗ គេអាចសង់ក្រាបដូច(រូបទី 1.5) ។




*រូបទី 1.5 ការវិវត្តកំហាប់របស់អ៊ីយ៉ុងអ៊ីយ៉ូឌួទៅតាមពេល*

### ក. ល្បឿនមធ្យមបំបាត់អ៊ីយ៉ុងអ៊ីយ៉ូឌួ $I^-$

ល្បឿនមធ្យមបំបាត់អ៊ីយ៉ុងអ៊ីយ៉ូឌួ $I^-$ ក្នុងចន្លោះពេល $t_1$ និង $t_2$ គឺជាផលធៀបរវាងបម្រែបម្រួលនៃកំហាប់អ៊ីយ៉ុង $I^-$ និងចន្លោះពេល $\Delta t = t_2 - t_1$ ។

ល្បឿនប្រតិកម្មគឺមីជាទំហំវិជ្ជមាន ដោយសារបម្រែបម្រួល $\Delta[I^-]$ មានតម្លៃអវិជ្ជមាន ព្រោះ $[I^-]_2 < [I^-]_1$ ។ ដូច្នេះគេកំណត់ល្បឿនមធ្យមបំបាត់ $I^-$ ក្នុងចន្លោះពេល $t_1$ និង $t_2$ តាមទំនាក់ទំនង

$$V_m(I^-)_{t_1,t_2} = -\frac{[I^-]_2 - [I^-]_1}{t_2 - t_1} = -\frac{\Delta[I^-]}{\Delta t}$$

បំណកស្រាយតាមក្រាប : ល្បឿនមធ្យមបំបាត់ $I^-$ ក្នុងចន្លោះពេល $t_1$ និង $t_2$ មានតម្លៃផ្ទុយនឹងមេគុណប្រាប់ទិសនៃខ្នាត់ $M_1M_2$ នៃខ្សែកោង $[I^-] = g(t)$ ត្រង់ចំណុចអាប់ស៊ីស $t_1$ និង $t_2$ ។

ជាទូទៅ : បើតាង R ជាអង្គធាតុប្រតិករ ដែលបាត់បង់នៅពេលប្រតិកម្ម គេបាន

ទំនាក់ទំនង: $V_m(R)_{t_1,t_2} = -\frac{\Delta[R]}{\Delta t}$ ។

*ឧទាហរណ៍* : តាមរយៈក្រាបនៅ(រូបទី 1.5 ) ។

ក. ចូរកំណត់រកល្បឿនមធ្យមបំបាត់អ៊ីយ៉ុង $I^-$ នៅចន្លោះពេល $t_1 = 50s$ និង $t_2 = 100s$ ។

ខ. ចូរទាញរកល្បឿនមធ្យមបំបាត់ទឹកអុកស៊ីសែននៅចន្លោះពេល $t = 50s$ និង $t_2 = 100s$ ។

*ចម្លើយ :*

ក. $V_m(I^-)_{t_1,t_2} = -\dfrac{[I^-]_2-[I^-]_1}{t_2-t_1} = -\dfrac{0.1\times10^{-2}-0.5\times10^{-2}}{100-50} = 8\times10^{-5}mol\ L^{-1}s^{-1}$

ខ. តាមសមីការតុល្យការប្រតិកម្ម : $H_2O_2 + 2H^+ + 2I^- \longrightarrow I_2 + 2H_2O$

$V_m(I^-)_{t_1,t_2} = 2V_m(H_2O_2)_{t_1,t_2}$

$V_m(H_2O_2)_{t_1,t_2} = \dfrac{V_m(I^-)_{t_1,t_2}}{2} = \dfrac{8\times10^{-5}}{2} = 4\times10^{-5}mol\ L^{-1}s^{-1}$ ។

## ខ. ល្បឿនខណៈបំបាត់អ៊ីយ៉ុងអ៊ីយ៉ូឌួ $I^-$

និយមន័យ : ល្បឿនខណៈបំបាត់អ៊ីយ៉ុងអ៊ីយ៉ូឌួ នៅខណៈ $t_1$ គឺជាលីមីតនៃល្បឿនមធ្យមកាលណាចន្លោះពេល $\Delta t = t_2 - t_1$ ខិតមករកសូន្យ $V(I^-)_{t_1} = \lim\limits_{\Delta t\to 0} -\dfrac{\Delta[I^-]}{\Delta t}$ ។

ល្បឿននេះមានតម្លៃផ្ទុយនិងដេរីវេនៃអនុគមន៍ $[I^-] = g(t)$ នៅពេល $t_1$ :

$$V(I^-)_{t_1} = -\left(\frac{d[I^-]}{dt}\right)_{t_1}$$

បំណកស្រាយតាមក្រាប : កាលណា $t_1$ ខិតទៅរក $t_2$ ខ្នាត់ $M_1M_2$ ទៅជាបន្ទាត់ប៉ះត្រង់ចំណុច $M_1$ នៃខ្សែកោង$[I^-] = g(t)$ ។ ល្បឿនបំបាត់អ៊ីយ៉ុងអ៊ីយ៉ូឌួនៅខណៈ $t_1$ មានតម្លៃផ្ទុយនិងមេគុណប្រាប់ទិសនៃបន្ទាត់ប៉ះរបស់ខ្សែកោង $[I^-] = g(t)$ ត្រង់ចំណុច $M_1$ អាប់ស៊ីស $t_1$ ( រូបទី 1.5 )

ជាទូទៅ : បើតាង R ជាអង្គធាតុប្រតិករដែលបាត់បង់នៅពេលប្រតិកម្ម ល្បឿនបំបាត់អង្គធាតុប្រតិករ R នៅខណៈ t : $V(R)_t = -\left(\dfrac{d[R]}{dt}\right)_t$ ។

*ឧទាហរណ៍* : តាមរយៈខ្សែកោងនៅក្នុងរូបទី 1.5 ចូរកំណត់រកល្បឿនបំបាត់ $I^-$ នៅខណៈ $t = 50s$ ។

*ចម្លើយ :*

សង់បន្ទាត់ប៉ះនៃខ្សែកោងត្រង់ចំណុច $M_1$ អាប់ស៊ីស $t_1 = 50s$ ។ នៅលើបន្ទាត់ប៉ះនេះ ដៅចំណុចពីរឆ្ងាយពីគ្នាបន្តិច $T_1$ និង $T_2$ ។ រកមេគុណប្រាប់ទិស P នៃបន្ទាត់ប៉ះ

$$P = -\frac{[I^-]_2-[I^-]_1}{t_2-t_1} = -\frac{0.85\times10^{-2}-0.1\times10^{-2}}{70-30} = -1,87\times10^{-4}mol\ L^{-1}s^{-1}$$

ដូច្នេះល្បឿនបំបាត់អ៊ីយ៉ុង $I^-$ : $V(I^-)_{50} = 1,87\times10^{-4}mol\ L^{-1}s^{-1}$ ។

## មេរៀនសង្ខេប

- ស៊ីនេទិចគីមីគឺសិក្សាពីល្បឿនវិវត្ត នៃប្រតិកម្មគីមី ។
- ល្បឿនប្រតិកម្មគីមីត្រូវបានគេឱ្យនិយមន័យតាម :

ល្បឿនមធ្យមកំណាអង្គធាតុកកើត P ក្នុងរយៈពេល $\Delta t$ គឺ $V_m(P)_{t_1,t_2} = \frac{\Delta[P]}{\Delta t}$

ល្បឿនខណៈកំណាអង្គធាតុកកើត P នៅខណៈ t គឺ $V(P)_t = \left(\frac{d[P]}{dt}\right)_t$

ល្បឿនមធ្យមបំបាត់អង្គធាតុប្រតិករ R ក្នុងរយៈពេល $\Delta t$ គឺ $V_m(R)_{t_1,t_2} = -\frac{\Delta[R]}{\Delta t}$

ល្បឿនខណៈបំបាត់អង្គធាតុប្រតិករ R នៅខណៈ t គឺ $V(R)_t = -\left(\frac{d[R]}{dt}\right)_t$ ។

## សំណួរនិងលំហាត់

1. គេមានប្រតិកម្ម : $ClO^-(aq) + 2H^+(aq) + 2I^-(aq) \longrightarrow I_2(aq) + Cl^-(aq) + 2H_2O(\ell)$

ក. តើប្រភេទគីមីណាខ្លះជាអង្គធាតុប្រតិករនិងណាខ្លះជាអង្គធាតុកកើត ?

ខ. ចូរឱ្យនិយមន័យល្បឿនមធ្យមកំណាអ៊ីយ៉ូត $I_2$ នៅចន្លោះពេល $t_1$ និង $t_2$ ។

គ. ចូរឱ្យនិយមន័យល្បឿនខណៈកំណាអ៊ីយ៉ូតនៅខណៈ t និងល្បឿនខណៈបំបាត់អ៊ីយ៉ុង $I^-$ នៅខណៈ t ។

ឃ. តើល្បឿនទាំងពីរនេះស្មើគ្នាឬខុសគ្នា ? ចូរសរសេរទំនាក់ទំនងរវាងល្បឿនទាំងពីរនេះ ។

2. ថ្មកំបោរអាចមានអំពើជាមួយអាស៊ីតក្លរីឌ្រិចតាមសមីការតុល្យការ

$CaCO_3(s) + 2H^+(aq) \longrightarrow Ca^{2+}(aq) + CO_2(g) + H_2O(\ell)$ ។នៅខណៈ $t = 0$ កំហាប់អ៊ីយ៉ុង $Ca^{2+}$ មានតម្លៃស្មើសូន្យ ។ នៅខណៈ $t = 15s$ កំហាប់អ៊ីយ៉ុង $Ca^{2+}$ កើតឡើងស្មើនឹង $1.8 \times 10^{-3} mol\ L^{-1}$ និងនៅខណៈ $t = 30s$ មានតម្លៃស្មើនឹង $3.13 \times 10^{-3} mol\ L^{-1}$ ។ ចូរគណនាល្បឿនមធ្យមកំណាអ៊ីយ៉ុង $Ca^{2+}$ នៅចន្លោះពេល 15s និង30s ។ ចូរទាញរកល្បឿនមធ្យមបំបាត់អ៊ីយ៉ុង $H^+$ ។

3 អាស៊ីតក្លរីឌ្រិចមានអំពើជាមួយម៉ាញេស្យូម តាងដោយសមីការតុល្យការ

$Mg(s) + 2H^+(aq) \longrightarrow Mg^{2+}(aq) + H_2(g)$

ការវិវត្តនៃកំហាប់អ៊ីយ៉ុង $Mg^{2+}$ នៅក្នុងសូលុយស្យុងជាអនុគមន៍នៃពេលតាងដោយខ្សែកោងខាងស្តាំនេះ ។




ក. គណនាល្បឿនមធ្យមកំណាអ៊ីយ៉ុង $Mg^{2+}$ នៅចន្លោះពេល $t_1 = 3min$ និង $t_2 = 5min$ ។

ខ. ចូរកំណត់រកល្បឿនខណៈកំណាអ៊ីយ៉ុង $Mg^{2+}$ នៅខណៈ $t = 4min$ ។

មេរៀនទី

# 2 កត្តាជះឥទ្ធិពលលើល្បឿនប្រតិកម្ម

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពន្យល់ពីល្បឿនប្រតិកម្មអាស្រ័យលើទំហំភាគល្អិតអង្គធាតុប្រតិករ ។
- ❑ បកស្រាយពីឥទ្ធិពលកំហាប់លើល្បឿនប្រតិកម្ម ។
- ❑ បកស្រាយពីឥទ្ធិពលនៃសីតុណ្ហភាពលើល្បឿនប្រតិកម្ម ។
- ❑ ពន្យល់ពីឥទ្ធិពលនៃកាតាលីករលើល្បឿនប្រតិកម្ម ។
- ❑ បកស្រាយទិន្នន័យតាមក្រាប ។

## 1. ឥទ្ធិពលទំហំភាគល្អិតលើល្បឿនប្រតិកម្ម

ប្រតិកម្មគីមីជាច្រើនទាក់ទងទៅនឹងទំហំភាគល្អិតរបស់អង្គធាតុប្រតិករ ។ តើទំហំនៃភាគល្អិតមានឥទ្ធិពលទៅលើល្បឿនប្រតិកម្មដូចម្តេច ?

### ពិសោធន៍

- វត្ថុបំណង : បង្ហាញពីឥទ្ធិពលទំហំភាគល្អិតនៃអង្គធាតុប្រតិករទៅលើល្បឿនប្រតិកម្ម ។
- សម្ភារៈ
    - កែវអែឡិនចំណុះ 250mL ចំនួនបី
    - ស៊ីរ៉ាំងចំណុះ 50mL ចំនួនបី
    - ឆ្នុកកៅស៊ូ
    - ទុយោជ័រតូចប្រវែង 20cm ចំនួនបីកំណាត់ ។
- ធាតុគីមី
    - សូលុយស្យុងអាស៊ីតក្លរីឌ្រិចកំហាប់ $1mol.L^{-1}$ ចំណុះ 200mL
    - ម្សៅកាល់ស្យូមកាបូណាត 20g
    - ដុំកាល់ស្យូមកាបូណាតតូចៗ 20g
    - ដុំកាល់ស្យូមកាបូណាតទំហំធំមធ្យមចំនួន 20g ដូចគ្នា ។

- **ដំណើរការពិសោធ**
  - ដាក់ម្សៅកាល់ស្យូមកាបូណាត 20g ក្នុងកែវអឺឡិនម៉ី ។
  - ចាក់អាស៊ីតក្លរីឌ្រិចកំហាប់ 1mol $L^{-1}$ ចំណុះ 50mL ទៅក្នុងកែវអឺឡិន ដែលភ្ជាប់ទៅនឹងសឺរ៉ាំង(មើលរូបទី 2.1) ។ កត់ត្រារយៈពេលប្រតិកម្មនិងមាឌឧស្ម័នកាបូនឌីអុកស៊ីតដែលទទួលបាន ។
  - ធ្វើដូចដំណើរការពិសោធ (2.1) ដោយប្រើដុំកាល់ស្យូមកាបូណាតតូចៗចំនួន 20g (មើលរូបទី 2.2) ។ កត់ត្រារយៈពេលប្រតិកម្មនិងមាឌឧស្ម័នកាបូនឌីអុកស៊ីតដែលទទួលបាន ។
  - ធ្វើដូចលំនាំដំណើរការពិសោធ (2.1) ដោយប្រើដុំកាល់ស្យូមកាបូណាតទំហំធំមធ្យមចំនួន 20g (មើលរូបទី 2.3) ។ កត់ត្រារយៈពេលប្រតិកម្មនិងមាឌឧស្ម័នកាបូនឌីអុកស៊ីតដែលទទួលបាន ។



*រូបទី 2.1* *រូបទី 2.2* *រូបទី 2.3*

*រូបទី 2.1 , 2.2 , 2.3 ពិសោធន៍ប្រតិកម្មសូលុយស្យុងអាស៊ីតក្លរីឌ្រិចជាមួយដុំកាល់ស្យូមកាបូណាតដែលមានទំហំខុសគ្នា*

  - សមីការប្រតិកម្មគីមី

$$CaCO_3(s) + 2HCl(aq) \longrightarrow CaCl_2(aq) + H_2O(\ell) + CO_2(g)$$

- សង្កេត
  - ប្រតិកម្មរវាងម្សៅកាល់ស្យូមកាបូណាត ជាមួយសូលុយស្យុងអាស៊ីតក្លរីឌ្រិច (រូបទី 2.1) ជាប្រតិកម្មលឿន ដោយប្រើរយៈពេល 60 វិនាទី ។
  - ប្រតិកម្មរវាងដុំកាល់ស្យូមកាបូណាតតូចៗ ជាមួយសូលុយស្យុងអាស៊ីតក្លរីឌ្រិច (រូបទី 2.2) ជាប្រតិកម្មយឺត ដោយប្រើរយៈពេលប្រមាណ 120 វិនាទី ។
  - ប្រតិកម្មរវាងដុំកាល់ស្យូមកាបូណាតដែលមានទំហំធំមធ្យមជាមួយសូលុយស្យុងអាស៊ីតក្លរីឌ្រិច (រូបទី 2.3)ប្រើពេលអស់ប្រមាណ 180 វិនាទី ទើបឈានដល់ទីបញ្ចប់ ។
- សន្និដ្ឋាន

  ល្បឿនប្រតិកម្មគីមីអាស្រ័យលើទំហំភាគល្អិតអង្គធាតុប្រតិករ
  - បើដុំនៃអង្គធាតុរឹងប្រតិករកាន់តែតូច នោះផ្ទៃប៉ះរបស់វាកាន់តែធំ ដែលធ្វើឱ្យល្បឿនប្រតិកម្មគីមីប្រព្រឹត្តទៅកាន់តែលឿន ។

- បើដុំនៃអង្គធាតុរឹងប្រតិករកាន់តែធំ នោះផ្ទៃប៉ះរបស់វាកាន់តែតូច ដែលធ្វើឱ្យល្បឿនប្រតិកម្មគីមីប្រព្រឹត្តទៅយឺត ។

***សំគាល់ :*** សម្រាប់ការប្រៀបធៀបនេះ ម៉ាស់កាល់ស្យូមកាបូណាតចំពោះករណីពិសោធន៍ទាំងបីខាងលើត្រូវស្មើគ្នា ។




***ទំហំដុំអង្គធាតុរឹងធំ នោះផ្ទៃប៉ះតូច*** ***ទំហំដុំអង្គធាតុរឹងតូច នោះផ្ទៃប៉ះធំ***

***រូបទី 2.4 បរិមាណដូចគ្នាទំហំផ្ទៃប៉ះខុសគ្នារវាងដុំអង្គធាតុរឹងធំនិងតូច***

ក្រាបបង្ហាញពីល្បឿនប្រតិកម្មអាស្រ័យទៅនឹងទំហំនៃដុំភាគល្អិត




***រូបទី 2.5 ក្រាបបង្ហាញពីល្បឿនប្រតិកម្មអាស្រ័យទៅនឹងទំហំនៃដុំភាគល្អិតអង្គធាតុប្រតិករ***

## 2. ឥទ្ធិពលកំហាប់លើល្បឿនប្រតិកម្ម

ការបង្កើនកំហាប់អង្គធាតុប្រតិករ គឺបង្កើនឱកាសនៃការទង្គិចរវាងម៉ូលេគុលអង្គធាតុប្រតិករ ។ ម្យ៉ាងទៀតការបង្កើនកំហាប់ គឺបង្កើនចំនួនទង្គិចរវាងម៉ូលេគុល ជាហេតុធ្វើឱ្យល្បឿនប្រតិកម្មកាន់តែលឿន ។ កំហាប់របស់ឧស្ម័នមួយកើនឡើង កាលណាសម្ពាធរបស់វាកើនឡើង ។ ដូច្នេះយើងអាចបង្កើនល្បឿនប្រតិកម្មរបស់ឧស្ម័នដោយបង្កើនសម្ពាធរបស់អង្គធាតុប្រតិករ ។

## 2.1. សិក្សាពិសោធន៍

### ពិសោធន៍ទី 1 : ឥទ្ធិពលនៃកំហាប់អ៊ីយ៉ុងអ៊ីយ៉ូឌួ $I^-$

- វត្ថុបំណង : តាមដានការវិវត្តនៃកំហាប់ $I_2$ អាស្រ័យទៅនិងកំហាប់អ៊ីយ៉ុង $I^-$ ។
- សម្ភារៈ : កែវបេស៊ែចំណុះ 150mL ចំនួនបី ចង្កឹះ ក្រូណូម៉ែត ។
- ជាតុគីមី
  - សូលុយស្យុងប៉ូតាស្យូមអ៊ីយ៉ូឌួ (KI) កំហាប់ $0.2 mol\ L^{-1}$
  - សូលុយស្យុងអាស៊ីតស៊ុលផួរិចកំហាប់ $0.5 mol\ L^{-1}$ និង
  - សូលុយស្យុងទឹកអុកស៊ីសែនកំហាប់ $10^{-2} mol\ L^{-1}$ ។

តារាង 2.1 ដំណើរការពិសោធតាមការរៀបចំល្បាយសូលុយស្យុងបីដូចបង្ហាញខាងក្រោម

| លេខរៀងកែវបេស៊ែ | ទី 1 | ទី 2 | ទី 3 |
|---|---|---|---|
| មានសូលុយស្យុង $I^-$ ($0.2 mol\ L^{-1}$) ជា mL | 10 | 20 | 40 |
| កំហាប់ដើមនៃ $I^-$ $[I^-]_0$ ($mol\ L^{-1}$) | 0.02 | 0.04 | 0.08 |
| មានសូលុយស្យុង $H_2SO_4$ ($0.5 mol\ L^{-1}$) ជា mL | 10 | 10 | 10 |
| កំហាប់ដើមនៃ $H^+$ $[H^+]_0$ ($mol\ L^{-1}$) | 0.1 | 0.1 | 0.1 |
| មានទឹក (mL) | 30 | 20 | 0 |
| បន្ថែមសូលុយស្យុងទឹកអុកស៊ីសែន($10^{-2} mol\ L^{-1}$)ទៅក្នុងកែវបេស៊ែ (mL) | 50 | 50 | 50 |
| មានសូលុយស្យុងសរុបក្នុងកែវបេស៊ែ (mL) | 100 | 100 | 100 |

- នៅខណៈ $t = 0$ គេថែមទឹកអុកស៊ីសែន 50mL កំហាប់ $10^{-2} mol\ L^{-1}$ ទៅក្នុងកែវបេស៊ែនីមួយៗ រួចកូរល្បាយឱ្យស្មើសាច់និងសង្កេតមើលការវិវត្តនៃពណ៌របស់ $I_2$ (រូបទី 2.6)




រូបទី 2.6 : ឥទ្ធិពលនៃកំហាប់ $I_2$ លើល្បឿនប្រតិកម្ម

- សមីការគីមីតាងប្រតិកម្ម : $H_2O_2 + 2I^- + 2H^+ \longrightarrow I_2 + 2H_2O$

- សង្កេត : នៅខណៈ t មួយគេសង្កេតឃើញពណ៌របស់ $I_2$ កើតឡើងក្នុងកែវបេស៊ែទី 3 មានសភាពជាំខ្លាំងជាងកែវបេស៊ែទី 2 ហើយ $I_2$ កើតឡើងក្នុងកែវបេស៊ែទី 2 ជាំជាងកែវបេស៊ែទី 1 ។
  - គេអាចអះអាងដូចតទៅ : $[I_2]_t$ ទី 3 > $[I_2]_t$ ទី 2 > $[I_2]_t$ ទី 1 ពីព្រោះកំហាប់ដើម $I^-$ ក្នុងកែវបេស៊ែគឺ $[I^-]_0$ ទី 3 > $[I^-]_0$ ទី 2 > $[I^-]_0$ ទី 1 ។ ដូច្នេះកាលណាកំហាប់ $I^-$ កាន់តែធំ ការកកើតនៃ $I_2$ ក៏កាន់តែច្រើន ។
  - ល្បឿនមធ្យមនៃកំណឌីអ៊ីយ៉ូត ($I_2$) ចន្លោះពេល t = 0 និង t មានតម្លៃគឺ

$$V_m(I_2)_{0,t} = \frac{[I_2]_t - [I_2]_0}{t - 0} = \frac{[I_2]_t}{t} \qquad ([I_2]_0 = 0)$$

គេបាន $V_m(I_2)_{0,t}$ ទី 3 > $V_m(I_2)_{0,t}$ ទី 2 > $V_m(I_2)_{0,t}$ ទី 1

- សន្និដ្ឋាន : ល្បឿនមធ្យមនៃកំណ $I_2$ កើនឡើងកាលណាកំហាប់ដើមអ៊ីយ៉ុង $I^-$ កើន ។

## ពិសោធន៍ទី 2 : ឥទ្ធិពលនៃកំហាប់ទឹកអុកស៊ីសែន

- វត្ថុបំណង : តាមដានឥទ្ធិពលនៃកំហាប់ទឹកអុកស៊ីសែនទៅលើល្បឿនវិវត្តនៃប្រតិកម្ម ។
- សម្ភារៈ : ដូចក្នុងពិសោធន៍ទី 1 ។
- ធាតុគីមី : ដូចក្នុងពិសោធន៍ទី 1 ។

តារាង 2.2 ដំណើរការពិសោធតាមការរៀបចំល្បាយសូលុយស្យុងបីដូចបង្ហាញខាងក្រោម

| លេខរៀងកែវបេស៊ែ | ទី 1 | ទី 2 | ទី 3 |
|---|---|---|---|
| មាឌ (mL) សូលុយស្យុង KI (កំហាប់ 0.4mol $L^{-1}$) | 50 | 50 | 50 |
| កំហាប់ដើមនៃអ៊ីយ៉ុងអ៊ីយ៉ូឌួ : $[I^-]_0$ (mol $L^{-1}$) | 0.20 | 0.20 | 0.20 |
| មាឌ (mL) សូលុយស្យុង $H_2SO_4$ កំហាប់ 0.5mol $L^{-1}$ | 10 | 10 | 10 |
| កំហាប់ដើមនៃអ៊ីយ៉ុង $H^+$ : $[H^+]_0$ (mol $L^{-1}$) | 0.1 | 0.1 | 0.1 |
| មាឌទឹក (mL) | 30 | 20 | 10 |
| បន្ថែមមាឌ (mL) សូលុយស្យុង $H_2O_2$ កំហាប់ 0.1mol $L^{-1}$ នៅខណៈ t = 0 | 10 | 20 | 30 |
| កំហាប់ដើមទឹកអុកស៊ីសែន $[H_2O_2]_0$ (mol $L^{-1}$) | 0.01 | 0.02 | 0.03 |
| មាឌសូលុយស្យុងសរុបក្នុងកែវបេស៊ែ (mL) | 100 | 100 | 100 |

***ចំណាំ*** : ក្នុងការពិសោធនេះ គេប្រើបរិមាណអ៊ីយ៉ុង $I^-$ មិនគ្រប់គ្រាន់ ។ ដោយកំហាប់ $I^-$ មានដូចគ្នាក្នុងសូលុយស្យុងនីមួយៗ គេនឹងទទួលបានកំហាប់ចុងក្រោយ $[I_2]_\infty$ ដូចៗគ្នាក្នុងកែវបេស៊ែនីមួយៗ ក្នុងកំឡុងពេលគ្រប់គ្រាន់ ។

នៅខណៈ $t = 0$ គេចាក់សូលុយស្យុង $H_2O_2$ រៀងគ្នា 10mL , 20mL និង 30mL ទៅក្នុងកែវបេស៊ែទី1 ទី2 និងទី3 ដែលមានសូលុយស្យុង $I^-$ លាយអាស៊ីតស្រាប់ ។ បន្ទាប់មកគេធ្វើល្បាយសូលុយស្យុងទាំងបីឱ្យស្មើសាច់ រួចសង្កេតមើលការវិវត្តពណ៌ (មើលរូបទី 2.7) ។




*រូបទី 2.7 ឥទ្ធិពលនៃកំហាប់ $H_2O_2$ ទៅលើល្បឿនប្រតិកម្មរវាង $I^-$ និង $H_2O_2$*

- **សង្កេត** : នៅខណៈណាមួយគេសង្កេតឃើញពណ៌របស់ឌីអ៊ីយ៉ូត ($I_2$) ដែលកើតឡើងក្នុងកែវបេស៊ែរទី3 ដាំជាងកែវទី2 ហើយកែវទី2 ដាំជាងកែវទី1 ។
  - នៅខណៈពេល t គេអាចអះអាងថា : $[I_2]_t$ ទី3 > $[I_2]_t$ ទី2 > $[I_2]_t$ ទី1
  - ល្បឿនកំណនៃ $I_2$ គឺ : $V_m(I_2)_{0,t}$ ទី3 > $V_m(I_2)_{0,t}$ ទី2 > $V_m(I_2)_{0,t}$ ទី1
- **សន្និដ្ឋាន** : ល្បឿនមធ្យមនៃកំណ $I_2$ កើនកាលណាកំហាប់ដើម $H_2O_2$ កើន ។

## 2.2. ទូទៅកម្មនិងបំណកស្រាយ

### ក. ច្បាប់កំហាប់

តាមរយៈពិសោធន៍ខាងលើ គេធ្វើទូទៅកម្មចំពោះស្ទើរតែគ្រប់ប្រតិកម្មក្នុងសូលុយស្យុង ។

**វិធានទូទៅ** : ល្បឿនកំណអង្គធាតុកកើត (ផលិតផល)ឬល្បឿនបំបាត់អង្គធាតុប្រតិករកើនឡើង កាលណាកំហាប់នៃអង្គធាតុប្រតិករកើនឡើង ។

ជាទូទៅល្បឿនកំណអង្គធាតុកកើតឬល្បឿនបំបាត់អង្គធាតុប្រតិករ នៅពេលចាប់ផ្តើមប្រតិកម្មគឺលឿន ហើយថយចុះទៅតាមពេល ព្រោះកំហាប់អង្គធាតុប្រតិករថយចុះ ។

### ខ. បំណកស្រាយ

ម៉ូលេគុល ឬអ៊ីយ៉ុងទាំងឡាយមានចលនាឥតឈប់ឈរក្នុងសូលុយស្យុង ។ ចលនានេះ ធ្វើឱ្យមានការប៉ះទង្គិចកើតមានឡើង ហើយក្នុងករណីទង្គិចខ្លះវាបង្កើតបានជាផលិតផល ។ ទង្គិចណាដែលបណ្តាលឱ្យមានកំណអង្គធាតុកកើត ឈ្មោះថា **ទង្គិចប្រសិទ្ធ** ។ ល្បឿនកំណអង្គធាតុកកើតកាន់តែធំ

ភាលណាចំនួនទង្គិចប្រសិទ្ធកាន់តែច្រើន ។ ទង្គិចប្រសិទ្ធកាន់តែមានច្រើនលុះត្រាកំហាប់អង្គធាតុប្រតិករកើននៅក្នុងសូលុយស្យុង ។ ដូចនេះនៅក្នុងសូលុយស្យុងល្បឿនកំណនៃអង្គធាតុកកើតកើនជាមួយកំណើនកំហាប់អង្គធាតុប្រតិករ ។ បំណកស្រាយនេះក៏ត្រឹមត្រូវផងដែរ ចំពោះប្រតិកម្មទាំងឡាយដែលសម្រេចបានក្នុងផាសឧស្ម័ននៅមាឧថេរ ។

### គ. អនុវត្តន៍

- ដើម្បីធ្វើប្រតិកម្មយឺតមួយឱ្យលឿន គេត្រូវបង្កើនកំហាប់អង្គធាតុប្រតិករឱ្យធំ ។ បើក្នុងផាសចំហាយគេត្រូវធ្វើប្រតិកម្មឱ្យស្ថិតក្រោមសម្ពាធខ្ពស់ ។
- ដើម្បីធ្វើប្រតិកម្មនៅក្នុងសូលុយស្យុងមួយឱ្យយឺត គេត្រូវពង្រាវមជ្ឈដ្ឋានប្រតិកម្ម ដោយបន្ថែមអង្គធាតុរំលាយ ។ បច្ចេកទេសនេះត្រូវបានគេប្រើក្នុងអត្រាកម្ម ។ ពេលដែលគេចង់បញ្ឈប់ប្រតិកម្មមួយគេត្រូវយកល្បាយប្រតិកម្មបន្តិចទៅថែមទឹក ។ ការពង្រាវនេះបានធ្វើឱ្យយឺតដល់ល្បឿនប្រតិកម្ម ។

គួរកត់សំគាល់ថា ការលាងដោយទឹកច្រើនដងទៅលើស្បែកដែលប៉ះសារធាតុគីមី ដែលគ្រោះថ្នាក់ បានបន្ថយកំហាប់នៃសារធាតុគីមីនោះ ធ្វើឱ្យល្បឿនប្រតិកម្មបំផ្លាញស្បែកថយចុះ ។

## ១. សម្ពាធនិងល្បឿនប្រតិកម្ម

ឧស្ម័នធ្វើប្រតិកម្មលឿននៅសម្ពាធខ្ពស់ ។ ពីព្រោះនៅសម្ពាធខ្ពស់ម៉ូលេគុលឧស្ម័នកាន់តែខិតជិតគ្នា នោះការទង្គិចកាន់តែមានញឹកញាប់ ។ លក្ខណៈនេះស្រដៀងគ្នាទៅនឹងការទង្គិចរវាងភាគល្អិតក្នុងសូលុយស្យុងដែលមានកំហាប់កាន់តែធំ ។



*រូបទី 2.8 ប្រតិកម្មរវាងឧស្ម័នពីរនៅសម្ពាធទាបនិងសម្ពាធខ្ពស់*

សម្ពាធខ្ពស់ត្រូវបានគេប្រើជាញឹកញាប់ក្នុងប្រតិកម្មនៅឧស្សាហកម្មដើម្បីឱ្យប្រតិកម្មប្រព្រឹត្តទៅកាន់តែលឿន ។ ***ឧទាហរណ៍*** ប៉ូលីអេទីឡែន បានបង្កើតឡើងពីអេទីឡែននៅសម្ពាធយ៉ាងខ្ពស់ ។

គេប្រើសម្ពាធ 200atm ក្នុងលំនាំហេបើ (Haber) ដើម្បីផលិតអាម៉ូញ៉ាក់ ពីអាសូតនិងអ៊ីដ្រូសែន ។សម្ពាធខ្ពស់ ត្រូវបានប្រើដើម្បីផលិតអាម៉ូញ៉ាក់ឱ្យទទួលបានភាគរយច្រើននៅស្ថានភាពលំនឹងនិងធ្វើឱ្យប្រតិកម្មប្រព្រឹត្តទៅកាន់តែលឿន : $N_2(g) + 3H_2(g) \underset{\text{សម្ពាធខ្ពស់}}{\overset{\text{កាតាលីករ Fe}}{\rightleftharpoons}} 2NH_3(g)$ ។

# 4. ឥទ្ធិពលនៃសីតុណ្ហភាពលើល្បឿនប្រតិកម្ម

កំណើនសីតុណ្ហភាពរបស់ល្បាយប្រតិកម្មមួយ បង្កើនល្បឿនប្រតិកម្មគីមី ករណីនេះកើតឡើងទាំងប្រតិកម្មបញ្ចេញកម្តៅនិងប្រតិកម្មស្រូបកម្តៅ ។

## 4.1. សិក្សាពិសោធន៍

### ពិសោធន៍ : ឥទ្ធិពលនៃសីតុណ្ហភាពលើល្បឿនប្រតិកម្ម

ប្រតិកម្មអុកស៊ីតកម្មអ៊ីយ៉ុងអ៊ីយ៉ូឌួ ( $I^-$ ) ដោយទឹកអុកស៊ីសែន ( $H_2O_2$ )

$$H_2O_2 + 2I^- + 2H^+ \longrightarrow I_2 + 2H_2O$$




*រូបទី 2.9 ពិសោធន៍សិក្សាឥទ្ធិពលសីតុណ្ហភាពទៅលើល្បឿនប្រតិកម្មកំណាអ៊ីយ៉ុត*

- **វត្ថុបំណង** : តាមដានការវិវត្តនៃកំហាប់ $I_2$ អាស្រ័យនឹងសីតុណ្ហភាព ។
- **សម្ភារៈ**
  - កែវបេស៊ែចំណុះ 150mL ចំនួន 3
  - បំពង់សាកធ្វើអំពីកែវ ចំនួន 6 ទែម៉ូម៉ែតចំនួន 3 ។
  - ចង្កៀងអាល់កុល 1 ។
- **ជាតុគីមី**
  - សូលុយស្យុង KI កំហាប់ $0.2mol \cdot L^{-1}$
  - សូលុយស្យុងអាស៊ីតស៊ុលផួរិច កំហាប់ $0.5mol \cdot L^{-1}$
  - ទឹកអុកស៊ីសែនកំហាប់ $0.1mol \cdot L^{-1}$ ។
- **ដំណើរការពិសោធ**
  - រៀបចំសូលុយស្យុងបីគឺ 5mL សូលុយស្យុង KI បន្ថែម 1mL សូលុយស្យុងអាស៊ីតស៊ុលផួរិចកំហាប់ $0.5mol \cdot L^{-1}$ ដាក់ក្នុងបំពង់សាក 3 ផ្សេងគ្នា ។
  - យកសូលុយស្យុងទឹកអុកស៊ីសែនដាក់ក្នុងបំពង់សាក 3 ផ្សេងគ្នា ។

- យកសូលុយស្យុង KI នៅក្នុងបំពង់សាកទី1 ចាក់ចូលទៅក្នុងសូលុយស្យុង $H_2O_2$ ក្នុងបំពង់សាកទី 2 ដែលត្រាំក្នុងទឹកកក (0°C) ទឹកត្រជាក់ (20°C) និងទឹកក្តៅ (60°C) នៅពេលស្មើគ្នា (រូបទី 2.9 ) ។
- តាមដានការប្រែពណ៌សូលុយស្យុង ដោយសារវត្តមាន $I_2$ ក្នុងកំឡុងពេលកំណត់មួយ ។

- សង្កេត : គេឃើញសូលុយស្យុងដែលកម្តៅនៅសីតុណ្ហភាព 60°C ពណ៌ជាំជាងសូលុយស្យុងដែលត្រាំនៅសីតុណ្ហភាព 30°C ហើយសូលុយស្យុងនៅសីតុណ្ហភាព 30°C មានពណ៌ជាំជាងសូលុយស្យុងនៅសីតុណ្ហភាព 0°C ។
- សន្និដ្ឋាន : ល្បឿនកំណអ៊ីយ៉ូតកើនឡើង កាលណាសីតុណ្ហភាពកើនឡើង ។
- ទូទៅកម្ម : ល្បឿនកំណនៃអង្គធាតុកកើតឬបំបាត់អង្គធាតុប្រតិករ កើនជាមួយសីតុណ្ហភាព ។
- បំណកស្រាយ :

តាមទ្រឹស្តីទង្គិច គេដឹងថាការទង្គិចរវាងម៉ូលេគុល ឬអ៊ីយ៉ុងនៃអង្គធាតុប្រតិករមិនសុទ្ធតែនាំឱ្យកើតផលិតផលនោះទេ ។ ឯការទង្គិចដែលឱ្យផលិតផលហៅថា **ទង្គិចប្រសិទ្ធ** ។

នៅសីតុណ្ហភាពណាមួយម៉ូលេគុល ឬអ៊ីយ៉ុងមិនមានថាមពលស៊ីនេទិចដូចគ្នាទេ ។ មានតែម៉ូលេគុល ឬអ៊ីយ៉ុងដែលមានថាមពលខ្ពស់ជាងគេប៉ុណ្ណោះ ដែលនាំឱ្យមានទង្គិចប្រសិទ្ធ ។ កាលណាសីតុណ្ហភាពកើនឡើង នាំឱ្យចំនួនទង្គិចប្រសិទ្ធក្នុងមួយខ្នាតពេលកកើនឡើងដែរ នេះជាហេតុនាំឱ្យមានកំណើនល្បឿនប្រតិកម្ម ។

## 4.2. អនុវត្តន៍

ឥទ្ធិពលសីតុណ្ហភាពទៅលើល្បឿនប្រតិកម្មត្រូវបានយកទៅប្រើពីរយ៉ាងក្នុងការអនុវត្ត :

### ក. ការពន្លឿននិងផ្តើមប្រតិកម្មដោយដំឡើងសីតុណ្ហភាព

- ប្រតិកម្មគីមីមួយចំនួនប្រព្រឹត្តទៅយឺតណាស់នៅសីតុណ្ហភាពធម្មតា ។ ***ឧទាហរណ៍*** ប្រតិកម្មអេស្ទែកម្ម សាប៊ូកម្មជាដើម ។ គេអាចធ្វើឱ្យប្រតិកម្មនេះ ប្រព្រឹត្តទៅលឿនដោយដំឡើងសីតុណ្ហភាព ។ ក្នុងលោហៈកម្មដែក គេប្រើសីតុណ្ហភាពខ្ពស់ប្រហែល 1000°C ក្នុងឡស្លដែកដើម្បីរំដោះដែកចេញពីអ៊ែអុកស៊ីតរបស់វា ។
- ក្នុងករណីផ្សេងទៀត គេបង្កើនសីតុណ្ហភាពដើម្បីធ្វើឱ្យប្រតិកម្មមួយដែលយឺតបំផុត អាចចាប់ផ្តើមឡើងវិញបាន ។ ការផ្តល់កម្តៅតាមវិធីដុតបានធ្វើឱ្យដុំធ្យូង ឬឧសចាប់ផ្តើមឆេះ ហើយបន្តចំហេះនេះ ។ ល្បាយសាំងនិងខ្យល់ឆេះនៅក្នុងស៊ីឡាំងម៉ាស៊ីនដោយសារផ្កាភ្លើងនៃប៊ូស៊ី ។

ខ. ការពន្យឺតនិងបញ្ឈប់ប្រតិកម្មដោយបញ្ចុះសីតុណ្ហភាព

***ការរំលត់ប្រព័ន្ធគីមី :*** គេអាចរាំងខ្ទប់ការវិវត្តនៃប្រព័ន្ធគីមីមួយដោយធ្វើឱ្យប្រព័ន្ធគីមីត្រជាក់ភ្លាមមួយរំពេច ។ ល្បឿនប្រតិកម្មនឹងទៅជាសូន្យ ហើយប្រព័ន្ធគីមីបានរក្សាសមាសភាពរបស់វាដដែលដូចនៅសីតុណ្ហភាពខ្ពស់ ។ នេះគឺជាការរំលត់ប្រព័ន្ធគីមីមួយ ។

***ការរក្សាអាហារ :*** អាហារដែលមានប្រភពពីសត្វ ឬរុក្ខជាតិរមែងរងនូវប្រតិកម្មតំហយគុណភាពដើម ដោយសារមីក្រូសារពាង្គកាយនៃមជ្ឈដ្ឋានជុំវិញ ហើយបាត់បង់គុណភាពនិងប្លែងជាសារធាតុផ្សេងៗ ដែលអាចប៉ះពាល់ដល់សុខភាព ។ អាហារអាចរក្សាបានច្រើនថ្ងៃក្នុងទូទឹកកកនៅសីតុណ្ហភាព 4°C ហើយបានយូរខែនៅសីតុណ្ហភាព −18°C ក្នុងទូភ្លាសេ ។

# 5. កាតាលីករនិងកាតាលីស

## 5.1. កាតាលីករ

កាតាលីករ ជាសារធាតុដែលពន្លឿនល្បឿនប្រតិកម្មគីមីកើតឯង ហើយវាកើតឡើងវិញដោយគ្មានបាត់បង់លក្ខណៈគីមីនៅពេលប្រតិកម្មចប់ ។

ទឹកអុកស៊ីសែន ជាភ្នាក់ងារអុកស៊ីតកម្មដ៏ប្រពៃ គេប្រើវាជាភ្នាក់ងារបន្សុទ្ធក្នុងសារធាតុជំរះក្អែលសម្លាប់បាក់តេរី សម្លាប់មីក្រូសារពាង្គកាយនិងប្រើសម្រាប់លាងរបួស ។ សូលុយស្យុងទឹកអុកស៊ីសែនក៏ប្រើសម្រាប់សំអាតកញ្ចក់ឧបករណ៍អេឡិចត្រូនិចមួយចំនួនផងដែរ ។

ទឹកអុកស៊ីសែនមិនមានស្ថិរភាព វាបំបែកឱ្យជាឧស្ម័នអុកស៊ីសែននិងទឹក ។ សមីការតាងប្រតិកម្មបំបែកទឹកអុកស៊ីសែន : $2H_2O_2(aq) \longrightarrow 2H_2O(\ell) + O_2(g)$

ប្រតិកម្មបំបែកទឹកអុកស៊ីសែនយឺតណាស់ ។ ដើម្បីរក្សាសូលុយស្យុងទឹកអុកស៊ីសែនឱ្យបានយូរ គេត្រូវប្រើដបស្រអាប់ឬដបពណ៌ត្នោត ។ គេអាចបង្កើនល្បឿនប្រតិកម្មបំបែកនៃទឹកអុកស៊ីសែនដោយបន្ថែមកាតាលីករ ។ ជាទូទៅកាតាលីករប្រើក្នុងបរិមាណបន្តិចបន្តួច ។ ក្នុងទីពិសោធន៍ គេប្រើកាតាលីករសម្រាប់ការបំបែកទឹកអុកស៊ីសែនដើម្បីធ្វើអុកស៊ីសែន ។ អុកស៊ីតលោហៈមួយចំនួនជាកាតាលីករដ៏ល្អប្រពៃសម្រាប់ការបំបែកទឹកអុកស៊ីសែន ។ ***ឧទាហរណ៍*** ម៉ង់កាណែស (IV) អុកស៊ីត($MnO_2$) ប្រើជាកាតាលីករក្នុងការបំបែកទឹកអុកស៊ីសែន ។ ឥទ្ធិពលនៃការបន្ថែមម៉ង់កាណែស (IV) អុកស៊ីតបន្តិចទៅលើទឹកអុកស៊ីសែននិងបង្ហាញក្នុងពិសោធន៍ខាងក្រោម ។

## ពិសោធន៍ទី 1 : ការបំបែកនៃទឹកអុកស៊ីសែន

- វត្ថុបំណង : បង្ហាញពីឥទ្ធិពលនៃកាតាលីករទៅលើល្បឿនប្រតិកម្ម ។
- សម្ភារៈ
  - បំពង់សាកពីរ
  - ជើងទម្របំពង់សាក
  - ឈើគូស ។
- ជាតុគីមី
  - ទឹកអុកស៊ីសែន
  - ក្រាមម៉ង់កាណែស (IV) អុកស៊ីត ។
- ដំណើរការពិសោធ
  - ដាក់ទឹកអុកស៊ីសែនប្រមាណ 5mL ទៅក្នុងបំពង់សាកនីមួយៗ ។
  - បំពង់សាកទី 1 សាកល្បងជាមួយរងើកភ្លើងឈើគូសលើមាត់បំពង់សាក ។ កត់ត្រាអ្វីដែលអ្នកបានឃើញ ។
  - បំពង់សាកទី 2 បន្ថែមម៉ង់កាណែស (IV) អុកស៊ីតកន្លះស្លាបព្រាកាហ្វេ បន្ទាប់មកសាកល្បងជាមួយរងើកភ្លើងឈើគូសនៅលើមាត់បំពង់សាក ។ កត់ត្រាអ្វីដែលអ្នកបានឃើញ ។




*រូបទី 2.10 ការបំបែកនៃទឹកអុកស៊ីសែនដោយកាតាលីករ $MnO_2$*

- សង្កេត
  - បំពង់សាកទី 1 : រងើកភ្លើងឈើគូសនៅដដែល ។
  - បំពង់សាកទី 2 : រងើកភ្លើងឈើគូសឆេះច្រាលឡើងវិញ ។
- សន្និដ្ឋាន : ក្នុងបំពង់សាកទី 2 ដោយមានកាតាលីករម៉ង់កាណែស (IV) អុកស៊ីតធ្វើឱ្យឧស្ម័នអុកស៊ីសែនភាយឡើងច្រើន បណ្តាលឱ្យរងើកភ្លើងឈើគូសឆេះច្រាលឡើងវិញ ។

## ពិសោធន៍ទី 2 :

- វត្ថុបំណង : បង្ហាញពីឥទ្ធិពលនៃកាតាលីករលើកំហាប់នៃអង្គធាតុប្រតិករប្រែប្រួល ។
- សម្ភារៈ
  - កែវអែឡិន 250mL
  - សឺរ៉ាំងប្លាស្ទិក 20mL
  - ឆ្នុកកៅស៊ូ
  - ទុយោ
  - ស៊ីឡាំងក្រិតចំណុះ 100mL
  - ជញ្ជីង ។
- ធាតុគីមី
  - សូលុយស្យុង $H_2O_2$ កំហាប់ $0.2mol.L^{-1}$ និងកំហាប់ $0.1mol.L^{-1}$
  - ម្សៅ $MnO_2$ ។
- ដំណើរការពិសោធ
  - ដាក់សូលុយស្យុង $H_2O_2$ កំហាប់ $0.2mol.L^{-1}$ ចំនួន 50mL ទៅក្នុងកែវអែឡិន ។ បន្ថែមបរិមាណ $MnO_2$ ចំនួន 3g បន្ទាប់មកភ្ជាប់ទុយោពីកែវអែឡិនទៅសឺរ៉ាំង(មើលរូបទី 2.11 ) ។ កត់ត្រាមាឌឧស្ម័នដែលទទួលបានក្នុងសឺរ៉ាំងរាល់ 30 វិនាទីម្តងៗ ។
  - ធ្វើដូចពិសោធន៍ខាងលើដោយប្រើ $H_2O_2$ កំហាប់ $0.1mol.L^{-1}$ ។
  - សង់ខ្សែកោងតាងឱ្យបម្រែបម្រួលមាឌឧស្ម័នអុកស៊ីសែនជាអនុគមន៍ទៅនឹងរយៈពេលនៃពិសោធន៍ទាំងពីរ ។



*រូបទី 2.11 ការបំបែកនៃទឹកអុកស៊ីសែននៅកំហាប់ខុសគ្នាដោយប្រើកាតាលីករដូចគ្នា*




*រូបទី 2.12 ឥទ្ធិពលកំហាប់លើល្បឿនប្រតិកម្ម*

- **លទ្ធផល** ៖ តាមរយៈក្រាបដែលទទួលបានពីពិសោធន៍បង្ហាញថា ៖
  - កាលណាកំហាប់សូលុយស្យុងទឹកអុកស៊ីសែនធំ ល្បឿនប្រតិកម្មបំបែកទឹកអុកស៊ីសែនលឿនជាងកំហាប់ទឹកអុកស៊ីសែនតូច ។
  - មាឌឧស្ម័នអុកស៊ីសែនដែលទទួលបានពីសូលុយស្យុងទឹកអុកស៊ីសែននៅកំហាប់ $0.1\text{mol L}^{-1}$ មានតែពាក់កណ្ដាលមាឌអុកស៊ីសែនដែលទទួលបានពីសូលុយស្យុងទឹកអុកស៊ីសែននៅកំហាប់$0.2\text{mol L}^{-1}$ ។

កាតាលីករមានឥទ្ធិពលទៅលើល្បឿនប្រតិកម្មគឺ ប្រែប្រួលទៅតាមលក្ខខណ្ឌដូចគ្នានិងប្រតិកម្មមិនប្រើកាតាលីករដែរ ។ ដូច្នេះល្បឿនប្រតិកម្មដែលមានកាតាលីករចូលរួម គឺកើនឡើង កាលណា ៖

- បង្កើនសីតុណ្ហភាព
- បង្កើនកំហាប់សូលុយស្យុង
- បង្កើនសម្ពាធនៃឧស្ម័ន

ប្រតិកម្មគីមីជាច្រើនត្រូវការកាតាលីករ ។ ការប្រើបរិមាណកាតាលីករច្រើនធ្វើឱ្យប្រតិកម្មប្រព្រឹត្តទៅកាន់តែរហ័ស ។

## 5.2. កាតាលីស

កាតាលីសជាអំពើនៃកាតាលីករទៅលើប្រតិកម្មគីមី ។ គេបែងចែកប្រភេទកាតាលីសតាមធម្មជាតិនៃប្រព័ន្ធដែលកើតឡើងពីអង្គធាតុប្រតិករនិងកាតាលីករ ។

- កាតាលីសអូម៉ូសែន (ស្មើសាច់ ) ៖ កាលណាកាតាលីករនិងអង្គធាតុប្រតិករស្ថិតក្នុងផាសតែមួយ ។ ***ឧទាហរណ៍*** ឌីស្មូតកម្មទឹកអុកស៊ីសែនដោយអ៊ីយ៉ុងដែកជាកាតាលីសអូម៉ូសែនពីព្រោះទឹកអុកស៊ីសែន(អង្គធាតុប្រតិករ)និងអ៊ីយ៉ុងដែក(កាតាលីករ)ស្ថិតក្នុងសូលុយស្យុងទឹកបង្កើតបានជាផាសតែមួយ ។



*រូបទី 2.13 គូទាំងពីរនៃទឹកអុកស៊ីសែន និងវិបាកការ៉ា*

ឌីស្មូតកម្មជាប្រតិកម្មអុកស៊ីដូរេដុកកម្មកើតឯង ដែលមានអង្គធាតុប្រតិករមួយដើរតួជារេដុករផងនិងអុកស៊ីតករផង ។

***ឧទាហរណ៍*** ឌីស្មូតកម្មទឹកអុកស៊ីសែន ដែលក្នុងនោះ $H_2O_2$ នៃគូ $H_2O_2/H_2O$ ជាអុកស៊ីតករនិង $H_2O_2$ នៃគូ $O_2/H_2O_2$ ជារេដុករ ។

- កាតាលីសអេតេរ៉ូសែន ( មិនស្មើសាច់ ): កាលណាកាតាលីករនិងអង្គធាតុប្រតិករស្ថិតនៅក្នុងផាសពីរផ្សេងគ្នា។ ***ឧទាហរណ៍ :*** ឌីស្មូតកម្មទឹកអុកស៊ីសែនដោយលោហៈប្លាទីន ជាកាតាលីករអេតេរ៉ូសែន ពីព្រោះលោហៈប្លាទីនជាផាសរឹងនិងទឹកអុកស៊ីសែនជាផាសរាវ ។
- កាតាលីសអង់ស៊ីម : ជាករណីដោយឡែកនៃកាតាលីសអូម៉ូសែន ដែលកាតាលីករជាអង់ស៊ីម (ប្រូតេអ៊ីនដែលបង្កឡើងពីភាវៈរស់) ។ ***ឧទាហរណ៍ :*** ឌីស្មូតកម្មទឹកអុកស៊ីសែនដោយកាតាឡាសនៃឈាមជាកាតាលីសអង់ស៊ីម ។

## ៥.៣. លក្ខណៈនៃកាតាលីករ

### ក. នាទីលើស៊ីនេទិច

កាតាលីករអាចបង្កើនល្បឿនតែទៅលើប្រតិកម្មទាំងឡាយណាដែលប្រព្រឹត្តទៅតាមទែម៉ូឌីណាមិចប៉ុណ្ណោះ ។ បើប្រតិកម្មមួយមិនអាចប្រព្រឹត្តទៅតាមបែបទែម៉ូឌីណាមិចក្នុងលក្ខខណ្ឌណាមួយនោះទេ គ្មានកាតាលីករណាមួយអាចធ្វើឱ្យប្រតិកម្មប្រព្រឹត្តទៅបានឡើយ ។

- លោហៈ Cu គ្មានអំពើជាមួយអាស៊ីតក្លរីឌ្រិចទេ ។ គេថាប្រតិកម្មគីមីរវាងលោហៈទង់ដែងនិងអាស៊ីតក្លរីឌ្រិច មិនអាចប្រព្រឹត្តទៅតាមទែម៉ូឌីណាមិចទេ ។ គេមិនអាចរកកាតាលីករណាមួយធ្វើឱ្យប្រតិកម្មនេះប្រព្រឹត្តទៅបានទេ ។
- គេលាយ $O_2$ មួយមាឌនិង $H_2$ ពីរមាឌ ទុកក្នុងរយៈពេលដ៏យូរ គេពុំឃើញមានប្រតិកម្មកើតឡើងទេ ។ ទោះបីប្រតិកម្មនេះ អាចប្រព្រឹត្តទៅតាមទែម៉ូឌីណាមិចក៏ដោយ ។ បើគេយកអណ្តាតភ្លើងឬប្រើកាតាលីករ (ប្លាទីន) ទៅប៉ះល្បាយ $O_2$ និង $H_2$ នេះ ប្រតិកម្មគីមីកើតមានយ៉ាងលឿនដោយផ្ទុះ ។

### ខ. បាតុភូតវិសេសភាព

កាលណាកាតាលីករមួយមានសកម្មភាពលើប្រតិកម្មមួយច្បាស់លាស់ គេនិយាយថាកាតាលីករមានវិសេសភាពចំពោះប្រតិកម្មនោះ ។

***ឧទាហរណ៍ :*** ដេស៊ីដ្រូសែនកម្មអេតាណុលជាអេតាណាល់ អាចរងកាតាលីកម្មដោយលោហៈទង់ដែង ឬប្លាទីនប៉ុណ្ណោះ ។ $CH_3-CH_2-OH \xrightarrow[\text{ឬ Pt}]{Cu} CH_3-CHO+H_2(g)$

## គ. កាតាលីករដែលប្រើទូទៅមានបរិមាណតិច

ជាញឹកញាប់បរិមាណតិចនៃកាតាលីករអាចបំលែងបរិមាណដ៏ច្រើននៃអង្គធាតុប្រតិករបាន ។

## ឃ. កាតាលីករចូលរួមប្រតិកម្ម

***ឧទាហរណ៍*** : ឌីស្មូតកម្មទឹកអុកស៊ីសែនដោយកាតាលីករជាអ៊ីយ៉ុងដែក ។

- ករណីកាតាលីករជាអ៊ីយ៉ុង $Fe^{2+}$




*រូបទី 2.14 វិធានហ្គាម៉ាបង្ហាញថាអ៊ីយ៉ុង $Fe^{2+}$ និង $Fe^{3+}$ អាចជាកាតាលីករ ឌីស្មូតកម្មទឹកអុកស៊ីសែន*

គូរេដុកដែលចូលរួមប្រតិកម្មមាន : $H_2O_2/H_2O$ $Fe^{3+}/Fe^{2+}$ និង $O_2/H_2O_2$ ។ តាមវិធានកាម៉ា :

នៅតំណាក់ការទី 1 ទឹកអុកស៊ីសែន (អុកស៊ីតករនៃគូ $H_2O_2/H_2O$ )ធ្វើអុកស៊ីតកម្មលើអ៊ីយ៉ុង $Fe^{2+}$ (រេដុករនៃគូ $Fe^{3+}/Fe^{2+}$ ) ។ សមីការតាងប្រតិកម្ម :

$$H_2O_2 + 2H^+ + 2e^- \longrightarrow 2H_2O$$
$$Fe^{2+} \longrightarrow Fe^{3+} + 1e^- \quad (\times 2)$$
$$\overline{H_2O_2 + 2H^+ + 2Fe^{2+} \longrightarrow 2H_2O + 2Fe^{3+} \quad (1)}$$

នៅតំណាក់ការទី 2 ទឹកអុកស៊ីសែន(រេដុករនៃគូ $O_2/H_2O_2$ )ទទួលរងអុកស៊ីតកម្ម ដោយអ៊ីយ៉ុង $Fe^{3+}$ (អុកស៊ីតករនៃគូ $Fe^{3+}/Fe^{2+}$ ) :

$$H_2O_2 \longrightarrow O_2 + 2H^+ + 2e^-$$
$$Fe^{3+} + 1e^- \longrightarrow Fe^{2+} \quad (\times 2)$$
$$\overline{H_2O_2 + 2Fe^{3+} \longrightarrow O_2 + 2H^+ + 2Fe^{2+} \quad (2)}$$

បូកសមីការ (1) និង (2) គេបានសមីការតុល្យការឌីស្មូតកម្មទឹកអុកស៊ីសែន

$$H_2O_2 + \cancel{2H^+} + \cancel{2Fe^{2+}} \longrightarrow 2H_2O + \cancel{2Fe^{3+}}$$
$$H_2O_2 + \cancel{2Fe^{3+}} \longrightarrow O_2 + \cancel{2H^+} + \cancel{2Fe^{2+}}$$
$$\overline{2H_2O_2 \longrightarrow O_2 + 2H_2O}$$

- ករណីដែលកាតាលីករជាអ៊ីយ៉ុង $Fe^{3+}$

លំដាប់នៃប្រតិកម្មបន្តបន្ទាប់ច្រាសទៅនិងករណីខាងលើ ។ ដំបូងគឺប្រតិកម្មទី 2 បានប្រព្រឹត្តទៅ (អ៊ីយ៉ុង $Fe^{3+}$ ទទួលរងរេដុកម្មជា $Fe^{2+}$ ) បន្ទាប់មកប្រតិកម្មទី 1 បានបន្តទៅទៀតដែលនាំឱ្យកើតអ៊ីយ៉ុង $Fe^{3+}$ មកវិញ ។

ការបំបាត់អ៊ីយ៉ុង $Fe^{2+}$ និង $Fe^{3+}$ ក្នុងបន្ទាំសមីការ (1) និង (2) បានពន្យល់ថា កាតាលីករមិនបង្ហាញក្នុងតុល្យការនៃប្រតិកម្មទេ ។

ខូទៅកម្ម ៖ ក្នុងពេលកាតាលីសអូម៉ូសែន កាតាលីករចូលរួមប្រតិកម្មបានបាត់ក្នុងដំណាក់ទី I ប៉ុន្តែបានកើតវិញក្នុងដំណាក់ការបន្ទាប់ ។

## ង. តួនាទីកាតាលីករនៅក្នុងប្រតិកម្ម

កាតាលីករអូម៉ូសែន ៖ កាលណាប្រភេទគីមីមួយមាននាទីជាកាតាលីករក្នុងកាតាលីសអូម៉ូសែន ជាទូទៅ ៖

- ប្រតិកម្មសរុបត្រូវបានបំបែកជាពីរឬច្រើនដំណាក់
- កាតាលីករបាត់បង់នៅក្នុងដំណាក់ទី I ហើយកើតឡើងវិញនៅដំណាក់បន្ទាប់ ។

ឥទ្ធិពលនៃកាតាលីករទៅលើល្បឿនប្រតិកម្មអាចបង្ហាញដូចនៅក្នុងរូបទី 2.15 ។ កាតាលីករអូម៉ូសែនបំបែកប្រតិកម្មមួយឱ្យទៅជាប្រតិកម្មច្រើន ដែលមានថាមពលសកម្មខ្សោយនិងល្បឿនប្រតិកម្មលឿនជាង ។




*រូបទី 2.15 ក្រាប (ក) បង្ហាញពីការគ្មានឥទ្ធិពលកាតាលីករទៅលើថាមពលសកម្មនៃប្រតិកម្ម ។ ក្រាប (ខ) បង្ហាញពីឥទ្ធិពលកាតាលីករទៅលើថាមពលសកម្មនៃប្រតិកម្ម ។*

វត្តមានកាតាលីករធ្វើឱ្យមានប្រែប្រួលផ្លូវប្រតិកម្ម តែមិនធ្វើឱ្យប្រែប្រួលភាពដើមនៃអង្គធាតុប្រតិករ និងភាពស្រេចនៃអង្គធាតុកកើតទេ ។

កាតាលីសអេតេរ៉ូសែន ៖ ចំពោះកាតាលីសអេតេរ៉ូសែន ប្រតិកម្មប្រព្រឹត្តទៅលើផ្ទៃប៉ះកាតាលីករដែលវាស្ថិតនៅគ្មានកំណែប្រែគីមីពេលប្រតិកម្មចប់ ។ កាតាលីករអេតេរ៉ូសែនក៏បន្ថយថាមពលសកម្មនៃប្រតិកម្មដែរ ។ កាតាលីកររឹងកាន់តែមានប្រសិទ្ធភាព កាលណាវាស្ថិតនៅជាបំណែកគ្រាប់ល្អិតតូចៗ (គ្រាប់ម្សៅ) ។

## 5.4. ស្វ័យកាតាលីស

***និយមន័យ ៖*** ស្វ័យកាតាលីស គឺជាកាតាលីសនៃប្រតិកម្មដោយផលិតផលកកើតមួយរបស់វា ។

សិក្សាប្រតិកម្មស្វ័យកាតាលីសនៃរេដុកម្មអ៊ីយ៉ុងពែម៉ង់កាណាត $MnO_4^-$ ដោយអាស៊ីតអុកសាលិច $H_2C_2O_4$ ។

គូរេដុកចូលរួមប្រតិកម្មមាន ៖ $MnO_4^- / Mn^{2+}$ និង $CO_2/H_2C_2O_4$

សមីការគីមីតាងប្រតិកម្ម ៖ $2MnO_4^- + 5H_2C_2O_4 + 6H^+ \longrightarrow 2Mn^{2+} + 10CO_2 + 8H_2O$

## ពិសោធន៍ស្វ័យកាតាលីស

- វត្ថុបំណង : បកស្រាយស្វ័យកាតាលីសនៃប្រតិកម្មរេដុកម្មអ៊ីយ៉ុង $MnO_4^-$ ដោយអាស៊ីតអុកសាលិច ។
- សម្ភារៈ : កែវបេស៊ែចំណុះ 150mL ចំនួនពីរនិងស៊ីឡាំងក្រិត ។
- ធាតុគីមី
  - សូលុយស្យុងអាស៊ីតអុកសាលិចកំហាប់ 0.1mol $L^{-1}$ សូលុយស្យុងអាស៊ីតស៊ុលផួរិចខាប់
  - សូលុយស្យុងប៉ូតាស្យូមពែម៉ង់កាណាតកំហាប់ $2\times10^{-2}$mol $L^{-1}$
  - សូលុយស្យុងម៉ង់កាណែសស៊ុលផាត ។
- ដំណើរការពិសោធ
  - ចាក់សូលុយស្យុងអាស៊ីតអុកសាលិច 20mL ដោយប្រើស៊ីឡាំងក្រិតទៅក្នុងកែវបេស៊ែទាំងពីរ
  - បន្ថែមអាស៊ីតស៊ុលផួរិចខាប់ 2 ឬ 3 ដំណក់ទៅក្នុងកែវបេស៊ែទាំងពីរ
  - បន្ថែមសូលុយស្យុងម៉ង់កាណែសស៊ុលផាត (មានអ៊ីយ៉ុង $Mn^{2+}$) 2 ឬ 3 ដំណក់ទៅក្នុងកែវបេស៊ែទី 2 ។
  - បន្ថែមសូលុយស្យុងប៉ូតាស្យូមពែម៉ង់កាណាត 10mL ទៅក្នុងកែវបេស៊ែទាំងពីរនៅពេលជាមួយគ្នា ។
- សង្កេត : ពីរឬបីនាទីក្រោយមកគេសង្កេតឃើញមានបម្រែបម្រួលពណ៌សូលុយស្យុងក្នុងកែវបេស៊ែទី 2 (មានអ៊ីយ៉ុង $Mn^{2+}$ ) ។ រីឯសូលុយស្យុងក្នុងកែវបេស៊ែទី 1 ដែលគ្មានអ៊ីយ៉ុង $Mn^{2+}$ នោះបានប្រែពណ៌ក្រោយរយៈពេលច្រើននាទី ។



រូបទី 1.17 ឥទ្ធិពលកាតាលីសនៃអ៊ីយ៉ុង $Mn^{2+}$ ទៅលើរេដុកម្មអ៊ីយ៉ុង $MnO_4^-$ ដោយអាស៊ីតអុកសាលិច

- បំណកស្រាយ : អ៊ីយ៉ុង $Mn^{2+}$ ធ្វើកាតាលីសប្រតិកម្មអុកស៊ីតកម្មអាស៊ីតអុកសាលិច ដោយអ៊ីយ៉ុងពែម៉ង់កាណាត ។ ដោយអ៊ីយ៉ុង $Mn^{2+}$ កើតពីប្រតិកម្ម ដូចនេះវាជាស្វ័យកាតាលីស ។
- សន្និដ្ឋាន : ក្នុងប្រតិកម្មខាងលើអ៊ីយ៉ុង $Mn^{2+}$ ដើរតួជាស្វ័យកាតាលីករ ។

## 5.4. អត្ថប្រយោជន៍នៃកាតាលីសចំពោះឧស្សាហកម្ម

កាតាលីសមានសារៈសំខាន់យ៉ាងខ្លាំងចំពោះឧស្សាហកម្មគីមី ព្រោះប្រតិកម្មនៅក្នុងឧស្សាហកម្មមួយចំនួនធំជាប្រតិកម្មប្រើកាតាលីករ ។ កាតាលីករបានបង្កើនទិន្នផលនៃប្រតិកម្ម និងធ្វើឱ្យប្រតិកម្មប្រព្រឹត្តទៅនៅសីតុណ្ហភាពមិនសូវខ្ពស់ ដែលជាហេតុធ្វើឱ្យតម្លៃផលិតផលចុះថោក ។

## មេរៀនសង្ខេប

- ភាគល្អិតអង្គធាតុរឹងនៃអង្គធាតុប្រតិករកាន់តែតូច ផ្ទៃប៉ះកាន់តែធំ ធ្វើអង្គធាតុប្រតិករទង្គិចកាន់តែញឹកញាប់បណ្តាលឱ្យប្រតិកម្មប្រព្រឹត្តទៅកាន់តែលឿន ។
- ប្រតិកម្មភាគច្រើនប្រព្រឹត្តទៅលឿន កាលណាកំហាប់អង្គធាតុប្រតិករធំ ។
- ក្នុងសូលុយស្យុង ល្បឿននៃប្រតិកម្មសមាមាត្រទៅនឹងកំហាប់ ព្រោះភាគល្អិតកាន់តែនៅជិតគ្នាធ្វើឱ្យការទង្គិចកើតមានញឹកញាប់ ។
- ល្បឿននៃប្រតិកម្មរបស់ឧស្ម័នកើនឡើងកាលណាគេបង្កើនសម្ពាធរបស់វា ។
- ល្បឿនកំណអង្គធាតុកកើត ឬបំបាត់អង្គធាតុប្រតិករកើនជាមួយនឹងកំហាប់នៃអង្គធាតុប្រតិករ ។ ជាទូទៅ ក្នុងពេលប្រព្រឹត្តទៅនៃប្រតិកម្មគីមីល្បឿនកំណអង្គធាតុកកើត ឬបំបាត់អង្គធាតុប្រតិករថយចុះ ពីព្រោះកំហាប់នៃអង្គធាតុប្រតិករថយចុះជាលំដាប់ ។
- ល្បឿនកំណនៃផលិតផល(អង្គធាតុកកើត)ឬបំបាត់អង្គធាតុប្រតិករកើនឡើង កាលណាសីតុណ្ហភាពកើនឡើង ។
- ការបង្កើនកំហាប់ដើមនៃអង្គធាតុប្រតិករនិងការដំឡើងសីតុណ្ហភាពនាំឱ្យកើនដល់ល្បឿនកំណអង្គធាតុកកើត ឬល្បឿនបំបាត់អង្គធាតុប្រតិករ ។
- ដើម្បីបន្ថយល្បឿនប្រតិកម្មមួយ គេអាចបន្ថយកំហាប់ដោយការពង្រាវឬបញ្ចុះសីតុណ្ហភាពនៃមជ្ឈដ្ឋានប្រតិកម្ម ។
- កាតាលីករជាសារធាតុដែលពន្លឿនល្បឿនប្រតិកម្មគីមីកើតឯង ហើយកើតឡើងវិញដោយគ្មានបាត់បង់លក្ខណៈគីមីនៅពេលប្រតិកម្ម ។
- កាតាលីសជាអំពើនៃកាតាលីករទៅលើប្រតិកម្មគីមី ។
- កាតាលីសអូម៉ូសែន កាលណាកាតាលីករនិងអង្គធាតុប្រតិករមានជាសតែមួយ ។
- កាតាលីសអេតេរ៉ូសែន កាលណាកាតាលីករនិងអង្គធាតុប្រតិករមានជាសពីរផ្សេងគ្នា ។
- កាតាលីសអង់ស៊ីមជាករណីដោយឡែកនៃកាតាលីសអូម៉ូសែន ដែលកាតាលីករជាអង់ស៊ីម (ប្រូតេអ៊ីនដែលបង្កឡើងពីភាវៈរស់) ។
- ស្វ័យកាតាលីស គឺជាកាតាលីសនៃប្រតិកម្មមួយដោយសារផលិតផលមួយដែលវាបានបង្កើតឡើង ។
- ប្រសិទ្ធភាពកាតាលីករអេតេរ៉ូសែនកាន់តែខ្ពស់កាលណាផ្ទៃប៉ះកាន់តែធំ ។
- ផលប្រយោជន៍ឧស្សាហកម្មនៃកាតាលីស គឺការបង្កើតល្បឿនប្រតិកម្ម ការបង្កើនផលិតផលនិងការសំរាំងផលិតផល ។

## ? សំណួរនិងលំហាត់

1. តើទំហំភាគល្អិតនៃអង្គធាតុប្រតិករមានឥទ្ធិពលដូចម្ដេចដល់ល្បឿនប្រតិកម្ម ?
2. ចូរប្រាប់ពីកត្តាបួនយ៉ាងដែលជះឥទ្ធិពលដល់ល្បឿនប្រតិកម្ម ។
3. ហេតុអ្វីបានជាល្បឿនប្រតិកម្មអាស្រ័យលើសីតុណ្ហភាព ? ចូរបកស្រាយ ។
4. នៅសីតុណ្ហភាពជាក់លាក់មួយ អាស៊ីតក្លរីឌ្រិចមានប្រតិកម្មជាមួយដុំថ្មម៉ាប ឬកាល់ស្យូមកាបូណាត ដោយល្បឿនយឺតជាងជាមួយម្សៅថ្មម៉ាប ។

   ក. ចូរពន្យល់ហេតុអ្វីបានជាល្បឿនប្រតិកម្មកើតឡើងខុសៗគ្នា ។

   ខ. ចូរពណ៌នាពីវិធីពីរយ៉ាងដែលធ្វើឱ្យល្បឿនប្រតិកម្មខាងលើប្រែប្រួល ។
5. តើល្បឿនប្រតិកម្មកំណឌីអ៊ីយ៉ូតប្រែប្រួលដូចម្ដេចក្នុងពេលអុកស៊ីតកម្មអ៊ីយ៉ុង $I^-$ ដោយ $H_2O_2$ ?

   ក. កាលណា $[I^-]$ កើន　　　　ខ. កាលណា $[H_2O_2]$ ថយចុះ ។
6. អុកស៊ីតកម្ម $I^-$ ដោយទឹកសាវ៉ែលតាងដោយសមីការតុល្យការ:

   $ClO^- + 2I^- + 2H^+ \longrightarrow I_2 + Cl^- + H_2O$ ។ តើល្បឿនបំបាត់អ៊ីយ៉ុងអ៊ីប៉ូក្លរីត $ClO^-$ ប្រែប្រួលដូចម្ដេច កាលណាគេបន្ថែមទៅក្នុងមជ្ឈដ្ឋានប្រតិកម្មនូវ :

   ក. ប៉ូតាស្យូមអ៊ីយ៉ូដួ (KI)　　　　ខ. សូដ្យូមក្លរួ (NaCl) ។
7. តើអ្នកបកស្រាយដូចម្ដេច អំពីឥទ្ធិពលនៃកំណើនកំហាប់អង្គធាតុប្រតិករទៅលើល្បឿនបំបាត់របស់វា ?
8. ក្នុងកែវមួយដែលមានគ្រាប់ស័ង្កសី (Zn) គេបានបន្ថែមអាស៊ីតក្លរីឌ្រិចខាប់ល្មម ។ ប្រតិកម្មពុះកញ្ជ្រោល ។ តើអ្នកត្រូវធ្វើដូចម្ដេចដើម្បីបន្ថយល្បឿន ?
9. តើការប្រែពណ៌នៃសូលុយស្យុងប៉ូតាស្យូមពែម៉ង់កាណាតដោយអាស៊ីតអុកសាលិចប្រព្រឹត្តទៅលឿននៅសីតុណ្ហភាពជុំវិញ (សីតុណ្ហភាពបន្ទប់) ឬនៅ 0°C ?
10. ចូរឱ្យនិយមន័យកាតាលីករ ។
11. អ្វីទៅជាកាតាលីសអូម៉ូសែននិងកាតាលីសអេតេរ៉ូសែន ?
12. អ្វីទៅជាកាតាលីសអង់ស៊ីម ?
13. ចូរឱ្យឧទាហរណ៍មួយនៃកាតាលីសអូម៉ូសែននៃឌីស្មូតកម្មទឹកអុកស៊ីសែន ។
14. ចូរឱ្យឧទាហរណ៍មួយនៃកាតាលីសអេតេរ៉ូសែននៃឌីស្មូតកម្មទឹកអុកស៊ីសែន ។
15. តើអ៊ីយ៉ុងដែក ( $Fe^{2+}$ ឬ $Fe^{3+}$ .) ធ្វើអន្តរាគមន៍ដូចម្ដេច ចំពោះកាតាលីសឌីស្មូតកម្មទឹកអុកស៊ីសែន ?
16. ចូរប្រាប់ឈ្មោះប្រតិកម្មស្វ័យកាតាលីសមួយ ។

17. ចូរប្រាប់ពីអត្ថប្រយោជន៍កាតាលីករក្នុងឧស្សាហកម្ម ។

18. បញ្ជាក់ថា តើជាកាតាលីសអូម៉ូសែន ឬអេតេរ៉ូសែន ចំពោះប្រតិកម្មនីមួយៗខាងក្រោម :

ក. $2NH_3(g) + \frac{5}{2}O_2(g) \xrightarrow{Pt} 2NO(g) + 3H_2O(\ell)$

ខ. $2H_2O_2(aq) \xrightarrow{Fe^{3+}(aq)} O_2(g) + 2H_2O(\ell)$

គ. $2H_2O_2(aq) \xrightarrow{MnO_2(s)} O_2(g) + 2H_2O(\ell)$

ឃ. $CH_3COOH(aq) + C_2H_5OH(aq) \xrightarrow{H^+(aq)} CH_3COO(C_2H_5)(aq) + H_2O(\ell)$

ង. $SO_2(g) + \frac{1}{2}O_2(g) \xrightarrow{NO_2(g)} SO_3(g)$

ច. $2Al(s) + 3I_2(s) \xrightarrow{H_2O(\ell)} 2AlI_3(s)$

19. ក. កាលណាគេធ្វើឱ្យចំហាយអេតាណុលឆ្លងកាត់លើអាលុយមីននៅ 400°C គេទទួលបានចំហាយទឹក អេតាណុលមិនប្រតិកម្មនិងឧស្ម័នម្យ៉ាងទៀតបម្រែពណ៌សូលុយស្យុងប្រូម ។ តើឧស្ម័នដែលកើតឡើងនោះជាអ្វី ? សរសេរសមីការតុល្យការរបស់វាជាមួយឌីប្រូមនិងឱ្យសមីការកំណាវាពីអេតាណុល ។

ខ. កាលណាគេធ្វើឱ្យចំហាយអេតាណុលប៉ះទង់ដែងដុតក្តៅនៅ 300°C គេទទួលបានល្បាយឧស្ម័នមួយដែលកំណញើសក្នុងបំពង់ត្រជាក់ ហើយក្នុងភាពរាវវាឱ្យកករពណ៌លឿងជាមួយ 2.4 – DNPH (DNPH ជាឌីនីត្រូផេនីលអ៊ីដ្រាស៊ីន)និងប្រតិកម្មកញ្ចក់ឆ្លុះប្រាក់ ។ តើឧស្ម័ននោះជាអ្វី ? សរសេរសមីការតុល្យការនៃកំណាវាពីអេតាណុល ។

គ. តើអាលុយមីននិងទង់ដែងក្នុងប្រតិកម្មនៃពិសោធន៍ទាំងពីរមាននាទីជាអ្វី ?

20. គេឱ្យប៉ូតង់ស្យែលស្តង់ដាអុកស៊ីដូ-រេដុកម្មនៅ 25°C សម្រាប់គូរេដុក :

$Cr_2O_7^{2-}$ / $Cr^{3+}$: $E_1^\circ = 1.32V$ និង $Cu^{2+}$ / $Cu$ : $E_2^\circ = 0.34V$ ។

ក. តើគេអាចធ្វើរេដុកម្មអ៊ីយ៉ុងឌីក្រូម៉ាត $Cr_2O_7^{2-}$ ដោយចរន្តឧស្ម័នឌីអ៊ីដ្រូសែនបានឬទេ ? តើត្រូវការធ្វើសូលុយស្យុងឱ្យមានមជ្ឈដ្ឋានអាស៊ីតឬទេ ? ចូរសរសេរសមីការតុល្យការនៃប្រតិកម្ម ។

ខ. គេរកកាតាលីករមួយសម្រាប់ប្រតិកម្មនេះ ។ តើអ៊ីយ៉ុង $Cu^{2+}$ អាចយកមកប្រើបានឬទេ ?

គ. តើពិសោធន៍ណាខ្លះដែលត្រូវធ្វើមុននិងសន្និដ្ឋានថា អ៊ីយ៉ុង $Cu^{2+}$ ធ្វើកាតាលីសទៅលើប្រតិកម្មនោះ ?

21. ក្នុងកែវបេស៊ែមួយគេលាយមាឌស្មើគ្នា (ប្រហែល 25mL )នៃសូលុយស្យុងពីរដែលមានកំហាប់ស្មើគ្នា $2 \times 10^{-2} mol.L^{-1}$ គឺទីមួយជាសូលុយស្យុង KI និងទីពីរជាសូលុយស្យុងប៉ូតាស្យូមពែអុកសូឌីស៊ុលផាត ។ នៅរយៈពេលប្រហែលមួយនាទីមានពណ៌លេចឡើងក្នុងសូលុយស្យុង ។

ក. តើប្រភេទគីមីណាខ្លះដែលទទួលអុកស៊ីតកម្ម ហើយដោយអុកស៊ីតករណា ?

ខ. ចូរសរសេរសមីការតុល្យការ (1) នៃប្រតិកម្មរវាងគូ : $S_2O_8^{2-}/SO_4^{2-}$ និង $I_2/I^-$ ។

គ. ប្រតិកម្មអុកស៊ីដូរេដុកម្ម ដូចតទៅជាប្រតិកម្មលឿន :

$$2Fe^{3+} + 2I^- \longrightarrow 2Fe^{2+} + I_2 \quad (2)$$

$$2Fe^{2+} + S_2O_8^{2-} \longrightarrow 2Fe^{3+} + 2SO_4^{2-} \quad (3)$$

ចូរទាញបង្ហាញថា អ៊ីយ៉ុង $Fe^{2+}$ និង $Fe^{3+}$ ដែលតាមនិយមន័យជាកាតាលីករនៃប្រតិកម្ម (1) ។

គេឱ្យ : $S_2O_8^{2-}/SO_4^{2-}$ ($E^\circ = 2.01V$) និង $I_2/I^-$ ($E^\circ = 0.54V$)

## ? សំណួរនិងលំហាត់ជំពូក 1

1. តើកត្តាអ្វីខ្លះដែលនាំឱ្យមានកំណែប្រែដល់ល្បឿនប្រតិកម្មគីមី ?
2. កាលណាគេបង្កើនកំហាប់អង្គធាតុប្រតិករ ហេតុអ្វីខ្លះធ្វើឱ្យល្បឿនប្រតិកម្មគីមីកើនឡើង ?
3. ហេតុអ្វីបានជាទំហំភាគល្អិតអង្គធាតុប្រតិករកាន់តែតូច ធ្វើឱ្យប្រតិកម្មប្រព្រឹត្តទៅឡើងកាន់តែលឿន ?
4. ហេតុអ្វីបានជាឧស្ម័នធ្វើប្រតិកម្មលឿនកាលណាគេបង្កើនសម្ពាធទៅលើវា ? ចូរពន្យល់ ។
5. ហេតុអ្វីការទង្គិចរវាងម៉ូលេគុលនិងម៉ូលេគុលត្រូវការជាចាំបាច់ក្នុងប្រតិកម្មគីមីជាច្រើន ?
6. នៅសីតុណ្ហភាព 500°C សមាសធាតុឌីមេទីលអេទែបំបែកយឺតៗឱ្យជាមេតាន កាបូនម៉ូណូអុកស៊ីតនិងឧស្ម័នអ៊ីដ្រូសែនតាមសមីការ :

$$CH_3OCH_3(g) \longrightarrow CH_4(g) + CO(g) + H_2(g)$$

ក. ចូរឱ្យនិយមន័យល្បឿនមធ្យមបំបាត់ឌីមេទីលអេទែនៅចន្លោះពេល $t_1$ និង $t_2$

ខ. ចូរឱ្យនិយមន័យល្បឿនមធ្យមកំណមេតាននៅចន្លោះពេល $t_1$ និង $t_2$

គ. សរសេរទំនាក់ទំនងរវាងល្បឿនមធ្យមបំបាត់អង្គធាតុប្រតិករនិងល្បឿនមធ្យមកំណអង្គធាតុកកើត ។

7. ទិន្នន័យខាងក្រោមប្រមូលបានអំឡុងពេលសិក្សាប្រតិកម្មដូចខាងក្រោម :

$$2Br^-(aq) + H_2O_2(aq) + 2H_3O^+(aq) \longrightarrow Br_2(aq) + 4H_2O(\ell)$$

| រយៈពេល t(s) | [ $H_3O^+$ ] M ឬ mol $L^{-1}$ | [$Br_2$] M ឬ mol $L^{-1}$ |
|---|---|---|
| 0 | 0.0500 | 0 |
| 85 | 0.0298 | 0.0101 |
| 95 | 0.0280 | 0.0110 |
| 105 | 0.0263 | 0.0118 |

ចូរប្រើវិធីពីរយ៉ាងដើម្បីគណនាល្បឿនមធ្យមបំបាត់អ៊ីយ៉ុង$H_3O^+$ និងកំណ $Br_2$ នៅចន្លោះពេល $t = 85s$ និង $t = 95s$ ។

8. ប្រតិកម្មមួយតាងដោយសមីការ $2NO(g) + Br_2(g) \longrightarrow 2NOBr(g)$

គណនាល្បឿនមធ្យមបំបាត់អង្គធាតុប្រតិករកាលណា :

ក. កំហាប់ប្រូមថយចុះ $5.3 \times 10^{-5}M$ ក្នុងចន្លោះពេល $\Delta t = 38s$ ។

ខ. កំហាប់អាសូតអុកស៊ីតថយចុះ $1.04 \times 10^{-5}M$ ក្នុងចន្លោះពេល $\Delta t = 38s$ ។

9. ខ្សែកោងទាំងពីរនេះតាងឱ្យកំហាប់ [C] នៃអង្គធាតុគីមី C ក្នុងមជ្ឈដ្ឋានប្រតិកម្មអនុគមន៍ទៅនិងរយៈពេល t ។ បញ្ជាក់ថា តើខ្សែកោងណាមួយត្រូវអង្គធាតុកកើត ហើយខ្សែកោងណាមួយត្រូវនិងអង្គធាតុប្រតិករ ?



(a) (b)

10. ខ្សែកោងខាងក្រោមនេះតាងឱ្យបម្រែបម្រួលកំហាប់ឌីអ៊ីយ៉ូត $[I_2] = f(t)$ ក្នុងប្រតិកម្ម :

$$S_2O_8^{2-} + 2I^- \longrightarrow I_2 + 2SO_4^{2-}$$

ក. តើកំហាប់ឌីអ៊ីយ៉ូតនៅពេលអនន្តមានប៉ុន្មាន ?

ខ. កំណត់ល្បឿនមធ្យមកំណនៃឌីអ៊ីយ៉ូតនៅពេល $t_1 = 10min$ និង $t_2 = 20min$ ។




11. ក. ដោយដឹងថា អាស៊ីតអុកសាលិចជារេដុករនៃគូ $CO_2/H_2C_2O_4$ ។ ចូរឱ្យសមីការតុល្យការអុកស៊ីតកម្មរបស់វាដោយអ៊ីយ៉ុងពែម៉ង់កាណាតក្នុងមជ្ឈដ្ឋានអាស៊ីត ។

ខ. ឱ្យនិយមន័យនៃល្បឿនបំបាត់អ៊ីយ៉ុង $MnO_4^-$ នៅខណៈ t ។

គ. តើមានទំនាក់ទំនងដូចម្តេចរវាងល្បឿនបំបាត់អាស៊ីតអុកសាលិចនិងល្បឿនបំបាត់នៃ $MnO_4^-$ ក្នុងខណៈពេលនីមួយៗ ?

12. ទឹកអុកស៊ីសែនធ្វើប្រតិកម្មបំបែកយឺតៗ ចំពោះមុខកាតាលីករដែលមានសមីការតុល្យការ :

$2H_2O_2(aq) \longrightarrow O_2(g) + 2H_2O(\ell)$ ។ តាមវិធីសមស្រប គេអាចកំណត់កំហាប់ទឹកអុកស៊ីសែនដែលនៅសល់ក្នុងសូលុយស្យុង ហើយទទួលបានលទ្ធផលដូចក្នុងតារាង:

| t(min) | 0 | 1 | 3 | 5 | 7 | 10 | 12 | 15 |
|---|---|---|---|---|---|---|---|---|
| $[H_2O_2](10^{-2}mol\ L^{-1})$ | 4.5 | 4.0 | 3.1 | 2.4 | 1.9 | 1.3 | 1.1 | 0.8 |

ក. ចូរសង់ខ្សែកោង $[H_2O_2] = f(t)$

ខ. ចូរកំណត់រកល្បឿនមធ្យមបំបាត់ទឹកអុកស៊ីសែននៅចន្លោះពេល $t = 0$ និង $t_2 = 10min$

គ. ចូរកំណត់រកល្បឿនបំបាត់ទឹកអុកស៊ីសែននៅខណៈ $t = 0$ និង $t_2 = 10min$ ។

# ជំពូក 2 សមាសធាតុក្នុងសូលុយស្យុងទឹកនិងកម្លាំងអន្តរម៉ូលេគុល




សមាសធាតុរឹងអាចជាសមាសធាតុអ៊ីយ៉ុង ឬម៉ូលេគុល ។ ក្នុងអង្គធាតុរឹងអ៊ីយ៉ុង ទម្រង់ក្រាមត្រូវបានបង្កើតឡើងដោយសារបន្ទុកភាគល្អិតទាញគ្នាទៅវិញទៅមកដោយកម្លាំងអ៊ីយ៉ុង ។ ក្នុងអង្គធាតុរឹងម៉ូលេគុលទម្រង់ក្រាមបង្កឡើងដោយការប្រទាញគ្នាទៅវិញទៅមកដោយកម្លាំងអន្តរម៉ូលេគុល ។ កាលណាគេរំលាយសមាសធាតុអ៊ីយ៉ុងនិងសមាសធាតុម៉ូលេគុលក្នុងទឹក សមាសធាតុទាំងនេះមានលក្ខណៈខុសៗគ្នា ។

មេរៀនទី

# 1 សមាសធាតុក្នុងសូលុយស្យុងទឹក

**ចប់មេរៀននេះ សិស្សអាច**

- ❑ សរសេរសមីការបំបែកជាអ៊ីយ៉ុងនៃសមាសធាតុអ៊ីយ៉ុងដែលរលាយក្នុងទឹក ។
- ❑ ព្យាករណ៍ ថាតើកករនិងកើតមាន ឬគ្មានកាលណាសូលុយស្យុងបានលាយចូលគ្នា ។
- ❑ សរសេរសមីការអ៊ីយ៉ុងសម្រួលសម្រាប់ប្រតិកម្មបង្កើតកករ ។
- ❑ ប្រៀបធៀបការបំបែកនៃសមាសធាតុអ៊ីយ៉ុងជាមួយសមាសធាតុម៉ូលេគុល ។
- ❑ បែងចែកភាពខុសគ្នារវាងអេឡិចត្រូលីតខ្លាំងនិងអេឡិចត្រូលីតខ្សោយ ។

## 1. ការបំបែក

នៅពេលសមាសធាតុដែលបង្កើតឡើងពីអ៊ីយ៉ុងបំបែកក្នុងទឹក អ៊ីយ៉ុងបានផ្តាច់ចេញពីគ្នា (មើលរូបទី 1.1) ការផ្តាច់នៃអ៊ីយ៉ុងនេះកើតឡើងនៅពេលដែលសមាសធាតុអ៊ីយ៉ុងរលាយហៅថា **ការបំបែក** ។ ***ឧទាហរណ៍*** ការបំបែកនៃសូដ្យូមក្លរួនិងកាល់ស្យូមក្លរួក្នុងទឹកបង្ហាញតាមរយៈសមីការខាងក្រោម :

$$NaCl(s) \xrightarrow{H_2O} Na^+(aq) + Cl^-(aq) \quad (1)$$

$$CaCl_2(s) \xrightarrow{H_2O} Ca^{2+}(aq) + 2Cl^-(aq) \quad (2)$$



*រូបទី 1.1 : ការរលាយនៃ NaCl ក្នុងទឹក*

សមីការ (1) បង្ហាញថា 1mol នៃ NaCl បំបែកបាន 1mol អ៊ីយ៉ុង $Na^+$ និង 1mol អ៊ីយ៉ុង $Cl^-$ ក្នុងសូលុយស្យុង ។ ចំណែក 1mol នៃ $CaCl_2$ បំបែកបាន 1mol អ៊ីយ៉ុង $Ca^{2+}$ និង 2mol អ៊ីយ៉ុង $Cl^-$ ក្នុងសូលុយស្យុង ។

ឧបមាថាការបំបែក 100 % សូលុយស្យុងដែលមាន 1mol នៃ NaCl ឱ្យ 1mol នៃអ៊ីយ៉ុង $Na^+$ និង 1mol នៃអ៊ីយ៉ុង $Cl^-$ ។ យើងឧបមាថា សមាសធាតុអ៊ីយ៉ុងទាំងអស់រលាយនិងបំបែក 100 % ។ ដូច្នេះ ការបំបែកនៃ NaCl អាចសរសេរ :

$$\underset{1mol}{NaCl(s)} \xrightarrow{H_2O} \underset{1mol}{Na^+(aq)} + \underset{1mol}{Cl^-(aq)}$$

ចំណែកសូលុយស្យុងដែលមាន 1mol នៃ $CaCl_2$ រលាយចូលក្នុងទឹក នោះការបំបែកឱ្យ :

$$CaCl_2(s) \xrightarrow{H_2O} Ca^{2+}(aq) + 2Cl^-(aq) \quad (2)$$

1mol　　1mol　　2mol

***ឧទាហរណ៍ :*** សរសេរសមីការការបំបែកអាលុយមីញ៉ូមស៊ុលផាត ($Al_2(SO_4)_3$ )ក្នុងទឹក ។ តើមានប៉ុន្មានម៉ូលនៃអ៊ីយ៉ុង $Al^{3+}$ និងអ៊ីយ៉ុង $SO_4^{2-}$ បានបង្កើតឡើងដោយការរំលាយ 1mol នៃ នៃអាលុយមីញ៉ូមស៊ុលផាត ? គណនាចំនួនម៉ូលសរុបនៃអ៊ីយ៉ុងដែលបានកើតឡើង ។

***ចម្លើយ :***

ការបំបែកនៃអាលុយមីញ៉ូមស៊ុលផាតក្នុងទឹក

$$Al_2(SO_4)_3(s) \xrightarrow{H_2O} 2Al^{3+}(aq) + 3SO_4^{2-}(aq)$$

1mol　　2mol　　3mol

ដោយចំនួនម៉ូល $Al_2(SO_4)_3$ គឺ 1mol ។ ដូច្នេះចំនួនម៉ូលនៃអ៊ីយ៉ុង $Al^{3+}$ គឺ 2mol និងចំនួនម៉ូលនៃអ៊ីយ៉ុង $SO_4^{2-}$ គឺ 3mol ។

ចំនួនម៉ូលសរុបនៃអ៊ីយ៉ុងក្នុងសូលុយស្យុង $Al_2(SO_4)_3$ គឺ :

2mol នៃ $Al^{3+}$ + 3mol នៃ $SO_4^{2-}$ = 5mol ។

**បំហាត់អនុវត្តន៍**

ចូរសរសេរសមីការបំបែកជាអ៊ីយ៉ុងនៃសមាសធាតុខាងក្រោមនិងប្រាប់ចំនួនម៉ូលនៃអ៊ីយ៉ុងដែលបង្កើតឡើង ។

ក. 1mol នៃអាម៉ូញ៉ូមក្លរួ ($NH_4Cl$)

ខ. 1mol នៃសូដ្យូមស៊ុលផាត ($Na_2SO_4$)

គ. 0.1mol នៃបារ្យូមនីត្រាត ( $Ba(NO_3)_2$ ) ។

## 1.1. ប្រតិកម្មបង្កើតកករ

សមាសធាតុមួយចំនួនមិនរលាយទាំងស្រុងទេ ។ សមាសធាតុទាំងនេះហៅថា សមាសធាតុរលាយតិច ដែលគេប្រើវាសម្រាប់គោលបំណងផ្សេងៗ ។ គេមានការលំបាកក្នុងការសរសេរវិធានកម្រិតរលាយដើម្បីប្រើគ្រប់លក្ខខណ្ឌទាំងអស់ ។ ប៉ុន្តែគេអាចសរសេរជាគោលការណ៍មួយចំនួនដែលអាចឱ្យអ្នកព្យាករណ៍ ថាតើសមាសធាតុដែលបានបង្កើតឡើងពីអ៊ីយ៉ុងរលាយឬអត់ ។

គោលការណ៍ទូទៅនៃកម្រិតរលាយ

- សមាធាតុសូដ្យូម ប៉ូតាស្យូមនិងអាលុយមីញ៉ូម-រលាយក្នុងទឹក ។
- សមាសធាតុនីត្រាត អាសេតាតនិងក្លរ៉ាតរលាយក្នុងទឹក ។
- អំបិលក្លរួភាគច្រើនរលាយលើកលែងតែអំបិលប្រាក់ អំបិលបារត (I) និងអំបិលសំណ (II) ក្លរួមិនរលាយ ។
- អំបិលស៊ុលផាតរលាយលើកលែងតែអំបិលស៊ុលផាតនៃបារ្យូម ស្ត្រុងចូម សំណ កាល់ស្យូមនិងបារត ។



*រូបទី 1.2 : សមាសធាតុអ៊ីយ៉ុងអាចរលាយឬមិនរលាយក្នុងទឹក ។ $NiCl_2$ , $KMnO_4$ , $CuSO_4$ និង $Pb(NO_3)_2$ រលាយក្នុងទឹក ។ រីឯ AgCl និង CuS មិនរលាយក្នុងទឹក ។*

- អំបិលកាបូណាត ផូស្វាតនិងស៊ីលីកាតមិនរលាយ លើកលែងតែអំបិលកាបូណាតនៃសូដ្យូមប៉ូតាស្យូមនិងអាម៉ូញ៉ូមដែលរលាយ ។
- អំបិលស៊ុលភីតមិនរលាយលើកលែងតែអំបិលស៊ុលភីតនៃកាល់ស្យូម ស្ត្រង់ចូម សូដ្យូមប៉ូតាស្យូម និងអាម៉ូញ៉ូមដែលរលាយ ។

***ឧទាហរណ៍*** : តើកាល់ស្យូមផូស្វាត $Ca_3(PO_4)_2$ រលាយឬមិនរលាយ ? តាមគោលការណ៍ទូទៅនៃកម្រិតរលាយនិងតារាង 1.1 អំបិលផូស្វាតស្ទើរតែទាំងអស់មិនរលាយ រីឯ $Ca_3(PO_4)_2$ ក៏មិនរលាយដែរ ។

ក្នុងតារាង 1.1 អាចឱ្យយើងព្យាករ ថាតើនឹងមានអ្វីកើតឡើង បើសូលុយស្យុងនៃសមាសធាតុរលាយពីរបានលាយចូលគ្នា ។ បើការរលាយនៃសមាសធាតុទាំងពីរនាំឱ្យមានបន្សំអ៊ីយ៉ុងដែលកើតឡើងជាសមាសធាតុមិនរលាយនោះ កករនឹងកើតមាន ។ កករនឹងកើតមានឡើងកាលណាការប្រទាញគ្នារវាងអ៊ីយ៉ុងនិងអ៊ីយ៉ុងធំជាងការប្រទាញគ្នារវាងអ៊ីយ៉ុងនិងម៉ូលេគុលទឹកដែលនៅហ៊ុមព័ទ្ធជុំវិញ ។

តើកករនឹងកើតមាន ឬទេនៅពេលដែលសូលុយស្យុងអាម៉ូញ៉ូមស៊ុលផួនិងកាត់ម្ញ៉ូមនីត្រាតបានលាយបញ្ចូលគ្នា ? តាមរយៈតារាង 1.1 អ្នកអាចដឹងថាកាត់ម្ញ៉ូមនីត្រាត $Cd(NO_3)_2$ ជាសមាសធាតុរលាយព្រោះវាជាអំបិលនីត្រាត ។ រីឯអាម៉ូញ៉ូមស៊ុលផួក៏ជាសមាសធាតុរលាយ ។

### តារាង 1.1 លក្ខណៈរលាយក្នុងទឹករបស់សមាសធាតុមួយចំនួន

| អាញ៉ុង | កាចុង | | | | | | | | | | | | | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | $H^{+}$ | $K^{+}$ | $Na^{+}$ | $Ag^{+}$ | $NH_4^{+}$ | $Mg^{2+}$ | $Ca^{2+}$ | $Ba^{2+}$ | $Zn^{2+}$ | $Cd^{2+}$ | $Hg^{2+}$ | $Pb^{2+}$ | $Cu^{2+}$ | $Fe^{2+}$ | $Fe^{3+}$ | $Al^{3+}$ |
| $OH^{-}$ | រ | រ | រ | – | រ | ម | ត | រ | ម | ម | – | ម | ម | ម | ម | ម |
| $Cl^{-}$ | រ/ហ | រ | រ | ម | រ | រ | រ | រ | រ | រ | រ | ត | រ | រ | រ | រ |
| $NO_3^{-}$ | រ/ហ | រ | រ | រ | រ | រ | រ | រ | រ | រ | រ | រ | រ | រ | រ | រ |
| $CH_3COO^{-}$ | រ/ហ | រ | រ | រ | រ | រ | រ | រ | រ | រ | រ | រ | រ | រ | រ | ត |
| $S^{2-}$ | រ/ហ | រ | រ | ម | រ | រ | ត | រ | ម | ម | ម | ម | ម | ម | - | - |
| $SO_3^{2-}$ | រ/ហ | រ | រ | ម | រ | ម | ម | ម | ម | ម | ម | ម | ម | ម | - | - |
| $SO_4^{2-}$ | រ/មហ | រ | រ | ត | រ | រ | ត | ម | រ | រ | រ | ម | រ | រ | រ | រ |
| $CO_3^{2-}$ | រ/ហ | រ | រ | ម | រ | ម | ម | ម | ម | ម | ម | ម | ម | ម | ម | - |
| $SiO_3^{2-}$ | រ/មហ | រ | រ | ម | រ | ម | ម | ម | ម | ម | - | ម | ម | ម | ម | ម |
| $PO_4^{3-}$ | រ/មហ | រ | រ | ម | រ | ម | ម | ម | ម | ម | ម | ម | ម | ម | ម | ម |

រ : សមាសធាតុរលាយក្នុងទឹក ម : សមាសធាតុមិនរលាយក្នុងទឹក ត : សមាសធាតុរលាយតិច

ហ : សមាសធាតុហើរឬងាយបំបែកជាឧស្ម័នហើរឡើង មហ : សមាសធាតុមិនហើរ — : សមាសធាតុដែលពុំកើតមាន

សមីការនៃការបំបែកអាចសរសេរ :

$$(NH_4)_2S(s) \xrightarrow{H_2O} 2NH_4^{+}(aq) + S^{2-}(aq)$$

$$Cd(NO_3)_2(s) \xrightarrow{H_2O} Cd^{2+}(aq) + 2NO_3^{-}(aq)$$




*រូបទី 1.3 : ប្រតិកម្មបង្កើតកករកាត់ម្ញូមស៊ុលផួ CdS*

ផលិតផលពីរដែលនឹងអាចកើតមានក្នុងប្រតិកម្មជំនួសទ្វេរវាង $(NH_4)_2S$ និង $Cd(NO_3)_2$ គឺអាម៉ូញ៉ូមនីត្រាត $NH_4NO_3$ និង កាត់ម្ញូមស៊ុលផួ CdS ។

សមីការបង្ហាញនូវភាពមិនស្គាល់នៃភាពរូបរបស់ផលិតផល :

$$(NH_4)_2S(aq) + Cd(NO_3)_2(aq) \longrightarrow 2NH_4NO_3(?) + CdS(?)$$

ដើម្បីសម្រេចថាតើកករអាចនឹងកើតមាន ឬអត់ អ្នកត្រូវស្គាល់ពីកម្រិតរលាយនៃសមាសធាតុទាំងពីរនេះ ។ តាមតារាង 1.1 អ្នកឃើញថា $NH_4NO_3$ រលាយក្នុងទឹក ។ ប៉ុន្តែ CdS មិនរលាយក្នុងទឹកទេ ។ ដូច្នេះ កាលណាសូលុយស្យុង $(NH_4)_2S$ និង $Cd(NO_3)_2$ បានលាយចូលគ្នានោះ គឺមានកករតែមួយគត់ដែលនឹងកើតមានឡើងគឺ CdS ។

តាមរយៈរូបទី 1.3 បង្ហាញពីក្រោម CdS កើតមានឡើង កាលណាសូលុយស្យុងទាំងពីរបានលាយចូលគ្នា ។ សមីការតើមីតាងប្រតិកម្ម :

$$(NH_4)_2S(aq) + Cd(NO_3)_2(aq) \longrightarrow 2NH_4NO_3(aq) + CdS(s)$$

## 1.2. សមីការអ៊ីយ៉ុងសម្រួល

ប្រតិកម្មនៃអ៊ីយ៉ុងទាំងឡាយក្នុងសូលុយស្យុងទឹកតាងដោយសមីការអ៊ីយ៉ុងសម្រួល ប្រសើរជាងសមីការគីមី ។ សមីការអ៊ីយ៉ុងសម្រួលជាសមីការដែលសរសេរតែសមាសធាតុនិងអ៊ីយ៉ុងទាំងឡាយណាដែលរងនូវបម្រែបម្រួលគីមីក្នុងពេលប្រតិកម្មក្នុងសូលុយស្យុងទឹក ។

ដើម្បីសរសេរសមីការអ៊ីយ៉ុងសម្រួល ដំបូងប្ដូរសមីការគីមីទៅជាសមីការអ៊ីយ៉ុងសព្វ ។ សមាសធាតុអ៊ីយ៉ុងរលាយទាំងអស់ បង្ហាញដោយបានបំបែកជាអ៊ីយ៉ុងក្នុងសូលុយស្យុង ។ ចំណែកកករបង្ហាញជាអង្គធាតុរឹង ។ ចំពោះប្រតិកម្មបង្កើតកករ CdS អាចសរសេរជាសមីការអ៊ីយ៉ុងសព្វ :

$$Cd^{2+}(aq) + 2NO_3^-(aq) + 2NH_4^+(aq) + S^{2-}(aq) \rightarrow CdS(s) + 2NO_3^-(aq) + 2NH_4^+(aq)$$

កត់សំគាល់ថា សូលុយស្យុងទឹកនៃអ៊ីយ៉ុងអាម៉ូញ៉ូមនិងសូលុយស្យុងទឹកនៃអ៊ីយ៉ុងនីត្រាត បង្ហាញនៅអង្គទាំងពីរនៃសមីការ ។ បំបាត់ $NH_4^+$ និង $NO_3^-$ ពីសមីការអ៊ីយ៉ុងសព្វខាងលើគេបានសមីការអ៊ីយ៉ុងសម្រួល : $Cd^{2+}(aq) + S^{2-}(aq) \longrightarrow CdS(s)$

សមីការអ៊ីយ៉ុងសម្រួលមិនមែនប្រើសម្រាប់តែប្រតិកម្មរវាង $(NH_4)_2S$ និង $Cd(NO_3)_2$ ទេ ។ ប៉ុន្តែសមីការនេះក៏អាចប្រើសម្រាប់ប្រតិកម្មដែលបង្កើតកករកាត់ម្យូមស៊ុលផួនៅពេលដែលសូលុយស្យុងនៃអ៊ីយ៉ុងទាំងនេះបានលាយចូលគ្នា ។ ***ឧទាហរណ៍*** សមីការអ៊ីយ៉ុងសម្រួលសម្រាប់កករ CdS កាលណាសូលុយស្យុង $CdSO_4$ និង $H_2S$ បានលាយចូលគ្នា ។

$$Cd^{2+}(aq) + SO_4^{2-}(aq) + 2H^+(aq) + S^{2-}(aq) \longrightarrow CdS(s) + 2H^+(aq) + SO_4^{2-}$$

$$Cd^{2+}(aq) + S^{2-}(aq) \longrightarrow CdS(s)$$

***លំហាត់គំរូ :*** តើកករនឹងកើតមានឡើងឬទេ កាលណាគេលាយសូលុយស្យុងទឹកនៃស័ង្កសីនីត្រាតនិងអាម៉ូញ៉ូមស៊ុលផាតចូលគ្នា ? ចូរសរសេរសមីការប្រតិកម្មជំនួសទ្វេដែលអាចមាន ។ បន្ទាប់មកសរសេរសមីការគីមី សមីការអ៊ីយ៉ុងសព្វនិងសមីការអ៊ីយ៉ុងសម្រួលសម្រាប់ប្រតិកម្មនេះ ។

***ចម្លើយ :*** ប្រើតារាង 1.1 ដើម្បីកំណត់ផលិតផលជាសមាសធាតុមិនរលាយ

សរសេរសមីការប្រតិកម្មជំនួសទ្វេដែលអាចមានដូចតទៅ :

$$Zn(NO_3)_2(aq) + (NH_4)_2S(aq) \longrightarrow ZnS(?) + 2NH_4NO_3(?)$$

តាមតារាង 1.1 បញ្ជាក់ថា ZnS គឺជាស៊ុលផួមិនរលាយ ។ ចំណែក $NH_4NO_3$ ជាសមាសធាតុរលាយ

សមីការគីមី :

$$Zn(NO_3)_2(aq) + (NH_4)_2S(aq) \longrightarrow ZnS(s) + 2NH_4NO_3(aq)$$

សមីការអ៊ីយ៉ុងសព្វ : $Zn^{2+}(aq) + 2NO_3^-(aq) + 2NH_4^+(aq) + S^{2-}(aq) \longrightarrow$

$$ZnS(s) + 2NH_4^+(aq) + 2NO_3^-(aq)$$

អ៊ីយ៉ុងអាម៉ូញ៉ូមនិងអ៊ីយ៉ុងនីត្រាតដែលមាននៅអង្គទាំងពីរនៃសមីការជាអ៊ីយ៉ុងទស្សនិក ។ សមីការអ៊ីយ៉ុងសម្រួល : $Zn^{2+}(aq) + S^{2-}(aq) \longrightarrow ZnS(s)$

**លំហាត់អនុវត្តន៍**

1. តើកករនិងកើតមានឡើងឬទេ បើសូលុយស្យុងប៉ូតាស្យូមស៊ុលផាតនិងបារ្យ៉ូមនីត្រាតបានលាយចូលគ្នា ? បើមានកករកើតឡើង ចូរសរសេរសមីការអ៊ីយ៉ុងសម្រួលសម្រាប់ប្រតិកម្មនេះ ។
2. តើកករនិងកើតមានឡើងឬទេ បើសូលុយស្យុងប៉ូតាស្យូមនីត្រាតនិងម៉ាញេស្យូមស៊ុលផាតបានលាយចូលគ្នា ? បើមានកករកើតឡើង ចូរសរសេរសមីការអ៊ីយ៉ុងសម្រួលសម្រាប់ប្រតិកម្មនេះ ។
3. តើកករនិងកើតមានឡើងឬទេ បើសូលុយស្យុងបារ្យ៉ូមក្លរួនិងសូដ្យូមស៊ុលផាតបានលាយចូលគ្នា ? បើមានកករកើតឡើង ចូរប្រាប់ពីអ៊ីយ៉ុងទស្សនិកនិងសរសេរសមីការអ៊ីយ៉ុងសម្រួល ។
4. សរសេរសមីការអ៊ីយ៉ុងសម្រួលសម្រាប់ការបង្កើតកករនីកែល (II) ស៊ុលផួ ។

## 2. អ៊ីយ៉ុងកម្ម

សមាសធាតុម៉ូលេគុលមួយចំនួនក៏អាចមានសណ្ឋានជាអ៊ីយ៉ុងក្នុងសូលុយស្យុងដែរ ។ ភាគច្រើនជាសមាសធាតុប៉ូលែ ។ អ៊ីយ៉ុងកើតឡើងពីម៉ូលេគុលនៃអង្គធាតុរលាយដោយអំពើនៃអង្គធាតុរំលាយហៅថា **អ៊ីយ៉ុងកម្ម** ។

កាលណាសមាសធាតុអ៊ីយ៉ុងរលាយ អ៊ីយ៉ុងដែលកើតឡើងត្រូវបានផ្តាច់ចេញពីគ្នា ។ កាលណាសមាសធាតុម៉ូលេគុលរលាយក្នុងអង្គធាតុរំលាយប៉ូលែ អ៊ីយ៉ុងក៏បានកើតដែរ តែមិនមានចំពោះសមាសធាតុមិនរលាយទេ ។ អ៊ីយ៉ុងទាំងឡាយក្នុងសូលុយស្យុងទឹកគឺអ៊ីយ៉ុងកើតឡើងដោយម៉ូលេគុលអង្គធាតុរលាយហ៊ុមព័ទ្ធដោយម៉ូលេគុលទឹក ។ ថាមពលដែលបញ្ចេញជាកម្តៅអំឡុងពេលអ៊ីដ្រាតកម្មនៃអ៊ីយ៉ុងផ្តល់ថាមពលដើម្បីបំបែកសម្ព័ន្ធកូវ៉ាឡង់ ។

ជាទូទៅ ការរលាយរបស់សមាសធាតុក្នុងសូលុយស្យុង អាស្រ័យលើកម្លាំងសម្ព័ន្ធខាងក្នុងម៉ូលេគុលនៃអង្គធាតុរលាយនិងកម្លាំងប្រទាញរវាងម៉ូលេគុលនៃអង្គធាតុរលាយនិងអង្គធាតុរំលាយ ។ បើកម្លាំងសម្ព័ន្ធខាងក្នុងម៉ូលេគុលអង្គធាតុរលាយខ្សោយជាងកម្លាំងប្រទាញនៃម៉ូលេគុលអង្គធាតុរំលាយ នោះសម្ព័ន្ធកូវ៉ាឡង់នៃអង្គធាតុរលាយត្រូវបានបំបែក ហើយម៉ូលេគុលផ្តាច់ចេញពីគ្នាទៅជាអ៊ីយ៉ុង ។ អ៊ីដ្រូសែនក្លរួ (HCl) ជាសមាសធាតុម៉ូលេគុលបំបែកជាអ៊ីយ៉ុងក្នុងសូលុយស្យុងទឹក ។ សមាសធាតុនេះមានសម្ព័ន្ធប៉ូលែខ្ពស់ ។ កម្លាំងប្រទាញរវាងម៉ូលេគុលប៉ូលែ (HCl) និងម៉ូលេគុលប៉ូលែរបស់ទឹក គឺខ្លាំងគ្រប់គ្រាន់ដើម្បីបំបែកសម្ព័ន្ធ (HCl) ឱ្យទៅជាអ៊ីយ៉ុងអ៊ីដ្រូសែននិងអ៊ីយ៉ុងក្លរ ។

$$HCl(g) \xrightarrow{H_2O} H^+(aq) + Cl^-(aq)$$

## 3. អ៊ីយ៉ុងអ៊ីដ្រូញ៉ូម (The hydronium ion)

សមាសធាតុម៉ូលេគុលជាច្រើន ដែលមានអាតូមអ៊ីដ្រូសែនចងសម្ព័ន្ធដោយសម្ព័ន្ធកូវ៉ាឡង់ប៉ូលែ ។ សមាសធាតុទាំងនេះឱ្យជាអ៊ីយ៉ុងក្នុងសូលុយស្យុងទឹកដោយបញ្ចេញអ៊ីយ៉ុង $H^+$ ។ អ៊ីយ៉ុង $H^+$ ប្រទាញម៉ូលេគុល ឬអ៊ីយ៉ុងយ៉ាងខ្លាំងដែលធ្វើឱ្យវាមិនអាចនៅតែឯង ។ អ៊ីដ្រូសែនក្លរួរលាយក្នុងទឹក គឺជាឧទាហរណ៍នៃប្រតិកម្មគីមីដែលប្រូតុងបានផ្ទេរដោយផ្ទាល់ពី HCl ទៅម៉ូលេគុលទឹក ហើយវាក្លាយជាសម្ព័ន្ធកូវ៉ាឡង់ទៅនិងអុកស៊ីសែនជាសណ្ឋាន $H_3O^+$ ។

$$H_2O(\ell) + HCl(g) \longrightarrow H_3O^+(aq) + Cl^-(aq)$$




*រូបទី2.4 : ប្រតិកម្មបង្កើតអ៊ីយ៉ុងអ៊ីដ្រូញ៉ូម $H_3O^+$*

អ៊ីយ៉ុង $H_3O^+$ ហៅថាអ៊ីយ៉ុងអ៊ីដ្រូញ៉ូម ។ ប្រតិកម្មអ៊ីយ៉ុង $H^+$ ទៅជាអ៊ីយ៉ុង $H_3O^+$ ផ្តល់ថាមពលច្រើនសម្រាប់ធ្វើម៉ូលេគុលអង្គធាតុរលាយទៅជាអ៊ីយ៉ុង ។

## 4. អេឡិចត្រូលីតខ្លាំងនិងអេឡិចត្រូលីតខ្សោយ

សារធាតុទាំងឡាយដែលឱ្យផលជាអ៊ីយ៉ុង និងចម្លងចរន្តអគ្គិសនីក្នុងសូលុយស្យុងជាអេឡិចត្រូលីត ។ ចំណែកសារធាតុមិនឱ្យផលជាអ៊ីយ៉ុងនិងមិនចម្លងចរន្តអគ្គិសនីក្នុងសូលុយស្យុងគឺមិនអេឡិចត្រូលីត ។

អ៊ីដ្រូសែនអាឡូសែនទាំងអស់ជាសមាសធាតុម៉ូលេគុលដែលមានសម្ព័ន្ធកូវ៉ាឡង់ទោល ។ សមាសធាតុទាំងនោះជាឧស្ម័នដែលរលាយបានច្រើននៅក្នុងទឹកនិងជាសមាសធាតុអេឡិចត្រូលីត ។ អ៊ីដ្រូសែនក្លរួ អ៊ីដ្រូសែនប្រូមួនិងអ៊ីដ្រូសែនអ៊ីយ៉ូឌួ ចម្លងចរន្តអគ្គិសនីយ៉ាងខ្លាំងក្នុងសូលុយស្យុងទឹក ។ មានតែអ៊ីដ្រូសែនភ្លុយអរួ (HF) តែមួយគត់ដែលចម្លងចរន្តអគ្គិសនីខ្សោយនៅកំហាប់ដូចគ្នា ។




*រូបទី 1.5 : អេឡិចត្រូលីតខ្លាំងដូចជា NaCl ចំណែកអេឡិចត្រូលីតខ្សោយដូចជា HF និងសាការ៉ូសជាមិនអេឡិចត្រូលីត*

ភាពចម្លងចរន្តអគ្គិសនីនៃសូលុយស្យុងអេឡិចត្រូលីតអាស្រ័យទៅនឹងលទ្ធភាពនៃការបំបែកជាអ៊ីយ៉ុងរបស់អេឡិចត្រូលីតក្នុងសូលុយស្យុង (រូបទី 1.5) ។

## 4.1. អេឡិចត្រូលីតខ្លាំង

អ៊ីដ្រូសែនក្លរួ អ៊ីដ្រូសែនប្រូមួនិងអ៊ីដ្រូសែនអ៊ីយ៉ូឌួបំបែក 100 % ទៅជាអ៊ីយ៉ុងក្នុងសូលុយស្យុងទឹក ។ **អេឡិចត្រូលីតខ្លាំង** ជាសមាសធាតុទាំងឡាយដែលក្នុងសូលុយស្យុងទឹកវាចម្លងចរន្តអគ្គិសនីបានល្អ ហើយសមាសធាតុនោះបំបែកជាអ៊ីយ៉ុងទាំងស្រុងក្នុងសូលុយស្យុងទឹក ។ សូលុយស្យុងអ៊ីដ្រូសែនក្លរួ អ៊ីដ្រូសែនប្រូមួ និងអ៊ីដ្រូសែនអ៊ីយ៉ូឌួក្នុងទឹកជាសូលុយស្យុងអាស៊ីត ។ អាស៊ីតទាំងនេះរលាយទាំងស្រុងក្នុងទឹកជាសូលុយស្យុងអេឡិចត្រូលីតខ្លាំង ។

អេឡិចត្រូលីតខ្លាំងរលាយក្នុងទឹកឱ្យផលជាអ៊ីយ៉ុងតែមួយមុខ ។ ***ឧទាហរណ៍*** អេឡិចត្រូលីតខ្លាំងមួយចំនួនដូចជា NaCl អាចរលាយបានច្រើនក្នុងទឹកនិងឱ្យជាអ៊ីយ៉ុង $Na^+$ និង $Cl^-$ ក្នុងសូលុយស្យុងទឹក ។

## 4.2. អេឡិចត្រូលីតខ្សោយ

សមាសធាតុម៉ូលេគុលមួយចំនួនជាអេឡិចត្រូលីតខ្សោយ ព្រោះក្នុងសូលុយស្យុងទឹកវាបំបែកទៅជាអ៊ីយ៉ុងបានតិចតួច ។ ***ឧទាហរណ៍*** អ៊ីដ្រូសែនភ្លុយអរួ (HF) រលាយក្នុងទឹកឱ្យជាសូលុយស្យុងអាស៊ីតភ្លុយអរីឌ្រិច ។ សម្ព័ន្ធរវាងអ៊ីដ្រូសែននិងភ្លុយអរ ខ្លាំងជាងសម្ព័ន្ធរវាងអ៊ីដ្រូសែននិងអាឡូសែនដទៃទៀត ។ នៅពេលអ៊ីដ្រូសែនភ្លុយអរួរលាយក្នុងទឹក ម៉ូលេគុលខ្លះបំបែកជាអ៊ីយ៉ុង $H^+$ និង $F^-$ ។ ប៉ុន្តែប្រតិកម្មច្រាស បានបញ្ជូនអ៊ីយ៉ុង $H^+$ និងអ៊ីយ៉ុង $F^-$ ទៅជាសណ្ឋានម៉ូលេគុលអ៊ីដ្រូសែនភ្លុយអរួវិញតាមសមីការ :

$$HF(aq) + H_2O(l) \rightleftharpoons H_3O^+(aq) + F^-(aq)$$

កំហាប់នៃ HF ធំជាងកំហាប់អ៊ីយ៉ុង $H_3O^+$ និងកំហាប់អ៊ីយ៉ុង $F^-$ ។

អ៊ីដ្រូសែនភ្លុយអរួគឺជាឧទាហរណ៍នៃអេឡិចត្រូលីតខ្សោយ ។ អេឡិចត្រូលីតខ្សោយ គឺជាសមាសធាតុទាំងឡាយណាដែលក្នុងសូលុយស្យុងទឹកវាចម្លងចរន្តអគ្គិសនីខ្សោយ(មានវត្តមានអ៊ីយ៉ុងតិចតួច) ។ ឧទាហរណ៍ផ្សេងទៀតនៃអេឡិចត្រូលីតខ្សោយ ដូចជាអាស៊ីតអាសេទិច $CH_3COOH$ បំបែកជាអ៊ីយ៉ុងតិចតួចក្នុងសូលុយស្យុងទឹក ។

$$CH_3COOH(aq) + H_2O(\ell) \rightleftharpoons CH_3COO^-(aq) + H_3O^+(aq)$$

ចំណែកមិនអេឡិចត្រូលីតដូចជា ម៉ូលេគុលសាការ៉ូសរលាយក្នុងទឹក ប៉ុន្តែមិនបំបែកជាអ៊ីយ៉ុងក្នុងសូលុយស្យុងទេដូច្នេះ ក្នុងសូលុយស្យុងទឹកវាមិនចម្លងអគ្គិសនី ។



មិនអេឡិចត្រូលីត(អំពូលមិនភ្លឺ) អេឡិចត្រូលីតខ្សោយ(អំពូលភ្លឺខ្សោយ) អេឡិចត្រូលីតខ្លាំង(អំពូលភ្លឺខ្លាំង)

***រូបទី 1.6 : ពិសោធន៍បង្ហាញអំពីការបំភ្លឺអំពូលអគ្គិសនីនៃអេឡិចត្រូលីតខ្លាំង -ខ្សោយ តាមរយៈការចម្លងចរន្តអគ្គិសនី***

ការពិពណ៌នាអំពីអេឡិចត្រូលីតខ្លាំង ឬអេឡិចត្រូលីតខ្សោយមិនគប្បីភាន់ច្រឡំទៅនឹងការពិពណ៌នាអំពីកំហាប់សូលុយស្យុង ឬការពង្រាវ ។ អេឡិចត្រូលីតខ្លាំង ឬអេឡិចត្រូលីតខ្សោយខុសគ្នាពីកម្រិតបំបែកជាអ៊ីយ៉ុង ឬកម្រិតអ៊ីយ៉ុងកម្ម ។ កំហាប់និងការពង្រាវសូលុយស្យុងខុសគ្នាពីចំនួនម៉ូលនៃអង្គធាតុរលាយដែលបានរលាយក្នុងបរិមាណផ្តល់ឱ្យនៃធាតុរំលាយ ។ អាស៊ីតក្លរីឌ្រិចជាអេឡិចត្រូលីតខ្លាំង ។ នេះជាការពិត សូម្បីតែសូលុយស្យុងរាវខ្លាំងដល់ 0.00001M ក៏ដោយ ។ ផ្ទុយទៅវិញ អាស៊ីតអាសេទិចជាអេឡិចត្រូលីតខ្សោយ សូម្បីតែសូលុយស្យុងវាខាប់រហូតដល់ 10M ក៏ដោយ ។

## មេរៀនសង្ខេប

- សមាសធាតុអ៊ីយ៉ុងរលាយក្នុងទឹកបំបែកជាអ៊ីយ៉ុង ។
- សមីការអ៊ីយ៉ុងសម្រួល ជាសមីការដែលសរសេរតែសមាសធាតុនិងអ៊ីយ៉ុងទាំងឡាយណា ដែលរងនូវបម្រែបម្រួលគីមីក្នុងប្រតិកម្មនៅក្នុងសូលុយស្យុង ។
- អំពើដែលអ៊ីយ៉ុងកើតឡើងពីម៉ូលេគុលអង្គធាតុរលាយ ដោយអង្គធាតុរំលាយហៅថា **អ៊ីយ៉ុងកម្ម** ។
- អ៊ីដ្រាតកម្មនៃអ៊ីយ៉ុងផ្តល់ថាមពលដើម្បីបំបែកសម្ព័ន្ធកូវ៉ាឡង់ ។
- ការរលាយរបស់សមាសធាតុក្នុងសូលុយស្យុង អាស្រ័យលើសម្ព័ន្ធខាងក្នុងម៉ូលេគុលរបស់អង្គធាតុរលាយនិងកម្លាំងប្រទាញរវាងម៉ូលេគុលនៃអង្គធាតុរលាយនិងអង្គធាតុរំលាយ ។
- សារធាតុទាំងឡាយដែលបំបែកឱ្យផលជាអ៊ីយ៉ុងក្នុងសូលុយស្យុងហៅថា **អេឡិចត្រូលីត** ។
- អេឡិចត្រូលីតខ្លាំង ជាសារធាតុទាំងឡាយដែលក្នុងសូលុយស្យុងរាវបំបែកជាអ៊ីយ៉ុងទាំងស្រុងនិងចម្លងចរន្តអគ្គិសនីបានល្អ ។
- អេឡិចត្រូលីតខ្សោយ ជាសារធាតុទាំងឡាយដែលក្នុងសូលុយស្យុងរាវបំបែកជាអ៊ីយ៉ុងបានតិចតួចនិងចម្លងចរន្តអគ្គិសនីខ្សោយ ។

## សំណួរនិងលំហាត់

1. រកចំនួនម៉ូលនៃអ៊ីយ៉ុងដែលមាននៅក្នុង 1L នៃសូលុយស្យុង 1M :

   ក. KCl ខ. $Mg(NO_3)_2$ ។

2. ប្រើតារាង 1.1 ចូរព្យាករថាតើសមាសធាតុខាងក្រោមជាសមាសធាតុរលាយ ឬមិនរលាយ :

   ក. KCl ខ. $NaNO_3$ គ. AgCl ឃ. $BaSO_4$

   ង. $Ca_3(PO_4)_2$ ច. $(NH_4)_2S$ ឆ. FeS ។

3. ដូចម្តេចហៅថា សមីការអ៊ីយ៉ុងសម្រួល ?

4. ដូចម្តេចហៅថា អ៊ីយ៉ុងកម្ម ?

5. ក. ចូរឱ្យនិយមន័យនិងភាពខុសគ្នារវាងអេឡិចត្រូលីតខ្លាំងនិងអេឡិចត្រូលីតខ្សោយ ។

   ខ. ចូរឱ្យឧទាហរណ៍ពីរចំពោះប្រភេទនីមួយៗ ។

6. ចូរសរសេរសមីការបំបែកជាអ៊ីយ៉ុងក្នុងទឹករបស់សមាសធាតុខាងក្រោម :

   ក. KI ខ. $NaNO_3$ គ. $MgCl_2$ ឃ. $Na_2SO_4$ ។

7. ចូរសរសេរសមីការសម្រាប់ការបំបែកសមាសធាតុអ៊ីយ៉ុងក្នុងទឹកនិងប្រាប់ពីចំនួនម៉ូលសរុបនៃអ៊ីយ៉ុងដែលកើតឡើង :

   ក. 0.50 ម៉ូល ស្ត្រុងចូមនីត្រាត ខ. 0.50 ម៉ូល សូដ្យូមផូស្វាត ។

8. ប្រើតារាង 1.1 ចូរសរសេរសមីការតុល្យការនិងសមីការអ៊ីយ៉ុងសម្រួល (ក្នុងសូលុយស្យុងទឹក ) សម្រាប់ប្រតិកម្មដូចតទៅ:

   ក. បារត (II) ក្លរួ + ប៉ូតាស្យូមស៊ុលផួ →

   ខ. សូដ្យូមកាបូណាត + កាល់ស្យូមក្លរួ →

   គ. ទង់ដែង (II) ក្លរួ + អាម៉ូញ៉ូមផូស្វាត →

9. ចូរបង្ហាញអ៊ីយ៉ុងទស្សនិកក្នុងប្រតិកម្មរវាង KCl និង $AgNO_3$ ក្នុងសូលុយស្យុងទឹក ។

10. ទង់ដែង (II) ក្លរួនិងសំណ (II) នីត្រាត ប្រតិកម្មជាមួយគ្នាក្នុងសូលុយស្យុងទឹកដោយប្រតិកម្មជំនួសទ្វេ ។

    ក. ចូរថ្លឹងសមីការឱ្យមានលំនឹង ខ. ចូរសរសេរសមីការអ៊ីយ៉ុងសព្វ

    គ. ចូរសរសេរសមីការអ៊ីយ៉ុងសម្រួល

    ឃ. បើទង់ដែង (II) ក្លរួ 13.45g ចូលប្រតិកម្ម គណនាម៉ាសកករអតិបរមាដែលនឹងកើតមាន ។

មេរៀនទី

# 2 កម្លាំងអន្តរម៉ូលេគុល

**ចប់មេរៀននេះ សិស្សអាច**

- ប្រៀបធៀបសមាសធាតុអ៊ីយ៉ុងនិងសមាសធាតុម៉ូលេគុលតាមលក្ខណៈរូបរបស់វានិងប្រភេទកម្លាំងដែលមានអំពើលើវា
- ពណ៌នាពីកម្លាំងឌីប៉ូល-ឌីប៉ូល
- ពន្យល់ពីភាពខុសគ្នារបស់សម្ព័ន្ធអ៊ីដ្រូសែននិងកម្លាំងឌីប៉ូល-ឌីប៉ូល
- ពណ៌នាពីកម្លាំងរបាយឡុនដុននិងទំនាក់ទំនងកម្លាំងរបស់វាទៅនឹងប្រភេទកម្លាំងប្រទាញផ្សេងទៀត ។

## 1. ការប្រៀបធៀបសមាសធាតុអ៊ីយ៉ុងនិងសមាសធាតុកូវ៉ាឡង់

ភាគល្អិតទាំងឡាយតែងតែប្រទាញគ្នាទៅវិញទៅមក ។ ដូច្នេះ ដើម្បីជម្នះកម្លាំងទំនាញគ្នាទៅវិញទៅមក ភាគល្អិតត្រូវការថាមពល ។ បើភាគល្អិតទទួលថាមពលខ្ពស់វានឹងបំបែកចេញពីគ្នា ។ ថាមពលខ្ពស់ជាហេតុធ្វើឱ្យសារធាតុប្តូរពីភាពរាវទៅជាឧស្ម័ន ។

ចំណុចរំពុះនៃសារធាតុ គឺជារង្វាស់ដ៏ល្អនៃភាពខ្លាំងរបស់កម្លាំងដែលប្រទាញភាគល្អិតទៅវិញទៅមក ។ សមាសធាតុកូវ៉ាឡង់ភាគច្រើនរលាយនៅសីតុណ្ហភាពទាបជាងសមាសធាតុអ៊ីយ៉ុង ។ តារាង 2.1 បង្ហាញពីសារធាតុអ៊ីយ៉ុងមានទំនោរជាអង្គធាតុរឹងដែលមានចំណុចរលាយខ្ពស់និងសារធាតុកូវ៉ាឡង់មានទំនោរជាឧស្ម័ន អង្គធាតុរាវ ឬអង្គធាតុរឹងដែលមានចំណុចរំពុះទាប ។

តារាងទី 2.1 : ការប្រៀបធៀបសារធាតុអ៊ីយ៉ុងនិងសារធាតុម៉ូលេគុល

| ប្រភេទសារធាតុ | និយមប្រើ | ភាពរូបនៅសីតុណ្ហភាពបន្ទប់ | ចំណុចរលាយ (°C) | ចំណុចរំពុះ (°C) |
|---|---|---|---|---|
| សារធាតុអ៊ីយ៉ុង<br>ប៉ូតាស្យូមក្លរួ KCl | អំបិលជំនួស | រឹង | 770 | |
| សូដ្យូមក្លរួ NaCl | អំបិលសម្ល | រឹង | 801 | 1413 |
| កាល់ស្យូមភ្លុយអរួ $CaF_2$ | ភ្លុយអរកម្មក្នុងទឹក | រឹង | 1423 | 2500 |
| សារធាតុកូវ៉ាឡង់<br>មេតាន $CH_4$ | ឧស្ម័នធម្មជាតិ | ឧស្ម័ន | –182 | –164 |
| អេទីលអាសេតាត $CH_3COOCH_2CH_3$ | ទឹកលាងក្រចក | អង្គធាតុរាវ | –84 | 77 |
| ទឹក $H_2O$ | ប្រើច្រើនមុខ | អង្គធាតុរាវ | 0 | 100 |
| អិបតាដេកាន $C_{17}H_{36}$ | ក្រមួនទៀន | រឹង | 22 | 302 |

## 2. អ៊ីយ៉ុងមានបន្ទុកផ្ទុយគ្នាប្រទាញគ្នាទៅវិញទៅមក

ជាទូទៅសារធាតុអ៊ីយ៉ុងមានកម្លាំងប្រទាញខ្លាំងជាងសារធាតុកូវ៉ាឡង់ ។ សារធាតុអ៊ីយ៉ុងផ្សំដោយអ៊ីយ៉ុងវិជ្ជមាននិងអ៊ីយ៉ុងអវិជ្ជមាន ។ អ៊ីយ៉ុងនីមួយៗបានប្រទាញទៅលើអ៊ីយ៉ុងទាំងឡាយដែលមានបន្ទុកផ្ទុយគ្នា ។ ចំពោះអ៊ីយ៉ុងតូចៗពួកវាប្រទាញគ្នាយ៉ាងខ្លាំងក្នុងបណ្ដាញក្រាម តែបណ្ដាញក្រាមអាចខូចខាតនៅសីតុណ្ហភាពខ្ពស់ ។

ភាពខ្លាំងនៃកម្លាំងអ៊ីយ៉ុងអាស្រ័យលើទំហំនៃអ៊ីយ៉ុងនិងចំនួនបន្ទុក ។ សមាសធាតុអ៊ីយ៉ុងដែលមានអ៊ីយ៉ុងចូលផ្សំតូចមានចំណុចរលាយខ្ពស់ ។ បើអ៊ីយ៉ុងធំ ចម្ងាយរវាងអ៊ីយ៉ុងនិងអ៊ីយ៉ុងឆ្ងាយ ធ្វើឱ្យកម្លាំងប្រទាញខ្សោយ ។ ហេតុនេះហើយបានជាប៉ូតាស្យូមក្លរួ (KCl) រលាយនៅសីតុណ្ហភាពទាបជាងសូដ្យូមក្លរួ (NaCl) ។ ចំណែកអ៊ីយ៉ុងដែលខុសគ្នាដោយចំនួនបន្ទុកដែលវាមាន ។ បើអ៊ីយ៉ុងមានបន្ទុកធំជាង គឺកម្លាំងអ៊ីយ៉ុងធំជាងធៀបនិងអ៊ីយ៉ុងដែលមានបន្ទុកតូចជាង ។ ហេតុនេះហើយ បានជាកាល់ស្យូមភ្លុយអរួ ($CaF_2$) រលាយនៅសីតុណ្ហភាពខ្ពស់ជាងសីតុណ្ហភាពរលាយរបស់ NaCl ។

## 3. កម្លាំងអន្តរម៉ូលេគុលប្រទាញម៉ូលេគុលទៅវិញទៅមក

ចំពោះសារធាតុកូវ៉ាឡង់ កម្លាំងដែលមានអំពើទៅវិញទៅមករវាងម៉ូលេគុលហៅថា "**កម្លាំងអន្តរម៉ូលេគុល**" ។ កម្លាំងទាំងនោះអាចជាកម្លាំងឌីប៉ូល-ឌីប៉ូល ឬកម្លាំងរបាយឡុនដុន (London) ។ កម្លាំងទាំងពីរនេះកើតឡើង នៅពេលម៉ូលេគុលនៅជិតគ្នា ហើយថយចុះយ៉ាងរហ័សនៅពេលម៉ូលេគុលឋិតទៅឆ្ងាយ ។ ពីព្រោះកម្លាំងទាំងនេះជះឥទ្ធិពលទៅវិញទៅមកនៅពេលដែលម៉ូលេគុលនៅជិតគ្នាប៉ុណ្ណោះ ។ កម្លាំងនេះស្ទើរតែគ្មាន នៅពេលដែលម៉ូលេគុលឧស្ម័នទង្គិចគ្នា ។ សារធាតុដែលមានកម្លាំងប្រទាញខ្សោយនឹងនៅជាឧស្ម័ន ព្រោះវាគ្មានកម្លាំងទំនាញគ្រប់គ្រាន់ដើម្បីភ្ជាប់ម៉ូលេគុលជាមួយគ្នានៅជាអង្គធាតុរាវ ឬអង្គធាតុរឹង ។

កម្លាំងទំនាញគ្នារវាងម៉ូលេគុលនិងម៉ូលេគុលកើតឡើងនៅពេលម៉ូលេគុលនៅជិតគ្នា។ កម្លាំងអន្តរម៉ូលេគុលរបស់សារធាតុខ្សោយ កាលណាសារធាតុនោះមានចំណុចរំពុះជិតតម្លៃសូន្យដាច់ខាត ។

***ឧទាហរណ៍*** ឧស្ម័នអ៊ីដ្រូសែន ($H_2$) ពុះនៅ –252.8°C ។

កម្លាំងអន្តរម៉ូលេគុលខ្លាំង កាលណាសារធាតុម៉ូលេគុលមានចំណុចរំពុះខ្ពស់ខ្លាំង ។

***ឧទាហរណ៍*** កូរ៉ូនីន ($C_{24}H_{12}$) ពុះនៅសីតុណ្ហភាព 525°C ។

## 4. កម្លាំងឌីប៉ូល-ឌីប៉ូល

ក្នុងកម្លាំងឌីប៉ូល-ឌីប៉ូល ខាងចុងវិជ្ជមាននៃម៉ូលេគុលមួយប្រទាញទៅលើខាងចុងអវិជ្ជមាននៃម៉ូលេគុលជិតខាង ។ សម្ព័ន្ធប៉ូលែកើតឡើងរវាងអាតូមដែលមានអេឡិចត្រូអវិជ្ជមានខុសគ្នា ចងសម្ព័ន្ធគ្នាទៅវិញទៅមក ។ កាលណាអាតូមដែលបានចងសម្ព័ន្ធកូវ៉ាឡង់នឹងគ្នា មានអេឡិចត្រូអវិជ្ជមានខុសគ្នាខ្លាំង ធ្វើឱ្យម៉ូលេគុលមានភាពប៉ូលែកាន់តែខ្លាំង ។

**កម្លាំងឌីប៉ូល-ឌីប៉ូល មានឥទ្ធិពលទៅលើចំណុចរលាយនិងចំណុចរំពុះ**

កាលណាម៉ូលេគុលប៉ូលែឋិតជិតគ្នា វាប្រទាញគ្នាទៅវិញទៅមក ។ កម្លាំងប្រទាញគ្នាកាន់តែធំ បើកម្រិតប៉ូលែកាន់តែខ្លាំង ។ នៅពេលម៉ូលេគុលកាន់តែប៉ូលែ កម្លាំងឌីប៉ូល-ឌីប៉ូលកាន់តែធំ ។ គេសំគាល់ឃើញថា ចំណុចរំពុះនៃសារធាតុប្រាប់ឱ្យយើងដឹងពីកម្លាំងរវាងម៉ូលេគុលនិងម៉ូលេគុល ។

***ឧទាហរណ៍*** តារាង 2.2 បង្ហាញថាសមាសធាតុប៉ូលែប្រូប៉ាន-1-អុល ($C_3H_7OH$) ពុះនៅ 97.4°C ។ សមាសធាតុដែលប៉ូលែតិចនៃទំហំស្រដៀងគ្នាប្រូប៉ាន-1-ត្យុល ($C_3H_7SH$) ពុះនៅ 67.8°C ។ សមាសធាតុមិនប៉ូលែប៊ុយតាន($C_4H_{10}$) ក៏មានទំហំស្រដៀងគ្នាដែរ ពុះនៅ –0.5°C ។ ម៉ូលេគុលដែលមានកម្រិតប៉ូលែកាន់តែខ្លាំង កម្លាំងឌីប៉ូល-ឌីប៉ូលនឹងធ្វើឱ្យចំណុចរំពុះកាន់តែខ្ពស់ ។

តារាងទី 2.2 : ការប្រៀបធៀបកម្លាំងឌីប៉ូល-ឌីប៉ូល

| សារធាតុ | ចំណុចរំពុះ (°C) | ភាពប៉ូលែ | ភាពនៅសីតុណ្ហភាពបន្ទប់ | ទម្រង់ |
|---|---|---|---|---|
| ប្រូប៉ាន -1- អុល ($C_3H_7OH$) | 97.4 | ប៉ូលែ | រាវ |  |
| ប្រូប៉ាន-1-ត្យុល ($C_3H_7SH$) | 67.8 | ប៉ូលែតិច | រាវ |  |
| ប៊ុយតាន $C_4H_{10}$ | –0.5 | មិនប៉ូលែ | ឧស្ម័ន |  |
| ទឹក $H_2O$ | 100 | ប៉ូលែ | រាវ |  |
| អ៊ីដ្រូសែនស៊ុលផួ $H_2S$ | –60.7 | ប៉ូលែតិច | ឧស្ម័ន |  |
| អាម៉ូញ៉ាក់ $NH_3$ | –33.35 | ប៉ូលែ | ឧស្ម័ន |  |
| ផូស្វ៊ីន $PH_3$ | –87.7 | ប៉ូលែតិច | ឧស្ម័ន |  |

## 5. សម្ព័ន្ធអ៊ីដ្រូសែន

តារាង 2.2 បង្ហាញពីការប្រៀបធៀបចំណុចរំពុះនៃទឹក ($H_2O$) និងអ៊ីដ្រូសែនស៊ុលផួ ($H_2S$) ។ ម៉ូលេគុលទាំងពីរនេះមានទំហំនិងទម្រង់ប្រហាក់ប្រហែលគ្នា។ ចំណុចរំពុះនៃ$H_2O$ ខ្ពស់ជាងចំណុចរំពុះ$H_2S$ ខ្លាំង ។ ដូចគ្នានេះដែរ ចំពោះ $NH_3$ និង $PH_3$ ។ កម្រិតប៉ូលែនៃម៉ូលេគុលកាន់តែធំនោះចំណុចរំពុះកាន់តែខ្ពស់ ។

ប្រៀបធៀបចំណុចរំពុះនិងភាពខុសគ្នានៃកម្រិតអេឡិចត្រូអវិជ្ជមាននៃអ៊ីដ្រូសែនអាឡូសែនួ ដូចបង្ហាញក្នុងតារាង 2.3 ។ កំណើននៃភាពខុសគ្នានៃអេឡិចត្រូអវិជ្ជមាននាំឱ្យចំណុចរំពុះកើន ។ ចំណុចរំពុះកើនឡើងជាបន្តិចបន្តួចពី HCl ទៅ HBr ទៅ HI ប៉ុន្តែកើនឡើងខ្លាំងសម្រាប់ HF ។ ហេតុអ្វីបានជាមានការកើនឡើងយ៉ាងគំហុកដូច្នេះ ? ចម្លើយ គឺពិនិត្យមើលសណ្ឋានពិសេសនៃកម្លាំងឌីប៉ូល-ឌីប៉ូលហៅថា " សម្ព័ន្ធអ៊ីដ្រូសែន " ។

តារាងទី 2.3 ៖ ចំណុចរំពុះនៃអ៊ីដ្រូសែនអាឡូសែន

| សារធាតុ | HF | HCl | HBr | HI |
|---|---|---|---|---|
| ចំណុចរំពុះ (°C) | 20 | −85 | −67 | −35 |
| ភាពខុសគ្នានៃកម្រិតអេឡិចត្រូអវិជ្ជមានរវាងអាតូមជាដៃគូ | 1.8 | 1.0 | 0.8 | 0.5 |

## 5.1. សណ្ឋានសម្ព័ន្ធអ៊ីដ្រូសែនជាមួយអាតូមអេឡិចត្រូអវិជ្ជមាន

សម្ព័ន្ធអ៊ីដ្រូសែនខ្លាំងអាចកើតឡើងជាមួយអាតូមអ៊ីដ្រូសែន ដែលចងសម្ព័ន្ធកូវ៉ាឡង់ទៅនឹងអាតូមអេឡិចត្រូអវិជ្ជមានខ្លាំងដែល មានទីតាំងខាងលើផ្នែកខាងស្តាំនៃតារាងខួបមាន N , O ឬ F ។ កាលណាអាតូមអ៊ីដ្រូសែនចងសម្ព័ន្ធទៅនឹងអាតូម N , O និង F ធ្វើឱ្យអាតូមអ៊ីដ្រូសែនមានបន្ទុកវិជ្ជមានដោយភាគធំ ។ អាតូមអ៊ីដ្រូសែនដែលមានបន្ទុកវិជ្ជមានដោយភាគនៃម៉ូលេគុលប៉ូលែអាចប្រទាញទៅលើគូអេឡិចត្រុងមិនដាក់ហ៊ុនរបស់ម៉ូលេគុលក្បែរវា (រូបទី 2.1 ) ។




រូបទី 2.1 ក. របៀបចងសម្ព័ន្ធអ៊ីដ្រូសែន ខ. សម្ព័ន្ធអ៊ីដ្រូសែនរវាងម៉ូលេគុលទឹក

## 5.2. សម្ព័ន្ធអ៊ីដ្រូសែនជាកម្លាំងឌីប៉ូល-ឌីប៉ូលខ្លាំង

ភាពខុសគ្នានៃកម្រិតអេឡិចត្រូអវិជ្ជមាន ប្រាប់ពីកម្លាំងនៃសម្ព័ន្ធអ៊ីដ្រូសែន ។ ហេតុផលមួយដែលសម្ព័ន្ធអ៊ីដ្រូសែនជាកម្លាំងឌីប៉ូល- ឌីប៉ូលខ្លាំង ដោយសារអាតូមអ៊ីដ្រូសែនមានទំហំតូចនិងមានអេឡិចត្រុងតែមួយគត់ ។ នៅពេលដែលអេឡិចត្រុងនេះបានខិតទៅឆ្ងាយពីអាតូម H ដោយសារអាតូមដែលមានអេឡិចត្រូអវិជ្ជមានខ្លាំង នោះអាតូម H គ្មានអេឡិចត្រុងនៅសល់ទៀតទេ ។ ដូច្នេះ ប្រូតុងតែមួយនៃណ្វៃយ៉ូអ៊ីដ្រូសែនត្រូវបានបង្ហាញយ៉ាងច្បាស់ ។ ប្រូតុងរបស់អាតូមអ៊ីដ្រូសែនប្រទាញយ៉ាងខ្លាំងទៅលើគូអេឡិចត្រុងមិនសម្ព័ន្ធនៃម៉ូលេគុលផ្សេងទៀត ។ ដោយភាពខុសគ្នានៃអេឡិចត្រូអវិជ្ជមានធំ (ភាពប៉ូលែខ្លាំង) និងរួមផ្សំទំហំអាតូម H តូចផងទើបកម្លាំងសម្ព័ន្ធខ្លាំង ។

## ៥.៣. សម្ព័ន្ធអ៊ីដ្រូសែនពន្យល់ពីលក្ខណៈរបស់ទឹក

ថាមពលសម្ព័ន្ធអ៊ីដ្រូសែនទាបជាងថាមពលសម្ព័ន្ធគីមីធម្មតា ប៉ុន្តែកម្លាំងសម្ព័ន្ធអ៊ីដ្រូសែន អាចខ្លាំងជាងកម្លាំងអន្តរម៉ូលេគុលដទៃទៀត ។ សម្ព័ន្ធអ៊ីដ្រូសែនអាចឱ្យយើងពន្យល់ពីលក្ខណៈទាំងឡាយរបស់អង្គធាតុ ។ រូបទី 2.2 ជាឧទាហរណ៍បង្ហាញពីសម្ព័ន្ធអ៊ីដ្រូសែនដែលភ្ជាប់និងអាតូមអុកស៊ីសែន ។ ទឹកមានលក្ខណៈដូចគ្នា ។ ភាពដូចគ្នាទាំងនេះ គឺជាលទ្ធផលនៃសម្ព័ន្ធអ៊ីដ្រូសែន ។ ក្នុងម៉ូលេគុលទឹក អាតូមអ៊ីដ្រូសែនពីរចងសម្ព័ន្ធទៅនិងអាតូមអុកស៊ីសែនមួយដោយសម្ព័ន្ធកូវ៉ាឡង់ ។ អាតូមអ៊ីដ្រូសែននីមួយៗអាចបង្កើតសម្ព័ន្ធអ៊ីដ្រូសែនជាមួយអាតូមអុកស៊ីសែននៃម៉ូលេគុលក្បែរវា ។ ម៉ូលេគុលទឹកមានលទ្ធភាពបង្កើតសម្ព័ន្ធអ៊ីដ្រូសែនច្រើននៅពេលតែមួយបណ្តាលឱ្យកម្លាំងអន្តរម៉ូលេគុលក្នុងទឹកខ្លាំង ។




***រូបទី 2.2 ម៉ូលេគុលទឹក ប្រទាញគ្នាទៅវិញទៅមកដោយកម្លាំងសម្ព័ន្ធអ៊ីដ្រូសែនដែលធ្វើឱ្យទម្រង់ក្រាមទឹកកកមានកន្លែងទំនេរច្រើនជាងទឹករាវ***

អង្គធាតុទាំងឡាយតែងតែហាប់នៅភាពរឹងជាងនៅភាពរាវ តែទឹកនៅភាពរាវ ហាប់ជាងទឹកនៅភាពរឹងដោយសារសម្ព័ន្ធអ៊ីដ្រូសែននិងទ្រង់ទ្រាយនៃម៉ូលេគុលរបស់វា ។ ហេតុដូច្នេះហើយបានជាទឹកកកអណ្តែតលើទឹករាវ ។ មុំរវាងអាតូមអ៊ីដ្រូសែនទាំងពីរក្នុងម៉ូលេគុលទឹកគឺ 104.5° ។ មុំនេះនៅក្បែរមុំចតុមុខនិយ័ត 109.5° ។ នៅពេលទឹកក្លាយជាទឹកកក មុំក្នុងម៉ូលេគុលធ្វើឱ្យមានទម្រង់ធរណីមាត្រពិសេសក្នុងក្រាម (រូបទី 2.2 ) ។ ក្រាមទឹកកកមានបរិមាណបើកចំហច្រើន ដែលធ្វើឱ្យទឹកកកមានដង់ស៊ីតេទាបជាងទឹករាវ ។

ដោយភាពខុសគ្នានៃដង់ស៊ីតេទឹកនៅភាពរាវនិងទឹកនៅភាពរឹង អាចបកស្រាយនូវបាតុភូតជាច្រើនក្នុងពិភពធម្មជាតិ ។

***ឧទាហរណ៍*** ហេតុអ្វីបានជាទឹកកកអណ្តែតលើទឹក ទឹកត្រពាំងកកពីលើចុះក្រោមនិងមិនកកពីក្រោមឡើងលើ ? ដូច្នេះ ត្រីអាចរស់រានៅក្នុងទឹកក្រោមស្រទាប់ទឹកកកនៅរដូវរងារ ។ នៅពេលទឹកជ្រាបចូលទៅក្នុងបំណែកនៃថ្មឬបាយអរ វាអាចធ្វើឱ្យបាក់បែកដោយសារទឹករីកមាឌនៅពេល វាកក ។ អ្នកមិនត្រូវធ្វើឱ្យទឹកកកក្នុងឧបករណ៍ដាក់អាហារឬក្នុងប្រអប់ធ្វើពីកែវ ដែលអាចបណ្តាលឱ្យបែកបាក់ កាលណាទឹកកករារីកមាឌ ។

តារាងទី 2.4 :  ចំណុចរំពុះនៃឧស្ម័នកម្រ

| សារធាតុ | He | Ne | Ar | Kr | Xe | Rn |
|---|---|---|---|---|---|---|
| ចំណុចរំពុះ (°C) | –269 | –246 | –186 | –152 | –107 | –62 |
| ចំនួនអេឡិចត្រុង | 2 | 10 | 18 | 36 | 54 | 86 |

## 6. កម្លាំងរបាយឡុនដុន (London)

ចំពោះសមាសធាតុអ៊ីយ៉ុង កម្លាំងទំនាញគ្នាទៅវិញទៅមក ដោយអ៊ីយ៉ុងដែលមានបន្ទុកផ្ទុយគ្នាធ្វើឱ្យអ៊ីយ៉ុងទាំងឡាយនៅស្អិតជាប់គ្នា ។ រីឯម៉ូលេគុលប៉ូលែកម្លាំងឌីប៉ូល-ឌីប៉ូលទាញចូលគ្នាទៅវិញទៅមក ។ តើកម្លាំងអ្វីដែលទាញគ្នាទៅវិញទៅមករវាងម៉ូលេគុលមិនប៉ូលែនិងរវាងអាតូមនិងអាតូម ?

***ឧទាហរណ៍*** ប្រេងសាំងមានអុកតាន $C_8H_{18}$ ដែលម៉ូលេគុលវាមិនប៉ូលែ ។ នៅសីតុណ្ហភាពបន្ទប់វាជាអង្គធាតុរាវ ។ ហេតុអ្វីបានជាអុកតានមិនមែនជាឧស្ម័ន ? ពិតជាមានកម្លាំងអន្តរម៉ូលេគុលមួយធ្វើឱ្យប្រេងសាំងក្លាយជាវត្ថុរាវ ។

ក្នុងឆ្នាំ1930 អ្នកគីមីជនជាតិអាល្លឺម៉ង់ឈ្មោះ Fritz W London បានបកស្រាយបញ្ហានេះ ។ ម៉ូលេគុលមិនប៉ូលែមានទម្រង់ពិសេសនៃកម្លាំងឌីប៉ូល-ឌីប៉ូលហៅថា **កម្លាំងរបាយឡុនដុន** ។ ក្នុងកម្លាំងឌីប៉ូល- ឌីប៉ូល ផ្នែកអវិជ្ជមាននៃម៉ូលេគុលប្រទាញទៅលើដំបន់វិជ្ជមាននៃម៉ូលេគុលក្បែរគ្នា ។ ដូច្នេះក្នុងកម្លាំងរបាយឡុនដុនគ្មានផ្នែកពិសេសនៃម៉ូលេគុលដែលជានិច្ចកាលវិជ្ជមាន ឬអវិជ្ជមានទេ ។

### 6.1. កម្លាំងរបាយឡុនដុនកើតមានរវាងម៉ូលេគុលមិនប៉ូលែ

ជាទូទៅ ភាពរឹងមាំនៃកម្លាំងរបាយឡុនដុនរវាងភាគល្អិតមិនប៉ូលែកើនឡើងព្រមគ្នាជាមួយម៉ាសម៉ូលេគុលនៃភាគល្អិតកើនឡើង ។ ជាទូទៅកាលណាម៉ាសម៉ូលេគុលកើនឡើងចំនួនអេឡិចត្រុងក្នុងម៉ូលេគុលក៏កើនឡើងដែរ ។ ពិនិត្យមើលចំណុចរំពុះនៃឧស្ម័នកម្រក្នុងតារាង 2.4 ។ ជាទូទៅ ចំណុចរំពុះកើននៅពេលចំនួនអេឡិចត្រុងក្នុងអាតូមកើន ។ ចំពោះក្រុមអាតូមដែលផ្សំដោយអាតូមដូចគ្នានិងម៉ូលេគុលមិនប៉ូលែដូចឧស្ម័នកម្រ ឬអ៊ីដ្រូសែនអាឡូសែនក្ដីដែរ ។ កម្លាំងរបាយឡុនដុន គឺសមាមាត្រទៅនឹងចំនួនវត្តមានអេឡិចត្រុង ។



ក. ម៉ូលេគុលមិនប៉ូលែអាចបង្កឱ្យមានប៉ូលែមួយភ្លែត ។

ខ. ភាពប៉ូលកម្មនៃម៉ូលេគុលប៉ះគ្នា

គ. កម្លាំងរបាយឡុនដុនធ្វើឱ្យម៉ូលេគុលប្រទាញគ្នាទៅវិញទៅមក ។

*រូបទី 2.3 ឌីប៉ូលបណ្ដោះអាសន្នក្នុងម៉ូលេគុលបង្កឱ្យមានកម្លាំងប្រទាញរវាងម៉ូលេគុលនិងម៉ូលេគុល*

## 6.2. កម្លាំងរបាយឡុនដុនបានមកពីឌីប៉ូលបណ្ដោះអាសន្ន

តើអេឡិចត្រុងដើរតួនាទីយ៉ាងដូចម្ដេចក្នុងកម្លាំងរបាយឡុនដុន ? អេឡិចត្រុងក្នុងអាតូម ឬម៉ូលេគុលអាចធ្វើចលនាមិនឈប់ឈរ ។ ការធ្វើចលនារបស់អេឡិចត្រុងមិនត្រឹមតែនៅក្នុងអ័រប៊ីតាល់ទេ តែវាអាចធ្វើចលនាពីផ្នែកមួយទៅផ្នែកមួយទៀតនៃអាតូម ។ កាលណាអេឡិចត្រុងធ្វើចលនាឆ្ពោះទៅផ្នែកណាមួយនៃអាតូម ឬម៉ូលេគុលធ្វើឱ្យ ផ្នែកនោះក្លាយជាផ្នែកដែលមានបន្ទុកអវិជ្ជមានបណ្ដោះអាសន្ននិងផ្នែកមួយទៀតក៏នឹងក្លាយជាមានបន្ទុកវិជ្ជមានបណ្ដោះអាសន្នដែរ ។ បើផ្នែកបន្ទុកវិជ្ជមាននៃម៉ូលេគុលដែលកើតឡើងមួយភ្លែតធ្វើចលនាទៅជិតម៉ូលេគុលផ្សេងទៀត ផ្នែកវិជ្ជមាននេះអាចទាញអេឡិចត្រុងក្នុងម៉ូលេគុលដទៃទៀត ។ ផ្នែកបន្ទុកអវិជ្ជមាននៃម៉ូលេគុលដែលមានបន្ទុកកើតឡើងមួយភ្លែតអាចច្រានអេឡិចត្រុងរបស់ម៉ូលេគុលផ្សេងទៀតទៅឆ្ងាយ ។ ឌីប៉ូលបណ្ដោះអាសន្នដែលកើតឡើងប្រទាញគ្នាទៅវិញទៅមក (ដូចបង្ហាញក្នុងរូប 2.3 )និងធ្វើឱ្យឌីប៉ូលបណ្ដោះអាសន្នកើតមានឡើងក្នុងម៉ូលេគុលផ្សេងទៀត ។ នៅពេលដែលម៉ូលេគុលនៅជិតគ្នា វាតែងតែប្រទាញគ្នាទៅវិញទៅមកដោយសារតែអេឡិចត្រុងអាចផ្លាស់ទីបាន ។

# 7. លក្ខណៈនៃសារធាតុអាស្រ័យលើប្រភេទកម្លាំងអន្តរម៉ូលេគុល

ប្រៀបធៀបលក្ខណៈនៃសារធាតុអ៊ីយ៉ុង NaCl ជាមួយនិងសារធាតុមិនប៉ូលែ $I_2$ ដូចបង្ហាញក្នុងរូប 2.4 ។ លក្ខណៈខុសគ្នានៃសារធាតុ គឺទាក់ទងទៅនឹងភាពខុសគ្នានៃប្រភេទកម្លាំងដែលមានអំពើខាងក្នុងនៃសារធាតុនីមួយៗ ។ ដោយសារតែសារធាតុអ៊ីយ៉ុង សារធាតុកូវ៉ាឡង់ប៉ូលែនិងសារធាតុកូវ៉ាឡង់មិនប៉ូលែ មានរបាយអេឡិចត្រុងខុសគ្នា ទើបសារធាតុទាំងនោះមានប្រភេទកម្លាំងទំនាញក៏ខុសគ្នាដែរ ។

នៅពេលដែលម៉ូលេគុលមិនប៉ូលែអាចអនុវត្តតាមកម្លាំងរបាយឡុនដុន ម៉ូលេគុលប៉ូលែអាចអនុវត្តតាមទាំងកម្លាំងឌីប៉ូល-ឌីប៉ូលនិងកម្លាំងរបាយឡុនដុន ។ ការកំណត់ថា មានកម្លាំងអ្វីខ្លះដែលមានទំនាញគ្នាទៅវិញទៅមករវាងម៉ូលេគុលប៉ូលែ គឺមិនមានលក្ខណៈងាយស្រួលនោះទេ ។ កម្លាំងរបាយឡុនដុនក៏មានរវាងអ៊ីយ៉ុងនិងសមាសធាតុអ៊ីយ៉ុងដែរ ប៉ុន្តែកម្លាំងនេះ តូចធៀបទៅនឹងកម្លាំងទំនាញរវាងអ៊ីយ៉ុងនិងអ៊ីយ៉ុង ហើយគេអាចចោលវាបាន ។




ក្នុងក្រាមសូដ្យូមក្លរួ អ៊ីយ៉ុង$Na^+$ និង$Cl^-$ តម្រៀបគ្នាយ៉ាងទៀងទាត់តាមទិសដៅកែងគ្នាប្រាំទិស ។ អ៊ីយ៉ុងទាំងនេះប្រទាញគ្នាយ៉ាងខ្លាំងបណ្ដាលឱ្យចំណុចរំពុះរបស់ NaCl ខ្ពស់ 801°C ។

ក្នុងក្រាមអ៊ីយ៉ូត ភាគល្អិតទាំងឡាយជាម៉ូលេគុលណឺតដែលមិនអាចប្រទាញគ្នាបានខ្លាំង បណ្ដាលអ៊ីយ៉ូត($I_2$) មានចំណុចរំពុះទាប 114°C ។

*រូបទី 2.4 កម្លាំងរវាងអ៊ីយ៉ុងនិងអ៊ីយ៉ុង ជាទូទៅខ្លាំងជាងកម្លាំងរវាងម៉ូលេគុលនិងម៉ូលេគុល ។ ដូច្នេះ ចំណុចរំពុះនៃសារធាតុអ៊ីយ៉ុងខ្ពស់ជាងសារធាតុម៉ូលេគុល*

## ៨. ទំហំភាគល្អិតនិងទ្រង់ទ្រាយក៏ដើរតួនាទីសំខាន់

ជាទូទៅកម្លាំងឌីប៉ូល-ឌីប៉ូលខ្លាំងជាងកម្លាំងរបាយឡុនដុន ។ តែកម្លាំងទាំងពីរនេះគឺតែងតែខ្សោយជាងកម្លាំងអ៊ីយ៉ុងនិងអ៊ីយ៉ុងក្នុងក្រាម តែមានករណីលើកលែងខ្លះ ។ កត្តាចម្បងគឺទំហំរបស់អាតូមអ៊ីយ៉ុង ឬម៉ូលេគុល ។ ភាគល្អិតកាន់តែធំ គឺចម្ងាយរវាងភាគល្អិតកាន់តែឆ្ងាយនិងកម្លាំងទំនាញកាន់តែខ្សោយ ។ បើសារធាតុអ៊ីយ៉ុងមានទំហំអ៊ីយ៉ុងធំ ជាពិសេសគឺអ៊ីយ៉ុងមិនស៊ីមេទ្រី ចំណុចរំពុះនៃសារធាតុអ៊ីយ៉ុងនេះ គឺទាបណាស់ ។ សារធាតុអ៊ីយ៉ុងខ្លះអាចស្ថិតនៅជាភាពរាវនៅសីតុណ្ហភាពបន្ទប់ ដូចជា 1- ប៊ុយទីលពីរីដ្យូមនីត្រាត (រូបទី 2.5 ក) ។

ទម្រង់ធរណីមាត្ររបស់ភាគល្អិតក៏ដើរតួសំខាន់ក្នុងការកំណត់កម្លាំងទំនាញ ។ ***ឧទាហរណ៍*** ម៉ូលេគុលកូរ៉ូណែន ($C_{24}H_{12}$) មានទំហំធំណាស់ (រូបទី 2.5 ខ) ។ ម៉ូលេគុលវារាបស្មើ ហើយអាចនៅជិតគ្នានិងមានកម្លាំងទំនាញយ៉ាងខ្លាំង ។ អាស្រ័យដូចនេះ ចំណុចរំពុះនៃកូរ៉ូណែនដែលមានម៉ូលេគុលមិនប៉ូលែខ្ពស់ប្រហាក់ប្រហែលទៅនឹងសមាសធាតុអ៊ីយ៉ុងមួយចំនួន ។



*រូបទី 2.5 ក. សមាសធាតុអ៊ីយ៉ុងប៉ូលីអាតូម 1- ប៊ុយទីលពីរីឌ្យូមនីត្រាតជាអង្គធាតុរាវនៅសីតុណ្ហភាពបន្ទប់ ។*



*រូបទី 2.5 ខ ម៉ូលេគុលកូរ៉ូណែន ($C_{24}H_{12}$) មានទំហំធំ ហើយរាបស្មើបណ្តាលឱ្យមានកម្លាំងបាយឡុនដុនខ្លាំង ។*

## សង្ខេបមេរៀន

- ភាគល្អិតប្រទាញគ្នាទៅមក វាត្រូវការថាមពលលើស ដើម្បីភ្ជាប់គ្នាទៅវិញទៅមក ។
- ចំណុចរំពុះនៃសារធាតុ គឺសម្រាប់វាស់ភាពខ្លាំងនៃកម្លាំងភាគល្អិតដែលប្រទាញគ្នាទៅវិញទៅមក ។
- សារធាតុអ៊ីយ៉ុង ដែលមានអ៊ីយ៉ុងតូចមានចំណុចរំពុះខ្ពស់មានភាពរូបជាអង្គធាតុរឹងនៅសីតុណ្ហភាពធម្មតា ។
- សារធាតុកូវ៉ាឡង់មានចំណុចរំពុះទាប មានភាពរូបជាឧស្ម័ន ឬអង្គធាតុរាវនៅសីតុណ្ហភាពធម្មតា ។
- កម្លាំងអន្តរម៉ូលេគុលជាកម្លាំងដែលប្រទាញគ្នារវាងម៉ូលេគុលនិងម៉ូលេគុល ។
- ជាទូទៅសារធាតុអ៊ីយ៉ុងមានកម្លាំងទំនាញខ្លាំងជាងសារធាតុកូវ៉ាឡង់ ។
- ភាពខ្លាំងនៃកម្លាំងអ៊ីយ៉ុងអាស្រ័យលើទំហំនិងចំនួនបន្ទុកនៃអ៊ីយ៉ុង ។
- កម្លាំងឌីប៉ូល- ឌីប៉ូល ជាកម្លាំងប្រទាញគ្នារវាងម៉ូលេគុលប៉ូលែ ។
- សម្ព័ន្ធអ៊ីដ្រូសែនជាកម្លាំងអន្តរម៉ូលេគុលកើតឡើងកាលណាអាតូមអ៊ីដ្រូសែនចងសម្ព័ន្ធទៅនឹងអាតូមដែលមានអេឡិចត្រូអវិជ្ជមានខ្លាំង ។
- ចំណុចរំពុះរបស់ទឹកខ្ពស់ជាងចំណុចរំពុះរបស់អ៊ីដ្រូសែនស៊ុលផួ ព្រោះទឹកមានភាពប៉ូលែជាងអ៊ីដ្រូសែនស៊ុលផួ ។
- ចំណុចរំពុះកើនឡើងពី HCl ទៅ HBr ទៅ HI ប៉ុន្តែកើនឡើងខ្លាំងសម្រាប់ HF ។
- សម្ព័ន្ធអ៊ីដ្រូសែនជាសម្ព័ន្ធអន្តរម៉ូលេគុល ។ វាកើតឡើងរវាងម៉ូលេគុលទី 1 ដែលមានអាតូមអ៊ីដ្រូសែន (ប៉ូលកម្មវិជ្ជមាន) និងម៉ូលេគុលទី 2 ដែលមានអាតូមនៃធាតុអេឡិចត្រូអវិជ្ជមានខ្លាំងដូចជាអុកស៊ីសែន ( O )ឬអាសូត( N ) ។
- ថាមពលសម្ព័ន្ធអ៊ីដ្រូសែនគឺខ្សោយជាងសម្ព័ន្ធគីមីធម្មតា ប៉ុន្តែខ្លាំងជាងកម្លាំងអន្តរម៉ូលេគុលផ្សេងទៀត ។
- កម្លាំងវេបាយឡូនដុន ជាកម្លាំងអន្តរម៉ូលេគុលបានមកពីការផ្តល់ឱ្យមិនទៀងទាត់នៃអេឡិចត្រុងនិងការបង្កើតឡើងនូវឌីប៉ូលបណ្តោះអាសន្ន ។
- ភាគល្អិតកាន់តែធំ វាកាន់តែឆ្ងាយពីគ្នានាំឱ្យកម្លាំងទំនាញខ្សោយ ។

## ? សំណួរនិងលំហាត់

1. តើកម្លាំងអ្វីដែលប្រទាញម៉ូលេគុល NaCl ទៅវិញទៅមក ?
2. ចូរពណ៌នាពីកម្លាំងឌីប៉ូល- ឌីប៉ូល ។
3. តើកម្លាំងអ្វីដែលផ្តល់ឱ្យទឹកមានលក្ខណៈឯកភាពគ្នា ?
4. ចូរពន្យល់ហេតុអ្វីបានជាអុកស៊ីសែន អាសូតនិងភ្លុយអរក្នុងម៉ូលេគុលនៃសារធាតុអាចបង្កើតសម្ព័ន្ធអ៊ីដ្រូសែនបានខ្លាំង ។
5. តើភាពខ្លាំងនៃកម្លាំងរបាយឡុនដុនទាក់ទងទៅនឹងចំនួនអេឡិចត្រុងយ៉ាងដូចម្តេច ?
6. ក. តើណាមួយជាសារធាតុមិនប៉ូលែ : $CF_4$ ឬ $CH_2F_2$ ?
   ខ. តើសារធាតុណាមួយដែលទំនងជាមានចំណុចរំពុះខ្ពស់ជាង ? ចូរពន្យល់ ។
7. $NH_3$ មានចំណុចរំពុះខ្ពស់ជាង $PH_3$ ។ ចូរពន្យល់ ។
8. ហេតុអ្វីបានអាកុង (Ar) ពុះនៅសីតុណ្ហភាពខ្ពស់ជាងណេអុង (Ne) ?
9. ហេតុអ្វីបានជាទឹកកកអណ្តែតលើទឹករាវ ?
10. ហេតុអ្វីបានជា $CBr_4$ ពុះនៅសីតុណ្ហភាពខ្ពស់ជាង $CCl_4$ ?
11. មានកម្លាំងបីយ៉ាង : កម្លាំងអ៊ីយ៉ុង កម្លាំងឌីប៉ូល-ឌីប៉ូលនិងកម្លាំងរបាយឡុនដុន ។ តើកម្លាំងណាមួយដែលខ្លាំងជាងគេបំផុត ។

## ? សំណួរនិងលំហាត់ជំពូក 2

1. ចូរសរសេរសមីការបំបែកជាអ៊ីយ៉ុងនៃសមាសធាតុខាងក្រោមនិងប្រាប់ចំនួនម៉ូលនៃអ៊ីយ៉ុងដែលកើតឡើង

ក. 0.5mol នៃ $Zn(NO_3)_2$

ខ. 2mol នៃ $Na_2CO_3$

គ. 1mol នៃ $AlCl_3$ ។

2. ចូរកំណត់សមាសធាតុខាងក្រោមជាសមាសធាតុរលាយ ឬមិនរលាយក្នុងទឹក :

ក. $Ca_3(PO_4)_2$ ខ. $Mn(OH)_2$ គ. $AgNO_3$

ឃ. $K_2S$ ង. $Hg(NO_3)_2$ ច. $CaCO_3$ ។

3. ចូរសរសេរសមីការអ៊ីយ៉ុងសព្វនិងអ៊ីយ៉ុងសម្រួលសម្រាប់ប្រតិកម្មខាងក្រោម :

ក. $2AgNO_3(aq) + Na_2SO_4(aq) \longrightarrow$

ខ. $BaCl_2(aq) + ZnSO_4(aq) \longrightarrow$

គ. $(NH_4)_2CO_3(aq) + CaCl_2(aq) \longrightarrow$

ឃ. $Na_2S(aq) + ZnCl_2(aq) \longrightarrow$ ។

4. ដូចម្តេចដែលហៅថាអ៊ីយ៉ុងកម្ម ?

5. តើមានភាពខុសគ្នាយ៉ាងដូចម្តេចរវាងមិនអេឡិចត្រូលីតនិងអេឡិចត្រូលីត ? រវាងអេឡិចត្រូលីតខ្សោយនិងអេឡិចត្រូលីតខ្លាំង ? ចូរលើកឧទាហរណ៍មួយៗមកបង្ហាញ ។

6. ចូររកអត្តសញ្ញាណកម្មសារធាតុនីមួយៗខាងក្រោមថាជាអេឡិចត្រូលីតខ្លាំងនិងអេឡិចត្រូលីតខ្សោយ ឬមិនអេឡិចត្រូលីត :

ក. $H_2O$ ខ. KCl គ. $HNO_3$ ឃ. $CH_3COOH$ ង. $C_{12}H_{22}O_{11}$ ។

7. ចូរបង្ហាញពីភាពខុសគ្នារវាងសមាសធាតុអ៊ីយ៉ុងនិងសមាសធាតុកូវ៉ាឡង់ ។

8. កាបូនតេត្រាក្លរួ ($CCl_4$) ជាសមាសធាតុមិនប៉ូលែ ។ តើកម្លាំងអ្វីដែលម៉ូលេគុលនេះប្រទាញគ្នា ?

9. តើមានអ្វីកើតឡើង កាលណាទឹកត្រូវបានដុតកម្តៅពី 25°C ដល់ 155°C ?

10. តើណាមួយមានចំណុចរំពុះខ្ពស់ជាង រវាង $CaCl_2$ និង NaCl ? ចូរពន្យល់ ។

11. ចូរប្រៀបធៀបកម្លាំងឌីប៉ូល-ឌីប៉ូលនិងសម្ព័ន្ធអ៊ីដ្រូសែន ។

12. តាមតារាង 2.2 ទំព័រ 45 ហេតុអ្វីបានជាទឹកមានចំណុចរំពុះខ្ពស់ជាងគេ ? ចូរពន្យល់ ។

ជំពូក 3

# អាស៊ីត~បាស




អាស៊ីតឬបាសមាននៅក្នុងម្ហូបអាហារនិងផលិតផលប្រើនៅក្នុងផ្ទះបាយ ។

មេរៀនទី

# 1 ទ្រឹស្តីអាស៊ីត-បាស

**ចប់មេរៀននេះ សិស្សអាច**

- ❑ ពណ៌នាពីលក្ខណៈរបស់អាស៊ីត-បាស ។
- ❑ រាប់ឈ្មោះរបស់អាស៊ីត 5 ដែលប្រើនៅទីពិសោធន៍និងក្នុងឧស្សាហកម្ម ។
- ❑ កំណត់និយមន័យ អាស៊ីត-បាសតាមអារ៉េញូស ប្រុងស្តែត-ឡូរី និងតាមឡឺវីស ។
- ❑ ពន្យល់ពីលក្ខណៈខ្លាំងនិងខ្សោយរវាងអាស៊ីត-បាស ។

អាស៊ីតនិងបាសជាសមាសធាតុគីមីដែលមានសារៈសំខាន់ក្នុងជីវភាពនិងក្នុងឧស្សាហកម្ម ។ យើងតែងជួបប្រទះអាស៊ីត-បាស នៅក្នុងអាហារ ផ្លែឈើ និងផលិតផលប្រើនៅផ្ទះបាយ ។

## 1. លក្ខណៈអាស៊ីត-បាស

### 1.1. អាស៊ីត

ក. អាស៊ីតគឺជាសមាសធាតុដែលមានលក្ខណៈដូចខាងក្រោម :

- សូលុយស្យុងអាស៊ីតមានរសជូរ ។ សូលុយស្យុងខាប់របស់អាស៊ីតភាគច្រើនកាត់ខ្លាំង វាអាចកាត់លោហៈ ស្បែក សម្លៀកបំពាក់ ។ អាស៊ីតភាគច្រើនពុល ។
- អាស៊ីតអាចប្តូរពណ៌អង្គធាតុចង្អុលពណ៌ ។
- អាស៊ីតខ្លះ មានប្រតិកម្មជាមួយលោហៈសកម្មរំដោះឧស្ម័នអ៊ីដ្រូសែន ។ លោហៈដែលឈរនៅខាងមុខអ៊ីដ្រូសែនក្នុងសេរីសកម្មភាពគីមីអាចមានប្រតិកម្មជាមួយអាស៊ីតឱ្យផលជាអំបិលនិងឧស្ម័នអ៊ីដ្រូសែន ។ ***ឧទាហរណ៍ :*** $Ba(s) + H_2SO_4(aq) \longrightarrow BaSO_4(s) + H_2(g)$
- អាស៊ីតមានប្រតិកម្មជាមួយបាសឱ្យផលជាអំបិលនិងទឹក ។
- អាស៊ីតជាអេឡិចត្រូលីត ដូចនេះសូលុយស្យុងរបស់វាក្នុងទឹកជាភ្នាក់ងារចម្លងចរន្តអគ្គិសនី ។ សូលុយស្យុងអាស៊ីតខ្លះជាអេឡិចត្រូលីតខ្លាំង ហើយខ្លះទៀតជាអេឡិចត្រូលីតខ្សោយ ។

## ១. នាមវលីអាស៊ីត

• អ៊ីដ្រូអាស៊ីត គឺជាអាស៊ីតដែលមានធាតុផ្សំពីរផ្សេងគ្នា គឺអ៊ីដ្រូសែននិងធាតុដែលមានកម្រិតអេឡិចត្រូអវិជ្ជមានខ្លាំង។ អាស៊ីតអសរីរាង្គជាច្រើនជាអ៊ីដ្រូអាស៊ីត។ ***ឧទាហរណ៍ :*** HF , HCl , HBr... ។

តារាងទី 1.1 : ឈ្មោះនិងរូបមន្តរបស់អ៊ីដ្រូអាស៊ីត

| រូបមន្ត | ឈ្មោះអាស៊ីត |
|---|---|
| HF | អាស៊ីតភ្លុយអរីឌ្រិចឬអ៊ីដ្រូភ្លុយអរិច |
| HCl | អាស៊ីតក្លរីឌ្រិចឬអ៊ីដ្រូក្លរិច |
| HBr | អាស៊ីតប្រូមីឌ្រិចឬអ៊ីដ្រូប្រូមិច |
| HI | អាស៊ីតអ៊ីយ៉ូឌីឌ្រិចឬអ៊ីដ្រូអ៊ីយ៉ូឌិច |
| $H_2S$ | អាស៊ីតស៊ុលភីឌ្រិច |

ការហៅឈ្មោះអ៊ីដ្រូអាស៊ីត : គេហៅឈ្មោះខាងដើមរបស់ធាតុទី2 + បច្ច័មបទ“**អ៊ីឌ្រិច**”។

• អុកស៊ីអាស៊ីត គឺជាអាស៊ីតដែលមានធាតុផ្សំ អ៊ីដ្រូសែន អុកស៊ីសែននិងធាតុទីបី ដែលភាគច្រើនជាអលោហៈ។ ***ឧទាហរណ៍ :*** $HNO_3$ , $H_2SO_4$... ។

តារាងទី 1.2 : ឈ្មោះអុកស៊ីអាស៊ីតនិងអាញ៉ុងរបស់វា

| រូបមន្ត | ឈ្មោះអាស៊ីត | អាញ៉ុង | |
|---|---|---|---|
| $HNO_3$ | អាស៊ីតនីទ្រិច | $NO_3^-$ | នីត្រាត |
| $H_2SO_4$ | អាស៊ីតស៊ុលផួរិច | $SO_4^{2-}$ | ស៊ុលផាត |
| $H_3PO_4$ | អាស៊ីតផូស្វរិច | $PO_4^{3-}$ | ផូស្វាត |
| HOCl | អាស៊ីតអ៊ីប៉ូក្លរ៉ឺ | $ClO^-$ | អ៊ីប៉ូក្លរីត |
| $HClO_2$ | អាស៊ីតក្លរ៉ឺ | $ClO_2^-$ | ក្លរីត |
| $H_2CO_3$ | អាស៊ីតកាបូនិច | $CO_3^{2-}$ | កាបូណាត |
| $CH_3COOH$ | អាស៊ីតអាសេទិច | $CH_3COO^-$ | អាសេតាត |

• បើមានអាស៊ីតពីរស្រដៀងគ្នា គេឱ្យបច្ច័មបទ "អ៊ី "ទៅអាស៊ីតណាដែលមានអុកស៊ីសែន (O) តិច និងបច្ច័មបទ "អ៊ិច " ទៅអាស៊ីតដែលមានអុកស៊ីសែនច្រើន ។

***ឧទាហរណ៍ :*** $HNO_2$ អាស៊ីតនីត្រី , $HNO_3$ អាស៊ីតនីទ្រិច ។

## គ. អាស៊ីតបំបែកជាអ៊ីយ៉ុងអ៊ីដ្រូញ៉ូម $H_3O^+$

យើងបានដឹងហើយថា អេឡិចត្រូលីតខ្លះខ្លាំងនិងខ្លះទៀតខ្សោយ អាស្រ័យដោយវាបំបែកសព្វ ឬដោយភាគ(មិនសព្វ) ។ អាស៊ីតជាអេឡិចត្រូលីត គេអាចចែកជាអាស៊ីតខ្លាំង ឬខ្សោយដូចក្នុងតារាងទី 1.3 ។

តារាងទី 1.3 : អាស៊ីតខ្លាំងនិងខ្សោយមួយចំនួន

| អាស៊ីតខ្លាំង | | អាស៊ីតខ្សោយ | |
|---|---|---|---|
| អាស៊ីតក្លរីឌ្រិច | $HCl$ | អាស៊ីតអាសេទិច | $CH_3COOH$ |
| អាស៊ីតប្រូមីឌ្រិច | $HBr$ | អាស៊ីតស្យានីឌ្រិច | $HCN$ |
| អាស៊ីតអ៊ីយ៉ូឌីឌ្រិច | $HI$ | អាស៊ីតភ្លុយអរីឌ្រិច | $HF$ |
| អាស៊ីតនីទ្រិច | $HNO_3$ | អាស៊ីតនីត្រី | $HNO_2$ |
| អាស៊ីតស៊ុលផួរិច | $H_2SO_4$ | អាស៊ីតស៊ុលផួរី | $H_2SO_3$ |
| អាស៊ីតពែក្លរិច | $HClO_4$ | អាស៊ីតអ៊ីប៉ូក្លរី | $HClO$ |

• អាស៊ីតនីទ្រិច $HNO_3$ ជាអាស៊ីតខ្លាំងប្រតិកម្មជាមួយទឹកតាងដោយសមីការ :

$$HNO_3(\ell) + H_2O(\ell) \longrightarrow H_3O^+(aq) + NO_3^-(aq)$$

• អាស៊ីតខ្សោយរលាយក្នុងទឹក មានផ្នែកមួយនៃម៉ូលេគុលវាបានបំបែកជាអ៊ីយ៉ុងក្នុងពេលប្រតិកម្ម ។ អាស៊ីតអ៊ីប៉ូក្លរីជាអាស៊ីតខ្សោយ វាមានប្រតិកម្មជាមួយទឹកតាមសមីការ :

$$HOCl(\ell) + H_2O(\ell) \rightleftharpoons H_3O^+(aq) + ClO^-(aq)$$

សញ្ញាព្រួញទៅមកក្នុងសមីការនេះ បង្ហាញពីលំនឹងសមីការដោយអ៊ីយ៉ុង $ClO^-$ ប្រតិកម្មជាមួយអ៊ីយ៉ុង $H_3O^+$ ឱ្យជាអាស៊ីត $HOCl$ ។ ក្នុងពេលជាមួយគ្នានោះ ម៉ូលេគុល $HOCl$ មានប្រតិកម្មជាមួយទឹកឱ្យជាអ៊ីយ៉ុងវិញ ។

## 1.2. បាស

### ក. បាស

បាស ជាអេឡិចត្រូលីត ។ បាសភាគច្រើនជាអង្គធាតុរឹង ។ បាសគឺជាសមាសធាតុដែលមានលក្ខណៈ :



រូបទី 1.1 បាសប្រើក្នុងផ្ទះ

- សូលុយស្យុងបាសស្អាបទៅរអិលនិងមានរសល្វីង ។ បាសច្រើនមានលក្ខណៈកាត់ខ្លាំងវាអាចកាត់ស្បែកនិងកំណាត់សំពត់ ... ។ បាសជាភ្នាក់ងារសំអាត ព្រោះវាអាចកំចាត់ខ្លាញ់និងប្រេងបាន ។ បាសខ្លះ ដូចជាម៉ាញ៉េស្យូមអ៊ីដ្រុកស៊ីត $Mg(OH)_2$ ស្ទើរតែមិនរលាយក្នុងទឹក ហើយបាសខ្លះទៀតដូចជាប៉ូតាស្យូមអ៊ីដ្រុកស៊ីតរលាយខ្លាំងក្នុងទឹកវាស្រូបចំហាយទឹកក្នុងខ្យល់និងរលាយក្នុងទឹក ។ បាសដែលរលាយខ្លាំងក្នុងទឹកហៅថា " បាសអាល់កាលី "ឬ" អាល់កាលី " ។ ភាគច្រើននៃបាសប្រភេទនេះ ជាបាសរបស់លោហៈដែលឋិតនៅក្នុងក្រុមទី I នៃតារាងខួបធាតុគីមី ។

- បាសអាចប្តូរពណ៌អង្គធាតុចង្អុលពណ៌ ។
- បាសមានប្រតិកម្មជាមួយអាស៊ីត ឱ្យផលជាអំបិលនិងទឹក ។

***ឧទាហរណ៍ :***

$$HCl(\ell) + NaOH(s) \longrightarrow NaCl(aq) + H_2O(\ell)$$

អាស៊ីត បាស អំបិល ទឹក



រូបទី 1.2 ក្រដាស pH ពណ៌ក្រហមប្រែជាពណ៌ខៀវក្នុងសូលុយស្យុងបាស

ខ. បាសបំបែកជាអ៊ីយ៉ុងអ៊ីដ្រុកស៊ីត ($OH^-$)

គេអាចចែកបាស ជាបាសខ្លាំង ឬខ្សោយដូចក្នុងតារាងទី 1.4 ។

តារាងទី 1.4 : បាសខ្លាំងនិងខ្សោយមួយចំនួន

| បាសខ្លាំង | | បាសខ្សោយ | |
|---|---|---|---|
| សូដ្យូមអ៊ីដ្រុកស៊ីត | $NaOH$ | អាម៉ូញ៉ាក់ | $NH_3$ |
| ប៉ូតាស្យូមអ៊ីដ្រុកស៊ីត | $KOH$ | សូដ្យូមកាបូណាត | $Na_2CO_3$ |
| កាល់ស្យូមអ៊ីដ្រុកស៊ីត | $Ca(OH)_2$ | ប៉ូតាស្យូមកាបូណាត | $K_2CO_3$ |
| បារ្យូមអ៊ីដ្រុកស៊ីត | $Ba(OH)_2$ | អានីលីន | $C_6H_5NH_2$ |
| សូដ្យូមផូស្វាត | $Na_3PO_4$ | ទ្រីមេទីលអាមីន | $(CH_3)_3N$ |

- សូដ្យូមអ៊ីដ្រុកស៊ីតជាបាសខ្លាំងពេលរលាយក្នុងទឹក តាងដោយសមីការ :

$$NaOH(s) \xrightarrow{H_2O} Na^+(aq) + OH^-(aq)$$

- អាម៉ូញ៉ាក់ $NH_3$ ជាបាសខ្សោយ ។ វាជាឧស្ម័ននៅសីតុណ្ហភាពបន្ទប់ តែវារលាយខ្លាំងក្នុងទឹក បង្កើតជា អាម៉ូញ៉ាក់រាវ ។ ម៉ូលេគុលអាម៉ូញ៉ាក់ខ្លះក្នុងសូលុយស្យុងមានប្រតិកម្មជាមួយទឹករហូតដល់ប្រព័ន្ធមានលំនឹង ។ សមីការតាងប្រតិកម្ម :

$$NH_3(aq) + H_2O(l) \rightleftharpoons NH_4^+(aq) + OH^-(aq)$$

- ពេលរលាយក្នុងទឹក បាសទាំងពីរប្រភេទ (បាសខ្លាំង និងខ្សោយ)បង្កើតបានជាអ៊ីយ៉ុងអ៊ីដ្រុកស៊ីត ($OH^-$) ដូចគ្នា ។

## 2. អាស៊ីតប្រើក្នុងឧស្សាហកម្ម

អាស៊ីត ជាសារធាតុគីមីសំខាន់ណាស់នៅទីពិសោធន៍និងក្នុងឧស្សាហកម្មដូចជា : អាស៊ីតស៊ុលផួរិច ($H_2SO_4$) អាស៊ីតនីទ្រិច ($HNO_3$) អាស៊ីតក្លរីឌ្រិច ($HCl$) អាស៊ីតផូស្វរិច ($H_3PO_4$) និងអាស៊ីតអាសេទិច ($CH_3COOH$) ។

## 2.1. អាស៊ីតស៊ុលផួរិច ($H_2SO_4$)

អាស៊ីតស៊ុលផួរិច ($H_2SO_4$) ជាផលិតផលគីមី មានសារៈសំខាន់ណាស់ និងប្រើច្រើនបំផុតនៅក្នុងលោក ។ គេប្រើវាជាច្រើនលានតោនក្នុងមួយឆ្នាំៗ ។

អាស៊ីតស៊ុលផួរិចសុទ្ធមានសភាពខាប់ដូចប្រេង គ្មានពណ៌ និងគ្មានក្លិន ។ អាស៊ីតនេះមានប្រើនៅក្នុងឧស្សាហកម្មផលិត ៖ លោហៈ ប្រេង ក្រដាស ល័ក្ខ ថ្នាំពណ៌ សាប៊ូ និងវត្ថុធាតុគីមីជាច្រើនទៀត ។ វាជាភ្នាក់ងារដេអ៊ីដ្រាតកម្ម(ដកទឹក) ។ ស្ករ និងសមាសធាតុសរីរាង្គដទៃទៀតក៏ធ្វើដេអ៊ីដ្រាតកម្មដោយអាស៊ីតនេះដែរ ។




រូបទី 1.3 អាស៊ីតប្រើក្នុងជីវភាព

## 2.2. អាស៊ីតនីទ្រិច ($HNO_3$)

អាស៊ីតនីទ្រិច ($HNO_3$) សុទ្ធជាអង្គធាតុរាវងាយហើរ ។ កាលណាគេដាក់វាហាលខ្យល់ អាស៊ីតនេះហុយជាផ្សែង ។ ការណ៍នេះបណ្ដាលមកពីការប៉ះគ្នារវាងចំហាយអាស៊ីតនិងចំហាយទឹកនៃខ្យល់ បង្កើតបានជាតំណក់ល្អិតៗមានសភាពដូចអ័ព្ទ ។ គេប្រើវាយ៉ាងច្រើននៅក្នុងឧស្សាហកម្ម ។ បើគេរំលាយវានៅក្នុងទឹក គេបានអាស៊ីតដែលមានស្ថេរភាពបំផុត ។ អាស៊ីតនេះមានក្លិនឈ្លក់ កាត់ស្បែក ហើយអាចជាមូលហេតុនៃចំហេះ ។ គេប្រើវាសម្រាប់ធ្វើប្លាស្ទិច ល័ក្ខ និងក្នុងផលិតកម្មឱសថ ។ អាស៊ីតនីទ្រិចជាសូលុយស្យុងគ្មានពណ៌ វាក្លាយជាពណ៌លឿង ព្រោះវាបំបែកទៅជាឧស្ម័នអាសូតឌីអុកស៊ីតពណ៌ត្នោត ។

## 2.3. អាស៊ីតផូស្វរិច ($H_3PO_4$)

ផូស្វរ អាសូត និងប៉ូតាស្យូម ជាធាតុសំខាន់សម្រាប់រុក្ខជាតិនិងសត្វ ។ ផលិតផលអាស៊ីតផូស្វរិចដែលផលិតរាល់ឆ្នាំបានប្រើដោយផ្ទាល់ក្នុងឧស្សាហកម្មផលិតជីនិងចំណីសត្វ ។ អាស៊ីតផូស្វរិចរាវមានរសជូរនិងមិនពុល ។ គេប្រើវាក្នុងឧស្សាហកម្មផលិតសាប៊ូនិងសេរ៉ាមិច ។ អាស៊ីតនេះពុំមានជាភាពទោល (តែឯង)នៅក្នុងធម្មជាតិទេ គេច្រើនប្រទះវាក្នុងអណ្ដូងរ៉ែ ក្នុងភាពជាអំបិលកាល់ស្យូមផូស្វាត ។

### 2.4. អាស៊ីតក្លរីឌ្រិច (HCl)

ក្រពះរបស់យើងផលិតអាស៊ីតក្លរីឌ្រិចដើម្បីជួយរំលាយអាហារ ។អាស៊ីតក្លរីឌ្រិចមានសារៈសំខាន់ណាស់ក្នុងឧស្សាហកម្ម ។ គេត្រាំលោហៈក្នុងសូលុយស្យុងអាស៊ីតនេះ ដើម្បីទាញយកធាតុមិនសុទ្ធពីផ្ទៃខាងក្រៅ ។ នៅក្នុងឧស្សាហកម្មគេប្រើវាជាភ្នាក់ងារសំអាតក្នុងលំនាំផលិតអាហារ ក្នុងការទាញយកម៉ាញេស្យូមពីទឹកសមុទ្រ និងក្នុងផលិតកម្មធាតុគីមីផ្សេងៗទៀត . . . ។

### 2.5. អាស៊ីតអាសេទិច ($CH_3COOH$)

អាស៊ីតអាសេទិចសុទ្ធជាសូលុយស្យុងថ្លា គ្មានពណ៌ មានក្លិនឈ្ងួល ។ វាកកនៅសីតុណ្ហភាព 17°C ។ ល្បើងនៃរុក្ខជាតិទាំងឡាយបង្កើតជាទឹកខ្មេះដែលមានផ្ទុកអាស៊ីតអាសេទិច ។ នៅក្នុងទឹកខ្មេះមានផ្ទុកអាស៊ីតអាសេទិចពី 4 ទៅ 8 % ។ គេប្រើអាស៊ីតនេះនៅក្នុងឧស្សាហកម្មសំយោគគីមី ការផលិតប្លាស្ទិច ។ វាជាវត្ថុធាតុដើមក្នុងការផលិតអាហារបន្ថែមដូចជា : លីស៊ីន អាស៊ីតអាមីណូ . . . ។

## 3. អាស៊ីត-បាសតាមអារ៉េញ៉ូស

លោកអារ៉េញ៉ូស (Arrhenius) ជាគីមីវិទូជនជាតិស៊ុយអែត (1859-1927) យល់ថាសូលុយស្យុងអាស៊ីតនិងបាសអាចចម្លងចរន្តអគ្គិសនី ។ ដូច្នេះតាមទ្រឹស្តីរបស់គាត់ អាស៊ីតនិងបាសបង្កើតជាអ៊ីយ៉ុងក្នុងសូលុយស្យុង ។ **" អាស៊ីតជាសមាសធាតុគីមីដែលបង្កើតអ៊ីយ៉ុងអ៊ីដ្រូសែនក្នុងសូលុយស្យុងទឹក "** ។

***ឧទាហរណ៍ :*** $HCl\ (g) \xrightarrow{\text{ទឹក}} H^+\ (aq) + Cl^-\ (aq)$

**" បាស ជាសមាសធាតុដែលបង្កើតអ៊ីយ៉ុងអ៊ីដ្រុកស៊ីត ($OH^-$) ក្នុងសូលុយស្យុងទឹក "** ។

***ឧទាហរណ៍ :*** $NaOH\ (s) \xrightarrow{\text{ទឹក}} Na^+\ (aq) + OH^-\ (aq)$

### 3.1. សូលុយស្យុងអាស៊ីត

សូលុយស្យុងអាស៊ីតទាំងអស់ជាអេឡិចត្រូលីត ។ អាស៊ីតជាម៉ូលេគុលប៉ុន្តែ វាអាចទាញយកអ៊ីយ៉ុងអ៊ីដ្រូសែន ($H^+$) មួយឬច្រើនពីម៉ូលេគុលទឹក ។ ក្នុងសូលុយស្យុងទឹក អ៊ីយ៉ុង $H^+$ (ប្រូតុង)តែងចងសម្ព័ន្ធជាមួយម៉ូលេគុលទឹកដោយរងអ៊ីដ្រាតកម្ម ។ អ៊ីដ្រាតកម្មអ៊ីយ៉ុងអ៊ីដ្រូសែនតាងដោយសមីការ :

$$H^+\ (aq) + H_2O(l) \longrightarrow H_3O^+\ (aq)$$

អ៊ីយ៉ុងកម្មនៃអាស៊ីត $HNO_3$ តាងដោយសមីការ :

$$HNO_3\ (\ell) + H_2O\ (l) \longrightarrow H_3O^+\ (aq) + NO_3^-\ (aq)$$

អ៊ីយ៉ុងកម្មនៃម៉ូលេគុលអ៊ីដ្រូសែនក្លរក្នុងទឹកតាងដោយសមីការ ៖

$$HCl\ (g) + H_2O\ (l) \longrightarrow H_3O^+\ (aq) + Cl^-(aq)$$

## ៣.២. សូលុយស្យុងបាស

បាសភាគច្រើនជាសមាសធាតុអ៊ីយ៉ុង ដែលមានកាចុងលោហៈនិងអាញ៉ុងអ៊ីដ្រុកស៊ីត ។ កាលណាបាសរលាយសព្វក្នុងទឹក ឱ្យជាអ៊ីយ៉ុង ( $OH^-$ ) សូលុយស្យុងនោះជាបាសខ្លាំង ។ ***ឧទាហរណ៍ ៖*** សូដ្យូមអ៊ីដ្រុកស៊ីត (NaOH) ជាបាសដែលប្រើនៅទីពិសោធន៍ វារលាយក្នុងទឹកហើយបំបែកដូចសមីការ ៖

$$NaOH\ (s) \xrightarrow{H_2O} Na^+\ (aq) + OH^-(aq)$$

លោហៈដែលចិតនៅក្នុងក្រុមទី I នៃតាងរាងខួប ជាពួកលោហៈអាល់កាឡាំងមាន Li , Na , K , Rb និង Cs ដែលអាចបង្កើតបានជាសូលុយស្យុងបាស ។ បាសទាំងអស់មិនមែនសុទ្ធតែជាសមាសធាតុអ៊ីយ៉ុងទេ ។ បាសដែលតែងប្រើនៅក្នុងផ្ទះសម្រាប់សំអាត គឺអាម៉ូញ៉ាក់ ($NH_3$) ។ ប្រតិកម្ម $NH_3$ ជាមួយទឹកដូចជាអ៊ីយ៉ុងអ៊ីដ្រុកស៊ីតតាងដោយសមីការ ៖

$$NH_3\ (aq) + H_2O\ (l) \rightleftharpoons NH_4^+\ (aq) + OH^-\ (aq)$$

## ៣.៣. កម្លាំងអាស៊ីតនិងបាស

### ក. កម្លាំងអាស៊ីត

អាស៊ីតខ្លាំង គឺជាអេឡិចត្រូលីតខ្លាំងដែលអាចបំបែកជាអ៊ីយ៉ុងទាំងស្រុងនៅក្នុងទឹក ។ អាស៊ីតខ្លាំងភាគច្រើនជាអាស៊ីតអសរីរាង្គដូចជា ៖ អាស៊ីតក្លរីឌ្រិច HCl អាស៊ីតនីទ្រិច $HNO_3$ អាស៊ីតពែក្លរិច $HClO_4$ និងអាស៊ីតស៊ុលផួរិច $H_2SO_4$ ។

$$HCl\ (aq) + H_2O\ (l) \longrightarrow H_3O^+\ (aq) + Cl^-\ (aq)$$

$$HNO_3\ (aq) + H_2O\ (l) \longrightarrow H_3O^+\ (aq) + NO_3^-\ (aq)$$

$$HClO_4\ (aq) + H_2O\ (l) \longrightarrow H_3O^+\ (aq) + ClO_4^-(aq)$$

$$H_2SO_4\ (aq) + H_2O\ (l) \longrightarrow H_3O^+\ (aq) + HSO_4^-\ (aq)$$

***ចំណាំ ៖*** អាស៊ីតស៊ុលផួរិច គឺជាអាស៊ីតឌីប្រូទិច(មានប្រូតុងពីរ) សមីការនេះយើងបង្ហាញតែអ៊ីយ៉ុងកម្មដំហានទី I ប៉ុណ្ណោះ ។ នៅភាពលំនឹងម៉ូលេគុលនៃសូលុយស្យុងអាស៊ីតខ្លាំងបានបំបែកជាអ៊ីយ៉ុងទាំងស្រុង ។

អាស៊ីតខ្លាំងនីមួយៗបំបែកជាអ៊ីយ៉ុងទាំងស្រុងក្នុងទឹកឱ្យជាអ៊ីយ៉ុងអ៊ីដ្រូសែនមួយក្នុងមួយម៉ូលេគុល ចំនួនអាតូមអ៊ីដ្រូសែនក្នុងរូបមន្តម៉ូលេគុលមិនបង្ហាញពីកម្លាំងអាស៊ីតឡើយ ។ ***ឧទាហរណ៍*** អាស៊ីតផូស្វរិច $H_3PO_4$ មានអាតូមអ៊ីដ្រូសែនបីក្នុងរូបមន្តម៉ូលេគុលវា តែជាអាស៊ីតខ្សោយ ។

អាស៊ីតសរីរាង្គដែលមានបង្គុំកាបុកស៊ីល (-COOH) ជាទូទៅជាអាស៊ីតខ្សោយ ។ ***ឧទាហរណ៍*** : អាស៊ីតអាសេទិច ($CH_3COOH$) បំបែកជាអ៊ីយ៉ុងអ៊ីដ្រូញ៉ូម ($H_3O^+$ ) និងអ៊ីយ៉ុងអាសេតាត ($CH_3COO^-$ ) ។ សមីការតាងប្រតិកម្ម :

$$CH_3COOH\ (aq) + H_2O(l) \rightleftharpoons H_3O^+\ (aq) + CH_3COO^-\ (aq)$$

ក្នុងម៉ូលេគុលអាស៊ីតអាសេទិចមានអាតូមអ៊ីដ្រូសែនបួន តែមានអាតូមអ៊ីដ្រូសែនតែមួយគត់ដែលបំបែកជាអ៊ីយ៉ុង ។ អាតូមអ៊ីដ្រូសែនក្នុងបង្គុំកាបុកស៊ីលក្នុងអាស៊ីតអាសេទិច បង្ហាញពីលក្ខណៈអាស៊ីតដែលបង្កើតជាអ៊ីយ៉ុងអ៊ីដ្រូញ៉ូមក្នុងសូលុយស្យុង ។




*រូបទី 3.4 ទម្រង់ម៉ូលេគុលអាស៊ីតអាសេទិច*

អាស៊ីតភាគច្រើនជា អាស៊ីតខ្សោយ ដែលបំបែកជាអ៊ីយ៉ុងក្នុងទឹកដោយភាគតែប៉ុណ្ណោះ ។

***ឧទាហរណ៍*** : អាស៊ីតស្យានីឌ្រិច HCN

$$HCN\ (aq) + H_2O(\ell) \rightleftharpoons H_3O^+\ (aq) + CN^-\ (aq)$$

តារាងទី 1.5 : សូលុយស្យុងអាស៊ីតមួយចំនួន

| អាស៊ីតខ្លាំង | អាស៊ីតខ្សោយ |
|---|---|
| $HI + H_2O \longrightarrow H_3O^+ + I^-$ | $HF + H_2O \rightleftharpoons H_3O^+ + F^-$ |
| $HClO_4 + H_2O \longrightarrow H_3O^+ + ClO_4^-$ | $H_3PO_4 + H_2O \rightleftharpoons H_3O^+ + H_2PO_4^-$ |
| $HBr + H_2O \longrightarrow H_3O^+ + Br^-$ | $CH_3COOH + H_2O \rightleftharpoons H_3O^+ + CH_3COO^-$ |
| $HCl + H_2O \longrightarrow H_3O^+ + Cl^-$ | $H_2CO_3 + H_2O \rightleftharpoons H_3O^+ + HCO_3^-$ |
| $H_2SO_4 + H_2O \longrightarrow H_3O^+ + HSO_4^-$ | $H_2S + H_2O \rightleftharpoons H_3O^+ + HS^-$ |

## ខ. កម្លាំងបាស

ដូចគ្នានឹងអាស៊ីតខ្លាំងដែរ បាសខ្លាំងគឺជាអេឡិចត្រូលីតខ្លាំងដែលអាចបំបែកជាអ៊ីយ៉ុងទាំងស្រុងនៅក្នុងទឹក ។ អ៊ីដ្រុកស៊ីតរបស់លោហៈអាល់កាឡាំងនិងលោហៈអាល់កាឡាំងដីមួយចំនួន គឺជាបាសខ្លាំង

(គ្រប់បាសរបស់លោហៈអាល់កាឡាំងទាំងអស់ជាបាសរលាយ) ។ បាសរបស់លោហៈអាល់កាឡាំងដីដែលមិនរលាយគឺ $Be(OH)_2$ និង $Mg(OH)_2$ ។ $Ca(OH)_2$ និង $Sr(OH)_2$ ជាបាសរលាយតិច ហើយ $Ba(OH)_2$ ជាបាសរលាយក្នុងទឹក ។ ***ឧទាហរណ៍ :***

$$NaOH\ (s) \xrightarrow{H_2O} Na^+\ (aq) + OH^-\ (aq)$$

$$KOH\ (s) \xrightarrow{H_2O} K^+\ (aq) + OH^-\ (aq)$$

$$Ba(OH)_2(s) \xrightarrow{H_2O} Ba^{2+}\ (aq) + 2OH^-\ (aq)$$

បាសខ្សោយ ក៏ដូចអាស៊ីតខ្សោយដែរ គឺជាអេឡិចត្រូលីតខ្សោយ ។ អាម៉ូញ៉ាក់ជាបាសខ្សោយព្រោះការបំបែករបស់វានៅក្នុងទឹកមានកំណត់ ។

$$NH_3\ (aq) + H_2O\ (\ell) \rightleftharpoons NH_4^+\ (aq) + OH^-\ (aq)$$

តារាងទី 1.6 : សូលុយស្យុងបាសមួយចំនួន

| បាសខ្លាំង | បាសខ្សោយ |
|---|---|
| $Ca(OH)_2 \longrightarrow Ca^{2+} + 2OH^-$ | $NH_3 + H_2O \rightleftharpoons NH_4^+ + OH^-$ |
| $Sr(OH)_2 \longrightarrow Sr^{2+} + 2OH^-$ | $C_6H_5NH_2 + H_2O \rightleftharpoons C_6H_5NH_3 + OH^-$ |
| $Ba(OH)_2 \longrightarrow Ba^{2+} + 2OH^-$ | |
| $NaOH \longrightarrow Na^+ + OH^-$ | |
| $KOH \longrightarrow K^+ + OH^-$ | |
| $RbOH \longrightarrow Rb^+ + OH^-$ | |
| $CsOH \longrightarrow Cs^+ + OH^-$ | |

## 4. អាស៊ីត-បាសតាមប្រុងស្តែត-ឡូរី

នៅឆ្នាំ1923 គីមីវិទូជនជាតិដាណឺម៉ាក់ឈ្មោះ ជេម ប្រុងស្តែត (J.N Brönsted) និងគីមីវិទូជនជាតិអង់គ្លេសឈ្មោះ ថូម៉ាសឡូរី (T.M Lowry) បានអភិវឌ្ឍដាច់ដោយឡែកពីគ្នាលើនិយមន័យអាស៊ីត-បាសរបស់លោកអារេញ៉ូស ។ ទ្រឹស្តីរបស់គាត់ទាំងពីរនេះកំណត់ថា : " ប្រុងស្តែត-ឡូរីអាស៊ីតគឺជាប្រភេទគីមី (អាតូម អ៊ីយ៉ុង ឬម៉ូលេគុល)ទាំងឡាយណាដែលបោះបង់ប្រូតុង " ។ ប្រូតុង គឺជា

អាតូមអ៊ីដ្រូសែនដែលបាត់អេឡិចត្រុង វាគឺជាអ៊ីយ៉ុងអ៊ីដ្រូសែនដែលតាងដោយ $H^+$ ។ អ៊ីដ្រូសែនក្លូជាប្រុងស្តែត-ឡូរីអាស៊ីត ពេលវាមានប្រតិកម្មជាមួយអាម៉ូញ៉ាក់ ។ HCl ឱ្យប្រូតុងទៅ $NH_3$ ច្រើនដូចក្នុងលំនាំប្រតិកម្ម HCl ជាមួយទឹក ។

$$HCl\ (g) + NH_3\ (aq) \longrightarrow NH_4^+\ (aq) + Cl^-\ (aq)$$

ប្រូតុងដែលផ្ទេរពីម៉ូលេគុល HCl ទៅម៉ូលេគុល $NH_3$ គឺបង្កើតបានជាអ៊ីយ៉ុងអាម៉ូញ៉ូម $NH_4^+$ ។ សមីការខាងក្រោមនេះបង្ហាញពីលក្ខណៈដូចគ្នានៃប្រតិកម្មនេះទៅនិងប្រតិកម្មនៃ HCl ជាមួយទឹក :



ក្នុងប្រតិកម្មទាំងពីរនេះ HCl ជាប្រុងស្តែត-ឡូរីអាស៊ីត ។ ទឹកក៏អាចមានអំពើជាប្រុងស្តែត-ឡូរីអាស៊ីតដែរ ។ ***ឧទាហរណ៍*** ក្នុងប្រតិកម្មខាងក្រោមនេះ ម៉ូលេគុលទឹកឱ្យប្រូតុងទៅម៉ូលេគុលអាម៉ូញ៉ាក់ ។

$$H_2O\ (\ell) + NH_3\ (aq) \rightleftharpoons NH_4^+\ (aq) + OH^-\ (aq)$$



**"ប្រុងស្តែត-ឡូរីបាស គឺជាប្រភេទគីមី (អាតូម អ៊ីយ៉ុង ឬម៉ូលេគុល) ទាំងឡាយណាដែលទទួលយកប្រូតុង "** ។ ***ឧទាហរណ៍ :*** សមីការប្រតិកម្មអាម៉ូញ៉ាក់រលាយនៅក្នុងទឹក :

$$NH_3\ (aq) + H_2O\ (l) \rightleftharpoons NH_4^+\ (aq) + OH^-\ (aq)$$

អាម៉ូញ៉ាក់ ជាប្រុងស្តែត-ឡូរីបាស ហើយក៏ជាអារ៉េញ៉ូសបាសដែរ ។ ដូចនេះ អារ៉េញ៉ូសបាសទាំងអស់ក៏ជាប្រុងស្តែត-ឡូរីបាសដែរ ។



***រូបទី 1.4 : ប្រតិកម្ម HCl និង $NH_3$***

ក្នុងប្រតិកម្មអាស៊ីត-បាសប្រុងស្តែត-ឡូរី ប្រូតុងបានផ្ទេរពីអង្គធាតុប្រតិករ (អាស៊ីត)ទៅអង្គធាតុមួយទៀត (បាស) រូបទី 1.4 នេះ បង្ហាញពីប្រតិកម្មរវាងប្រុងស្តែត-ឡូរីអាស៊ីត HCl និងប្រុងស្តែត-ឡូរីបាស $NH_3$ ។

### 4.1. ម៉ូណូប្រូទិចនិងប៉ូលីប្រូទិចអាស៊ីត

អាស៊ីតប្រុងស្ទែត-ឡូរី ចែកជាពីរប្រភេទ គឺម៉ូណូប្រូទិចអាស៊ីតនិងប៉ូលីប្រូទិចអាស៊ីត ។

- អាស៊ីតដែលឱ្យប្រូតុងតែមួយក្នុងមួយម៉ូលេគុលហៅថា **" ម៉ូណូប្រូទិចអាស៊ីត "** ។ ***ឧទាហរណ៍*** អាស៊ីតក្លរីឌ្រិច HCl អាស៊ីតនីទ្រិច $HNO_3$ អាស៊ីតពែក្លរិច $HClO_4$... ។

$$HCl\ (aq) + H_2O\ (l) \longrightarrow H_3O^+\ (aq) + Cl^-\ (aq)$$

- អាស៊ីតដែលឱ្យប្រូតុងលើសពីមួយក្នុងមួយម៉ូលេគុលហៅថា **" ប៉ូលីប្រូទិចអាស៊ីត "** ។ ប៉ូលីប្រូទិចអាស៊ីតមានពីរប្រភេទ គឺឌីប្រូទិចអាស៊ីតនិងទ្រីប្រូទិចអាស៊ីត ។ ឌីប្រូទិចអាចឱ្យប្រូតុងពីរក្នុងមួយម៉ូលេគុល ។ ***ឧទាហរណ៍ :***

$$H_2SO_4\ (aq) + H_2O \longrightarrow H_3O^+\ (aq) + HSO_4^-\ (aq)$$

$$HSO_4^-\ (aq) + H_2O\ (l) \longrightarrow H_3O^+\ (aq) + SO_4^{2-}\ (aq)$$

ទ្រីប្រូទិចអាស៊ីតអាចឱ្យប្រូតុងបីក្នុងមួយម៉ូលេគុល ។

សមីការតាងប្រតិកម្ម :

$$H_3PO_4\ (aq) + H_2O\ (l) \rightleftharpoons H_3O^+\ (aq) + H_2PO_4^-\ (aq)$$

$$H_2PO_4^-\ (aq) + H_2O\ (l) \rightleftharpoons H_3O^+\ (aq) + HPO_4^{2-}\ (aq)$$

$$HPO_4^{2-}\ (aq) + H_2O\ (l) \rightleftharpoons H_3O^+\ (aq) + PO_4^{3-}\ (aq)$$

## 5. អាស៊ីត-បាសតាមឡឺវីស

តាមនិយមន័យរបស់អារេញ៉ូសនិងប្រុងស្ទែត-ឡូរី បានបកស្រាយយ៉ាងច្រើនពីអាស៊ីតនិងបាស ។ នៅឆ្នាំ1923 គីមីវិទូជនជាតិអាមេរិកាំងឈ្មោះ ឡឺវីស (G.N.Lewis) បានឱ្យនិយមន័យមួយបែបផ្សេងទៀត ។ " **អាស៊ីតឡឺវីស គឺជាអាតូម អ៊ីយ៉ុង ឬម៉ូលេគុលដែលទទួលយកគូអេឡិចត្រុងដើម្បីបង្កើតសម្ព័ន្ធកូវ៉ាឡង់** " ។

***ឧទាហរណ៍ :***

$$H^+\ (aq) + :NH_3\ (aq) \longrightarrow [H-NH_3]^+\ (aq)\ \text{ឬ}\ [NH_4]^+\ (aq)$$

" **បាសឡឺវីស គឺជាអាតូម អ៊ីយ៉ុង ឬម៉ូលេគុលដែលបោះបង់គូអេឡិចត្រុងដើម្បីបង្កើតសម្ព័ន្ធកូវ៉ាឡង់** " ។

***ឧទាហរណ៍ :*** $BF_3\ (aq) + :\ddot{\underset{..}{F}}:^-\ (aq) \longrightarrow BF_4^-\ (aq)$

ដូច្នេះ ប្រតិកម្មអាស៊ីត-បាសឡឺវីស គឺជាប្រតិកម្មដែលបង្កើតសម្ព័ន្ធកូវ៉ាឡង់មួយ ឬច្រើនរវាងគូអេឡិចត្រុងដែលបោះបង់និងគូអេឡិចត្រុងដែលទទួលយក ។ ទោះបីជានិយមន័យអាស៊ីតបាសនេះខុសប្លែកពីនិយមន័យមុនក៏មានសមាសធាតុជាច្រើនអាចចាត់ទុកជាអាស៊ីត-បាសតាមលំនាំនេះដែរ ។

***ឧទាហរណ៍ :*** $NH_3$ ជាបាសអារេញ៉ូស ព្រោះអ៊ីយ៉ុង $OH^-$ បានកកើតនៅពេលដែលអាម៉ូញ៉ាក់ថិតក្នុងសូលុយស្យុង ។ វាជាប្រុងស្តែត-ឡូរីបាស ព្រោះវាទទួលប្រូតុងក្នុងប្រតិកម្មអាស៊ីត-បាស និងជាបាសឡឺវីស នៅគ្រប់ប្រតិកម្មវាឱ្យគូឌ្វេតាទោលដើម្បីបង្កើតសម្ព័ន្ធកូវ៉ាឡង់ ។

តារាងទី 1.7 : និយមន័យអាស៊ុ-បាស

| ប្រភេទ | អាស៊ីត | បាស |
|---|---|---|
| អារេញ៉ូស | បង្កើតអ៊ីយ៉ុង $H^+$ ឬ $H_3O^+$ | បង្កើតអ៊ីយ៉ុង $OH^-$ |
| ប្រុងស្តែត-ឡូរី | ឱ្យប្រូតុង ( $H^+$ ) | ទទួលប្រូតុង ( $H^+$ ) |
| ឡឺវីស | ទទួលគូអេឡិចត្រុង | ឱ្យគូអេឡិចត្រុង |

## មេរៀនសង្ខេប

- អាស៊ីតនិងបាស ជាសមាសធាតុគីមី ដែលមាននៅក្នុងអាហារ ផ្លែឈើ និងក្នុងផលិតផលផ្ទះបាយ ។
- អាស៊ីតដែលប្រើច្រើននៅក្នុងទីពិសោធន៍និងក្នុងឧស្សាហកម្មមាន : $H_2SO_4$ , $HNO_3$ , $HCl$ , $H_3PO_4$ និង $CH_3COOH$ ។
- និយមន័យអាស៊ីត- បាស :

  **-តាមអារេញ៉ូស** : អាស៊ីត ជាសមាសធាតុគីមីដែលបង្កើត $H^+$ ក្នុងសូលុយស្យុង ។
  បាសជាសមាសធាតុដែលបង្កើតអ៊ីយ៉ុង $OH^-$ ក្នុងសូលុយស្យុង ។

  **-តាមប្រុងស្តែត-ឡូរី**: អាស៊ីត ជាប្រភេទគីមីដែលបោះបង់ប្រូតុង ។
  បាសជាប្រភេទគីមីដែលទទួលយកប្រូតុង ។

  **-តាមឡឺវីស** : អាស៊ីត ជាប្រភេទគីមី (អាតូម អ៊ីយ៉ុង ឬម៉ូលេគុល) ដែលទទួលយកគូអេឡិចត្រុងដើម្បីបង្កើតសម្ព័ន្ធកូវ៉ាឡង់ ។
  បាសជាប្រភេទគីមី (អាតូម អ៊ីយ៉ុង ឬម៉ូលេគុល) ដែលបោះបង់គូអេឡិចត្រុងដើម្បីបង្កើតសម្ព័ន្ធកូវ៉ាឡង់ ។

## សំណួរនិងលំហាត់

1. ចូរប្រៀបធៀបពីលក្ខណៈរបស់អាស៊ីតទៅនឹងលក្ខណៈរបស់បាស ។
2. ឱ្យនិយមន័យបាសតាមអារ៉េញ៉ូសនិងតាមប្រុងស្ទែត-ឡូរី ។
3. ឱ្យនិយមន័យអាស៊ីតតាមអារ៉េញ៉ូស តាមប្រុងស្ទែត-ឡូរី និងតាមឡឺវីស ។
4. ចូរញែកសំគាល់រវាងម៉ូណូប្រូទិចអាស៊ីតនិងប៉ូលីប្រូទិចអាស៊ីត ។
5. ឱ្យឧទាហរណ៍ ម៉ូណូប្រូទិចអាស៊ីត ឌីប្រូទិចអាស៊ីត និងទ្រីប្រូទិចអាស៊ីតមួយប្រភេទៗឱ្យបាន2 ។
6. ចូរចង្អុលបង្ហាញសារធាតុនីមួយៗខាងក្រោមនេះ ណាខ្លះជាអាស៊ីត ជាបាស និងមិនមែន ។

   ក. $HCl$ ខ. $NaCl$

   គ. $Ca(OH)_2$ ឃ. $NH_4Cl$

   ង. $CH_4$ ច. $H_2CO_3$

   ឆ. $CaCO_3$ ជ. $NaOH$ ។

7. ចូរជ្រើសរើសអាស៊ីតខាងក្រោមនេះដោយដាក់តាមប្រភេទ ម៉ូណូប្រូទិច ឌីប្រូទិច និងទ្រីប្រូទិច ។

   ក. $HCl$ ខ. $HClO_4$

   គ. $H_2SO_3$ ឃ. $H_2SO_4$

   ង. $CH_3COOH$ ច. $HNO_3$

   ឆ. $H_3PO_2$ ជ. $H_3PO_4$ ។

8. ចូរបំពេញនិងថ្លឹងសមីការប្រតិកម្មអាស៊ីត បាសខាងក្រោម :

   ក. $H_2CO_3 + Sr(OH)_2 \longrightarrow$

   ខ. $HBr + Ba(OH)_2 \longrightarrow$

   គ. $NaBr + H_2SO_4 \longrightarrow$

# 2 ប្រតិកម្មអាស៊ីត-បាស

ចប់មេរៀននេះ សិស្សអាច

- ❑ ពណ៌នាពីអាស៊ីតឆ្លាស់និងបាសឆ្លាស់ ។
- ❑ ពណ៌នាពីសមាសធាតុអំផូទែ ។
- ❑ ពន្យល់ពីលំនាំប្រតិកម្មបន្សាប ។
- ❑ ពណ៌នាពីឥទ្ធិពលនៃភ្លៀងអាស៊ីត ។

## 1. អាស៊ីត - បាសឆ្លាស់

និយមន័យអាស៊ីត - បាសតាមប្រុងស្ទែត- ឡូរី អាចធ្វើជាមូលដ្ឋានសម្រាប់សិក្សាពីប្រតិកម្មផ្ទេរប្រូតុង ។ អាស៊ីតបានឱ្យប្រូតុង ឯម៉ូលេគុល ឬអ៊ីយ៉ុងដែលនៅសល់ក្រោយបោះបង់ប្រូតុង រួចហើយមានអំពើជាបាស ។ បាសនេះហៅថា បាសឆ្លាស់ ។ ដូច្នេះ ប្រភេទគីមីដែលនៅសល់ក្រោយពីអាស៊ីតប្រុងស្ទែត- ឡូរីបោះបង់ប្រូតុងគឺជា " បាសឆ្លាស់ "របស់អាស៊ីតនោះ ។

***ឧទាហរណ៍ :*** អ៊ីយ៉ុងភ្លុយអរ $F^-$ គឺជាបាសឆ្លាស់របស់អាស៊ីតភ្លុយអរីឌ្រិច HF ។

$$HF(aq) + H_2O(\ell) \rightleftharpoons F^-(aq) + H_3O^+(aq)$$

អាស៊ីត — បាសឆ្លាស់

នៅក្នុងប្រតិកម្មនេះ ម៉ូលេគុលទឹកគឺជាបាសប្រុងស្ទែត- ឡូរី វាទទួលប្រូតុងពីអាស៊ីតភ្លុយអរីឌ្រិច HF ដើម្បីកកើតជាអ៊ីយ៉ុងអ៊ីដ្រូញ៉ូម $H_3O^+$ ដែលជាអាស៊ីត ។ អ៊ីយ៉ុងអ៊ីដ្រូញ៉ូម $H_3O^+$ គឺជាអាស៊ីតឆ្លាស់របស់ទឹក ។ ដូចនេះប្រភេទគីមីដែលកកើតឡើងពេលដែលបាសប្រុងស្ទែត- ឡូរី ទទួលប្រូតុងមួយគឺជា " **អាស៊ីតឆ្លាស់** " របស់បាសនោះ ។

$$HF(aq) + H_2O(\ell) \rightleftharpoons F^-(aq) + H_3O^+(aq)$$

បាស — អាស៊ីតឆ្លាស់

ជាទូទៅប្រតិកម្មរវាងអាស៊ីត- បាសប្រុងស្ទែត- ឡូរី ជាប្រព័ន្ធមានលំនឹង មានន័យថាប្រតិកម្មនេះជាប្រតិកម្មទៅមក ។ ប្រតិកម្មនេះទាក់ទងទៅនិងគូអាស៊ីត- បាសពីរគឺ គូអាស៊ីត- បាសឆ្លាស់ ។

$$HF(aq) + H_2O(\ell) \rightleftharpoons F^-(aq) + H_3O^+(aq)$$

អាស៊ីត 1 — បាស 2 — បាស 1 — អាស៊ីត 2

តាមសមីការយើងឃើញថាមានគូអាស៊ីត-បាសឆ្លាស់ពីរគូ : គូ HF និង $F^-$ និងគូ $H_3O^+$ និង $H_2O$ ។ នៅគ្រប់គូអាស៊ីត-បាសឆ្លាស់ អាស៊ីតមានប្រូតុងមួយច្រើនជាបាសឆ្លាស់របស់វា ។

***ឧទាហរណ៍ :*** ចូរបញ្ជាក់ពីគូអាស៊ីត-បាសឆ្លាស់នៅក្នុងប្រតិកម្មរវាងអាម៉ូញ៉ាក់ និងអាស៊ីតភ្លុយអរិឌ្រិចក្នុងសូលុយស្យុងទឹក ។

$$NH_3(aq) + HF(aq) \rightleftharpoons NH_4^+(aq) + F^-(aq)$$

បាស　　អាស៊ីត　　　　អាស៊ីត　　　បាស

***ចម្លើយ :*** គូអាស៊ីត-បាសឆ្លាស់ទី(1) HF ជាអាស៊ីត ហើយ $F^-$ ជាបាសឆ្លាស់ និង(2) $NH_3$ ជាបាសហើយ $NH_4^+$ ជាអាស៊ីតឆ្លាស់ ។

គ្រប់អាស៊ីតប្រុងស្តែត-ឡូរី មានបាសឆ្លាស់ គ្រប់បាសប្រុងស្តែត-ឡូរីមានអាស៊ីតឆ្លាស់របស់វា ។ ដូច្នេះ គូអាស៊ីត/បាស គឺជាសំណុំនៃប្រភេទគីមីពីរឆ្លាស់គ្នាដែលប្តូរប្រូតុងគ្នាទៅវិញទៅមក ។

**លំហាត់អនុវត្តន៍**

ចូរបញ្ជាក់ពីគូអាស៊ីត-បាសឆ្លាស់នៅក្នុងប្រតិកម្ម :

ក. $CN^- + H_2O \rightleftharpoons HCN + OH^-$

ខ. $NH_3 + H_2O \rightleftharpoons NH_4^+ + OH^-$

**តារាងទី 2.1 : គូអាស៊ីត-បាសឆ្លាស់មួយចំនួន**

| អាស៊ីត | បាសឆ្លាស់ |
|---|---|
| - អាស៊ីតក្លរីឌ្រិច HCl | - អ៊ីយ៉ុងក្លរួ $Cl^-$ |
| - អាស៊ីតស៊ុលផួរិច $H_2SO_4$ | - អ៊ីយ៉ុងអ៊ីដ្រូសែណូស៊ុលផាត $HSO_4^-$ |
| - អ៊ីយ៉ុងអ៊ីដ្រូញ៉ូម $H_3O^+$ | - ទឹក $H_2O$ |
| - អ៊ីយ៉ុងអ៊ីដ្រូសែណូស៊ុលផាត $HSO_4^-$ | - អ៊ីយ៉ុងស៊ុលផាត $SO_4^{2-}$ |
| - អាស៊ីតអ៊ីប៉ូក្លរី HOCl | - អ៊ីយ៉ុងអ៊ីប៉ូក្លរីត $ClO^-$ |
| - អ៊ីយ៉ុងឌីអ៊ីដ្រូសែណូផូស្វាត $H_2PO_4^-$ | - អ៊ីយ៉ុងម៉ូណូអ៊ីដ្រូសែណូផូស្វាត $HPO_4^{2-}$ |
| - អ៊ីយ៉ុងអាម៉ូញ៉ូម $NH_4^+$ | - អាម៉ូញ៉ាក់ $NH_3$ |
| - អ៊ីយ៉ុងអ៊ីដ្រូសែណូកាបូណាត $HCO_3^-$ | - អ៊ីយ៉ុងកាបូណាត $CO_3^{2-}$ |
| - ទឹក $H_2O$ | - អ៊ីយ៉ុងអ៊ីដ្រុកស៊ីត $OH^-$ |
| អាស៊ីតឆ្លាស់ | បាស |

## 1.1. កម្លាំងអាស៊ីត-បាសឆ្លាស់

ប្រតិកម្មនៃអាស៊ីត- បាស ប្រុងស្ទែត- ឡូរី អាស្រ័យទៅនិងទំនាក់ទំនងនៃកម្លាំងអាស៊ីត និងកម្លាំងបាសដែលចូលរួម ។ ឧទាហរណ៍ : អាស៊ីតក្លរីឌ្រិច HCl គឺជាអាស៊ីតខ្លាំង ងាយឱ្យប្រូតុង ។ ដូច្នេះ អ៊ីយ៉ុងក្លរ $Cl^-$ មានទំនោរខ្សោយក្នុងការទាញនិងរក្សាប្រូតុង ហេតុនេះទើបអ៊ីយ៉ុងក្លរ $Cl^-$ ជាបាសខ្សោយខ្លាំង ។

$$\underset{\text{អាស៊ីតខ្លាំង}}{HCl(aq)} + \underset{\text{បាស}}{H_2O(\ell)} \longrightarrow \underset{\text{អាស៊ីត}}{H_3O^+(aq)} + \underset{\text{បាសខ្សោយ}}{Cl^-(aq)}$$

## 1.2. សន្និដ្ឋាន

- អាស៊ីតខ្លាំងឱ្យបាសឆ្លាស់ខ្សោយ ហើយបាសដែលខ្លាំង ឱ្យអាស៊ីតឆ្លាស់ខ្សោយ ។ បញ្ញត្តិនេះត្រឹមត្រូវស្របតាមកម្លាំងខុសគ្នារបស់អាស៊ីត- បាសដែលយកមកប្រៀបធៀបដើម្បីព្យាករណ៍លទ្ធផលនៃប្រតិកម្ម ។ ឧទាហរណ៍ ប្រតិកម្មនៃអាស៊ីតពែក្លរិច $HClO_4$ និងទឹក $H_2O$ :

$$\underset{\text{អាស៊ីតខ្លាំង}}{HClO_4(aq)} + \underset{\text{បាសខ្លាំង}}{H_2O(\ell)} \longrightarrow \underset{\text{អាស៊ីតខ្សោយ}}{H_3O^+(aq)} + \underset{\text{បាសខ្សោយ}}{ClO_4^-(aq)}$$

អ៊ីយ៉ុងអ៊ីដ្រូញ៉ូម $H_3O^+$ ខ្សោយខ្លាំងធៀបជាមួយអាស៊ីតពែក្លរិចក្នុងការឱ្យប្រូតុង ។ ដូចនេះ $HClO_4$ ជាអាស៊ីតខ្លាំងជាង ។ ក្នុងប្រតិកម្មនេះអ៊ីយ៉ុងពែក្លរ៉ាត $ClO_4^-$ និងទឹកគឺជាបាស ចំណែកអាស៊ីត $HClO_4$ ដែលជាអាស៊ីតខ្លាំង នោះអ៊ីយ៉ុង $ClO_4^-$ គឺជាបាសខ្សោយ ។ ដូច្នេះទឹកអាចទទួលប្រូតុងបានមុន ។ ប្រតិកម្មនេះ ប្រព្រឹត្តទៅតាមលំនាំអាស៊ីតខ្លាំងមានប្រតិកម្មជាមួយបាសខ្លាំងឱ្យផលជាអាស៊ីតខ្សោយ និងបាសខ្សោយ ។

ប្រៀបធៀបប្រតិកម្មរវាងទឹកនិងអាស៊ីតអាសេទិច

$$\underset{\text{អាស៊ីតខ្សោយ}}{CH_3COOH(aq)} + \underset{\text{បាសខ្សោយ}}{H_2O(\ell)} \longleftarrow \underset{\text{អាស៊ីតខ្លាំង}}{H_3O^+(aq)} + \underset{\text{បាសខ្លាំង}}{CH_3COO^-(aq)}$$

កំហាប់អ៊ីយ៉ុង $H_3O^+$ ក្នុងប្រតិកម្មនេះ ទាបជាងកំហាប់ $H_3O^+$ ក្នុងសូលុយស្យុង $HClO_4$ ព្រោះអាស៊ីតអាសេទិចជាអាស៊ីតខ្សោយ ។ ម៉ូលេគុលអាស៊ីតអាសេទិច $CH_3COOH$ មិនអាចប្រជែងជាមួយអ៊ីយ៉ុង $H_3O^+$ ក្នុងការផ្តល់ប្រូតុងទៅឱ្យបាសទេ ។ ឯអ៊ីយ៉ុងអាសេតាត $CH_3COO^-$ គឺជាបាសខ្លាំងជាងទឹក ដូច្នេះម៉ូលេគុល $H_2O$ មិនអាចទទួលប្រូតុងបានទេ ។ ចំណែកអ៊ីយ៉ុង $H_3O^+$ គឺជាអាស៊ីតខ្លាំង ហើយអ៊ីយ៉ុង $CH_3COO^-$ គឺជាបាសខ្លាំង ។

ដូច្នេះ ប្រតិកម្មនេះត្រូវទៅតាមទិសដៅខាងឆ្វេង ។

យើងសំគាល់ឃើញថាប្រតិកម្មអាស៊ីតពែក្លរិចនិងប្រតិកម្មអាស៊ីតអាសេទិចមានទិសដៅឆ្ពោះទៅអាស៊ីតខ្សោយនិងបាសខ្សោយ ។

- ប្រតិកម្មផ្ទេរប្រូតុងនេះទោរទៅខាងផលិតផលអាស៊ីតខ្សោយនិងបាសខ្សោយ ។ សម្រាប់ប្រតិកម្មដែលទិតទៅជិតទីបញ្ចប់ កំហាប់អង្គធាតុប្រតិករត្រូវធំជាងអាស៊ីតនិងបាសខាងផលិតផល ។

**តារាងទី 2.2 : ទំនាក់ទំនងកម្លាំងរបស់អាស៊ីត និងបាស**

(កម្លាំងអាស៊ីតកើន ↑ ; កម្លាំងបាសកើន ↓)

| អាស៊ីតឆ្លាស់ | រូបមន្ត | បាសឆ្លាស់ | រូបមន្ត |
|---|---|---|---|
| អាស៊ីតអ៊ីយ៉ូឌីឌ្រិច | $HI$ | អ៊ីយ៉ុងអ៊ីយ៉ូឌួ | $I^-$ |
| អាស៊ីតពែក្លរិច | $HClO_4$ | អ៊ីយ៉ុងពែក្លរ៉ាត | $ClO_4^-$ |
| អាស៊ីតប្រូមីឌ្រិច | $HBr$ | អ៊ីយ៉ុងប្រូមួ | $Br^-$ |
| អាស៊ីតក្លរីឌ្រិច | $HCl$ | អ៊ីយ៉ុងក្លរួ | $Cl^-$ |
| អាស៊ីតស៊ុលផួរិច | $H_2SO_4$ | អ៊ីយ៉ុងអ៊ីដ្រូសែណូស៊ុលផាត | $HSO_4^-$ |
| អាស៊ីតក្លរិច | $HClO_3$ | អ៊ីយ៉ុងក្លរ៉ាត | $ClO_3^-$ |
| អាស៊ីតនីទ្រិច | $HNO_3$ | អ៊ីយ៉ុងនីត្រាត | $NO_3^-$ |
| អ៊ីយ៉ុងអ៊ីដ្រូញ៉ូម | $H_3O^+$ | ទឹក | $H_2O$ |
| អាស៊ីតក្លរី | $HClO_2$ | អ៊ីយ៉ុងក្លរីត | $ClO_2^{2-}$ |
| អ៊ីយ៉ុងអ៊ីដ្រូសែណូស៊ុលផាត | $HSO_4^-$ | អ៊ីយ៉ុងស៊ុលផាត | $SO_4^{2-}$ |
| អាស៊ីតផូស្វរិច | $H_3PO_4$ | អ៊ីយ៉ុងឌីអ៊ីដ្រូសែណូផូស្វាត | $H_2PO_4^-$ |
| អាស៊ីតភ្លុយអរីឌ្រិច | $HF$ | អ៊ីយ៉ុងភ្លុយអរួ | $F^-$ |
| អាស៊ីតអាសេទិច | $CH_3COOH$ | អ៊ីយ៉ុងអាសេតាត | $CH_3COO^-$ |
| អាស៊ីតកាបូនិច | $H_2CO_3$ | អ៊ីយ៉ុងអ៊ីដ្រូសែណូកាបូណាត | $HCO_3^-$ |
| អាស៊ីតស៊ុលភីឌ្រិត | $H_2S$ | អ៊ីយ៉ុងអ៊ីដ្រូសែណូស៊ុលផួ | $HS^-$ |
| អ៊ីយ៉ុងឌីអ៊ីដ្រូសែណូផូស្វាត | $H_2PO_4^-$ | អ៊ីយ៉ុងអ៊ីដ្រូសែណូផូស្វាត | $HPO_4^-$ |
| អាស៊ីតអ៊ីប៉ូក្លរី | $HOCl$ | អ៊ីយ៉ុងអ៊ីប៉ូក្លរីត | $OCl^-$ |
| អ៊ីយ៉ុងអាម៉ូញ៉ូម | $NH_4^+$ | អាម៉ូញ៉ាក់ | $NH_3$ |
| អ៊ីយ៉ុងអ៊ីដ្រូសែណូកាបូណាត | $HCO_3^-$ | អ៊ីយ៉ុងកាបូណាត | $CO_3^{2-}$ |
| អ៊ីយ៉ុងអ៊ីដ្រូសែណូផូស្វាត | $HPO_3^{2-}$ | អ៊ីយ៉ុងផូស្វាត | $PO_4^{3-}$ |
| ទឹក | $H_2O$ | អ៊ីយ៉ុងអ៊ីដ្រុកស៊ីត | $OH^-$ |
| អាម៉ូញ៉ាក់ | $NH_3$ | អ៊ីយ៉ុងអាមីត | $NH_2^-$ |
| អ៊ីដ្រូសែន | $H_2$ | អ៊ីយ៉ុងអ៊ីដ្រួ | $H^-$ |

ក្នុងសូលុយស្យុង អាស៊ីតខ្លាំងទាំងអស់បំបែកជាអ៊ីយ៉ុងទាំងស្រុង បង្កើតជាអ៊ីយ៉ុងអ៊ីដ្រូញ៉ូម $H_3O^+$ ត្រូវនិងអាញ៉ុងរបស់វា ។ អាស៊ីតដែលនៅខាងក្រោមអ៊ីយ៉ុង $H_3O^+$ ក្នុងតារាងទី 2 មិនបំបែកជាអ៊ីយ៉ុងទាំងស្រុងនៅក្នុងទឹកទេ ។

## 2. សមាសធាតុអំផូទែ

សមាសធាតុខ្លះ មានលក្ខណៈទ្វេជាអាស៊ីតផងនិងជាបាសផង ។ សមាសធាតុដែលមានលក្ខណៈជាអាស៊ីត(បោះបង់ប្រូតុង)និងជាបាស(ទទួលប្រូតុង)ហៅថា " **សមាសធាតុអំផូទែ** " ។

***ឧទាហរណ៍ :*** ក្នុងប្រតិកម្មបំបែកអាស៊ីតស៊ុលផួរិច ទឹកមាននាទីជាបាស

$$H_2SO_4(aq) + H_2O(\ell) \longrightarrow H_3O^+(aq) + HSO_4^-(aq)$$

អាស៊ីត 1 បាស 2 អាស៊ីត 2 បាស 1

ហើយនិងទឹកមាននាទីជាអាស៊ីតនៅក្នុងប្រតិកម្មជាមួយអាម៉ូញ៉ាក់

$$NH_3(g) + H_2O(\ell) \longrightarrow NH_4^+(aq) + OH^-(aq)$$

បាស 1 អាស៊ីត 2 អាស៊ីត 1 បាស 2

ទឹកជាសមាសធាតុអំផូទែ ព្រោះម៉ូលេគុលទឹកអាចឱ្យប្រូតុង រួចក្លាយទៅជាអ៊ីយ៉ុងអ៊ីដ្រុកស៊ីត $OH^-$ ឬវាអាចទទួលប្រូតុងដើម្បីក្លាយទៅជាអ៊ីយ៉ុងអ៊ីដ្រូញ៉ូម $H_3O^+$ ។

សារធាតុដែលមាននាទីជាអាស៊ីតផង ឬជាបាសផង អាស្រ័យទៅលើកម្លាំងអាស៊ីត ឬកម្លាំងបាសដែលចូលរួមប្រតិកម្មជាមួយវា ។

បើទឹកមានប្រតិកម្មជាមួយសមាសធាតុដែលមាន **លក្ខណៈជាអាស៊ីតខ្លាំងជាងវា**នោះទឹកមាននាទី **ជាបាស** ។ តែបើវាមានប្រតិកម្មជាមួយម៉ូលេគុលដែលមាន **លក្ខណៈអាស៊ីតខ្សោយជាងវា** នោះទឹកមាន **នាទី ជាអាស៊ីត** ហើយម៉ូលេគុលដទៃទៀតនឹងមាននាទី **ជាបាស** ។




***រូបទី 2.1 : កម្រិតអាស៊ីតកើនឡើង***

អាស៊ីតរបស់ក្លរនីមួយៗ(រូបទី 2.1) មានអាតូមក្លរ និងអាតូមអ៊ីដ្រូសែនមួយដូចគ្នា តែវាខុសគ្នាដោយចំនួនអាតូមអុកស៊ីសែន ។ ដោយការផ្លាស់ប្តូរសម្ព័ន្ធប៉ូលែ O – H យើងឃើញកម្លាំងអាស៊ីតកើនឡើងពីអាស៊ីតអ៊ីប៉ូក្លរីទៅអាស៊ីតពែក្លរិច ។

## 3. ប្រតិកម្មបន្សាប

សមាសធាតុអាស៊ីតជាច្រើន មានប្រតិកម្មជាមួយសមាសធាតុបាស ដោយវាបន្សាបធាតុនីមួយៗ ។ សូដ្យូមប៊ីកាបូណាត $NaHCO_3$ និងអាស៊ីតតាកតារិច $H_2C_4H_4O_6$ ជាធាតុផ្សំពីរប្រភេទនៅក្នុងមេនំប៉័ង ។ ក្នុងពេលប្រតិកម្មសូលុយស្យុងសមាសធាតុទាំងពីរនេះបង្កើតឧស្ម័នកាបូនឌីអុកស៊ីត ។ ដោយសារឧស្ម័នកាបូនឌីអុកស៊ីតភាយចេញនេះហើយដែលធ្វើឱ្យនំឡើងប៉ោងឬរីកឡើង ។ ឧទាហរណ៍ផ្សេងទៀត ដូចជាសារធាតុអង់តាស៊ីតកាត់បន្ថយកម្រិតជាតិអាស៊ីតនៅក្នុងក្រពះដោយការបន្សាប ។

### 3.1. ប្រតិកម្មបន្សាបអាស៊ីតខ្លាំង-បាសខ្លាំង

ប្រតិកម្មអាស៊ីត-បាសរវាងអាស៊ីតក្លរីឌ្រិច (HCl) ដែលជាអាស៊ីតខ្លាំងនិងសូដ្យូមអ៊ីដ្រុកស៊ីត (NaOH) ជាបាសខ្លាំងដោយបំបែកជាអ៊ីយ៉ុងទាំងស្រុង បង្កើតបានជាអ៊ីយ៉ុងអ៊ីដ្រូញ៉ូម $H_3O^+$ និងជាអ៊ីយ៉ុង $OH^-$ ។ សមីការតាងប្រតិកម្ម :

$$HCl(aq) + NaOH(aq) \longrightarrow NaCl(aq) + H_2O(\ell)$$

សូលុយស្យុង NaOH 1 ម៉ូលបំបែកបានជា

$$NaOH(aq) \longrightarrow Na^+ (aq) + OH^- (aq)$$

ហើយក្នុងសូលុយស្យុងអាស៊ីតក្លរីឌ្រិច 1 ម៉ូលបំបែកបានជា

$$HCl(aq) + H_2O(\ell) \longrightarrow H_3O^+ (aq) + Cl^- (aq)$$

បើយើងលាយសូលុយស្យុងទាំងពីរនេះចូលគ្នា នោះប្រតិកម្មកើតមានតែរវាងអ៊ីយ៉ុង $H_3O^+$ និងអ៊ីយ៉ុង $OH^-$ ប៉ុណ្ណោះ ហើយបង្កើតបានជា NaCl និងទឹក

$$H_3O^+ (aq) + Cl^- (aq) + Na^+ (aq) + OH^- (aq) \longrightarrow Na^+ (aq) + Cl^- (aq) + 2H_2O(\ell)$$

ដោយអ៊ីយ៉ុង $Na^+$ និង $Cl^-$ មាននៅផ្នែកទាំងសងខាងនៃប្រតិកម្មនោះ អ៊ីយ៉ុង $Na^+$ និង $Cl^-$ នេះគឺជា "អ៊ីយ៉ុងទស្សនិក" ។ ឯអ៊ីយ៉ុងដែលចូលរួមក្នុងប្រតិកម្មនេះគឺអ៊ីយ៉ុង $H_3O^+$ និង $OH^-$ ចូលផ្សំគ្នាបានជាម៉ូលេគុលទឹក ។ ដូចនេះប្រតិកម្មបន្សាប គឺជាប្រតិកម្មនៃអ៊ីយ៉ុងអ៊ីដ្រូញ៉ូម $H_3O^+$ និងអ៊ីយ៉ុងអ៊ីដ្រុកស៊ីត $OH^-$ បង្កើតបានជាម៉ូលេគុលទឹក

$$H_3O^+ (aq) + OH^- (aq) \longrightarrow 2H_2O(\ell)$$

*សំគាល់* : ផលិតផល ដែលកើតក្រោយប្រតិកម្មបន្សាបគឺទឹក និងអំបិល ។ អំបិលជាសមាសធាតុអ៊ីយ៉ុងដែលផ្សំឡើងពីកាចុងបានពីបាស និងអាញ៉ុងបានពីអាស៊ីត ។

## 3.2. ភ្លៀងអាស៊ីត



*រូបទី 2.2 ឥទ្ធិពលភ្លៀងអាស៊ីតធ្វើឱ្យព្រៃឈើជ្រុះស្លឹកនិងងាប់*

ក្នុងលំនាំដំណើរការរោងចក្របានបញ្ចេញចោលនូវឧស្ម័ន : NO , $NO_2$ , $CO_2$ , $SO_2$ និង $SO_3$ ក្នុងបរិមាណជាច្រើន ។ សមាសធាតុទាំងនេះរលាយក្នុងបរិយាកាសបង្កើតបានជាសូលុយស្យុងអាស៊ីត ហើយធ្លាក់មកលើដីវិញក្រោមទម្រង់ជាភ្លៀង ឬព្រិល ។

*ឧទាហរណ៍* : ស្ពាន់ធ័រដែលបានមកពីចំហេះប្រេងនិងធ្យូងថ្មបង្កើតបានជាស្ពាន់ធ័រឌីអុកស៊ីត $SO_2$ រួចក្លាយជាស្ពាន់ធ័រទ្រីអុកស៊ីត $SO_3$ ដែលមានប្រតិកម្មជាមួយទឹកក្នុងបរិយាកាសបង្កើតបានជាអាស៊ីតស៊ុលផួរិច $H_2SO_4$ ។

សមីការតាងប្រតិកម្ម : $SO_3(g) + H_2O(\ell) \longrightarrow H_2SO_4(aq)$

តាមធម្មតាទឹកភ្លៀងតែងមានជាតិអាស៊ីតតិចតួច ប៉ុន្តែពេលខ្លះវាមានជាតិអាស៊ីតខ្លាំងហៅថា " ភ្លៀងអាស៊ីត " ។ ភ្លៀងអាស៊ីតធ្វើឱ្យខូចសំណាកនិងមានឥទ្ធិពលទៅលើប្រព័ន្ធអេកូឡូស៊ីដូចជា ទឹកបរិស្ថាន និងព្រៃឈើ ។ ម្យ៉ាងទៀតភ្លៀងអាស៊ីតក៏អាចជាបុព្វហេតុធ្វើឱ្យត្រីដែលរស់នៅក្នុងបឹង ទន្លេ និងប្រឡាយថយចុះ ឬងាប់ដែរ ។

## មេរៀនសង្ខេប

- ប្រភេទគីមីដែលសល់ក្រោយពីអាស៊ីតប្រុងស្ទែត-ឡូវីបោះបង់ប្រូតុងជាបាសឆ្លាស់របស់អាស៊ីតនោះ ។
- ប្រភេទគីមីដែលកកើតពេលបាសប្រុងស្ទែត-ឡូរីទទួលប្រូតុងជាអាស៊ីតឆ្លាស់របស់បាសនោះ ។
- គ្រប់ប្រតិកម្មអាស៊ីត-បាស ប្រុងស្ទែត-ឡូរី មានពីរគូអាស៊ីត បាសឆ្លាស់ ។
- អាស៊ីតខ្លាំងមានបាសឆ្លាស់ខ្សោយ ហើយបាសខ្លាំងមានអាស៊ីតឆ្លាស់ខ្សោយ ។
- សមាសធាតុដែលមានលក្ខណៈជាអាស៊ីតផងនិងជាបាសផងហៅថា " សមាសធាតុអំផូទែ " ។
- ប្រតិកម្មបន្សាប គឺជាប្រតិកម្មបង្កើតទឹក និងសមាសធាតុអ៊ីយ៉ុង (អំបិល) ។

## ? សំណួរនិងលំហាត់

1. ចូរឱ្យនិយមន័យ គូអាស៊ីត/បាសឆ្លាស់ ។
2. ដូចម្ដេចហៅថាសមាសធាតុអំផូទែ ? ឱ្យឧទាហរណ៍សារធាតុឬអ៊ីយ៉ុងដែលមានលក្ខណៈអំផូទែ ។
3. ចូរចាត់ថ្នាក់ប្រភេទគីមីដូចខាងក្រោមនេះថាជា អាស៊ីត បាស ប្រុងស្ទែត ឬដើរតួទាំងពីរ :

ក. $H_2O$ ខ. $OH^-$

គ. $H_3O^+$ ឃ. $NH_3$

ង. $NH_4^+$ ច. $NH_2^-$

ឆ. $NO_3^-$ ជ. $CO_3^{2-}$

ឈ. HBr ញ. HCN ។

4. ចូរសរសេររូបមន្តបាសឆ្លាស់របស់អាស៊ីតដូចតទៅ :

$HNO_2$ , $H_2SO_4$ , $H_2S$ , HCN និង HCOOH ។

5. ចូរបញ្ជាក់ពីគូអាស៊ីត បាសឆ្លាស់របស់ប្រតិកម្មដូចខាងក្រោម :

ក. $CH_3COO^- + HCN \rightleftharpoons CH_3COOH + CN^-$

ខ. $HCO_3^- + HCO_3^- \rightleftharpoons H_2CO_3 + CO_3^{2-}$

គ. $H_2SO_4(aq) + SO_3^{2-}(aq) \rightleftharpoons HSO_4^-(aq) + HSO_3^-(aq)$ ។

6. ចូរសរសេររូបមន្តអាស៊ីតឆ្លាស់របស់បាសដូចតទៅ :

ក. $HS^-$ ខ. $HCO_3^-$

គ. $CO_3^{2-}$ ឃ. $H_2PO_4^-$

ង. $HPO_4^{2-}$ ច. $PO_4^{3-}$

ឆ. $HSO_4^-$ ជ. $SO_4^{2-}$

ឈ. $SO_3^{2-}$ ។

7. តើគូអាស៊ីត បាសឆ្លាស់របស់ទឹកមានប៉ុន្មាន ?

ក. តើគូណាមួយដែលទឹកមាននាទីជាអាស៊ីត ?

ខ. តើគូមួយណាដែលទឹកមាននាទីជាបាស ?

8. តើកម្លាំងរបស់អាស៊ីត និងកម្លាំងរបស់បាសឆ្លាស់មានទំនាក់ទំនងគ្នាដូចម្តេច ?

9. តើកម្លាំងរបស់បាស និងកម្លាំងរបស់អាស៊ីតឆ្លាស់មានទំនាក់ទំនងដូចម្តេច ?

10. ប្រភេទខាងក្រោមនេះអាចចាត់ទុកជាអាស៊ីតផងនិងបាសផងក្នុងគូពីរផ្សេងគ្នា : $HSO_4^-$ , $HS^-$ , $HCO_3^-$ , $H_2O$ , $HSO_3^-$ និង $NH_3$ ។

ក. តើគេចាត់ទុកប្រភេទទាំងនេះយ៉ាងដូចម្តេច ?

ខ. ចូរសរសេរគូទាំងពីររបស់ប្រភេទនីមួយៗ ។

គ. ចូរបញ្ជាក់ គូណាខ្លះជាអាស៊ីតខ្លាំងនិងគូណាខ្លះជាបាសខ្លាំង ។

11. គេដាក់ស័ង្កសីឱ្យមានប្រតិកម្មជាមួយសូលុយស្យុង $H_2SO_4$ ចំនួន 100mL នៅកំហាប់ 6.00M ។ គណនា :

ក. ម៉ាសសង្កសីស៊ុលផាតដែលទទួលបាន

ខ. មាឌឧស្ម័នអ៊ីដ្រូសែនដែលភាយចេញពីប្រតិកម្មនៅសីតុណ្ហភាព STP ។

( Zn = 65 , S = 32 , O = 16 , H = 1 ឧស្ម័ន 1mol នៅ STP មានមាឌ 22.4L )

12. សំបកខ្យងមួយផ្សំពី $CaCO_3$ មានប្រតិកម្មជាមួយសូលុយស្យុង HCl គេទទួលបាន 1500mL ឧស្ម័ន $CO_2$ នៅសីតុណ្ហភាព STP រួមទាំង $CaCl_2$ និងទឹក ។ គណនា :

ក. បរិមាណ $CaCO_3$ ចូលរួមប្រតិកម្ម ?

ខ. មាឌសូលុយស្យុង HCl នៅ 2.00M ដែលប្រើក្នុងប្រតិកម្មនេះ ។

( Ca = 40 , C = 12 , O = 16 , H = 1 , Cl = 35.5 )

# 3 សូលុយស្យុងទឹកនិង pH

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាពីស្វ័យអ៊ីយ៉ុងកម្មនៃទឹក ។
- ពន្យល់និងប្រើប្រាស់មាត្រដ្ឋាន pH ។
- អនុវត្តការគណនាតម្លៃ pH ។

## 1. អ៊ីយ៉ុងអ៊ីដ្រូញ៉ូមនិងអ៊ីយ៉ុងអ៊ីដ្រុកស៊ីត

យើងសិក្សារួចមកហើយថា អាស៊ីតនិងបាសបង្កើតអ៊ីយ៉ុងអ៊ីដ្រូញ៉ូម $H_3O^+$ និងអ៊ីយ៉ុងអ៊ីដ្រុកស៊ីត $OH^-$ នៅក្នុងសូលុយស្យុង ។ ទឹកដែលជាធាតុរំលាយក៏ផ្តល់អ៊ីយ៉ុង $H_3O^+$ បានដែរ ។

### 1.1. ស្វ័យអ៊ីយ៉ុងកម្មនៃទឹក

អគ្គិសនីវិភាគបានបង្ហាញថា ទឹកជាអេឡិចត្រូលីតខ្សោយបំផុត ។ ទឹករងស្វ័យអ៊ីយ៉ុងកម្មដូចរូបភាពខាងក្រោម :



$H_2O\ (\ell) + H_2O\ (\ell) \rightleftharpoons H_3O^+\ (aq) + OH^-\ (aq)$

បាស អាស៊ីត

*រូបទី 3.1 ស្វ័យអ៊ីយ៉ុងកម្មនៃទឹក*

វត្តមានអ៊ីយ៉ុង $H_3O^+$ ក្នុងទឹកបានមកពីអ៊ីយ៉ុងកម្មដោយភាគនៃទឹក ។ ម៉ូលេគុលទឹកមួយបោះបង់ប្រូតុងមួយទៅឱ្យម៉ូលេគុលទឹកមួយទៀត បន្ទាប់មកម៉ូលេគុលទឹកដែលបោះបង់ប្រូតុងនោះក្លាយជាអ៊ីយ៉ុង $OH^-$ ចំណែកម៉ូលេគុលទឹកទទួលប្រូតុងក្លាយជាអ៊ីយ៉ុង $H_3O^+$ ។ ដូច្នេះវាជាការបន្ទេរប្រូតុងរវាងពីរម៉ូលេគុលទឹក(រូបទី 3.1) ។ ប្រតិកម្មនេះហៅថា **ស្វ័យអ៊ីយ៉ុងកម្មនៃទឹក** (ឬអូតូប្រូតូលីសនៃទឹក) ។

សមីការតាងប្រតិកម្ម : $H_2O\ (\ell) + H_2O\ (\ell) \rightleftharpoons H_3O^+\ (aq) + OH^-\ (aq)$

ពិសោធន៍ខាងលើបង្ហាញថាកំហាប់អ៊ីយ៉ុង $H_3O^+$ និង $OH^-$ នៅក្នុងទឹកសុទ្ធស្មើគ្នាគឺ $1.0 \times 10^{-7}$mol/L នៅសីតុណ្ហភាព 25°C ។ គេសរសេររូបមន្តរបស់អ៊ីយ៉ុងនីមួយៗនៅក្នុងវង់ក្រចកជ្រុង[ ] ។ *ឧទាហរណ៍* [ $H_3O^+$ ] មានន័យថា " កំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូមជាម៉ូលក្នុងមួយលីត្រ ឬកំហាប់ជាម៉ូលអ៊ីយ៉ុងអ៊ីដ្រូញ៉ូម " ។

គេអាចសរសេរ [ $H_3O^+$ ] = [ $OH^-$ ] = $1.0 \times 10^{-7}$M ក្នុងទឹកសុទ្ធនៅសីតុណ្ហភាព 25°C ។

$$[H_3O^+] = [OH^-] = 1.0 \times 10^{-7}M$$

## 1.2. ថេរស្វ័យអ៊ីយ៉ុងកម្មនៃទឹក (ឬផលគុណអ៊ីយ៉ុងនៃទឹក)

លំនឹងរបស់ទឹកនិងអ៊ីយ៉ុងវាដែលកកើតតាងដោយសមីការ:

$$2H_2O\ (\ell) \rightleftharpoons H_3O^+(aq) + OH^-(aq)$$

កន្សោមថេរលំនឹងនោះ ទាក់ទងនឹងកំហាប់នៃប្រភេទដែលមានក្នុងលំនឹង ។ ទំនាក់ទំនងនេះគឺ [ $H_3O^+$ ][ $OH^-$ ] = $K_c$ ។ ថេរលំនឹងនេះហៅថា **ថេរស្វ័យអ៊ីយ៉ុងកម្មនៃទឹក** ឬផលគុណអ៊ីយ៉ុងកម្មនៃទឹក ដែលតាងដោយនិមិត្តសញ្ញា $K_c$ ឬ $K_w$ ។ ផលគុណកំហាប់អ៊ីយ៉ុងទាំងពីរនេះថេរជានិច្ច ។

$$[H_3O^+][OH^-] = K_c = K_w = (1.0 \times 10^{-7})(1.0 \times 10^{-7}) = 1.0 \times 10^{-14}$$

ដូច្នេះគ្រប់សូលុយស្យុងរាវក្នុងទឹក " **ផលគុណកំហាប់អ៊ីយ៉ុង**[ $H_3O^+$ ]**និងកំហាប់អ៊ីយ៉ុង** [ $OH^-$ ] " មានតម្លៃថេរជានិច្ចនៅសីតុណ្ហភាពកំណត់មួយ ។ ផលគុណនេះហៅថា " **ផលគុណអ៊ីយ៉ុងនៃទឹក** " ។

**តារាងទី 3.1 : $K_w$ នៅសីតុណ្ហភាពកំណត់**

| សីតុណ្ហភាព (°C) | $K_w$ |
|---|---|
| 0 | $1.2 \times 10^{-15}$ |
| 10 | $3.0 \times 10^{-15}$ |
| 25 | $1.2 \times 10^{-14}$ |
| 50 | $5.3 \times 10^{-14}$ |

ថេរ $K_w$ នេះគ្មានខ្នាតទេ ប៉ុន្តែចំពោះកំហាប់[ $H_3O^+$ ] និង [ $OH^-$ ] គិតជា (mol $L^{-1}$) ។ អ៊ីយ៉ុងកម្មនៃទឹកកើនឡើង កាលណាសីតុណ្ហភាពកើន ។ ដូច្នេះផលគុណអ៊ីយ៉ុងនៃទឹក $K_w$ ក៏កើនពេលសីតុណ្ហភាពកើនឡើងដែរ(តារាងទី 3.1) ។ បើកំហាប់អ៊ីយ៉ុងមួយកើននោះកំហាប់អ៊ីយ៉ុងមួយទៀតថយចុះដូចបង្ហាញក្នុងតារាងទី 3.2 ។

តារាងទី 3.2 : កំហាប់និង $K_w$

| សូលុយស្យុង | $[H_3O^+]$ (M) | $[OH^-]$ (M) | $K_w = [H_3O^+][OH^-]$ |
|---|---|---|---|
| ទឹកសុទ្ធ | $1.0 \times 10^{-7}$ | $1.0 \times 10^{-7}$ | $1.0 \times 10^{-14}$ |
| 0.10M អាស៊ីតខ្លាំង | $1.0 \times 10^{-1}$ | $1.0 \times 10^{-13}$ | $1.0 \times 10^{-14}$ |
| 0.010M អាស៊ីតខ្លាំង | $1.0 \times 10^{-2}$ | $1.0 \times 10^{-12}$ | $1.0 \times 10^{-14}$ |
| 0.10M បាសខ្លាំង | $1.0 \times 10^{-13}$ | $1.0 \times 10^{-1}$ | $1.0 \times 10^{-14}$ |
| 0.010M បាសខ្លាំង | $1.0 \times 10^{-12}$ | $1.0 \times 10^{-2}$ | $1.0 \times 10^{-14}$ |
| 0.025M អាស៊ីតខ្លាំង | $2.5 \times 10^{-2}$ | $4.0 \times 10^{-13}$ | $1.0 \times 10^{-14}$ |
| 0.025M បាសខ្លាំង | $4.0 \times 10^{-13}$ | $2.5 \times 10^{-2}$ | $1.0 \times 10^{-14}$ |

កំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូមក្នុងសូលុយស្យុងសម្តែងលក្ខណៈអាស៊ីត ហើយកំហាប់អ៊ីយ៉ុងអ៊ីដ្រុកស៊ីតក្នុងសូលុយស្យុងសម្តែងលក្ខណៈបាស ។

***លំហាត់គំរូ*** : រកកំហាប់របស់អ៊ីយ៉ុង $[OH^-]$ ដែលមាននៅក្នុង $3.00 \times 10^{-5}$M សូលុយស្យុង HCl ?

***ចម្លើយ*** :

ដោយ HCl ជាអាស៊ីតខ្លាំង វាបំបែកជាអ៊ីយ៉ុងក្នុងសូលុយស្យុង តាមសមីការដូចខាងក្រោម :

$$HCl\ (g) + H_2O(\ell) \longrightarrow H_3O^+\ (aq) + Cl^-\ (aq)$$

ដូច្នេះក្នុង $3.00 \times 10^{-5}$M សូលុយស្យុង HCl មាន :

$[H_3O^+] = 3.00 \times 10^{-5}M$

ផលគុណអ៊ីយ៉ុងរបស់ទឹក

$K_w = [H_3O^+][OH^-] = 1.00 \times 10^{-14}$

នាំឱ្យ $[OH^-] = \dfrac{K_w}{[H_3O^+]} = \dfrac{1.00 \times 10^{-14}}{3.00 \times 10^{-5}} = 3.33 \times 10^{-10}M$

ដូច្នេះ កំហាប់ $[OH^-]$ មានក្នុងសូលុយស្យុងគឺ : $3.33 \times 10^{-10}M$

**លំហាត់អនុវត្តន៍**

1. គណនាកំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូម[ $H_3O^+$ ] មានក្នុងសូលុយស្យុង NaOH ដែលមានកំហាប់ $3.75 \times 10^{-2}$M ?
2. គណនាកំហាប់អ៊ីយ៉ុង [$OH^-$] ដែលមាននៅក្នុង សូលុយស្យុងអាស៊ីត $HNO_3$ 0.450M ?

## 1.3. សូលុយស្យុងអាស៊ីត បាស និងណឺត

កំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូមនិងកំហាប់អ៊ីយ៉ុងអ៊ីដ្រុកស៊ីតនៅក្នុងទឹកសុទ្ធដូចគ្នា វាជាសូលុយស្យុងណឺត ។ ដូចនេះ សូលុយស្យុងណាដែលកំហាប់[ $H_3O^+$ ] = [$OH^-$] ជាសូលុយស្យុងណឺត ។ ក្នុងសូលុយស្យុងមួយ បើកំហាប់[ $H_3O^+$ ] ធំជាងកំហាប់[$OH^-$] សូលុយស្យុងនោះជាអាស៊ីត តែបើកំហាប់[$OH^-$] ធំជាងកំហាប់[ $H_3O^+$ ] នោះវាជាសូលុយស្យុងបាស ។




*រូបទី 3.2 លក្ខណៈអាស៊ីត បាស ឬណឺតរបស់សូលុយស្យុង*

កំហាប់របស់អ៊ីយ៉ុង[ $H_3O^+$ ] និង [$OH^-$] របស់សូលុយស្យុងណឺតនៅ 25°C ស្មើនឹង $1.0 \times 10^{-7}$M ដូចគ្នា ។ ដូចនេះ បើកំហាប់[ $H_3O^+$ ] កើនធំជាង $1.0 \times 10^{-7}$M នោះសូលុយស្យុងប្រែជាអាស៊ីត ។ សូលុយស្យុងដែលមានកំហាប់អ៊ីយ៉ុង[ $H_3O^+$ ] $1.0 \times 10^{-5}$mol ក្នុង 1 លីត្រ នៅសីតុណ្ហភាព 25°C ជាសូលុយស្យុងអាស៊ីត ព្រោះ $1.0 \times 10^{-5}$ ធំជាង $1.0 \times 10^{-7}$ ។ បើកំហាប់ [$OH^-$] កើនធំជាង $1.0 \times 10^{-7}$M នោះសូលុយស្យុងប្រែជាបាស ។ សូលុយស្យុងដែលមានកំហាប់ [$OH^-$] = $1.0 \times 10^{-4}$mol/L នៅ 25°C ជាសូលុយស្យុងបាស ព្រោះ $1.0 \times 10^{-4}$ ធំជាង $1.0 \times 10^{-7}$ ។

# 2. មាត្រដ្ឋាន pH

## 2.1. និយមន័យ pH

លក្ខណៈអាស៊ីត ឬបាសរបស់សូលុយស្យុងមួយ អាស្រ័យនិងកំហាប់នៃអ៊ីយ៉ុង[ $H_3O^+$ ] ក្នុងសូលុយស្យុង ។ កំហាប់នេះប្រែប្រួលពីប៉ុន្មាន mol $L^{-1}$ ចំពោះសូលុយស្យុងអាស៊ីតខ្លាំងទៅ $10^{-14}$ ឬ

$10^{-15}$mol $L^{-1}$ ចំពោះសូលុយស្យុងបាសខ្លាំង ។ ប៉ុន្តែគេកម្រិតកំហាប់នៃអ៊ីយ៉ុង [ $H_3O^+$ ] នៅចន្លោះ : $1.0 \times 10^{-14}$mol $L^{-1} \leq [ H_3O^+ ] \leq 1.0$ mol $L^{-1}$ ។ យើងឃើញថា កំហាប់ $10^{-14}$mol $L^{-1}$ តូចណាស់បើធៀបទៅនឹងកំហាប់ 1.0 mol $L^{-1}$ (តូចជាង $10^7$ កោដិដង) ហេតុនេះហើយទើបគេនិយមប្រើទំហំ pH ។ នៅឆ្នាំ1909 គីមីវិទូជនជាតិដាណឺម៉ាកឈ្មោះលោក ***សូរ៉េន សូរ៉េនសែន*** (Soren Sorensen) បានស្នើឱ្យប្រើខ្នាតមួយឈ្មោះថា " pH " ។ pH មកពីពាក្យបារាំង " Potentield' hydrogène " មានន័យថា " សក្តានុពលអ៊ីដ្រូសែន " ។

- " pH នៃសូលុយស្យុងរាវជាទំហំផ្ទុយនឹងឡូការីតគោលដប់នៃកំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូម [ $H_3O^+$ ] របស់សូលុយស្យុង " (កំហាប់គិតជា mol $L^{-1}$ ) ។

  តាងដោយ : $pH = -\log[ H_3O^+ ]$

ដោយកំហាប់អ៊ីយ៉ុង [ $H_3O^+$ ] មានតម្លៃតូចពេក ជាទូទៅគេបញ្ជាក់វាក្រោមទម្រង់ជាស្វ័យគុណគត់និងអវិជ្ជមាននៃ 10 ។ ***ឧទាហរណ៍ :*** $10^{-3}$ , $10^{-5}$ ឬ $10^{-8}$mol $L^{-1}$ ។

បើកំហាប់ [ $H_3O^+$ ] = $1.0 \times 10^{-n}$mol $L^{-1}$ គេថា pH នៃសូលុយស្យុងស្មើ n (pH = n) ។

***ឧទាហរណ៍ :*** $[ H_3O^+ ] = 1.0 \times 10^{-3}$mol $L^{-1} \Rightarrow pH = 3.0$

$[ H_3O^+ ] = 1.0 \times 10^{-5}$mol $L^{-1} \Rightarrow pH = 5.0$

គេបាន : $[ H_3O^+ ] = 10^{-pH}$mol $L^{-1}$ ឬ $pH = -\log[ H_3O^+ ]$

pH ជាទំហំដែលគ្មានខ្នាត ។

- សូលុយស្យុងណឺតមួយនៅ 25°C មានកំហាប់អ៊ីយ៉ុង [ $H_3O^+$ ] , $1 \times 10^{-7}$M ។ ឡូការីតនៃ $1 \times 10^{-7}$ គឺ –7.0 ។

  តម្លៃ pH អាចកំណត់ :

  $pH = -\log[ H_3O^+ ] = -\log(1 \times 10^{-7}) = -(-7.0) = 7.0$




***រូបទី 3.3 ទំនាក់ទំនងរវាង pHនិងកំហាប់អ៊ីយ៉ុង [ $H_3O^+$ ]***

### ក. លក្ខណៈនៃទំហំ pH

- ទំហំ pH និងកំហាប់អ៊ីយ៉ុង [ $H_3O^+$ ] ប្រែប្រួលក្នុងទិសដៅផ្ទុយគ្នា (រូបទី 3.3) ។

  បើ pH ធំ ⇔ កំហាប់ [ $H_3O^+$ ] តូច

  បើ pH តូច ⇔ កំហាប់ [ $H_3O^+$ ] ធំ

- នៅគ្រប់ពេលដែលកំហាប់នៃអ៊ីយ៉ុង [ $H_3O^+$ ] ចែកនឹង 10 នោះ តម្លៃ pH ត្រូវកើន 1 ឯកតា ។

### ខ. មជ្ឈដ្ឋាននៃសូលុយស្យុង

គេកំណត់ភាពណឺត ភាពអាស៊ីត ភាពបាសនៃសូលុយស្យុងមួយតាមតម្លៃ pH របស់វា ។ នៅសីតុណភាព 25°C :

- មជ្ឈដ្ឋានណឺត pH = 7.0 : pH = 7.0 ⇔ [ $H_3O^+$ ] = $1.0 \times 10^{-7}$ mol L$^{-1}$.
- មជ្ឈដ្ឋានអាស៊ីត pH < 7.0 : pH < 7.0 ⇔ [ $H_3O^+$ ] > $1.0 \times 10^{-7}$ mol L$^{-1}$
- មជ្ឈដ្ឋានបាស pH > 7.0 : pH > 7.0 ⇔ [ $H_3O^+$ ] < $1.0 \times 10^{-7}$ mol L$^{-1}$




*រូបទី 3.4 សូលុយស្យុងអាស៊ីត បាស និងសូលុយស្យុងណឺត : pH និង [ $H_3O^+$ ] នៅ 25°C*

ដូចគ្នាដែរ " pOH នៃសូលុយស្យុងមួយគឺជាទំហំផ្ទុយនឹងឡូការីតនៃកំហាប់អ៊ីយ៉ុងអ៊ីដ្រុកស៊ីត [$OH^-$] " ។

តាងដោយ : $pOH = -\log[OH^-]$

សូលុយស្យុងណឺតមួយនៅសីតុណ្ហភាព 25°C មានកំហាប់ [ $OH^-$ ] , $1.0 \times 10^{-7}$M ដូច្នេះ pOH = 7.0 ។ យើងបានដឹងហើយថា តម្លៃ [ $H_3O^+$ ] និង [ $OH^-$ ] ទាក់ទងទៅនឹង $K_w$ ។ ឡូការីតផ្ទុយនៃ $K_w$ នៅសីតុណ្ហភាព 25°C : $1.0 \times 10^{-14}$ គឺស្មើនឹង 14.0 ។

$$pH + pOH = 14.0$$

តារាងទី 3.3 : តម្លៃ pH របស់សារធាតុមួយចំនួន (នៅ $25°C$)

| សារធាតុ | pH | សារធាតុ | pH |
|---|---|---|---|
| ទឹកក្រពះ | 1.0 – 3.0 | ទឹកនោម | 4.8 – 7.5 |
| ទឹកក្រូចឆ្មារ | 1.8 – 2.4 | ទឹកទុកហាលខ្យល់ | 5.5 |
| ទឹកខ្មេះ | 2.4 – 3.4 | ទឹកមាត់ | 6.4 – 6.9 |
| ទឹកផ្លែប៉ោម | 2.9 – 3.3 | ទឹកដោះគោ | 6.3 – 6.6 |
| ទឹកក្រូច | 3.0 – 4.0 | ទឹកបរិសុទ្ធ | 7.0 |
| ទឹកប៉េងប៉ោះ | 4.0 – 4.4 | ឈាម | 7.3 – 7.5 |
| ទឹកចេក | 4.5 – 5.7 | ទឹកភ្នែក | 7.4 |
| | | ទឹកអាម្មូញ៉ាក់ប្រើក្នុងផ្ទះ | 11.5 |

- បើកំហាប់ [ $H_3O^+$ ] ក្នុងសូលុយស្យុងធំជាងកំហាប់ [ $OH^-$ ] នោះសូលុយស្យុងជាអាស៊ីត ។

***ឧទាហរណ៍ :*** pH របស់សូលុយស្យុងអាស៊ីតមួយនៅ $25°C$ [ $H_3O^+$ ] : $1 \times 10^{-6}M$ គឺស្មើ 6.0 ។

$pH = -\log[H_3O^+] = -\log(1 \times 10^{-6}) = -(-6.0) = 6.0$

pH របស់សូលុយស្យុងនេះតូចជាង 7 ដូចនេះវាជាសូលុយស្យុងអាស៊ីត ។

$pOH = 14.0 - pH = 14.0 - 6.0 = 8.0$

តាមការគណនាតម្លៃ pOH ធំជាង 7.0 សូលុយស្យុងនេះពិតជាអាស៊ីត ។

តាមការគណនាស្រដៀងគ្នានេះ បានបង្ហាញថា pH របស់សូលុយស្យុងបាសនៅសីតុណ្ហភាព $25°C$ ធំជាង 7.0 ហើយតម្លៃ pOH តូចជាង 7.0 ។

តារាងទី 3.4 : $[H_3O^+]$ , $[OH^-]$ , pH និង pOH របស់សូលុយស្យុង

| សូលុយស្យុង | លក្ខខណ្ឌធម្មតា | នៅសីតុណ្ហភាព 25°C |
|---|---|---|
| ណឺត | $[H_3O^+] = [OH^-]$<br>pH = pOH | $[H_3O^+] = [OH^-] = 1 \times 10^{-7}M$<br>pH = pOH = 7.0 |
| អាស៊ីត | $[H_3O^+] > [OH^-]$<br>pH < pOH | $[H_3O^+] > 1 \times 10^{-7}M$<br>$[OH^-] < 1 \times 10^{-7}M$<br>pH < 7.0<br>pOH > 7.0 |
| បាស | $[H_3O^+] < [OH^-]$<br>pH > pOH | $[H_3O^+] < 1 \times 10^{-7}M$<br>$[OH^-] > 1 \times 10^{-7}M$<br>pH > 7.0<br>pOH < 7.0 |

កាលណាសីតុណ្ហភាពប្រែប្រួល តម្លៃពិតនិងប្រែប្រួលដែរ ព្រោះតម្លៃ $K_w$ ប្រែប្រួល តែទំនាក់ទំនង $pH + pOH = pK_w$ នៅរក្សាដដែល ។

គ. រង្វាស់ pH

មានវិធីពីរយ៉ាងសម្រាប់វាស់ pH ។ វិធីទីមួយ គឺការកំណត់ pH ដោយប្រើអង្គធាតុចង្អុលពណ៌ ឬក្រដាសចង្អុល pH ។ វិធីនេះរហ័ស ហើយងាយស្រួល ប៉ុន្តែផ្តល់លទ្ធផលមិនជាក់លាក់ ។ វិធីទីពីរ គឺប្រើឧបករណ៍ម្យ៉ាងហៅថា **pH ម៉ែត្រ** ។ ឧបករណ៍នេះ ផ្តល់លទ្ធផលជាក់លាក់ ប៉ុន្តែស្មុគស្មាញហើយមានតម្លៃថ្លៃ ។

- ***អង្គធាតុចង្អុលពណ៌***

ការកំណត់ pH ដោយប្រើអង្គធាតុចង្អុលពណ៌ ឬក្រដាសចង្អុល pH ។ អង្គធាតុចង្អុលពណ៌ជាសារធាតុសរីរាង្គ ដែលពណ៌របស់វាអាស្រ័យនិង pH ។ បម្រែបម្រួលពណ៌របស់វាកើតមាននៅក្នុងចន្លោះប្រហែល 2 ឯកតា pH ដែលហៅថា **តំបន់ប្រែពណ៌** ។ ដោយសារចង្អុលពណ៌នេះអាចឱ្យគេកំណត់តម្លៃប្រហែលនៃ pH របស់សូលុយស្យុងបាន ។ តារាងខាងក្រោមនេះបង្ហាញពីតំបន់ប្រែពណ៌និងពណ៌ក្នុងមជ្ឈដ្ឋានអាស៊ីតនិងបាសនៃអង្គធាតុចង្អុលពណ៌បី

តារាងទី 3.5 : ពណ៌របស់អង្គធាតុចង្អុលពណ៌ខ្លះប្រើក្នុងអត្រាកម្ម

| អង្គធាតុចង្អុលពណ៌ | តំបន់ប្រែពណ៌ | ពណ៌អាស៊ីត | ពណ៌បាស |
|---|---|---|---|
| អេល្យង់ទីន | 3.1 – 4.4 | ក្រហម | លឿង |
| ប្រូម៉ូទីម៉ុលខៀវ | 6.0 – 7.6 | លឿង | ខៀវ |
| ផេណុលផ្តាលេអ៊ីន | 8.2 – 10.0 | គ្មានពណ៌ | ក្លូឡាប |

ក្រដាសចង្អុល pH (ឬក្រដាស pH ) ជាក្រដាសដែលត្រាំដោយល្បាយនៃអង្គធាតុចង្អុលពណ៌ជាច្រើនរួចសំងួត ។ វាមានទម្រង់ជាបន្ទះទ្រវែង ឬជារមូរ ។ បើគេបន្តក់សូលុយស្យុងអាស៊ីត ឬបាសលើក្រដាស pH គេនឹងទទួលបានពណ៌ដែលអាចឱ្យគេកំណត់តម្លៃ pH បាន ។

- ***ការកំណត់ pH តាម pH ម៉ែត្រ***

pH ម៉ែត្រ ជាឧបករណ៍ដែលគេប្រើសម្រាប់កំណត់តម្លៃ pH របស់សូលុយស្យុងមួយបានជាក់លាក់ជាងអង្គធាតុចង្អុលពណ៌ ឬក្រដាស pH ។ វាជាមីលីវ៉ុលម៉ែត្រអេឡិចត្រូនិចដែលភ្ជាប់ដោយអេឡិចត្រូតពីរ ពេលត្រាំអេឡិចត្រូតនេះទៅក្នុងសូលុយស្យុង គេទទួលបានតម្លៃ pH ។



***រូបទី3.5 ឧបករណ៍ pHម៉ែត្រ***

# 3. ការគណនាទាក់ទងនឹង pH

## 3.1. គណនា pH ពី[ $H_3O^+$ ]

គេអាចគណនាតម្លៃ pH បានតាមសមីការ : $pH = -\log[H_3O^+]$ ។ កាលណាកំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូមកើននោះតម្លៃ pH ថយចុះ ។ សូលុយស្យុងដែលមានតម្លៃ pH = 0 គឺជាអាស៊ីតខ្លាំង សូលុយស្យុងមានតម្លៃ pH = 14 ជាបាសនិង pH = 7 ជាសូលុយស្យុងណឺត ។ សមីការខាងលើអាចសរសេរជា $[H_3O^+] = 10^{-pH}$ ដើម្បីគណនាកំហាប់អ៊ីយ៉ុង[ $H_3O^+$ ] ពី pH ។

បើតម្លៃ pH ជាលេខគត់ យើងអាចគណនាបានដោយងាយ ។ ***ឧទាហរណ៍*** : សូលុយស្យុងមួយមាន pH ស្មើនឹង 3 វាមានកំហាប់[ $H_3O^+$ ] ស្មើនឹង $10^{-3}$M ឬ 0.001M ។

***លំហាត់គំរូ :*** គណនា pH របស់សូលុយស្យុងអាស៊ីត ឬបាស រក pH នៃ :

ក. សូលុយស្យុងអាស៊ីត $HNO_3$ ដែលមានកំហាប់ 0.00010M ។

ខ. សូលុយស្យុងបាស KOH ដែលមានកំហាប់ 0.0136M

***ចម្លើយ :***

ដោយ $HNO_3$ និង KOH ជាអេឡិចត្រូលីតខ្លាំង វាបំបែកជាអ៊ីយ៉ុងទាំងស្រុងក្នុងសូលុយស្យុង ។

ចំពោះសូលុយស្យុង $HNO_3$ : $[H_3O^+] = 1.0 \times 10^{-4}M$

ចំពោះសូលុយស្យុង KOH : $[OH^-] = 1.36 \times 10^{-2}M$

ក. តាមសមីការ : $pH = -\log[H_3O^+]$

$$pH = -\log(1.0 \times 10^{-4}) = -(-4.00) = 4.00$$

$$\boxed{= 4.00}$$

ខ. តាមសមីការ : $K_w = [H_3O^+][OH^-] \Rightarrow [H_3O^+] = \dfrac{K_w}{[OH^-]}$

$$[H_3O^+] = \frac{1.0 \times 10^{-14}}{1.36 \times 10^{-2}} = 7.35 \times 10^{-13}$$

$$pH = -\log[H_3O^+] = -\log(7.35 \times 10^{-13}) = 13 - \log(7.35)$$

$$\boxed{= 12.13}$$

**លំហាត់អនុវត្តន៍**

1. គណនា pH របស់សូលុយស្យុងមួយបើ $[H_3O^+] = 5.0 \times 10^{-3}M$ ។
2. គណនា pH របស់សូលុយស្យុងមួយបើ $[OH^-] = 2.0 \times 10^{-3}M$ ។
3. គណនា pH របស់សូលុយស្យុង NaOH នៅកំហាប់ $1.0 \times 10^{-3}M$ ។

ក្នុងលំហាត់ភាគច្រើន កំហាប់អ៊ីយ៉ុង $[H_3O^+]$ មិនមានតម្លៃលេខគត់ទេ ។ ដូច្នេះគេត្រូវប្រើម៉ាស៊ីនគិតលេខ ដើម្បីគណនា ។

***ឧទាហរណ៍ :*** កំហាប់ $[H_3O^+]$ របស់សូលុយស្យុងមួយមាន $3.4 \times 10^{-5}M$ ដោយ $3.4 \times 10^{-5}M$ នៅចន្លោះ $10^{-4}$ និង $10^{-5}$ , pH របស់សូលុយស្យុងត្រូវនៅចន្លោះ 4 និង 5 ។

***លំហាត់គំរូ :*** គណនា pH របស់សូលុយស្យុងមួយដែលមាន [ $H_3O^+$ ] = $3.4 \times 10^{-5}$M ។

***ចម្លើយ :***

តាមសមីការ : $pH = -\log[H_3O^+]$

$pH = -\log(3.4 \times 10^{-5}) = 5 - \log(3.4)$

$= 4.47$

របៀបប្រើម៉ាស៊ីនគិតលេខក្នុងការគណនាតម្លៃ pH ខាងលើ :

[3] [·] [4] [log] = 0.53 ⇒ 5 − 0.53 = 4.47 ។

***លំហាត់គំរូ :*** សូលុយស្យុងមួយមាន pH = 7.52 ។ គណនា :

ក. កំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូម

ខ. កំហាប់អ៊ីយ៉ុងអ៊ីដ្រុកស៊ីត

គ. តើវាជាសូលុយស្យុងអាស៊ីត ឬសូលុយស្យុងបាស ?

***ចម្លើយ :***

ក. រកកំហាប់អ៊ីយ៉ុង [ $H_3O^+$ ]

តាមសមីការ : $pH = -\log[H_3O^+]$

$\Rightarrow = \log[H_3O^+] = -pH$

[ $H_3O^+$ ] = ចម្រាសលោការីត (−pH) = ចម្រាសលោការីត (−7.52)

$[H_3O^+] = 1.0 \times 10^{-7.52}$

$= 3.0 \times 10^{-8}$M

គណនាដោយម៉ាស៊ីនគិតលេខវិទ្យាសាស្ត្រ

[7] [·] [5] [2] [+ /−] [2nd] [$10^x$] ឬ [7] [·] [5] [2] [+ /−] [2nd] [Log]

ខ. រកកំហាប់អ៊ីយ៉ុង [$OH^-$ ]

តាមសមីការ : $K_w = [H_3O^+][OH^-] = 1.0 \times 10^{-14}$

យើងបាន $[H_3O^+][OH^-] = 1.0 \times 10^{-14}$

$$\Rightarrow [OH^-] = \frac{1.0 \times 10^{-14}}{[H_3O^+]}$$

$$[OH^-] = \frac{1.0 \times 10^{-14}}{3.0 \times 10^{-8}} = 3.3 \times 10^{-7}M$$

គ. ដោយ pH = 7.52 ធំជាង pH = 7 មានន័យថា សូលុយស្យុងនេះ ជាសូលុយស្យុងបាស ។

យំហាត់អនុវត្តន៍

1. ទឹកសំអាតកញ្ចក់នៅទីផ្សារមាន pH = 11.7 ។ គណនាកំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូមរបស់សូលុយស្យុងនោះ ។
2. គណនាតម្លៃ pH របស់សូលុយស្យុងមួយដែលមានកំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូមស្មើនឹង $2.5 \times 10^{-2}M$ ។
3. សូលុយស្យុងមួយមាន pH = 3.67 ។ គណនាតម្លៃកំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូម $[H_3O^+]$ របស់សូលុយស្យុងនោះ ។

## 3.2. ការគណនា pH និងកម្លាំងអាស៊ីត-បាស

យើងបានសិក្សារួចហើយពី pH របស់សូលុយស្យុងអាស៊ីតខ្លាំងនិងបាសខ្លាំង ។ ការសិក្សានេះមិនទាន់គ្រប់គ្រាន់ទេ យើងត្រូវពិនិត្យទៅលើអាស៊ីតខ្សោយ បាសខ្សោយ(ដូចតារាងទី3.6) ។

តារាងទី 3.6 : ទំនាក់ទំនងនៃ $[H_3O^+]$ , $[OH^-]$ និង pH (នៅ 25°C)

| សូលុយស្យុង | $[H_3O^+]$ | $[OH^-]$ | pH |
|---|---|---|---|
| KOH $1.0 \times 10^{-2}M$ | $1.0 \times 10^{-12}$ | $1.0 \times 10^{-2}$ | 12.00 |
| $NH_3$ 1.0M | $2.4 \times 10^{-11}$ | $4.2 \times 10^{-4}$ | 10.63 |
| ទឹកសុទ្ធ | $1.0 \times 10^{-7}$ | $1.0 \times 10^{-7}$ | 7.00 |
| HCl $1.0 \times 10^{-3}M$ | $1.0 \times 10^{-3}$ | $1.0 \times 10^{-11}$ | 3.00 |
| $CH_3COOH$ $1.0 \times 10^{-1}M$ | $1.3 \times 10^{-3}$ | $7.5 \times 10^{-12}$ | 2.87 |

- សូលុយស្យុង KOH ជាសមាសធាតុអ៊ីយ៉ុងរលាយហើយជាបាសខ្លាំង ។ កំហាប់ជាម៉ូលេគុលក្រាមរបស់សូលុយស្យុង KOH អាចឱ្យយើងគណនាកំហាប់ $[OH^-]$ និង $[H_3O^+]$ បានដោយផ្ទាល់តែម្តង ។

• អាស៊ីតក្លរីឌ្រិច ជាអាស៊ីតខ្លាំងក៏អាចគណនា [ $H_3O^+$ ] និង [ $OH^-$ ] បានដូចគ្នាដែរ ។ ចំពោះអាស៊ីតខ្សោយ ដូចជាអាស៊ីតអាសេទិច $CH_3COOH$ កំហាប់ [ $H_3O^+$ ] មិនអាចគណនាដោយផ្ទាល់ពីកំហាប់ជាម៉ូលរបស់វាបានទេ ព្រោះម៉ូលេគុលវាមិនបំបែកជាអ៊ីយ៉ុងទាំងអស់ទេ ។ ក៏ដូចគ្នាដែរចំពោះបាសខ្សោយ ។ ហើយ pH របស់សូលុយស្យុងទាំងនេះអាចវាស់បានតាមការពិសោធ ។ បន្ទាប់មកកំហាប់ [ $H_3O^+$ ] និង [ $OH^-$ ] អាចគណនាបានពីតម្លៃនៃរង្វាស់ pH ។

## មេរៀនសង្ខេប

- ផលគុណ [ $H_3O^+$ ]·[ $OH^-$ ] ហៅថា ផលគុណអ៊ីយ៉ុងរបស់ទឹក

  តាងដោយ $K_c$ ឬ $K_w = [H_3O^+] \cdot [OH^-] = 1.0 \times 10^{-14}$ ។
- សូលុយស្យុងអាស៊ីតមាន $[H_3O^+] > 10^{-7}M > [OH^-]$ ។
- សូលុយស្យុងបាសមាន $[H_3O^+] < 10^{-7}M < [OH^-]$ ។
- សូលុយស្យុងណឺតមាន $[H_3O^+] = 10^{-7}M = [OH^-]$ ។
- pH នៃសូលុយស្យុងរាវ ជាទំហំផ្ទុយនឹងលោការីតគោលដប់នៃកំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូមរបស់សូលុយស្យុងនោះ (គិតជា $mol \cdot L^{-1}$ )

  $pH = -\log[H_3O^+]$ (pH ជាទំហំគ្មានខ្នាត) ។
- pOH នៃសូលុយស្យុង ជាទំហំផ្ទុយនឹងលោការីតនៃកំហាប់ [ $OH^-$ ] : $pOH = -\log[OH^-]$ ។
- គេកំណត់ pH ដោយប្រើអង្គធាតុចង្អុលពណ៌ ឬក្រដាស pH និង pH ម៉ែត្រ ។

## ? សំណួរនិងលំហាត់

1. ដូចម្ដេចហៅថា ស្វ័យអ៊ីយ៉ុងកម្មនៃទឹក ។
2. ដូចម្ដេចហៅថា ផលគុណអ៊ីយ៉ុងនៃទឹក ។ តាងដោយនិមិត្តសញ្ញាអ្វី ?
3. តើគេប្រើ pH សម្រាប់វាស់អ្វី ? ឱ្យនិយមន័យ pH ។
4. ដូចម្ដេចហៅថា សូលុយស្យុងណឺត ? វាមាន pH ស្មើប៉ុន្មាន ?
5. ចូរឱ្យសមីការសម្រាប់គណនាតម្លៃ pH ។
6. ចូរឱ្យនិយមន័យ pOH ។ សរសេរសមីការដែលទាក់ទងនឹង pH និង pOH ។
7. តើមានវិធីប៉ុន្មានយ៉ាងសម្រាប់វាស់ pH របស់សូលុយស្យុង ?
8. គណនាកំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូមរបស់សូលុយស្យុងមួយ ដែលមានកំហាប់អ៊ីយ៉ុងអ៊ីដ្រុកស៊ីត $2.80 \times 10^{-9}M$ ។
9. សូលុយស្យុងមួយមាន pH ស្មើនឹង 1.50 ។ គណនាកំហាប់របស់អ៊ីយ៉ុង$[H_3O^+]$ និង$[OH^-]$ ។
10. គណនា pH របស់សូលុយស្យុង $Ba(OH)_2$ នៅកំហាប់ 0.0020M ។
11. រកតម្លៃ pH និង pOH នៃសូលុយស្យុង HCl នៅ 0.050M ។
12. សូលុយស្យុងមួយមាន pH = 3.60 ។ រកកំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូមរបស់សូលុយស្យុងនេះ ។
13. សូលុយស្យុងអាស៊ីត HCl មួយមានកំហាប់ $4.5 \times 10^{-3}M$ ។

    ចូរគណនា :

    ក. កំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូម $[H_3O^+]$

    ខ. កំហាប់អ៊ីយ៉ុង $[OH^-]$

    គ. pH របស់សូលុយស្យុង ។

មេរៀនទី

# 4 អត្រាកម្មអាស៊ីត–បាស

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាពីលក្ខខណ្ឌនៅចំណុចសមមូលក្នុងអត្រាកម្ម ។
- ពន្យល់ពីរបៀបជ្រើសរើសអង្គធាតុចង្អុលពណ៌ក្នុងអត្រាកម្ម ។
- ពណ៌នាពីរបៀបធ្វើអត្រាកម្មនិងធ្វើពិសោធន៍អត្រាកម្ម ។
- គណនាកំហាប់ជាម៉ូលរបស់សូលុយស្យុងពីទិន្នន័យអត្រាកម្ម ។

## 1. អត្រាកម្ម

យើងបានដឹងហើយថា ប្រតិកម្មបន្សាបកើតមានរវាងអាស៊ីតនិងបាសដែលក្នុងនោះអ៊ីយ៉ុងអ៊ីដ្រុកស៊ីត ($OH^-$) ទទួលយកប្រូតុងពីអ៊ីយ៉ុងអ៊ីដ្រូញ៉ូម ($H_3O^+$) បង្កើតបានពីរម៉ូលេគុលទឹក ។សមីការតាងប្រតិកម្ម :

$$H_3O^+(aq) + OH^-(aq) \longrightarrow 2H_2O(\ell)$$

តាមសមីការបង្ហាញថាមួយម៉ូលអ៊ីយ៉ុងអ៊ីដ្រូញ៉ូម និងមួយម៉ូលអ៊ីយ៉ុងអ៊ីដ្រុកស៊ីតមានចំនួនធាតុគីមីស្មើគ្នា និងផ្សំគ្នាតាមសមមាត្រ 1:1 ម៉ូល ។ ការបន្សាបកើតមានឡើងនៅពេលដែលអ៊ីយ៉ុងអ៊ីដ្រូញ៉ូមនិងអ៊ីយ៉ុងអ៊ីដ្រុកស៊ីតដែលផ្តល់ឱ្យដោយអង្គធាតុប្រតិករមានចំនួនស្មើគ្នា (រូបទី 4.1) ។



*រូបទី 4.1 ប្រតិកម្មបន្សាបរវាងសូលុយស្យុងអាស៊ីត អាស៊ីត HCl និងបាស NaOH*

សូលុយស្យុងខាងឆ្វេង(រូបទី 4.1)ប្រែពណ៌ក្រដាស pH ជាក្រហម ព្រោះវាជាអាស៊ីតសូលុយស្យុងខាងស្តាំប្រែពណ៌ក្រដាស pH ជាខៀវ ព្រោះវាជាបាស ។ ពេលដែលអ៊ីយ៉ុង ($H_3O^+$) និង ($OH^-$) បានពីប្រតិកម្មសូលុយស្យុងអាស៊ីត–បាសមានចំនួនស្មើគ្នាគេបានសូលុយស្យុងណឺតប្រែពណ៌ក្រដាស pH ជាបៃតង ។ សូលុយស្យុង HCl 1L នៅកំហាប់ 0.10M មានផ្ទុកអ៊ីយ៉ុងអ៊ីដ្រូញ៉ូម 0.10mol ។ យើងសន្មតថាបើដាក់ក្រោម NaOH 0.10mol ក្នុង

1L សូលុយស្យុង HCl នៅ 0.10M នោះ NaOH រលាយហើយផ្តល់អ៊ីយ៉ុង $OH^-$ 0.10mol ក្នុងសូលុយស្យុង ។ ដូច្នេះ HCl និង NaOH មានចំនួនជាតុគីមីស្មើគ្នា ។ អ៊ីយ៉ុងអ៊ីដ្រូញ៉ូមនិងអ៊ីយ៉ុងអ៊ីដ្រុកស៊ីតមានចំនួនស្មើគ្នារហូតដល់ផលិតផល $[H_3O^+] \times [OH^-]$ ត្រឡប់ទៅតម្លៃ $1.0 \times 10^{-14}$ ។ អំបិល NaCl ដែលកកើតក្នុងប្រតិកម្ម ជាលទ្ធផលនៃការបន្សាបអាស៊ីតខ្លាំងនិងបាសខ្លាំង ។ លទ្ធផលដែលទទួលបានគឺសូលុយស្យុងណឺត ។

អត្រាកម្ម (ឬអត្រាមាត្រ) អាស៊ីត-បាស ជាលំនាំ ឬបច្ចេកទេសដែលគេប្រើនៅទីពិសោធន៍ដើម្បីកំណត់កំហាប់របស់សូលុយស្យុងអាស៊ីត ឬបាសដែលមិនស្គាល់កំហាប់ ។

សូលុយស្យុងដែលគេស្គាល់កំហាប់ហៅថា " សូលុយស្យុងស្តង់ដា " ។

## 2. ចំណុចសមមូល

ចំណុចដែលសូលុយស្យុងពីរ មានចំនួនជាតុគីមីរលាយចូលគ្នាក្នុងសមាមាត្រស្មើគ្នា (ឬសមាមាត្រស្មើស្តូមេទ្រី)ហៅថា " ចំណុចសមមូល " ។ គេប្រើអង្គធាតុចង្អុលពណ៌និង pH ម៉ែត្រ ដើម្បីកំណត់ចំណុចសមមូល ។ ក្នុងអត្រាកម្ម ចំណុចដែលអង្គធាតុចង្អុលពណ៌ប្រែពណ៌ហៅថា " ចំណុចបញ្ចប់ " របស់អង្គធាតុចង្អុលពណ៌ ។ គេប្រើអង្គធាតុចង្អុលពណ៌ជាសញ្ញាឱ្យយើងដឹងពេលសូលុយស្យុងស្តង់ដាដែលមានបរិមាណគ្រប់គ្រាន់សម្រាប់បន្សាបសូលុយស្យុងមិនស្គាល់កំហាប់ ។

យើងបានទំនាក់ទំនង : $C_A V_A = C_B V_B$

តាមទំនាក់ទំនងនេះ យើងអាចគណនាកំហាប់ $C_A$ នៃសូលុយស្យុងអាស៊ីតបាន បើយើងស្គាល់តម្លៃ $V_A$ , $C_B$ និង $V_B$ ។

## 3. ជម្រើសអង្គធាតុចង្អុលពណ៌

នៅទីពិសោធន៍សម្រាប់អត្រាកម្មអាស៊ីត-បាស គេប្រើអង្គធាតុចង្អុលពណ៌ជាសញ្ញាឱ្យយើងដឹងពេលដែលចំនួនសូលុយស្យុងស្តង់ដាដែលបានបន្ថែមដល់ចំណុចបញ្ចប់ ឬចំណុចសមមូល ។ អង្គធាតុចង្អុលពណ៌ខ្លះដូចជា ទឹកកំបោរប្តូរពណ៌នៅចំណុច pH ប្រហែល 7 តែតំបន់ប្រែពណ៌របស់វានៅចន្លោះ pH = 5.5 – 8.0 ។ គេច្រើនប្រើប្រូម៉ូទីម៉ុលខៀវ ព្រោះតំបន់ប្រែពណ៌របស់វានៅចន្លោះ pH = 6.2 – 7.6 (មើលតារាង 1) ។ គេប្រើអង្គធាតុចង្អុលពណ៌ ដែលមានតំបន់ប្រែពណ៌ pH ប្រហែល 7 ដើម្បីកំណត់ចំណុចសមមូលរបស់ អាស៊ីតខ្លាំង / បាសខ្លាំង ព្រោះប្រតិកម្មបន្សាបអាស៊ីតខ្លាំងជាមួយបាសខ្លាំងឱ្យផលជាសូលុយស្យុងអំបិលដែលមាន pH = 7 ។

តារាងទី 4.1 : ការផ្លាស់ប្តូរតម្លៃរបស់អង្គធាតុចង្អុលពណ៌ខ្លះ

| ឈ្មោះអង្គធាតុចង្អុលពណ៌ | ពណ៌អាស៊ីត | តំបន់ប្រែពណ៌ (pH) | ពណ៌បាស |
|---|---|---|---|
| ទីម៉ុលខៀវ ( បម្រែពណ៌ទី 1 ) | ក្រហម | 1.2 – 2.8 | លឿង |
| មេទីលពណ៌ទឹកក្រូច | ក្រហម | 3.1 – 4.4 | លឿង |
| ខូណីសុល | ក្រហម | 5.0 – 8.0 | ខៀវ |
| ប្រូម៉ូទីម៉ុលខៀវ | លឿង | 6.2 – 7.6 | ខៀវ |
| ទីម៉ុលខៀវ ( បម្រែពណ៌ទី 2 ) | លឿង | 8.0 – 9.6 | ខៀវ |
| ផេណុលផ្តាលេអ៊ីន | គ្មានពណ៌ | 8.0 – 9.6 | កូឡាប |
| អាលីហ្សារីនលឿង | លឿង | 10.1 – 12.0 | ក្រហម |

ចំណែកអង្គធាតុចង្អុលពណ៌ ដែលប្តូរពណ៌នៅចំណុច pH ទាបជាង 7 ប្រើដើម្បីកំណត់ចំណុចសមមូលក្នុងអត្រាកម្ម **អាស៊ីតខ្លាំង/បាសខ្សោយ** ។ ***ឧទាហរណ៍*** មេទីលពណ៌ទឹកក្រូច ។ ចំណុចសមមូលរបស់អត្រាកម្មអាស៊ីតខ្លាំង/ បាសខ្សោយ ជាអាស៊ីត ព្រោះអំបិលដែលកកើតជាអាស៊ីតខ្សោយ ។ ដូច្នេះសូលុយស្យុងអំបិលនេះមាន pH ទាបជាង 7 ។ ឯអង្គធាតុចង្អុលពណ៌ដែលប្តូរពណ៌ពេល pH ខ្ពស់ជាង 7 ប្រើសម្រាប់កំណត់ចំណុចសមមូលរបស់អត្រាកម្ម **អាស៊ីតខ្សោយ/បាសខ្លាំង** ។ ***ឧទាហរណ៍*** ផេណុលផ្តាលេអ៊ីន ។ ប្រតិកម្មនេះបង្កើតសូលុយស្យុងអំបិលដែលមាន pH ធំជាង 7 ព្រោះអំបិលដែលកកើតជាបាសខ្សោយ ។ ការផ្លាស់ប្តូរពណ៌របស់អង្គធាតុចង្អុលពណ៌ជួយបានតិចតួចណាស់ក្នុងការកំណត់ ថាតើប្រតិកម្មរវាងអាស៊ីតនិងបាសសព្វ ឬគ្រប់គ្រាន់ ?

កាលណាគេបន្ថែមបាស pH ផ្លាស់ប្តូរពីតម្លៃទាបទៅតម្លៃខ្ពស់មួយ ។ ការផ្លាស់ប្តូរតម្លៃ pH ដំបូងកើតឡើងយឺតៗ បន្ទាប់មកលឿនរហូតដល់ចំណុចសមមូល ហើយបន្ទាប់មកទៀតយឺតម្តងទៀត កាលណាសូលុយស្យុងកាន់តែក្លាយជាបាស ។ ប្រភេទខ្សែកោង pH របស់អត្រាកម្ម អាស៊ីតខ្លាំង/ បាសខ្លាំង និងអាស៊ីតខ្សោយ/បាសខ្លាំង បង្ហាញដូចរូបទី 3.14 ។




*រូបទី 4.2 ខ្សែកោងអត្រាកម្មអាស៊ីត-បាស*

(ក) ពេលធ្វើអត្រាកម្ម HCl (អាស៊ីតខ្លាំង)នៅកំហាប់ 1.00M ចំនួន 50.0mL ជាមួយបាសខ្លាំង NaOH នៅកំហាប់ 1.00M នោះ ចំណុចសមមូលកើតនៅត្រង់ចំណុច pH 7.0 ។

(ខ) ពេលធ្វើអត្រាកម្ម $CH_3COOH$ (អាស៊ីតខ្សោយ)នៅកំហាប់ 1.00M ចំនួន 50.0mL ជាមួយបាសខ្លាំង NaOH នៅកំហាប់ 1.00M តម្លៃ pH ដំបូងខ្ពស់ ហើយចំណុចសមមូលកើតឡើងនៅ pH ខ្ពស់ជាង 7.00 ។

ឧបករណ៍ដែលចាំបាច់សម្រាប់ធ្វើអត្រាកម្ម :




(ក)



(ខ)




(គ)



(ឃ)


(ង)

*រូបទី 4.3*

(ក) ដបដាក់សូលុយស្យុងអាស៊ីតនិងបាស

(ខ) ពីប៉ែត (បំពង់បឺត)ដែលមានក្រិតមាឌច្បាស់លាស់

(គ) កែវអ៊ែរឡែនម៉ៃយឺ

(ឃ) ប៊ុយរ៉ែតដែលមានគំនូសក្រិតមាឌ

(ង)ដំឡើងឧបករណ៍សម្រាប់ធ្វើអត្រាកម្ម ។

## 4. គណនាអត្រាកម្ម

គោលបំណងរបស់អត្រាកម្ម គឺកំណត់កំហាប់ដើមរបស់សូលុយស្យុងក្នុងកែវអត្រាកម្មឬបរិមាណដើមរបស់អាស៊ីត ឬបាស ។ សមីការខាងក្រោមនេះ ទាក់ទងទៅនិងចំនួនម៉ូល n (ជាម៉ូល)របស់ធាតុរលាយទៅកំហាប់និងមាឌ ។

$\boxed{n = c \cdot V}$ c = កំហាប់ គិតជាម៉ូល/L V = មាឌ គិតជា L n = ចំនួនម៉ូល

នៅចំណុចសមមូលក្នុងអត្រាកម្មអាស៊ីតខ្លាំង បាសខ្លាំង ចំនួនអ៊ីយ៉ុងអ៊ីដ្រុកស៊ីតដែលបន្ថែមស្មើនិងចំនួនអ៊ីយ៉ុងអ៊ីដ្រូញ៉ូមដើម ។ ទំនាក់ទំនងនេះ តាងដោយ : $n_{H_3O^+} = n_{OH^-}$ ។

បើជំនួសចំនួនម៉ូលនីមួយៗនេះដោយទំនាក់ទំនងកំហាប់និងមាឌនៃផលិតផលយើងបាន :

$$\left(C_{H_3O^+}\right)\left(V_{H_3O^+}\right) = \left(C_{OH^-}\right)\left(V_{OH^-}\right) \quad \text{ឬ} \quad C_AV_A = C_BV_B$$

***លំហាត់គំរូ :*** សិស្សម្នាក់ធ្វើអត្រាកម្មសូលុយស្យុង HCl មិនស្គាល់កំហាប់ ចំនួន 40.00mL ជាមួយនិងសូលុយស្យុង NaOH កំហាប់ 0.5500M ។ មាឌសូលុយស្យុងបាសដែលត្រូវការចាំបាច់សម្រាប់ឱ្យដល់ចំណុចសមមូលមាន 24.64mL ។ រកកំហាប់ជាម៉ូលរបស់សូលុយស្យុង HCl ។

***ចម្លើយ ៖***

រកកំហាប់អ៊ីយ៉ុង $H_3O^+$ ក្នុងសូលុយស្យុង HCl

យើងដឹង $V_{H_3O^+} = 40.00mL = 0.04000L$

$V_{OH^-} = 24.64mL = 0.02464L$

$C_{OH^-} = 0.5500mol/L$ , $C_{H_3O^+} = ?$

តាមសមីការ នៅចំណុចសមមូល ៖

$C_AV_A = C_BV_B$ ឬ $\left(C_{H_3O^+}\right)\left(V_{H_3O^+}\right) = \left(C_{OH^-}\right)\left(V_{OH^-}\right)$

នាំឱ្យ $C_{H_3O^+} = \dfrac{(C_{OH^-})(V_{OH^-})}{V_{H_3O^+}}$

$= \dfrac{(0.5500mol/L)(0.02464L)}{0.04000L}$

$C_{H_3O^+} = 0.3388mol/L$ ។

## លំហាត់អនុវត្តន៍

1. គេប្រើសូលុយស្យុង HCl ចំនួន 20.6mL នៅកំហាប់ 0.010M ដើម្បីធ្វើអត្រាកម្មសូលុយស្យុង NaOH ចំនួន 30.0mL ។ រកចំនួនម៉ូលរបស់សូលុយស្យុង NaOH ដែលមាននៅចំណុចសមមូល ។
2. ដើម្បីបន្សាប 5.00L ភាគសំណាកភ្លៀងអាស៊ីតមួយគេត្រូវការ 11.3mL សូលុយស្យុង KOH នៅកំហាប់ 0.0102M ។ គណនាកំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូមរបស់ភាគសំណាកភ្លៀងអាស៊ីតនោះ ។

# ពិសោធន៍អត្រាកម្មអាស៊ីតខ្លាំង-បាសខ្លាំង

- វត្ថុបំណង : កំណត់កំហាប់របស់សូលុយស្យុងដែលមិនស្គាល់កំហាប់ ។
- ចំណេះដឹងមូលដ្ឋាន
  - ក្នុងអត្រាកម្ម សូលុយស្យុងដែលស្គាល់កំហាប់ច្បាស់លាស់ហៅថា " សូលុយស្យុងស្តង់ដា " ។ សូលុយស្យុងស្តង់ដាជាសូលុយស្យុងត្រូវបន្ថែមទៅលើសូលុយស្យុងដែលមិនស្គាល់កំហាប់រហូតដល់ប្រតិកម្មសព្វ ។ បើយើងស្គាល់មាឌនិងកំហាប់របស់សូលុយស្យុងស្តង់ដានិងមាឌរបស់សូលុយស្យុងដែលចូលរួមប្រតិកម្មក្នុងអត្រាកម្មនេះ យើងអាចរកកំហាប់របស់សូលុយស្យុងដែលយើងមិនស្គាល់កំហាប់នោះបាន ។
  - ក្នុងពិសោធន៍នេះ យើងនឹងកំណត់កំហាប់របស់សូលុយស្យុង NaOH ដែលយើងមិនស្គាល់ដោយប្រើសូលុយស្យុង HCl ដែលយើងស្គាល់កំហាប់ច្បាស់លាស់ ជាសូលុយស្យុងស្តង់ដា ។
  - សមីការតាងប្រតិកម្មនេះគឺ : $NaOH + HCl \longrightarrow NaCl + H_2O$
  - បើយើងប្រើមាឌនិងកំហាប់ HCl ជាក់លាក់ដើម្បីធ្វើ អត្រាកម្មលើ NaOH នោះ ចំណុចសមមូលរបស់វាគឺណឹត ។
  - តាមរយៈមាឌនិងកំហាប់ HCl ដែលធ្វើអត្រាកម្មលើ NaOH នៅ ចំណុចសមមូល យើងអាចគណនាកំហាប់របស់ NaOH ដែលយើងមិនស្គាល់បាន ។

  នៅចំណុចសមមូលយើងបាន : $C_AV_A = C_BV_B$

  $C_A$ : កំហាប់របស់ HCl (ស្គាល់)

  $C_B$ : កំហាប់របស់ NaOH (មិនស្គាល់)

  $V_A$ : មាឌរបស់ HCl (ស្គាល់)

  $V_B$ : មាឌរបស់ NaOH (ស្គាល់)

  - ចំណុចសមមូលនៃអត្រាកម្មនេះ ត្រូវបានស្គាល់ដោយអង្គធាតុចង្អុលពណ៌ផេណុលផ្តាលេអ៊ីន វាប្រែពីគ្មានពណ៌ទៅជាពណ៌ក្កូឡាបនៅចំណុចសមមូល ប៉ុន្តែនៅក្នុងពិសោធន៍នេះ យើងអាចប្រើទឹកស្ពៃក្តោបក្រហម វាប្រែពណ៌ពីបៃតងទៅជាពណ៌ក្រហម ។
- សំភារៈពិសោធន៍
  - កែវជ័រថ្លាចំនួនពីរ សឺរ៉ាំងចាក់ថ្នាំចំណុះ 20mL មួយ ជើងទម្រ

- ធាតុគីមីទឹកបិត
  - សូលុយស្យុងអាស៊ីត HCl (កំហាប់ 0.5M )
  - សូលុយស្យុងបាស NaOH
  - សូលុយស្យុងទឹកស្លែក្តោបក្រហម
- ដំណើរការពិសោធ
  - ចាក់សូលុយស្យុង NaOH ចំនួន 10mL ចូលទៅក្នុងកែវជ័រថ្លា ។
  - ចាក់សុលុយស្យុងទឹកស្លែក្តោបក្រហម 1mL ចូលទៅក្នុងកែវដាក់សូលុយស្យុង NaOH រួចកូរឱ្យសព្វ ។
  - បន្តក់សូលុយស្យុងអាស៊ីត HCl កំហាប់ 0.5M ចំនួន 20mL ចូលទៅក្នុងកែវដាក់សូលុយស្យុង NaOH មួយតំណក់ម្តងៗ រួចកូរឱ្យសព្វ ។
  - សង្កេតមើលពណ៌សូលុយស្យុង NaOH នៅពេលដែលបន្តក់សូលុយស្យុង HCl ចូល ។ បើសូលុយស្យុងនោះប្រែពណ៌ពីបៃតងទៅពណ៌ក្រហម យើងឈប់បន្តក់ HCl ភ្លាម ។



*រូបទី 4.4 អត្រាកម្មសូលុយស្យុង HCl*

  - ពិនិត្យមើលមាឌរបស់សូលុយស្យុង HCl និងកត់ត្រាចូលក្នុងតារាងលទ្ធផល ។
  - សូមធ្វើតាមលំនាំខាងលើនេះសម្រាប់ការសាកល្បងលើកទី 2 និងទី 3 ។
- លទ្ធផល

| សាកល្បងលើកទី | 1 | 2 | 3 |
|---|---|---|---|
| $V_{HCl(mL)}$<br>$C_M = 0.5M$ | | | |

- ពិភាក្សា

ក. គណនាមាឌមធ្យមរបស់សូលុយស្យុង HCl ដែលប្រើនៅក្នុងអត្រាកម្មនេះ ?

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

ខ. គណនាកំហាប់របស់សូលុយស្យុង NaOH ដែលធ្វើអត្រាកម្ម ?

. . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . . .

## មេរៀនសង្ខេប

- អត្រាកម្មជាលំនាំ ឬបច្ចេកទេសប្រើនៅទីពិសោធន៍ ដើម្បីកំណត់កំហាប់របស់សូលុយស្យុងអាស៊ីត ឬបាសដែលមិនស្គាល់កំហាប់ ។
- ចំណុចសមមូលជាចំណុចដែលសូលុយស្យុងពីរមានចំនួនធាតុគីមីរលាយចូលគ្នាក្នុងសមាមាត្រស្មើគ្នា ។
- គេប្រើអង្គធាតុចង្អុលពណ៌ជាសញ្ញាឱ្យយើងដឹងពីចំនួនសូលុយស្យុងស្តង់ដា ដែលបានបន្ថែមដល់ចំណុចបញ្ចប់ ឬចំណុចសមមូលហើយ ។
- ចំណែកថ្នាក់អត្រាកម្មអាស៊ីត-បាសមានបីប្រភេទ :
  - អត្រាកម្មអាស៊ីតខ្លាំងនិងបាសខ្លាំង
  - អត្រាកម្មអាស៊ីតខ្លាំងនិងបាសខ្សោយ
  - អត្រាកម្មអាស៊ីតខ្សោយនិងបាសខ្លាំង ។
- នៅចំណុចសមមូលបរិមាណអ៊ីយ៉ុង $OH^-$ ដែលដាក់ចូលស្មើនិងបរិមាណអ៊ីយ៉ុង $H_3O^+$ ដែលមាន យើងបានសមីការ : $C_AV_A = C_BV_B$

## សំណួរនិងលំហាត់

1. ដូចម្តេចដែលហៅថា អត្រាកម្ម ?
2. ចូរឱ្យនិយមន័យចំណុចសមមូល ។
3. នៅក្នុងដំណើរការអត្រាកម្ម តើអង្គធាតុចង្អុលពណ៌មានតួនាទីអ្វី ?
4. ដូចម្តេចហៅថា សូលុយស្យុងស្តង់ដា ?
5. តើយើងត្រូវជ្រើសរើសអង្គធាតុចង្អុលពណ៌អ្វី មកប្រើក្នុងអត្រាកម្មអាស៊ីតខ្លាំងនិងបាសខ្លាំង ?
6. តើទិន្នន័យអ្វីដែលគេត្រូវការដើម្បីគណនាកំហាប់របស់អាស៊ីតដែលគេមិនស្គាល់ ?
7. នៅចំណុចសមមូលក្នុងអត្រាកម្ម តើមានវត្ថុមានអ្វីក្នុងសូលុយស្យុង ?
8. គេដាក់ 29.5mL សូលុយស្យុង HCl 0.150M ឱ្យធ្វើប្រតិកម្មបន្សាបជាមួយសូលុយស្យុងបាស 25.0mL ។ ចូរគណនាកំហាប់របស់អ៊ីយ៉ុង $[OH^-]$ ដែលមានក្នុងសូលុយស្យុងបាសនោះ ។
9. រកមាឌអាស៊ីតនីទ្រិច នៅកំហាប់ 0.250M ដែលត្រូវការដើម្បីបន្សាបសូលុយស្យុង KOH ចំនួន 17.35mL នៅ 0.195M ។

10. ក្នុងពិសោធន៍អត្រាកម្មនៃ 20.4mL អាស៊ីត HCOOH មួយនៅ 0.883M ធ្វើប្រតិកម្មបន្សាបជាមួយ $Ba(OH)_2$

19.3mL ។ ចូរគណនាកំហាប់របស់សូលុយស្យុងបារ្យូមអ៊ីដ្រុកស៊ីត ។

11. គេដាក់អត្រាករ NaOH ចំនួន 72mL នៅកំហាប់ 0.55M ដើម្បីបន្សាបសូលុយស្យុងអាស៊ីតមួយ 220mL ។ ចូរគណនាកំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូម $[H_3O^+]$ ក្នុងសូលុយស្យុងអាស៊ីតនោះ ។

## ? សំណួរនិងលំហាត់ជំពូក 3

### I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវដែលមានតែមួយគត់ ។

1. តម្លៃ pH របស់អាស៊ីត $HNO_3$ នៅ 0.0010M ស្មើនឹង :

☐ ក. 1.0 ☐ ខ. 3.0 ☐ គ. 4.0 ☐ ឃ. 5.0 ។

2. ក្នុងចំណោមសូលុយស្យុងខាងក្រោមនេះ តើណាមួយដែលមានតម្លៃ pH ធំជាង 7 ?

☐ ក. $[OH^-] = 2.4\times10^{-2}M$ ☐ ខ. $[H_3O^+] = 1.53\times10^{-2}M$

☐ គ. 0.0001M HCl ☐ ឃ. $[OH^-] = 4.4\times10^{-9}M$ ។

3. pH ត្រូវបានកំណត់ដោយ :

☐ ក. $pH = -\log[H_3O^+]$ ☐ ខ. $pH = \log[H_3O^+]$ ☐ គ. $pH = -\ell n[H_3O^+]$ ។

4. pH ជាទំហំមួយដែលសម្តែងជា

☐ ក. mol.L ☐ ខ. $mol.L^{-1}$ ☐ គ. គ្មានខ្នាត ។

5. ផលគុណអ៊ីយ៉ុងនៃទឹកគឺ :

☐ ក. $[H_3O^+] = [OH^-]$ ☐ ខ. $[H_3O^+][OH^-] = K_w$

☐ គ. $[H_3O^+][OH^-] > 7$ ។

6. សូលុយស្យុងមួយមានកំហាប់ $[OH^-] = 10^{-4}mol.L^{-1}$ វាមាន pH :

☐ ក. 4 ☐ ខ. 10 ☐ គ. 12 ☐ ឃ. 14 ។

7. សូលុយស្យុងអាស៊ីតក្លរីឌ្រិចមួយមានកំហាប់ $10^{-2}mol.L^{-1}$ មានតម្លៃ pH :

☐ ក. 12 ☐ ខ. 2 ☐ គ. 4.6 ☐ ឃ. 8 ។

8. អាស៊ីតខ្លាំង គឺជាប្រភេទគីមីអាច :

☐ ក. ទទួលយកប្រូតុង ☐ ខ. បោះបង់ប្រូតុង ☐ គ. មានអំពើមិនសព្វជាមួយទឹក ។

9. ប្រតិកម្មរវាងអាស៊ីតខ្លាំងនិងបាសខ្លាំងជាប្រតិកម្ម :

☐ ក. សព្វ ☐ ខ. កំរិត ☐ គ. ស្រូបកម្ដៅ ។

10. នៅពេលអត្រាកម្មសូលុយស្យុងសម្រាប់អត្រាស្ថិតនៅ :

☐ ក. ក្នុងប៊ុយរ៉ែតក្រិត ☐ ខ. ក្នុងកែវបេស៊ែ ។

11. តម្លៃ pH នៅចំណុចសមមូលក្នុងអត្រាកម្មអាស៊ីតខ្លាំង បាសខ្លាំងគឺ :

☐ ក. ធំជាង 7.0 ☐ ខ. តូចជាង 7.0 ☐ គ. ស្មើនិង 7.0 ។

12. សូលុយស្យុងណឺតមាន :

☐ ក. កំហាប់ $H_3O^+$ ស្មើនឹង 7.0M

☐ ខ. មានអ៊ីយ៉ុងអ៊ីដ្រូញ៉ូមនិងគ្មានអ៊ីយ៉ុងអ៊ីដ្រុកស៊ីត

☐ គ. មានចំនួនអ៊ីយ៉ុងអ៊ីដ្រូញ៉ូមនិងអ៊ីយ៉ុងអ៊ីដ្រុកស៊ីតស្មើគ្នា

☐ ឃ. គ្មានចំណុចទាំងអស់ខាងលើទេ ។

13. សូលុយស្យុងមួយមាន pH 6.32 ។ តម្លៃ pOH វាស្មើនឹង :

☐ ក. 6.32 ☐ ខ. $4.8 \times 10^{-7}$

☐ គ. 7.68 ☐ ឃ. $2.1 \times 10^{-8}$ ។

14. តើកំរិត pH ណាមួយខាងក្រោមនេះ ដែលមានលក្ខណៈអាស៊ីតជាងគេ ?

☐ ក. pH = 1 ☐ ខ. pH = 5

☐ គ. pH = 9 ☐ ឃ. pH = 13 ។

15. តើអំបិលអ្វីដែលកកើតឡើងពេលគេធ្វើអត្រាកម្មសូលុយស្យុង $H_2SO_4$ ជាមួយនឹងសូលុយស្យុង $Ca(OH)_2$ : ☐ ក. កាល់ស្យូមស៊ុលផាត ☐ ខ. កាល់ស្យូមអ៊ីដ្រុកស៊ីត

☐ គ. កាល់ស្យូមអុកស៊ីត ☐ ឃ. កាល់ស្យូមផូស្វាត ។

## II. ចូរបំពេញល្បះខាងក្រោមឱ្យមានន័យត្រឹមត្រូវ

1. តាមអារេញ៉ូស " អាស៊ីតជាសមាសធាតុ. . . . . ដែលបង្កើតអ៊ីយ៉ុង . . . .ក្នុងសូលុយស្យុងទឹក ។ ឯបាស គឺជាសមាសធាតុដែលបង្កើតអ៊ីយ៉ុង. . . . . .ក្នុងសូលុយស្យុងទឹក" ។

2. ប្រភេទគីមីដែលសល់ក្រោយពីអាស៊ីតប្រុងស្ទែត-ឡូរីបោះបង់ . . . . . គឺជា . . . .របស់អាស៊ីតនោះ ។ ឯប្រភេទគីមីដែលកកើតពេលបាសប្រុងស្ទែតឡូរី . . . . គឺជា . . . . របស់បាសនោះ ។

3. pH នៃសូលុយស្យុងរាវជា . . . . . និងឡូការីតគោលដប់នៃកំហាប់អ៊ីយ៉ុង . . . . . របស់សូលុយស្យុង ។

4. អត្រាកម្មអាស៊ីត-បាស ជាលំនាំ ឬបច្ចេកទេសដែលគេប្រើនៅ . . . . . ដើម្បីកំណត់. . . . របស់សូលុយស្យុងអាស៊ីត ឬបាសដែល . . . . ។
5. ចំណុចសមមូលជាចំណុចដែល . . . . . មានចំនួន . . . រលាយចូលគ្នាក្នុងសមាមាត្រ . . . . ។
6. ចូរបំពេញចន្លោះទំនេរក្នុងតារាងខាងក្រោម :

| pH | [ $H_3O^+$ ] | សូលុយស្យុង |
|---|---|---|
| < 7 | …… | …… |
| …… | $< 1.0 \times 10^{-7}$M | …… |
| …… | …… | ណឺត |

7. ចូរបំពេញពាក្យ : អាស៊ីត បាស ឬណឺត

ក. pOH > 7 ជាសូលុយស្យុង . . . . ខ. pOH = 7 ជាសូលុយស្យុង . . . .

គ. pOH < 7 ជាសូលុយស្យុង . . . . ។

## III. សំណួរត្រិះរិះ

1. តើនិយមន័យអាស៊ីតតាមប្រុងស្ទែត-ឡូរី ខុសពីនិយមន័យអាស៊ីតតាមអារ៉េញ៉ូសដូចម្ដេច ?
2. តើកំហាប់អ៊ីយ៉ុង [ $OH^-$ ] ក្នុងសូលុយស្យុងអាម៉ូញ៉ាក់ធៀបជាមួយកំហាប់ [ $OH^-$ ] ក្នុងសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីតដូចគ្នា ឬទេ បើបាសទាំងពីរមានកំហាប់ស្មើគ្នា ?
3. តើមានន័យដូចម្ដេចពេលដែលរូបមន្តរបស់អ៊ីយ៉ុង ឬម៉ូលេគុលសរសេរនៅក្នុងវង់តង្កៀប ?
4. តើអ៊ីយ៉ុង [ $H_3O^+$ ] របស់ទឹកសុទ្ធនៅសីតុណ្ហភាព 25°C ស្មើនឹងប៉ុន្មាន ? តើវាមានតម្លៃដូចនេះគ្រប់សីតុណ្ហភាពឬទេ ?
5. ចូរឱ្យនិយមន័យគូអាស៊ីត-បាស ឆ្លាស់និងឱ្យឧទាហរណ៍ ។
6. ចូរបង្ហាញពីអាស៊ីតពីរនិងបាសឆ្លាស់របស់វាក្នុងសមីការប្រតិកម្មខាងក្រោម :

$$H_2SO_4(aq) + SO_3^{2-}(aq) \longrightarrow HSO_4^-(aq) + HSO_3^-(aq)$$

7. ចូរសរសេរសមីការផ្ទេរប្រូតុងរវាង $H_2SO_4(aq)$ និង $SO_4^{2-}(aq)$
8. សរសេរសមីការដែលទាក់ទងនឹង : $K_w$ , pH , [ $H_3O^+$ ] និង [ $OH^-$ ] ។
9. ធ្វើអត្តសញ្ញាណកម្ម សមាសធាតុខាងក្រោមនេះ ជាអាស៊ីត ឬជាបាសតាមចំណែកថ្នាក់របស់ប្រុងស្ទែត-ឡូរី ។ សម្រាប់ប្រភេទនីមួយៗ ចូរសរសេររូបមន្តនិងឈ្មោះរបស់ប្រភេទឆ្លាស់វា :

ក. $CH_3COO^-$ ខ. HCN គ. HOOCCOOH ឃ. $C_6H_5NH_3^+$ ។

10. តើអ្វីទៅជាប្រតិកម្មបន្សាប ?

11. តើតម្លៃ pH នៅចំណុចសមមូលរបស់អត្រាកម្មអាស៊ីតខ្សោយជាមួយបាសខ្លាំង តិចជាង ស្មើ ឬធំជាង 7.00 ?

12. ក្នុងអត្រាកម្ម តើមានន័យដូចម្ដេចនៅចំណុចបញ្ចប់ ?

13. ឱ្យឈ្មោះអង្គធាតុចង្អុលពណ៌ ដែលអ្នកយកមកប្រើដើម្បីធ្វើអត្រាកម្ម អាម៉ូញ៉ាក់ជាមួយអាស៊ីតក្លរីឌ្រិច ?

14. សរសេរសមីការ ផលគុណអ៊ីយ៉ុងរបស់ទឹក ។

15. សូលុយស្យុងបីមាន pH = 3 , 7 និង 11 ។ តើសូលុយស្យុងណាជាបាស ? ណាជាអាស៊ីត ?និងសូលុយស្យុងណាណឺត ?

16. ចូរពន្យល់ពីរបៀបគណនា pH ពីអ៊ីយ៉ុង [ $H_3O^+$ ] ដោយប្រើម៉ាស៊ីនគិតលេខ ។

17. ក្នុងចំណោមអង្គធាតុចង្អុលពណ៌ប្រើញឹកញាប់ ផេណុលផ្តាលេអ៊ីន អេល្យង់ទីននិងប្រូម៉ូទីម៉ុលខៀវ ។ តើណាមួយសមស្របក្នុងជម្រើសសម្រាប់ធ្វើអត្រាកម្មអាស៊ីតខ្សោយដោយបាសខ្លាំង ? ចូរបញ្ជាក់ ។

## IV. លំហាត់

1. រកតម្លៃ pH នៃល្បាយមួយដែលបានពីប្រតិកម្មនៃសូលុយស្យុង $NH_4OH$ ចំនួន 25.0mL នៅ 0.0500M ជាមួយនិងសូលុយស្យុងអាស៊ីត $HNO_3$ ចំនួន 25.0mL នៅ 0.0500M ។

2. រកកំហាប់អ៊ីយ៉ុង $H_3O^+(aq)$ និង $OH^-$ (aq) ក្នុងសូលុយស្យុងមួយដែលរៀបចំដោយ 0.100mol អាស៊ីត $HNO_3$ រលាយក្នុងទឹក 125mL ។

3. ចូររកកំហាប់អ៊ីយ៉ុង [ $H_3O^+$ ] របស់សូលុយស្យុងមួយដែលមាន pH = 4.08 ។ រកតម្លៃ pOH របស់សូលុយស្យុងនេះ ។

4. រកមាឌអាស៊ីតនីទ្រិច $HNO_3$ នៅ 0.250M ដែលត្រូវការចាំបាច់ដើម្បីបន្សាបសូលុយស្យុង KOH ចំនួន 17.35mL នៅកំហាប់ 0.195M ។

5. គេធ្វើអត្រាកម្មសូលុយស្យុង HCl 35.7mL នៅ 0.126M ជាមួយសូលុយស្យុង NaOH ចំនួន 25.0mL ។ ចូររកកំហាប់របស់សូលុយស្យុង NaOH ដែលប្រើនេះ ។

6. គេធ្វើអត្រាកម្មអាស៊ីតនីទ្រិច $HNO_3$ នៅ 0.31M ដោយបន្ថែមអត្រាករ KOH ចំនួន 75mL នៅ 0.24M រហូតដល់តម្លៃ pH = 7 ។ ចូររកមាឌរបស់សូលុយស្យុង $HNO_3$ ដែលត្រូវការចាំបាច់ក្នុងអត្រាកម្មនេះ ។

# ជំពូក 4 លំនឹងគីមី



ស្តាឡាក់ទីតជាថ្មកំបោរដែលដុះចេញពីពិដានគុហាចុះមកក្រោមនិងស្តាឡាក់មីតជាថ្មកំបោរដែលដុះពីបាតគុហាទៅលើ ។ វាកកើតឡើងពីការរំកិលលំនឹងនៃប្រតិកម្ម :

$$CaCO_3\ (s) + CO_2\ (aq) + H_2O\ (\ell) \rightleftharpoons Ca^{2+}\ (aq) + 2HCO_3^-\ (aq)$$ ។

មេរៀនទី

# 1 ធម្មជាតិនៃលំនឹងគីមី

ចប់មេរៀននេះ សិស្សអាច

- ឱ្យនិយមន័យលំនឹងគីមី ។
- បកស្រាយធម្មជាតិនៃថេរលំនឹងគីមី ។
- សរសេរកន្សោមថេរលំនឹងគីមីនិងគណនាថេរលំនឹង ។

នៅពេលគេដាក់ស្ករដែលមានបរិមាណច្រើនទៅក្នុងទឹក គេសង្កេតឃើញម៉ូលេគុលស្ករខ្លះរលាយទៅក្នុងទឹកនិងខ្លះទៀតមិនរលាយ ។ ការរលាយរបស់ស្ករទៅក្នុងទឹកនេះ មានលំនាំពីរកើតឡើង គឺការរលាយរបស់ម៉ូលេគុលស្ករទៅក្នុងទឹកនិងកំណជាក្រាមរបស់ម៉ូលេគុលស្ករឡើងវិញ ។ នៅពេលដែលល្បឿនរលាយនិងកំណជាក្រាមនៃម៉ូលេគុលស្ករស្មើគ្នា គេទទួលបានលំនឹងនៃការរលាយនិងកំណជាក្រាមនៃម៉ូលេគុលស្ករ ។ លំនឹងបែបនេះគេហៅថា លំនិងរូប ។ ក្នុងជំពូកនេះយើងនិងសិក្សាពីលំនឹងគីមី ។

## 1. ប្រតិកម្មទៅមក

តាមទ្រឹស្តី គ្រប់ប្រតិកម្មអាចប្រព្រឹត្តទៅតាមទិសពីរ គឺប្រតិកម្មតាមទិសបណ្តោយនិងប្រតិកម្មតាមទិសច្រាស ។ ដូច្នេះគ្រប់ប្រតិកម្មគីមី ដែលបានលើកឡើងជាប្រតិកម្មទៅមកនៅក្រោមលក្ខខណ្ឌសមស្របណាមួយ ។ ប្រតិកម្មគីមីមួយដែលក្នុងនោះមានអង្គធាតុកកើត (ផលិតផល) អាចមានប្រតិកម្មជាមួយគ្នាបង្កើតអង្គធាតុប្រតិករវិញគេហៅថា ប្រតិកម្មទៅមក ។

***ឧទាហរណ៍*** : បារត (II) អុកស៊ីតត្រូវកម្តៅ បំបែកធាតុជាបារតនិងអុកស៊ីសែនតាមសមីការប្រតិកម្ម :

$$2HgO(s) \xrightarrow{\Delta} 2Hg(\ell) + O_2(g)$$

កាលណាត្រូវកម្តៅដែរ បារតមានអំពើជាមួយអុកស៊ីសែន បង្កើតជាបារត (II) អុកស៊ីតវិញ ។ សមីការតាងប្រតិកម្ម :

$$2Hg(\ell) + O_2(g) \xrightarrow{\Delta} 2HgO(s)$$




***រូបទី 1.1 : ពេលត្រូវកម្តៅបារត(II) អុកស៊ីតបំបែកទៅជាធាតុបារត និងអុកស៊ីសែន ។ បារតរាវមានប្រតិកម្មជាមួយអុកស៊ីសែនបង្កើតជាបារត(II)អុកស៊ីតវិញ ។ ប្រតិកម្មទាំងពីរនេះជាប្រតិកម្មទៅមក ។***

***ពិសោធន៍ :*** គេដុតកម្តៅបារត (II) អុកស៊ីតក្នុងកែវបិតជិត គឺធ្វើយ៉ាងណាឱ្យអុកស៊ីសែននិងបារត ដែលកើតឡើងមិនអាចចេញបាន ។ គេសង្កេតឃើញអុកស៊ីសែននិងបារតដែលកកើតមកនោះចូលធ្វើប្រតិកម្មជាមួយគ្នាបង្កើតជាបារត (II) អុកស៊ីតវិញ ។

ក្នុងពេលប្រតិកម្មបំបែកនិងប្រតិកម្មកំណបារត (II) អុកស៊ីត មានល្បឿនស្មើគ្នានាំឱ្យបរិមាណបារត (II) អុកស៊ីត បារតនិងអុកស៊ីសែនក្នុងកែវលែងប្រែប្រួល ។ ពេលនោះ គេថាលំនឹងឌីណាមិចកើតមានឡើងរវាងប្រតិកម្មបំបែកនិងកំណបារត (II) អុកស៊ីត ។ សមីការគីមីតាងប្រតិកម្មពេលមានលំនឹងសរសេរដោយសញ្ញាព្រួញពីរទៅមក ។

***ឧទាហរណ៍ :*** $2HgO(s) \xrightleftharpoons{\Delta} 2Hg(\ell) + O_2(g)$

**ប្រតិកម្មទៅមកមានលំនឹងគីមី កាលណាល្បឿនប្រតិកម្មតាមទិសបណ្តោយស្មើនឹងប្រតិកម្មតាមទិសច្រាស ហើយកំហាប់នៃអង្គធាតុកកើតនិងអង្គធាតុប្រតិករលែងប្រែប្រួល ។**

## 2. លំនឹងគីមី

ប្រតិកម្មគីមីជាច្រើន ជាប្រតិកម្មទៅមកនៅក្រោមលក្ខខណ្ឌសីតុណ្ហភាពនិងកំហាប់ប្រក្រតី ។ ប្រតិកម្មទាំងនោះទៅដល់ស្ថានភាពលំនឹង ប្រសិនបើគ្មានសារធាតុណាមួយដែលពាក់ព័ន្ធនិងប្រតិកម្មបានហើរចេញ ឬរំដោះចេញពីប្រព័ន្ធប្រតិកម្ម ។

ករណីខ្លះ ប្រតិកម្មតាមទិសបណ្តោយប្រព្រឹត្តទៅស្ទើរតែទាំងស្រុង ទើបមានប្រតិកម្មតាមទិសច្រាសកើតមានឡើង ។ ដូច្នេះនៅពេលមានលំនឹងគីមីកំហាប់អង្គធាតុកកើតដែលទទួលបានពីប្រតិកម្មតាមទិសបណ្តោយធំជាងកំហាប់អង្គធាតុប្រតិករ ។ គេថាលំនឹងទោរទៅស្តាំដោយសារអង្គធាតុកកើតមានបរិមាណច្រើនលើសលុប ។ តាមសន្មត សមីការលំនឹងគីមីតាងដូចក្នុងប្រតិកម្មរវាងស្ពាន់ធ័រឌីអុកស៊ីត និងអុកស៊ីសែនឱ្យផលជាស្ពាន់ធ័រទ្រីអុកស៊ីត :

$2SO_2(g) + O_2(g) \rightleftharpoons 2SO_3(g)$

ព្រួញវែងតាងឱ្យប្រតិកម្មតាមទិសបណ្តោយ ដែលជាប្រតិកម្មនាំមុខ ។ ព្រួញខ្លីតាងឱ្យប្រតិកម្ម

តាមទិសច្រាស ដែលជាប្រតិកម្មមិននាំមុខ ។

ករណីខ្លះ ប្រតិកម្មតាមទិសបណ្ដោយប្រព្រឹត្តទៅដោយលំបាកនិងប្រតិកម្មតាមទិសច្រាសប្រព្រឹត្តទៅងាយស្រួល ។ ក្នុងករណីនេះ ពេលមានលំនឹងអង្គធាតុប្រតិករមានបរិមាណច្រើននិងអង្គធាតុកកើតមានបរិមាណតិច ។ គេថាលំនឹងទោរទៅឆ្វេង ។ សមីការលំនឹងតាងដូចករណីប្រតិកម្មអាស៊ីត-បាស ដែលកើតឡើងរវាងអាស៊ីតកាបូនិច និងទឹក :

$$H_2CO_3(aq) + H_2O(\ell) \rightleftarrows H_3O^+(aq) + HCO_3^-(aq)$$

មានករណីខ្លះទៀត ប្រតិកម្មតាមទិសបណ្ដោយ និងប្រតិកម្មតាមទិសច្រាសកើតមានឡើងស្ទើរតែដំណាលគ្នា ។ មុនពេលលំនឹងកើតឡើងគ្មានប្រតិកម្មណាមួយនាំមុខទេ ។ សមីការលំនឹងតាងដូចករណីប្រតិកម្មបំបែកជាអ៊ីយ៉ុងនៃអាស៊ីតអាសេទិចក្នុងទឹក ។

$$CH_3-COOH(aq) + H_2O(\ell) \rightleftharpoons H_3O^+(aq) + CH_3-COO^-(aq)$$

***សំគាល់ :*** ព្រួញទៅមកមានប្រវែងស្មើគ្នា ។

គេប្រើប្រតិកម្មគីមីសម្រាប់បំលែងអង្គធាតុប្រតិករឱ្យទៅជាអង្គធាតុកកើតដែលគេចង់បាន ។ អ្នកគីមីព្យាយាមបំលែងអង្គធាតុប្រតិករនានាឱ្យទៅជាអង្គធាតុកកើតតាមតែអាចធ្វើទៅបាន ដើម្បីបម្រើសេចក្ដីត្រូវការរបស់មនុស្សជាតិ ។

## 3. កន្សោមថេរលំនឹង

ឧបមាថា គេមានអង្គធាតុ A និង B ដែលមានអំពើជាមួយគ្នាឱ្យផលជាអង្គធាតុ C និង D ហើយ C និង D ចូលធ្វើប្រតិកម្មជាមួយគ្នាឱ្យផលជា A និង B វិញ ។ នៅក្រោមលក្ខខណ្ឌសមស្របណាមួយ ប្រតិកម្មទៅមកមានលំនឹងកើតឡើង ដែលគេតាងដោយសមីការខាងក្រោម :

$$aA + bB \underset{2}{\overset{1}{\rightleftarrows}} cC + dD$$

ពេលចាប់ផ្ដើមប្រតិកម្ម កំហាប់នៃអង្គធាតុ C និង D ស្មើសូន្យ រីឯកំហាប់អង្គធាតុ A និង B អតិបរមា ។ រូបទី 1.2 បង្ហាញពីល្បឿនប្រតិកម្មតាមទិសបណ្ដោយ(ទិស 1 )ថយចុះ ខណៈដែលនោះល្បឿនតាមទិសច្រាស(ទិស 2 )កើនឡើង ។ នៅពេលល្បឿនតាមទិសបណ្ដោយនិងតាមទិសច្រាសស្មើគ្នាពេលនោះលំនឹងកើតមានឡើង ។ គេមានលំនឹងកំហាប់នៃ A , B , C និង D លែងប្រែប្រួល បើលក្ខខណ្ឌប្រព័ន្ធមិនប្រែប្រួល ។




*រូបទី 1.2 : ប្រៀបធៀបល្បឿននៃប្រព័ន្ធប្រតិកម្ម ។*

គ្រប់ប្រតិកម្មទៅមក ដែលប្រព្រឹត្តទៅក្នុងមជ្ឈដ្ឋានស្មើសាច់នៅសីតុណ្ហភាពណាមួយ តែងតែមានថេរ K តាងឱ្យភាពលំនឹងនៃប្រព័ន្ធ ។ ថេរ K ឬថេរលំនឹង K សម្តែងដោយ :

$$K = \frac{[C]^c \times [D]^d}{[A]^a \times [B]^b}$$

[ ] : តាងឱ្យកំហាប់នៃសារធាតុនីមួយៗ គិតជា mol/L ។ ថេរលំនឹង K មិនអាស្រ័យនឹងកំហាប់ដើមនៃអង្គធាតុប្រតិករ តែវាអាស្រ័យតាមសីតុណ្ហភាពនៃប្រព័ន្ធ ។

## 4. ថេរលំនឹងនៃប្រព័ន្ធ $H_2$ , $I_2$ និង HI

គេដាក់ $I_2$ ក្នុងបំពង់កែវ ហើយបញ្ចូលឧស្ម័ន $H_2$ ឱ្យមានបរិមាណលើស រួចបិទកែវនោះឱ្យជិតមិនឱ្យឧស្ម័នហើរចេញបាន ។ បន្ទាប់មកគេយកបំពង់កែវនោះទៅកម្តៅនៅសីតុណ្ហភាពខ្ពស់ ដើម្បីឱ្យឧស្ម័ន $H_2$ មានប្រតិកម្មជាមួយចំហាយ $I_2$ ។ ចំហាយ $I_2$ មានពណ៌ស្វាយ(រូបទី 1.3.ក) ។ ដូច្នេះ គេអាចតាមដានល្បឿនប្រតិកម្មតាមរយៈចំហាយពណ៌ស្វាយនៃ $I_2$ ។




*រូបទី 1.3. ក. ចំហាយ $I_2$ ពេលចាប់ផ្តើមប្រតិកម្ម ។*

*ខ. បរិមាណ $I_2$ ត្រូវបានថយចុះពេលប្រតិកម្ម ។*

*គ. ចំហាយពណ៌ស្វាយលែងប្រែប្រួលពណ៌នៅពេល*

នៅពេលឧស្ម័ន $H_2$ និងចំហាយ $I_2$ ចូលធ្វើប្រតិកម្មជាមួយគ្នា ធ្វើឱ្យពណ៌នៃបំពង់កែវ ថយចុះជាលំដាប់(រូបទី 1.3.ខ) ។ គេគិតថាបំពង់កែវនិង

ប្រែជាគ្មានពណ៌នៅពេល $I_2$ ចូលធ្វើប្រតិកម្មអស់ ។ ដោយឧស្ម័នអ៊ីដ្រូសែន $H_2$ និងឧស្ម័នអ៊ីដ្រូសែនអ៊ីយ៉ូឌួ HI ដែលកកើតនោះសុទ្ធតែជាឧស្ម័នគ្មានពណ៌ ។ គេកម្តៅបំពង់កែវបន្តទៅទៀតដល់ដំណាក់កាលណាមួយ ចំហាយពណ៌ស្វាយលែងប្រែពណ៌ (រូបទី 1.3 គ) ។ ការដែលមិនប្រែពណ៌នេះ គឺដោយសារHI ដែលកកើតមករងនូវប្រតិកម្មបំបែកក្លាយជា $H_2$ និង $I_2$ វិញ ។ ល្បឿនប្រតិកម្មតាមទិសច្រាសកើតឡើងដោយសារកំហាប់ HI កើនឡើង ទន្ទឹមនឹងនោះល្បឿនប្រតិកម្មតាមទិសបណ្តោយថយចុះដោយសារកំហាប់ $I_2$ និង$H_2$ ថយចុះ ។ នៅពេលល្បឿនប្រតិកម្មទៅមកស្មើគ្នា នោះលំនឹងគីមីកើតមានឡើង ។ ចំហាយពណ៌ស្វាយ $I_2$ លែងប្រែពណ៌បញ្ជាក់ថា មានលំនឹងរវាងបរិមាណ$H_2$ , $I_2$ និងHI កើតមាន ។ សមីការគីមីតាងឱ្យប្រព័ន្ធមានលំនឹង :

$$H_2(g) + I_2(g) \rightleftharpoons 2HI(g)$$

កន្សោមថេរលំនឹងគីមីសរសេរ :

$$K = \frac{[HI]^2}{[H_2][I_2]}$$

ដើម្បីកំណត់តម្លៃថេរលំនឹង K ឱ្យជាក់លាក់ គេត្រូវកំណត់កំហាប់$[I_2]$ , $[H_2]$ និង$[HI]$ ឱ្យបានត្រឹមត្រូវនៅពេលប្រព័ន្ធមានលំនឹងនៅសីតុណ្ហភាពណាមួយ ។

តារាងទី 1.1 ជាលទ្ធផលដែលបានទទួលពីការពិសោធ4ដង ។ ពិសោធន៍ទី 1 និងទី 2 ផ្តើមពី $H_2$ និង $I_2$ និងពិសោធន៍ទី3 និងទី4 ផ្តើមពី HI ។ ការពិសោធទាំងអស់នេះប្រព្រឹត្តទៅនៅសីតុណ្ហភាព 425°C ។

**តារាងទី 1.1 : កំហាប់ $I_2$ , $H_2$ និង HI ដែលមានលំនឹងនៅសីតុណ្ហភាព 425°C**

| ពិសោធន៍ទី | $[I_2]$ | $[H_2]$ | $[HI]$ | $K = \frac{[HI]^2}{[Hg][I_2]}$ |
|---|---|---|---|---|
| 1 | $1.250 \times 10^{-3}$ | $3.560 \times 10^{-3}$ | $15.59 \times 10^{-3}$ | 54.62 |
| 2 | $2.336 \times 10^{-3}$ | $2.252 \times 10^{-3}$ | $16.85 \times 10^{-3}$ | 53.97 |
| 3 | $0.4953 \times 10^{-3}$ | $0.4953 \times 10^{-3}$ | $3.655 \times 10^{-3}$ | 54.45 |
| 4 | $1.141 \times 10^{-3}$ | $1.141 \times 10^{-3}$ | $8.410 \times 10^{-3}$ | 54.33 |

ថេរលំនឹង K នៃប្រព័ន្ធ $I_2$ , $H_2$ និង HI នៅសីតុណ្ហភាព 425°C មានតម្លៃជាមធ្យមគឺ : 54.34 ។ តម្លៃនេះ ប្រែប្រួលនៅពេលដែលគេប្តូរសីតុណ្ហភាពប្រព័ន្ធនេះ ។

*លំហាត់គំរូ 1:* សរសេរកន្សោមលំនឹងគីមីនៃប្រតិកម្មរវាងអ៊ីដ្រូសែន និងអាសូតនៅសីតុណ្ហភាព 500°C ។

***ចម្លើយ :***

សមីការតុល្យការលំនឹងគីមី : $3H_2(g) + N_2(g) \rightleftharpoons 2NH_3(g)$

កន្សោមលំនឹងគីមី : $K = \frac{[NH_3]^2}{[H_2]^3[N_2]}$ ។

*លំហាត់គំរូ 2:* គណនាថេរលំនឹង K នៃប្រព័ន្ធ $N_2$, $O_2$ និង NO នៅសីតុណ្ហភាព 1227°C ។ គេដឹងថាកំហាប់នៃអង្គធាតុនីមួយៗនៅពេលលំនឹងគីមីកើតឡើង :

$[N_2] = 6.4 \times 10^{-3} mol \cdot L^{-1}$ , $[O_2] = 1.7 \times 10^{-3} mol \cdot L^{-1}$ , $[NO] = 1.1 \times 10^{-3} mol \cdot L^{-1}$ ។

***ចម្លើយ :***

សមីការតុល្យការលំនឹងគីមី : $N_2(g) + O_2(g) \rightleftharpoons 2NO(g)$

កន្សោមថេរលំនឹងគីមី : $K = \frac{[NO]^2}{[N_2][O_2]}$

$$K = \frac{(1.1 \times 10^{-3} mol \cdot L^{-1})^2}{(6.4 \times 10^{-3} mol \cdot L^{-1})(1.7 \times 10^{-3} mol \cdot L^{-1})}$$

$K = 0.11$ ។

*លំហាត់គំរូ 3:* គេមានប្រតិកម្មមួយតាងដោយសមីការតុល្យការ

$$A(g) + B(g) \rightleftharpoons C(g) + D(g)$$

គេយកអង្គធាតុ A ចំនួន 1.00mol និង B ចំនួន 1.00mol ដាក់ក្នុងដប 1.00L ហើយបិទឱ្យជិត ។ រយៈពេលជប់ថ្ងៃក្រោយមក ប្រតិកម្មមានលំនឹងកើតឡើង នៅពេលនោះគេទទួលបាន C ចំនួន 0.200mol ។

ក. ចូរកំណត់រកកំហាប់ A និង B នៅពេលប្រព័ន្ធមានលំនឹង និងថេរលំនឹង K ។

ខ. គេធ្វើពិសោធន៍ម្តងទៀត ដោយយក C និង D ចំនួន 1.00mol ដូចគ្នាដាក់ក្នុងដប 1.00L ។ តើគេអាចទទួលបរិមាណ A ប៉ុន្មាននៅពេលប្រព័ន្ធមានលំនឹង ?

***ចម្លើយ :***

ក. សមីការតុល្យការ :

$$A(g) + B(g) \rightleftharpoons C(g) + D(g)$$

| | A(g) | B(g) | C(g) | D(g) |
|---|---|---|---|---|
| កំហាប់ដើម : | 1.00M | 1.00M | 0 | 0 |
| កំហាប់ប្រែប្រួលដោយប្រតិកម្ម : | 0.200M | 0.200M | 0.200M | 0.200M |
| កំហាប់ពេលមានលំនឹង : | 0.800M | 0.800M | 0.200M | 0.200M |

កន្សោមថេរលំនឹង :

$$K = \frac{[C][D]}{[A][B]} = \frac{(0.200)^2}{(0.800)^2}$$

$K = 0.062$ ។

ខ. នៅពេលប្រតិកម្មមានលំនឹង គេទទួលបានបរិមាណ A ចំនួន 0.800mol ដូចបរិមាណ A ក្នុងពិសោធន៍ទី 1 ដែរ ។

***លំហាត់គំរូ 4:*** គេយក 0.150mol នៃ $Cl_2$ និង 0.300mol នៃ $NO_2$ ដាក់ក្នុងប្រអប់បិទជិតដែលមានចំណុះ 1.50L ។ គេទុកឱ្យប្រព័ន្ធមានលំនឹងនៅសីតុណ្ហភាពកំណត់មួយ ។ កំហាប់ $NO_2Cl$ ពេលមានលំនឹងគឺ 0.054mol.$L^{-1}$ ។ គណនាតម្លៃ K នៅសីតុណ្ហភាពនោះ ។ គេឱ្យសមីការតុល្យការលំនឹង : $2NO_2Cl(g) \rightleftharpoons 2NO_2(g) + Cl_2(g)$ ។

***ចម្លើយ :***

រកកំហាប់ $Cl_2$ និង $NO_2$

តាមទំនាក់ទំនង : $C = \frac{n}{V}$

$$C_{Cl_2} = \frac{0.15}{1.5} = 0.100M$$

$$C_{NO_2} = \frac{0.300}{1.5} = 0.200M$$

| | | | | |
|---|---|---|---|---|
| សមីការលំនឹង | : | $2NO_2Cl(g) \rightleftharpoons$ | $2NO_2(g)$ + | $Cl_2(g)$ |
| កំហាប់ដើម | : | 0 | 0.200M | 0.100M |
| កំហាប់ប្រែប្រួលដោយប្រតិកម្ម | : | 0.054M | 0.054M | 0.027M |
| កំហាប់លំនឹង | : | 0.054M | 0.146M | 0.073M |

$$K = \frac{[NO_2]^2[Cl_2]}{[NO_2Cl]^2}$$

$$K = \frac{(0.146)^2(0.073)}{(0.054)^2}$$

$$K = 0.5336$$ ។

## មេរៀនសង្ខេប

- តាមទ្រឹស្តីគ្រប់ប្រតិកម្មទាំងអស់អាចប្រព្រឹត្តទៅមក ។ ប្រតិកម្មទៅមកអាចកើតឡើងក្នុងប្រព័ន្ធមួយនៅពេលតែមួយ ។ បើប្រតិកម្មទៅមកមានល្បឿនស្មើគ្នា ពេលនោះប្រព័ន្ធដល់ស្ថានភាពលំនឹង ។
- លំនឹងគីមីមួយមានលក្ខណៈសំគាល់ដោយថេរលំនឹង K របស់វា ។ ថេរលំនឹងមិនអាស្រ័យនិងកំហាប់នៃអង្គធាតុប្រតិករ តែវាអាស្រ័យនិងសីតុណ្ហភាព ។
- ចំពោះប្រតិកម្ម : $aA + bB \rightleftharpoons cC + dD$ ដែលសម្រេចក្នុងមជ្ឈដ្ឋានស្មើសាច់នៅសីតុណ្ហភាពណាមួយ ថេរលំនឹង K សរសេរ : $K = \frac{[C]^c[D]^d}{[A]^a[B]^b}$

## ? សំណួរនិងលំហាត់

1. តើអ្វីទៅលំនិងគីមី ?

2. តើថេរលំនិង K សម្រាប់សំគាល់អ្វី ?

3. តើកត្តាអ្វីដែលនាំឱ្យថេរលំនិង K ប្រែប្រួល ?

4. សរសេរកន្សោមថេរលំនិងគីមីនៃប្រតិកម្ម :

$$4HCl(g) + O_2(g) \rightleftharpoons 2Cl_2(g) + 2H_2O(g)$$

5. សរសេរកន្សោមថេរលំនិងគីមីនៃប្រតិកម្ម : $2HI(g) \rightleftharpoons H_2(g) + I_2(g)$ ។

6. អាស៊ីតក្លរីឌ្រិចជាអាស៊ីតខ្លាំង នៅក្នុងទឹកវាបំបែកជាអ៊ីយ៉ុង $H_3O^+$ និង $Cl^-$ បានសព្វល្អ :

$HCl(aq) + H_2O(\ell) \rightleftharpoons H_3O^+(aq) + Cl^-(aq)$ ។

ចូរអ្នកសាកល្បងពិចារណាតម្លៃថេរលំនិង K នៃប្រតិកម្មខាងលើ តើតម្លៃរបស់ K អាចត្រូវនិងតម្លៃណាមួយ : $1 \times 10^{-2}$ , $1 \times 10^{-3}$ , $1 \times 10^{-5}$ ឬធំណាស់ ?

7. គេមានប្រតិកម្ម : $H_2(g) + Cl_2(g) \rightleftharpoons 2HCl(g)$ ដែលមានលំនិងនៅសីតុណ្ហភាព 1227°C ។ កំហាប់អង្គធាតុនៅពេលមានលំនិងគីមី : $[H_2] = [Cl_2] = 4.5 \times 10^{-3} mol \cdot L^{-1}$ និង $[HCl] = 62.5 \times 10^{-3} mol \cdot L^{-1}$ ។ ចូរគណនាតម្លៃថេរលំនិង K ។

ចម្លើយ : K = 192.90 ។

8. គេមានប្រតិកម្ម : $H_2(g) + I_2(g) \rightleftharpoons 2HI(g)$ ដែលមានលំនិងនៅសីតុណ្ហភាព 425°C ។ កំហាប់អង្គធាតុនៅពេលលំនិង : $[H_2] = 1.83 \times 10^{-1} mol \cdot L^{-1}$ , $[I_2] = 3.13 \times 10^{-3} mol \cdot L^{-1}$ និង $[HI] = 1.77 \times 10^{-2} mol \cdot L^{-1}$ ។ គណនាថេរលំនិង K ។

ចម្លើយ : K = 0.54

9. គណនាកំហាប់ HI ដែលបានមកពីអំពើនៃ $I_2$ និង $H_2$ នៅសីតុណ្ហភាព 425°C ។ កំហាប់អង្គធាតុប្រតិករនៅពេលលំនិង : $[I_2] = [H_2] = 4.79 \times 10^{-4} mol \cdot L^{-1}$ ។

គេឱ្យថេរលំនិង K = 54.3 ។

ចម្លើយ : $[HI] = 35.29 \times 10^{-4} mol \cdot L^{-1}$ ។

10. ល្បាយឧស្ម័នមួយផ្សំដោយ $N_2$ , $H_2$ និង $NH_3$ ។ ល្បាយនេះមានលំនឹងគីមីនៅសីតុណ្ហភាព 773K ។ កំហាប់អង្គធាតុនីមួយៗនៅពេលលំនឹង : $[N_2] = 0.602 mol\ L^{-1}$ , $[H_2] = 0.420 mol\ L^{-1}$ និង $[NH_3] = 0.113 mol\ L^{-1}$ ។

ចូរកំណត់រកថេរលំនឹងនៃប្រតិកម្ម ។

សមីការប្រតិកម្ម : $N_2(g) + 3H_2(g) \rightleftharpoons 2NH_3(g)$ ។

**ចម្លើយ** : $K = 0.286$ ។

11. ប្រតិកម្មមួយតាងដោយសមីការតុល្យការ : $XY_2Z(g) \rightleftharpoons Y_2(g) + XZ(g)$ ។ ប្រតិកម្មនេះមានលំនឹងនៅសីតុណ្ហភាព 627°C នៅក្នុងផ្តាំងបិទជិតមួយដែលមានចំណុះ 5L ។ បរិមាណនៃសារធាតុនីមួយៗនៅពេលលំនឹង : $n_{(XY_2Z)} = 0.084 mol$ , $n_{(Y_2)} = 0.035 mol$ និង $n_{(XZ)} = 0.059 mol$ ។ ចូរកំណត់រកថេរលំនឹង K នៃប្រព័ន្ធនៅសីតុណ្ហភាព 627°C ។

**ចម្លើយ** : $K = 4.92 \times 10^{-3}$ ។

12. ប្រតិកម្មរវាងឧស្ម័នស្ពាន់ធ័រឌីអុកស៊ីត និងអុកស៊ីសែន ឱ្យផលជាឧស្ម័នស្ពាន់ធ័រទ្រីអុកស៊ីត ។ គេឱ្យប្រព័ន្ធនេះមានលំនឹងនៅសីតុណ្ហភាព 873K ពីព្រោះនៅសីតុណ្ហភាពនោះគេទទួលបានឧស្ម័នស្ពាន់ធ័រទ្រីអុកស៊ីតច្រើន ។ កំហាប់នៃសារធាតុនីមួយៗនៅពេលលំនឹង $[SO_2] = 1.50 mol\ L^{-1}$ $[O_2] = 1.25 mol\ L^{-1}$ និង $[SO_3] = 3.50 mol\ L^{-1}$ ។ ចូរកំណត់រកថេរលំនឹងនៃប្រព័ន្ធ ។

**ចម្លើយ** : $K = 4.35$ ។

# 2 ការរំកិលលំនឹង

ចប់មេរៀននេះ សិស្សអាច

- ពណ៌នាកត្តាដែលនាំឱ្យរំខានលំនឹង ។
- បកស្រាយពីលក្ខណៈនៃប្រតិកម្មដែលឈានទៅរកភាពសព្វ ។
- ពន្យល់ពីផលអ៊ីយ៉ុងរួម ។

ប្រព័ន្ធទាំងឡាយដែលឈានទៅដល់លំនឹងគីមី គឺកំហាប់អង្គធាតុប្រតិករនិងអង្គធាតុកកើតលែងប្រែប្រួល ។ បើគេធ្វើឱ្យសម្ពាធ កំហាប់និងសីតុណ្ហភាពនៃប្រព័ន្ធប្រែប្រួល នោះលំនឹងគីមីក៏ប្រែប្រួលទៅរកលំនឹងថ្មីទៀតដែរ ជាហេតុនាំឱ្យកំហាប់នៃអង្គធាតុប្រតិករនិងអង្គធាតុកកើតក៏ប្រែប្រួលដែរ ។ អ្នកគីមីអាចធ្វើឱ្យលំនឹងគីមីរំកិលទៅតាមទិសដៅដែលគេចង់បាន ជាពិសេសគេធ្វើឱ្យលំនឹងគីមីរំកិលទៅរកផលិតផលដែលគេត្រូវការ ។

## 1. ព្យាករណ៍ទិសដៅនៃរំកិលលំនឹង

នៅឆ្នាំ1888 ឡឺសាតឺលីយេ (Le Chatelier) បានសិក្សាលើកត្តាដែលនាំឱ្យមានរំកិលលំនឹងនៃប្រព័ន្ធ ហើយបានចេញគោលការណ៍ : **បើប្រព័ន្ធមួយកំពុងមានលំនឹងរងនូវភាពតានតឹង លំនឹងនោះរំកិលទៅតាមទិសដៅដែលមានទំនោររំដោះភាពតានតឹង ។** គោលការណ៍នេះមានលក្ខណៈត្រឹមត្រូវគ្រប់លំនឹងឌីណាមិច គឺទាំងលំនឹងគីមី និងលំនឹងរូប ។ កត្តាដែលនាំឱ្យមានភាពតានតឹង(ឬរំខាន)ដល់លំនឹងគីមី គឺសម្ពាធ កំហាប់និងសីតុណ្ហភាព ។

### 1.1. ការប្រែប្រួលសម្ពាធ

ការប្រែប្រួលសម្ពាធមានឥទ្ធិពលទៅលើលំនឹងនៃប្រព័ន្ធដែលមានភាពរូបជាឧស្ម័នតែប៉ុណ្ណោះ ។ ដើម្បីឱ្យសម្ពាធមានឥទ្ធិពលទៅលើប្រព័ន្ធលំនឹងគីមីនៃប្រតិកម្មណាមួយ លុះត្រាតែចំនួនម៉ូលេគុល (ឬចំនួនម៉ូល) សរុបនៃអង្គធាតុប្រតិករខុសគ្នាពីចំនួនម៉ូលេគុល(ឬចំនួនម៉ូល) សរុបនៃអង្គធាតុកកើត ។

ក្នុងប្រតិកម្មសំយោគអាម៉ូញ៉ាក់តាមលំនាំ ហេប៊ែរ (Haber) តាងដោយសមីការតុល្យការ :

$$N_2(g) + 3H_2(g) \rightleftharpoons 2NH_3(g)$$

គេសំគាល់ឃើញថា ចំនួនម៉ូលេគុលសរុបនៃអង្គធាតុប្រតិករមានចំនួនបួន រីឯចំនួនម៉ូលេគុលសរុបនៃអង្គធាតុកកើតមានចំនួនពីរ ។




*រូបទី 2.3 ក. ប្រព័ន្ធមានលំនឹងមុនបង្កើនសម្ពាធ*

*រូបទី 2.3 ខ. ប្រព័ន្ធមានលំនឹងក្រោយបង្កើនសម្ពាធ*

ការបង្កើនសម្ពាធ គឺផ្តល់ភាពតានតឹង ឬការរំខានទៅឱ្យប្រព័ន្ធលំនឹង ។ តើប្រព័ន្ធលំនឹង $H_2$ , $N_2$ និង $NH_3$ រំកិលទៅទិសណាដើម្បីបន្ធូរបន្ថយភាពតានតឹង ? ការបង្កើនសម្ពាធ (បន្ថយមាឌឧស្ម័ន)ទៅលើប្រព័ន្ធ (រូបទី 2.3) នាំឱ្យកំហាប់នៃគ្រប់ប្រភេទគីមីដែលនៅក្នុងប្រព័ន្ធកើនឡើងដែរ ។ ប្រព័ន្ធអាចកាត់បន្ថយចំនួនម៉ូលេគុលសរុប ដើម្បីបន្ធូរបន្ថយសម្ពាធដែលជាហេតុធ្វើឱ្យលំនឹងរំកិលទៅស្តាំ ។
អង្គធាតុប្រតិករអាសូតនិងអ៊ីដ្រូសែនមានម៉ូលេគុលសរុបចំនួនបួន (អាសូតមួយម៉ូលេគុលនិងអ៊ីដ្រូសែនបីម៉ូលេគុល) ចូលធ្វើប្រតិកម្មជាមួយគ្នាឱ្យផលជាអាម៉ូញ៉ាក់តែពីរម៉ូលេគុលទេ ។ ដោយមានកំណ $NH_3$ ពី $N_2$ និង $H_2$ ធ្វើឱ្យប្រព័ន្ធមានចំនួនម៉ូលេគុលសរុបថយចុះ ជាហេតុនាំឱ្យសម្ពាធថយចុះដែរ ។ ទោះបីយ៉ាងនោះក៏ដោយក៏សម្ពាធនៅលំនឹងថ្មីនៅតែធំជាងសម្ពាធនៅលំនឹងដើមដែរ ។

ការបង្កើនសម្ពាធទៅលើឧស្ម័ននៅក្នុងប្រអប់បិទជិត ធ្វើឱ្យកំហាប់នៃឧស្ម័នកើនឡើង ។ ទោះបីការប្រែប្រួលសម្ពាធឧស្ម័នធ្វើឱ្យរំកិលលំនឹងក្តី ក៏សម្ពាធពុំមានឥទ្ធិពលទៅលើតម្លៃថេរលំនឹងទេ ។

អាម៉ូញ៉ាក់ដែលផលិតបានតាមលំនាំហេបិរ ត្រូវបានគេយកចេញជាបណ្តើរៗតាមវិធីបំលែងឧស្ម័នអាម៉ូញ៉ាក់ឱ្យទៅជាអាម៉ូញ៉ាក់រាវ ។ ការរំដោះអាម៉ូញ៉ាក់ចេញពីប្រព័ន្ធប្រតិកម្មធ្វើឱ្យសម្ពាធដោយភាគនៃអាម៉ូញ៉ាក់ថយចុះនិងកំហាប់របស់វាក៏ថយចុះដែរ ជាហេតុបណ្តាលឱ្យលំនឹងរំកិលទៅស្តាំ ។

គេបញ្ចូលឧស្ម័នកម្រ ដូចជាអេល្យូម (He) ទៅក្នុងផ្ទាំងសំយោគអាម៉ូញ៉ាក់ ធ្វើឱ្យសម្ពាធសរុបនៃឧស្ម័ននៅក្នុងផ្ទាំងកើនឡើង តែសម្ពាធដោយភាគនៃឧស្ម័នប្រតិកម្មមិនប្រែប្រួលទេ ។ គេសង្កេតឃើញថាគ្មានការរំកិលលំនឹងទេ ។




*រូបទី 2.2 ការបញ្ចូលឧស្ម័ន He ទៅក្នុងផ្ទាំងសំយោគ $NH_3$ ពុំបានធ្វើឱ្យរំកិលលំនឹងទេ ។*

ដូច្នេះ ការបង្កើនសម្ពាធដោយបន្ថែមឧស្ម័នដែលមិនមែនជាឧស្ម័នអង្គធាតុប្រតិករ ឬអង្គធាតុកកើតមិនអាចមានឥទ្ធិពលទៅលើការរំកិលលំនឹងនៃប្រព័ន្ធប្រតិកម្មឡើយ ។

## 1.2. បម្រែបម្រួលកំហាប់

ការបង្កើនកំហាប់អង្គធាតុប្រតិករ គឺបង្កើតភាពតានតឹងឱ្យទៅប្រព័ន្ធលំនឹងដែរ ។ ប្រព័ន្ធលំនឹងគីមីមួយតាងដោយសមីការតុល្យការ : $A + B \rightleftharpoons C + D$

ការបង្កើនកំហាប់ A នៃប្រព័ន្ធប្រតិកម្ម ធ្វើឱ្យប្រព័ន្ធរងនូវភាពតានតឹង ។ ដើម្បីបន្ធូរបន្ថយភាពតានតឹងអង្គធាតុ A ខ្លះដែលបានបន្ថែមមានអំពើជាមួយ B ឱ្យផលជា C និង D បន្ថែមទៀត ។ លំនឹងគីមីដែលទទួលបានថ្មីនេះមានកំហាប់ A ធំជាងកំហាប់ A ក្នុងលំនឹងដើម តែកំហាប់ B នៅលំនឹងថ្មីតូចជាងកំហាប់ដើមវិញ ។ រូបទី 2.3 បង្ហាញពីឥទ្ធិពលនៃការបន្ថែមកំហាប់អង្គធាតុប្រតិករលើប្រព័ន្ធលំនឹង ។




*រូបទី 2.3 ក- $N_2$ , $H_2$ និង $NH_3$ មានលំនឹងក្នុងមជ្ឈដ្ឋានបិទជិត និងមានសមីការតុល្យការ :*

$$N_2(g) + 3H_2(g) \rightleftharpoons 2NH_3(g)$$

*ខ- ការបន្ថែមអាសូតជាហេតុនាំឱ្យលំនឹងដើមមានភាពតានតឹង*

*គ- លំនឹងថ្មីមានកំហាប់ $N_2$ និង $NH_3$ ធំជាងកំហាប់ដើម រីឯ $H_2$ មានកំហាប់តូចជាងកំហាប់ដើម*

ដូចគ្នានេះដែរ បើគេបន្ថែម B នាំឱ្យលំនឹងរំកិលទៅស្ដាំ ។ តែបើគេបន្ថែមកំហាប់ C ឬ D លំនឹងរំកិលទៅឆ្វេងវិញ ។

ដូច្នេះការបង្កើនកំហាប់នៃអង្គធាតុប្រតិករ ឬអង្គធាតុកកើតនៅក្នុងប្រព័ន្ធមួយដែលកំពុងមានលំនឹងធ្វើឱ្យប្រព័ន្ធនោះមានការរំកិលលំនឹងដើម្បីរំដោះភាពតានតឹង ។

ការប្រែប្រួលកំហាប់ពុំមានប៉ះពាល់ដល់តម្លៃថេរលំនឹងទេ គឺដោយសារមានបម្រែបម្រួលស្មើគ្នានៃភាគយកនិងភាគបែងរបស់កន្សោមថេរលំនឹងគីមី ។ ដូច្នេះកំហាប់ថ្មីផ្ដល់តម្លៃថេរលំនឹងដដែលពេលលំនឹងគីមីថ្មីកើនឡើង ។

លំនាំគីមីមួយចំនួនធំជាប្រតិកម្មមិនស្មើសាច់ ដែលក្នុងនោះអង្គធាតុប្រតិករ ឬអង្គធាតុកកើតមានភាពរូបខុសគ្នា ។ កំហាប់នៃអង្គធាតុរឹងសុទ្ធនិងអង្គធាតុរាវសុទ្ធពុំប្រែប្រួលទេ តាមសន្មតគេមិនសរសេរកំហាប់អង្គធាតុរឹងនិងអង្គធាតុរាវនៅក្នុងកន្សោមថេរលំនឹងទេ ។

***ឧទាហរណ៍ :*** ប្រតិកម្មបំបែក $CaCO_3$ នៅពេលប្រព័ន្ធមានលំនឹងតាងដោយសមីការតុល្យការ :

$$CaCO_3(s) \rightleftharpoons CaO(s) + CO_2(g)$$

អង្គធាតុកកើតជាអង្គធាតុរឹង និងឧស្ម័ន ។ ដោយសារ $CaCO_3$ និង CaO ជាអង្គធាតុរឹង គេមិនសរសេរនៅក្នុងកន្សោមថេរលំនឹងទេ ។ ដូច្នេះគេបានថេរលំនឹង :

$$K = [CO_2]$$

ដោយសារចំនួនម៉ូលេគុលសរុបនៃឧស្ម័ននៅអង្គខាងឆ្វេងនិងអង្គខាងស្តាំខុសគ្នា ការប្រែប្រួលសម្ពាធធ្វើឱ្យមានឥទ្ធិពលទៅលើលំនឹងនៃប្រតិកម្ម ។ សម្ពាធខ្សោយសមប្រកបសម្រាប់ប្រតិកម្មបំបែក $CaCO_3$ ឱ្យផលជា CaO និង $CO_2$ ។ សម្ពាធធំសមប្រកបសម្រាប់ប្រតិកម្មតាមទិសច្រាស គឺ $CO_2$ ចូលធ្វើប្រតិកម្មជាមួយ CaO បង្កើត $CaCO_3$ វិញ ។ ដោយសារ CaO និង $CaCO_3$ ជាអង្គធាតុរឹង ការប្រែប្រួលបរិមាណរបស់វាមិនបានធ្វើឱ្យប្រែប្រួលកំហាប់ $CO_2$ នៅពេលលំនឹងទេ ។

ចំពោះអង្គធាតុរំលាយដូចជាទឹក គេក៏មិនសរសេរកំហាប់របស់វានៅក្នុងកន្សោមថេរលំនឹងដែរ ។ ***ឧទាហរណ៍*** ការរលាយរបស់អាស៊ីតអាសេទិចដែលជាអាស៊ីតខ្សោយក្នុងទឹក ។ អាស៊ីតអាសេទិចជាអង្គធាតុរលាយនិងទឹកជាអង្គធាតុរំលាយ សមីការតុល្យការលំនឹង :

$$CH_3COOH(aq) + H_2O(\ell) \rightleftharpoons CH_3COO^-(aq) + H_3O^+(aq)$$

កន្សោមថេរលំនឹង : $K = \dfrac{[CH_3COO^-][H_3O^+]}{[CH_3COOH]}$

ករណីស្វ័យអ៊ីយ៉ុងកម្មនៃទឹក ឬអូតូប្រូតូលីសនៃទឹកដែលតាងដោយសមីការតុល្យការ :

$$2H_2O(\ell) \rightleftharpoons H_3O^+(aq) + OH^-(aq)$$

កន្សោមថេរលំនឹង : $K_w$ ឬ $K_e = [H_3O^+][OH^-]$ ។

***សំគាល់ :***

- បើថេរលំនឹង K មានតម្លៃធំខ្លាំង មានន័យថានៅសល់អង្គធាតុប្រតិករតិចតួចណាស់ដែលមិនបានចូលធ្វើប្រតិកម្ម ។
- បើថេរលំនឹង K មានតម្លៃតូចខ្លាំង មានន័យថាផលិតផលដែលកកើតមានតិចតួចណាស់ ។

*លំហាត់គំរូ* **:** នៅសីតុណ្ហភាព 798°K ប្រតិកម្មបំបែកកាល់ស្យូមកាបូណាតមានថេរលំនឹង K ស្មើ $3.35 \times 10^{-3}$ ។ ចូរកំណត់រកកំហាប់កាបូនឌីអុកស៊ីតនៅពេលប្រតិកម្មមានលំនឹង ។

***ចម្លើយ :***

សរសេរសមីការតុល្យការតាងឱ្យលំនឹងនៃប្រតិកម្ម :

$$CaCO_3(s) \rightleftharpoons CaO(s) + CO_2(g)$$

សរសេរកន្សោមថេរលំនឹង : $K = [CO_2] = 3.35 \times 10^{-3}$

ដូច្នេះកំហាប់ : $[CO_2] = 3.35 \times 10^{-3} mol\ L^{-1}$ ។

## 1.3. បម្រែបម្រួលសីតុណ្ហភាព

ក្នុងប្រតិកម្មទៅមក បើមានប្រតិកម្មតាមទិសដៅណាមួយបញ្ចេញកម្តៅ នោះប្រតិកម្មតាមទិសដៅច្រាសជាប្រតិកម្មស្រូបកម្តៅ ។ ផលដែលទទួលបានពីបម្រែបម្រួលសីតុណ្ហភាពទៅលើល្បាយលំនឹងមួយ អាស្រ័យទៅតាមភាពផ្ទុយគ្នានៃប្រតិកម្មស្រូប ឬបញ្ចេញកម្តៅ ។ ការបន្ថែមថាមពលជាសណ្ឋានកម្តៅ (បង្កើនសីតុណ្ហភាព) ជាលក្ខខណ្ឌសមប្រកបសម្រាប់ប្រតិកម្មស្រូបកម្តៅ ។ ការបន្ថយថាមពល (បញ្ចុះសីតុណ្ហភាព) ជាលក្ខខណ្ឌសមប្រកបសម្រាប់ប្រតិកម្មបញ្ចេញកម្តៅ ។ ការបង្កើនសីតុណ្ហភាពធ្វើឱ្យល្បឿនប្រតិកម្មកើនឡើងនៅក្នុងប្រព័ន្ធលំនឹងមួយ ថ្វីបើល្បឿនប្រតិកម្មតាមទិសច្រាសកើតមានឡើងមិនស្មើគ្នាយ៉ាងណាក៏ដោយ ថេរលំនឹងនៃប្រព័ន្ធនោះអាស្រ័យទៅតាមសីតុណ្ហភាពតែប៉ុណ្ណោះ ។

### ក. សំយោគអាម៉ូញ៉ាក់

ប្រតិកម្មសំយោគអាម៉ូញ៉ាក់តាមលំនាំហេបិរ ជាប្រតិកម្មបញ្ចេញកម្តៅ ក្នុងសមីការតុល្យការប្រតិកម្មមានបង្ហាញថាមពលជាកម្តៅនៅខាងអង្គធាតុកកើត ។

$$N_2(g) + 3H_2(g) \rightleftharpoons 2NH_3(g) + 92kJ$$

សីតុណ្ហភាពខ្ពស់ជាលក្ខខណ្ឌសមប្រកបដល់ប្រតិកម្មបំបែកអាម៉ូញ៉ាក់ ដែលជាប្រតិកម្មស្រូបកម្តៅ ។ ចំណែកនៅសីតុណ្ហភាពទាបជាលក្ខខណ្ឌសមប្រកបដល់ប្រតិកម្មសំយោគអាម៉ូញ៉ាក់ ដែលជាប្រតិកម្មបញ្ចេញកម្តៅ ។ ប៉ុន្តែនៅសីតុណ្ហភាពទាបប្រតិកម្មសំយោគអាម៉ូញ៉ាក់ប្រព្រឹត្តទៅយឺតណាស់ ។ នៅសីតុណ្ហភាពខ្ពស់លំនឹងកើតឡើងឆាប់រហ័ស តែកំហាប់ $NH_3$ នៅពេលប្រព័ន្ធមានលំនឹងគឺតូច ។ សីតុណ្ហភាពសមស្របសម្រាប់ប្រតិកម្មសំយោគអាម៉ូញ៉ាក់ប្រហែល 500°C និងប្រព្រឹត្តទៅនៅក្រោមសម្ពាធខ្ពស់ប្រហែល 700 – 1000atm ។

## ១. ការផលិតឌីអាសូតតេត្រាអុកស៊ីត

ឌីអាសូតតេត្រាអុកស៊ីតជាឧស្ម័នគ្មានពណ៌ ។ គេអាចផលិតវាពីឧស្ម័នអាសូតឌីអុកស៊ីត ដែលជាឧស្ម័នមានពណ៌ត្នោត ។ សមីការតុល្យការប្រតិកម្ម :

$2NO_2(g) \rightleftharpoons N_2O_4(g)$ + កម្ដៅ

ប្រតិកម្មនេះជាប្រតិកម្មបញ្ចេញកម្ដៅ ។ រូបទី 2.4 ក បង្ហាញពីល្បាយលំនឹងនៃឧស្ម័ន $NO_2$ និង $N_2O_4$ នៅសីតុណ្ហភាព 25°C ។




*រូបទី 2.4 ភាពខុសគ្នានៃសីតុណ្ហភាពធ្វើឱ្យមានការរំកិលនិងបង្កើតលំនឹងថ្មី ។*

បើគេបញ្ចុះសីតុណ្ហភាពប្រព័ន្ធឱ្យដល់ 0°C ធ្វើឱ្យប្រព័ន្ធរងភាពតានតឹង ។ ដើម្បីទប់ទល់ភាពតានតឹងប្រព័ន្ធរំកិលលំនឹងទៅស្ដាំ ឬតាមទិសដៅប្រតិកម្មបញ្ចេញកម្ដៅ ។ ការរំកិលលំនឹងនេះធ្វើឱ្យបរិមាណ $N_2O_4$ (ឧស្ម័នគ្មានពណ៌)កើនឡើង និងបរិមាណ $NO_2$ (ឧស្ម័នពណ៌ត្នោត)ថយចុះ ។ ហេតុនេះហើយទើបដបមានពណ៌ត្នោតស្រាលជាងមុន (រូបទី 2.4ខ) ។ តម្លៃថេរលំនឹង K ពេលនេះកើនឡើង ។ បើគេបង្កើនសីតុណ្ហភាពប្រព័ន្ធឱ្យដល់ 100°C នោះប្រព័ន្ធរងភាពតានតឹង ហើយក៏រំកិលលំនឹងទៅឆ្វេង ឬតាមទិសដៅប្រតិកម្មស្រូបកម្ដៅ ។ ពេលប្រព័ន្ធមានលំនឹងបរិមាណឧស្ម័ន $N_2O_4$ ថយចុះ និងបរិមាណ $NO_2$ កើនឡើង (រូបទី 2.4គ) ។ ដោយសារបរិមាណឧស្ម័ន $N_2O_4$ តិចជាងមុន ទើបតម្លៃ K ថយចុះ ។

បម្រែបម្រួលសីតុណ្ហភាពប្រព័ន្ធនាំឱ្យតម្លៃថេរលំនឹង K ប្រែប្រួល :

- ចំពោះប្រតិកម្មតាមទិសបណ្ដោយដែលជាប្រតិកម្មបញ្ចេញកម្ដៅ ការបង្កើនសីតុណ្ហភាពនាំឱ្យតម្លៃ K ថយចុះ ។ ដូចករណីប្រតិកម្ម : $2NO_2(g) \rightleftharpoons N_2O_4(g)$ + កម្ដៅ
- ចំពោះប្រតិកម្មស្រូបកម្ដៅ ដូចជាប្រតិកម្មបំបែក $CaCO_3$ ។ ថាមពលជាសណ្ឋានកម្ដៅបង្ហាញនៅអង្គខាងឆ្វេងនៃសមីការប្រតិកម្ម :

$$556kJ + CaCO_3(s) \rightleftharpoons CaO(s) + CO_2(g)$$

ការបង្កើនសីតុណ្ហភាព គឺបង្កើនថាមពលឱ្យប្រព័ន្ធធ្វើឱ្យលំនឹងរំកិលទៅស្តាំឬតាមទិសដៅប្រតិកម្មស្រូបកម្តៅ ។ ករណីនេះតម្លៃ K កើនឡើង ។

គេអាចបង្កើនល្បឿនប្រតិកម្មដោយប្រើកាតាលីករសមស្របណាមួយ ។ តែកាតាលីករគ្មានឥទ្ធិពលទៅលើបរិមាណនៃសារធាតុនៅពេលលំនឹងទេ វាគ្រាន់តែធ្វើឱ្យប្រព័ន្ធឆាប់ដល់លំនឹងតែប៉ុណ្ណោះ ។ ដូច្នេះកាតាលីករគ្មានឥទ្ធិពលទៅលើថេរលំនឹង K ទេ ។

## 2. ប្រតិកម្មឈានទៅរកសព្វ

អ៊ីយ៉ុងខ្លះ ចូលធ្វើប្រតិកម្មជាមួយគ្នាឱ្យផលជាឧស្ម័នឬកករ ឬអង្គធាតុបំបែកជាអ៊ីយ៉ុងបានតិច ។ ប្រតិកម្មបែបនេះឈានទៅរកសព្វដោយសារអ៊ីយ៉ុងទាំងនោះបានរំដោះចេញពីសូលុយស្យុងស្ទើរតែអស់ ។

### 2.1. ប្រតិកម្មកំណឧស្ម័ន

អ៊ីយ៉ុងខ្លះ ចូលធ្វើប្រតិកម្មជាមួយគ្នាឱ្យផលជាសារធាតុមិនស៊ប់ ។ សារធាតុទាំងនោះកើតមកហើយ វាក៏បែកធាតុទៅវិញភ្លាម ។ *ឧទាហរណ៍* អាស៊ីតកាបូនិច ($H_2CO_3$) ដែលកើតឡើងពីប្រតិកម្មរវាងអ៊ីយ៉ុង $H_3O^+$ និងអ៊ីយ៉ុង $CO_3^{2-}$ ។ អាស៊ីតកាបូនិចជាអង្គធាតុមិនស៊ប់ វាបំបែកធាតុជា $H_2O$ និង $CO_2$ ។

$$2H_3O^+(aq) + CO_3^{2-}(aq) \rightleftharpoons H_2CO_3(aq) + 2H_2O(\ell)$$

$$H_2CO_3(aq) \rightleftharpoons H_2O(\ell) + CO_2(g)$$

ប្រតិកម្មនេះឈានទៅរកសព្វដោយសារផលិតផលកកើតជាឧស្ម័ន $CO_2$ ដែលបានហើរចេញពីសូលុយស្យុង ហើយចូលទៅក្នុងខ្យល់ ។

### 2.2. ប្រតិកម្មឱ្យផលជាកករ




*រូបទី 2.5 អំពើរវាងអ៊ីយ៉ុង $Ag^+$ និង $Cl^-$ ឱ្យកករ AgCl*

បើគេចាក់សូលុយស្យុងសូដ្យូមក្លរួចូលក្នុងសូលុយស្យុងប្រាក់នីត្រាត គេសង្កេតឃើញកករពណ៌សកើតឡើងភ្លាម ។ កករពណ៌ស គឺប្រាក់ក្លរួដែលជាអង្គធាតុរលាយក្នុងទឹកបានតិចតួចណាស់ ។ សមីការអ៊ីយ៉ុងសព្វតាងឱ្យប្រតិកម្ម :

$$Na^+(aq) + Cl^-(aq) + Ag^+(aq) + NO_3^-(aq) \longrightarrow Na^+(aq) + NO_3^-(aq) + AgCl(s)$$

ដោយអ៊ីយ៉ុង $Na^+$ និងអ៊ីយ៉ុង $NO_3^-$ ជាអ៊ីយ៉ុងទស្សនិក ដែលមិនបានចូលធ្វើប្រតិកម្ម ។ គេអាចសរសេរសមីការអ៊ីយ៉ុងសម្រួល : $Ag^+ (aq) + Cl^- (aq) \longrightarrow AgCl(s)$

បើបរិមាណ(ចំនួនម៉ូល) NaCl ស្មើនិងបរិមាណ $AgNO_3$ ដែលចាក់បញ្ចូលគ្នា នោះក្រោយប្រតិកម្មចប់ គេសង្កេតឃើញក្នុងសូលុយស្យុងមានសល់តែអ៊ីយ៉ុង $Na^+$ និងអ៊ីយ៉ុង $NO_3^-$ ។ ចំណែកអ៊ីយ៉ុង $Ag^+$ និងអ៊ីយ៉ុង $Cl^-$ ចូលផ្សំជាមួយគ្នាឱ្យផលជា AgCl ដែលជាអង្គធាតុរលាយក្នុងទឹកបានតិចតួចណាស់ ។ ដូច្នេះក្នុងសូលុយស្យុងមានអ៊ីយ៉ុង $Ag^+$ និងអ៊ីយ៉ុង $Cl^-$ តិចណាស់ដើម្បីធ្វើប្រតិកម្មច្រាសទៅវិញ ។ ប្រតិកម្មរវាង NaCl និង $AgNO_3$ ឈានទៅរកសព្វដោយសារអង្គធាតុកកើតមួយមិនរលាយក្នុងទឹក ។

## 2.3. ប្រតិកម្មឱ្យផលជាសារធាតុបំបែកជាអ៊ីយ៉ុងបានតិច

ប្រតិកម្មបន្សាបរវាងអ៊ីយ៉ុង $H_3O^+$ ដែលបានពីសូលុយស្យុងអាស៊ីត និងអ៊ីយ៉ុង $OH^-$ ដែលបានពីសូលុយស្យុងបាស ឱ្យផលជាទឹកដែលជាអង្គធាតុបំបែកជាអ៊ីយ៉ុងបានតិច ។ ប្រតិកម្មរវាងសូលុយស្យុងអាស៊ីតក្លរីឌ្រិច និងសូលុយស្យុងសូដតាងដោយសមីការតុល្យការ :

$$Na^+ (aq) + OH^- (aq) + H_3O^+ (aq) + Cl^- (aq) \longrightarrow Na^+ (aq) + Cl^- (aq) + 2H_2O(\ell)$$

សមីការអ៊ីយ៉ុងសម្រួល :

$$H_3O^+ (aq) + OH^- (aq) \longrightarrow 2H_2O(\ell)$$

ដោយសារទឹកជាអង្គធាតុបំបែកជាអ៊ីយ៉ុងបានតិចតួច ។ ដូច្នេះអ៊ីយ៉ុង $H_3O^+$ និងអ៊ីយ៉ុង $OH^-$ ត្រូវបានរំដោះចេញពីសូលុយស្យុងស្ទើរតែអស់ ។ ប្រតិកម្មឈានទៅរកសព្វដោយសារមានអង្គធាតុកកើតមួយ ដែលជាអង្គធាតុបំបែកជាអ៊ីយ៉ុងក្នុងទឹកបានតិចតួចណាស់ ។

# 3. ផលអ៊ីយ៉ុងរួម

សូលុយស្យុងដែលមានសមាសធាតុមួយរលាយចូល ហើយបំបែកជាអ៊ីយ៉ុង(កាចុង និងអាញ៉ុង) បើគេបន្ថែមអ៊ីយ៉ុងណាមួយចូលទៅក្នុងសូលុយស្យុងនោះ ហើយធ្វើឱ្យមានកករសមាសធាតុដើមវិញ ឬបន្ថយកម្រិតអ៊ីយ៉ុងកម្មនៃសមាសធាតុដើម បាតុភូតនេះគេហៅថា **ផលអ៊ីយ៉ុងរួម** ។

## 3.1. ផលអ៊ីយ៉ុងរួមឱ្យជាកករ

គេអាចរំកិលលំនឹងនៃប្រតិកម្មណាមួយទៅតាមទិសដៅដែលគេចង់បានដោយអនុវត្តតាមគោលការណ៍ឡឺសាតឺលីយេ ។ គេមានសូលុយស្យុងសូដ្យូមក្លរួឆ្អែត ដែលមានសមីការលំនឹង :

$$NaCl(s) \rightleftharpoons Na^+ (aq) + Cl^- (aq)$$

គេរំលាយឧស្ម័នអ៊ីដ្រូសែនក្លរួទៅក្នុងសូលុយស្យុងឆ្អែតនោះ តើលំនឹងប្រែប្រួលយ៉ាងដូចម្ដេច ? ឧស្ម័នអ៊ីដ្រូសែនក្លរួរលាយក្នុងទឹកយ៉ាងខ្លាំង ហើយបំបែកជាអ៊ីយ៉ុង $H_3O^+$ និងអ៊ីយ៉ុង $Cl^-$ បានសព្វល្អ តាមសមីការតុល្យការ :

$$HCl(g) + H_2O(\ell) \rightleftharpoons H_3O^+(aq) + Cl^-(aq)$$

ការរលាយឧស្ម័នអ៊ីដ្រូសែនក្លរួក្នុងសូលុយស្យុងសូដ្យូមក្លរួឆ្អែត នាំឱ្យកំហាប់អ៊ីយ៉ុង $Cl^-$ កើនឡើង ។ ដូច្នេះការបន្ថែមឧស្ម័នអ៊ីដ្រូសែនក្លរួនាំឱ្យប្រព័ន្ធមានភាពតានតឹង ។ ដើម្បីរំដោះភាពតានតឹង អ៊ីយ៉ុង $Cl^-$ ចូលផ្សំជាមួយអ៊ីយ៉ុង $Na^+$ ឱ្យផលជាកករ (ឬក្រាម) NaCl វិញ ។ នៅលំនឹងថ្មី កំហាប់អ៊ីយ៉ុង $Cl^-$ ធំជាងកំហាប់ដើម និងកំហាប់អ៊ីយ៉ុង $Na^+$ ថយចុះ ។

## 3.2. ផលអ៊ីយ៉ុងរួមបន្ថយកម្រិតអ៊ីយ៉ុងកម្ម

អាស៊ីតអាសេទិច ជាអេឡិចត្រូលីតខ្សោយ(អាស៊ីតខ្សោយ)ក្នុងទឹកវាបំបែកជាអ៊ីយ៉ុងបានតិច ។ សូលុយស្យុងអាស៊ីតអាសេទិចដែលមានកំហាប់ 0.1M អាចបែកជាអ៊ីយ៉ុងបានតែ 1.3 % ប៉ុណ្ណោះ ឱ្យផលជាអ៊ីយ៉ុង $H_3O^+$ និងអ៊ីយ៉ុង $CH_3COO^-$ ។ សមីការលំនឹងអ៊ីយ៉ុងកម្ម :

$$CH_3COOH(aq) + H_2O(\ell) \rightleftharpoons H_3O^+(aq) + CH_3COO^-(aq)$$

សូដ្យូមអាសេតាតជាអំបិលរលាយក្នុងទឹក ហើយបំបែកជាអ៊ីយ៉ុងបានសព្វល្អតាមសមីការតុល្យការ : $CH_3COONa(s) \longrightarrow CH_3COO^-(aq) + Na^+(aq)$

បើគេយកក្រាមសូដ្យូមអាសេតាតបន្តិច ដាក់ក្នុងសូលុយស្យុងអាស៊ីតអាសេទិច នាំឱ្យកំហាប់អ៊ីយ៉ុងអាសេតាត ($CH_3COO^-$ ) កើនឡើង ។ អ៊ីយ៉ុង $CH_3COO^-$ ចូលធ្វើប្រតិកម្មជាមួយអ៊ីយ៉ុង $H_3O^+$ បង្កើតជា $CH_3COOH$ វិញ(តាមគោលការណ៍ឡឺសាតឺលីយេ) ។ កំហាប់ $CH_3COOH$ កើនឡើង រីឯកំហាប់អ៊ីយ៉ុង $H_3O^+$ ថយចុះ ។ ដូច្នេះអាស៊ីតអាសេទិចបំបែកជាអ៊ីយ៉ុងបានតិចជាងមុន ។

ជាទូទៅ សូលុយស្យុងអេឡិចត្រូលីតខ្សោយបំបែកជាអ៊ីយ៉ុងថយចុះ កាលណាគេបន្ថែមអំបិលដែលមានអ៊ីយ៉ុងណាមួយដូចអ៊ីយ៉ុងរបស់អេឡិចត្រូលីតខ្សោយនោះ ។ រូបទី 2.6 បង្ហាញពីសូលុយស្យុងអាស៊ីតអាសេទិចនៅកំហាប់ 0.25M ដែលមាន pH ប្រហែល 2.7 ។ គេយកក្រាមសូដ្យូមអាសេតាតដាក់ចូលទៅក្នុងសូលុយស្យុងអាស៊ីតអាសេទិចនេះ ។ សូលុយស្យុងថ្មី ដែលបានទទួលមាន pH ប្រហែល 4.5 ។ បញ្ជាក់ថាកំហាប់អ៊ីយ៉ុង $H_3O^+$ ថយចុះ ។ ដូច្នេះអាស៊ីតអាសេទិចបំបែកជាអ៊ីយ៉ុងបានតិចជាងមុន ។




សូលុយស្យុងអាស៊ីតអាសេទិច 0.25M មាន pH = 2.7

សូលុយស្យុងអាស៊ីតអាសេទិច 0.25M ដែលបន្ថែមគ្រាមសូដ្យូមអាសេតាតបន្តិចមាន pH= 4.49

***រូបទី2.6 ផលអ៊ីយ៉ុងរួមនៃអ៊ីយ៉ុង $CH_3COO^-$ ធ្វើឱ្យអាស៊ីត $CH_3COOH$ បំបែកជាអ៊ីយ៉ុងថយចុះ ។***

***លំហាត់គំរូ1 :*** គេមានសមីការខាងក្រោម :$2A(g) + B(g) \rightleftharpoons 2C(g)$ $K = 1.0\times10^{-8}$ ។ បើគេយក 0.40mol នៃអង្គធាតុ A និង 0.25mol នៃអង្គធាតុ B ទៅដាក់ក្នុងធុងបិទជិត ដែលមានមាឌ 1L ហើយគេទុកឱ្យប្រតិកម្មនេះមានលំនឹង ។ ចូរកំណត់រកកំហាប់ C នៅពេលលំនឹង ។

***ចម្លើយ :***

| | | | |
|---|---|---|---|
| សមីការតុល្យការ : | $2A(g)$ + | $B(g)$ $\rightleftharpoons$ | $2C(g)$ |
| កំហាប់ដើម : | 0.40M | 0.25M | 0.00 |
| កំហាប់ប្រែប្រួលដោយប្រតិកម្ម : | 2x | x | 2x |
| កំហាប់ពេលលំនឹង : | 0.40−2x | 0.25 − x | 2x |

$$K = \frac{[C]^2}{[A]^2[B]} = \frac{[2x]^2}{(0.4 - 2x)^2(0.25 - x)}$$

ដោយតម្លៃ K មានតម្លៃតូចពេក នាំឱ្យយើងដឹងថា x ក៏មានតម្លៃតូចខ្លាំងណាស់ដែរ ។ ដូច្នេះតម្លៃ x និង 2x អាចចោលបាន កាលណាគេយកតម្លៃនេះទៅដកនឹងតម្លៃដែលធំ 0.4 និង 0.25 ។

គេបាន : $K = \frac{4x^2}{(0.40)^2(0.25)} = 1.0\times10^{-8}$

$$\frac{x^2}{0.010} = 1.0\times10^{-8}$$

$$x = \sqrt{1.0\times10^{-10}} = 1.0\times10^{-5}M$$

$$[C] = 2x$$

$$[C] = 2 \times 1.0\times10^{-5}M$$

$[C] = 2.0 \times 10^{-5}M$

ផ្ទៀងផ្ទាត់តម្លៃ K

$$K = \frac{[C]^2}{[A]^2[B]} = \frac{(2.0 \times 10^{-5})^2}{(0.40)^2(0.25)} = 1.0 \times 10^{-8}$$

តម្លៃ K នេះស្មើនឹងតម្លៃ K ដែលគេឱ្យក្នុងលំហាត់ ។

ដូច្នេះ តម្លៃ $0.40 - 2x = 0.40$ និង $0.25 - x = 0.50$ អាចទទួលយកបាន ។

***លំហាត់គំរូ 2 :*** ប្រតិកម្មខាងក្រោមនេះប្រព្រឹត្តទៅនៅសីតុណ្ហភាព 400°C :

$$H_2(g) + I_2(g) \rightleftharpoons 2HI(g) \quad K = 50.0$$

បើគេយក 0.0800mol នៃអ៊ីដ្រូសែននិង 0.0800mol នៃអ៊ីយ៉ូតទៅដាក់ក្នុងផ្លាំង 1.00L ហើយបិទជិតនិងទុកប្រព័ន្ធឱ្យមានលំនឹង ។ ចូរកំណត់រកកំហាប់អ៊ីយ៉ូតនៅពេលលំនឹង ។

***ចម្លើយ:***

| | | $H_2(g)$ | + $I_2(g)$ $\rightleftharpoons$ | $2HI(g)$ |
|---|---|---|---|---|
| សមីការតុល្យការ | : | $H_2(g)$ | + $I_2(g)$ $\rightleftharpoons$ | $2HI(g)$ |
| កំហាប់ដើម | : | 0.0800M | 0.0800M | 0.00 |
| កំហាប់ប្រែប្រួលដោយប្រតិកម្ម | : | x | x | 2x |
| កំហាប់ពេលលំនឹង | : | 0.0800 − x | 0.0800 − x | 2x |

វិធីទី 1 : $K = \frac{[HI]^2}{[H_2]\ [I_2]} = \frac{(2x)^2}{(0.0800 - x)^2} = 50.0$

បើគេមិនគិតតម្លៃ x ចំពោះផលដក $0.0800 - x$ គេបាន :

$$K = \frac{(2x)^2}{(0.0800)^2} = 50.0$$

$4x^2 = 50.0 \times (0.0800)^2$

$x = \frac{0.0800}{2}\sqrt{50.0}$

$x = 0.283$

គេសង្កេតឃើញ x មានតម្លៃធំជាង 0.0800 ។ ដូច្នេះតម្លៃ x មិនអាចចោលបានទេ ។

**វិធីទី 2** : $K = \frac{(2x)^2}{(0.0800 - x)^2} = 50.0$

$\frac{2x}{0.0800 - x} = \sqrt{50.0} = 7.07$

$x = 0.0624 mol \cdot L^{-1}$ ឬ $0.0624M$

គេបាន : $[I_2] = 0.0800 - x = 0.0800 - 0.0624$

$[I_2] = 0.0176 mol \cdot L^{-1}$

ផ្ទៀងផ្ទាត់ : $K = \frac{(2x)^2}{(0.0800 - x)^2} = \frac{4(0.0624)^2}{(0.0176)^2} = 50.3$

ដូច្នេះវិធីនេះអាចទទួលយកបាន ។

## មេរៀនសង្ខេប

- កត្តាដែលនាំឱ្យរំកិលលំនឹងនៃប្រព័ន្ធ គឺសម្ពាធ កំហាប់ និងសីតុណ្ហភាព ។
- សម្ពាធមានឥទ្ធិពលតែទៅលើប្រព័ន្ធដែលមានភាពរូបជាឧស្ម័ន ហើយចំនួនម៉ូលេគុលសរុបនៅខាងអង្គធាតុប្រតិករខុសគ្នាពីចំនួនម៉ូលេគុលសរុបនៅខាងអង្គធាតុកកើត ។
- ការបង្កើនកំហាប់នៃអង្គធាតុប្រតិករ ឬអង្គធាតុកកើតទៅក្នុងលំនឹងនៃប្រតិកម្មណាមួយ ធ្វើឱ្យប្រព័ន្ធនេះរំកិលលំនឹងទៅតាមទិសដៅបន្ថយកំហាប់ ។
- ការបង្កើនសីតុណ្ហភាពធ្វើឱ្យប្រព័ន្ធរំកិលលំនឹងតាមទិសដៅប្រតិកម្មស្រូបកម្ដៅ ។ ការបញ្ចុះសីតុណ្ហភាពធ្វើឱ្យប្រព័ន្ធរំកិលលំនឹងតាមទិសដៅប្រតិកម្មបញ្ចេញកម្ដៅ ។ ការប្រែប្រួលសីតុណ្ហភាពនាំឱ្យប្រែប្រួលតម្លៃ K ។
- អ៊ីយ៉ុងខ្លះធ្វើប្រតិកម្មជាមួយគ្នាឱ្យផលជាឧស្ម័ន ឬកករ ឬអង្គធាតុបំបែកជាអ៊ីយ៉ុងបានតិចតួច ។ ប្រតិកម្មបែបនេះឈានទៅរកសព្វដោយសារអ៊ីយ៉ុងទាំងនោះរំដោះចេញពីសូលុយស្យុងស្ទើរតែអស់ ។
- សូលុយស្យុងអេឡិចត្រូលីតខ្សោយបំបែកជាអ៊ីយ៉ុងមានកម្រិតថយចុះ កាលណាគេបន្ថែមអំបិលដែលមានអ៊ីយ៉ុងណាមួយដូចអ៊ីយ៉ុងអេឡិចត្រូលីតខ្សោយនោះ ។

## ? សំណួរនិងលំហាត់

1. ចូរឱ្យឈ្មោះកត្តាទាំងបីដែលនាំឱ្យរំខានដល់លំនឹង ។
2. ចូររៀបរាប់ស្ថានភាពទាំងបីដែលអ៊ីយ៉ុងចូលធ្វើប្រតិកម្មជាមួយគ្នាឈានទៅរកសព្វ ។
3. ចូររៀបរាប់ពីផលអ៊ីយ៉ុងរួម ។
4. ចូរព្យាករណ៍ទិសដៅរំកិលលំនឹងនៃប្រព័ន្ធខាងក្រោមកាលណាគេបង្កើនសម្ពាធលើវា ។

   ក. $3O_2(g) \rightleftharpoons 2O_3(g)$

   ខ. $H_2(g) + Cl_2(g) \rightleftharpoons 2HCl(g)$

   គ. $2N_2(g) + O_2(g) \rightleftharpoons 2N_2O(g)$

   ឃ. $SO_2(g) + \frac{1}{2}O_2(g) \rightleftharpoons SO_3(g)$ ។

5. ចូរព្យាករណ៍ទិសដៅរំកិលលំនឹងនៃប្រព័ន្ធខាងក្រោមកាលណាគេបន្ថយសម្ពាធទៅលើវា ។

   ក. $2H_2O_2(aq) \rightleftharpoons 2H_2O(\ell) + O_2(g)$

   ខ. $NH_4Cl(s) \rightleftharpoons NH_3(g) + HCl(g)$

   គ. $CO(g) + H_2O(g) \rightleftharpoons CO_2(g) + H_2(g)$

   ឃ. $N_2(g) + O_2(g) \rightleftharpoons 2NO(g)$ ។

6. តើលំនឹងនីមួយៗខាងក្រោមរំកិលទៅទិសដៅណាមួយ ?

   ក. បើគេរំដោះ $O_2$ ចេញពីប្រព័ន្ធ :

   $$4NH_3(g) + 5O_2(g) \rightleftharpoons 4NO(g) + 6H_2O(g)$$

   ខ. បើគេបន្ថែម $O_2$ ឱ្យទៅប្រព័ន្ធ :

   $$2Cl_2(g) + O_2(g) \rightleftharpoons 2Cl_2O(g)$$

   គ. បើគេបន្ថែម C ឱ្យទៅប្រព័ន្ធ :

   $$C(s) + \frac{1}{2}O_2(g) \rightleftharpoons CO(g)$$ ។

7. តើលំនឹងប្រែប្រួលដូចម្តេចបើគេឱ្យប្រព័ន្ធលំនឹងនីមួយៗរងនូវបុព្វហេតុដូចខាងក្រោម ?

   ក. បង្កើនកម្តៅប្រព័ន្ធ :

   $$CO(g) + H_2O(g) \rightleftharpoons CO_2(g) + H_2(g) + \text{កម្តៅ}$$

   ខ. បន្ថែមកាតាលីករឱ្យប្រព័ន្ធ :

   $$CH_4(g) + H_2O(g) \xrightleftharpoons{\text{កម្តៅ}} CO(g) + 3H_2(g)$$

គ. បន្ថែមឧស្ម័ន $CO_2$ ឱ្យប្រព័ន្ធ :

$$CaCO_3(s) + H_2O(\ell) + CO_2(g) \rightleftharpoons Ca(HCO_3)_2(aq)$$

ឃ. បញ្ចុះសីតុណ្ហភាពប្រព័ន្ធ :

$$2SO_2(g) + O_2(g) \rightleftharpoons 2SO_3(g) + \text{កម្តៅ}$$ ។

8. ចូររកអត្ថសញ្ញាណអ៊ីយ៉ុងរួមចំពោះស្ថានភាពលំនឹងនៃប្រព័ន្ធដូចខាងក្រោម ។

ក. គេបន្ថែម NaCl 10g ទៅក្នុងសូលុយស្យុងអាស៊ីតក្លរីឌ្រិច ដែលមានកំហាប់ $1.0 mol.L^{-1}$ ។

ខ. គេបន្ថែមសូលុយស្យុង HCOONa ចំនួន 100mL នៅកំហាប់ 2M ទៅក្នុងសូលុយស្យុង HCOOH ដែលមានកំហាប់ 2M ។

9. គេមានប្រព័ន្ធលំនឹង : $2CO_2(g) \rightleftharpoons 2CO(g) + O_2(g)$ នៅលក្ខខណ្ឌលំនឹងសមស្របមួយ ល្បឿនប្រតិកម្មបំបែក $CO_2$ មានតម្លៃ $4.55\times10^{-4} mol.L^{-1}s^{-1}$ ។

ក. តើល្បឿនប្រតិកម្មបន្សំរវាង CO និង $O_2$ នៅលំនឹងនេះមានតម្លៃប៉ុន្មាន ?

ខ. តើល្បឿនប្រតិកម្មបន្សំរវាង CO និង $O_2$ នៅពេលចាប់ផ្តើមប្រតិកម្មប៉ុន្មាន ?

មេរៀនទី

# 3 លំនឹងនៃអាស៊ីត បាស និងអំបិល

ចប់មេរៀននេះ សិស្សអាច

- ពន្យល់ពីបញ្ញត្តិថេរអ៊ីយ៉ុងកម្មនៃអាស៊ីតនិងសរសេរកន្សោមថេរលំនឹងរបស់វា ។
- រំលឹកពីថេរអ៊ីយ៉ុងកម្មនៃទឹក ។
- បកស្រាយអ៊ីដ្រូលីសនៃអាញ៉ុងនិងកាចុង ។
- ពន្យល់និងធ្វើសូលុយស្យុងតំប៉ុង ។

## 1. ថេរអ៊ីយ៉ុងកម្មនៃអាស៊ីតខ្សោយ

នៅសីតុណ្ហភាពបន្ទប់ សូលុយស្យុងអាស៊ីតអាសេទិចនៅកំហាប់ 0.1M មានអាស៊ីតតែ 1.3 % បានបែកជាអ៊ីយ៉ុង រីឯ 98.7 % ទៀតមិនបានបែកជាអ៊ីយ៉ុងទេ ។ នៅក្នុងសូលុយស្យុងមានប្រភេទគីមី $CH_3COOH$ , $H_3O^+$ និង $CH_3COO^-$ ។ សមីការលំនឹងអ៊ីយ៉ុងកម្មនៃអាស៊ីតអាសេទិច :

$$CH_3COOH(aq) + H_2O(\ell) \rightleftharpoons H_3O^+(aq) + CH_3COO^-(aq)$$

កន្សោមថេរលំនឹងសរសេរ : $K = \dfrac{[H_3O^+][CH_3COO^-]}{[CH_3COOH][H_2O]}$

គ្រប់សូលុយស្យុងរាវ ដែលទឹកជាអង្គធាតុរំលាយ ហើយមានបរិមាណច្រើនលើសលុប គេចាត់ទុកកំហាប់របស់វាថេរ ($55.5 mol\ L^{-1}$) នៅពេលប្រព័ន្ធវិវត្ត ។ ដោយ K និង $[H_2O]$ មានតម្លៃថេរនាំឱ្យផលគុណ $K[H_2O]$ ក៏មានតម្លៃថេរដែរ ។ គេតាង $K[H_2O] = K_a$

ដូច្នេះ $K_a = \dfrac{[H_3O^+][CH_3COO^-]}{[CH_3COOH]}$

$K_a$ ហៅថា ថេរអ៊ីយ៉ុងកម្មនៃអាស៊ីត ។ ថេរអ៊ីយ៉ុងកម្មនៃអាស៊ីតមិនប្រែប្រួលនៅសីតុណ្ហភាពកំណត់ណាមួយ តែវាប្រែប្រួលនៅពេលសីតុណ្ហភាពប្រែប្រួល ។

ដើម្បីកំណត់តម្លៃ $K_a$ នៃអាស៊ីតអាសេទិច គេត្រូវស្គាល់កំហាប់ប្រភេទគីមី : $H_3O^+$ , $CH_3COO^-$ និង $CH_3COOH$ តាមរយៈពិសោធន៍វាស់ pH នៃសូលុយស្យុងអាស៊ីតអាសេទិច ។

តារាងទី 3.1 អ៊ីយ៉ុងកម្មនៃអាស៊ីតអាសេទិចនៅសីតុណ្ហភាព 25°C

| កំហាប់ដើម ($C_a$) | % អ៊ីយ៉ុងកម្ម ($\alpha$) | $[H_3O^+]$ | $[CH_3COOH]$ សល់ | $K_a$ |
|---|---|---|---|---|
| 0.100M | 1.33 | 0.00133M | 0.0987M | $1.79 \times 10^{-5}$ |
| 0.0500M | 1.89 | 0.000945M | 0.0491M | $1.82 \times 10^{-5}$ |
| 0.0100M | 4.17 | 0.000417M | 0.00958M | $1.81 \times 10^{-5}$ |
| 0.0010M | 12.6 | 0.000126M | 0.000874M | $1.82 \times 10^{-5}$ |

***សំគាល់ :*** $\alpha = \frac{[H_3O^+] \times 100}{C_a}$ ឬ $\frac{[CH_3COO^-] \times 100}{C_a}$ ។

នៅសីតុណ្ហភាពថេរ បើគេបង្កើនកំហាប់អ៊ីយ៉ុង $CH_3COO^-$ ដោយបន្ថែមអំបិល $CH_3COONa$ ទៅក្នុងសូលុយស្យុងអាស៊ីតអាសេទិចនាំឱ្យមានការរំកិលលំនឹងអ៊ីយ៉ុងកម្មនៃអាស៊ីតអាសេទិច (តាមគោលការណ៍ឡឺសាតឺលីយេ) ។ ការរំកិលលំនឹងនេះនាំឱ្យ $[H_3O^+]$ ថយចុះ រីឯ $[CH_3COOH]$ កើនឡើងវិញ ។ ដូច្នេះថេរលំនឹងថ្មី $K_a$ នៅរក្សាតម្លៃដដែល ។

***លំហាត់គំរូ :*** សូលុយស្យុងអាស៊ីត HA មួយនៅកំហាប់ 0.1M មាន pH = 2.2 ។ ចូរកំណត់រកថេរអ៊ីយ៉ុងកម្មនៃអាស៊ីត HA ។ គេឱ្យ : $10^{0.8} = 6.3$

***ចម្លើយ :***

រកកំហាប់អ៊ីយ៉ុង $H_3O^+$ ។

$[H_3O^+] = 10^{-pH} = 10^{-2.2}M$

$[H_3O^+] = 10^{-3} \times 10^{0.8} = 6.3 \times 10^{-3}M$

សមីការតុល្យការអ៊ីយ៉ុងកម្មនៃអាស៊ីត HA

| | $HA\ (aq) + H_2O\ (\ell)$ | $\rightleftharpoons$ $H_3O^+\ (aq)$ | $+\ A^-\ (aq)$ |
|---|---|---|---|
| កំហាប់ដើម : | 0.1M | 0 | 0 |
| កំហាប់ប្រែប្រួលដោយប្រតិកម្ម : | 0.0063M | 0.0063M | 0.0063M |
| កំហាប់ពេលលំនឹង : | (0.1– 0.0063)M | 0.0063M | 0.0063M |

$$K_a = \frac{[H_3O^+][A^-]}{[HA]} = \frac{0.0063 \times 0.0063}{(0.1 - 0.0063)} = \frac{(0.0063)^2}{0.0937} = 4.23 \times 10^{-4}$$ ។

## 2. ថេរអ៊ីយ៉ុងកម្មនៃទឹក

យើងបានសិក្សាស្វ័យអ៊ីយ៉ុងកម្មនៃទឹក(អូតូប្រូតូលីសនៃទឹក)នៅជំពូកទី3 មេរៀនទី3 ។ ទឹកអាចមានអំពើដូចអាស៊ីតផង ឬបាសផង ។ ទឹកមានអំពើជាមួយគ្នាតាមសមីការតុល្យការ :

$$H_2O\ (\ell) + H_2O\ (\ell) \rightleftharpoons H_3O^+\ (aq) + OH^-\ (aq)$$

អាស៊ីត បាស អាស៊ីត បាស

ប្រតិកម្មនេះហៅថា ស្វ័យអ៊ីយ៉ុងកម្ម ឬអូតូប្រូតូលីស ។ កំហាប់អ៊ីយ៉ុង $H_3O^+$ និងអ៊ីយ៉ុង $OH^-$ តូចណាស់នៅពេលមានលំនឹង ។ កន្សោមថេរអ៊ីយ៉ុងកម្មនៃទឹក :

$K_w$ ឬ $K_c = [H_3O^+][OH^-]$

នៅសីតុណ្ហភាព 25°C ទឹកសុទ្ធមាន : $[H_3O^+] = [OH^-] = 1.0 \times 10^{-7}M$

$K_w = [H_3O^+][OH^-] = (1.0 \times 10^{-7})^2 = 1.0 \times 10^{-14}$ ។

## 3. អ៊ីដ្រូលីសនៃអំបិល

អំបិលបានកើតឡើងពីប្រតិកម្មបន្សាបរវាងអាស៊ីតប្រុងស្ទែតនិងបាសប្រុងស្ទែត ។ ពេលអំបិលរលាយក្នុងទឹក វាបំបែកជាអ៊ីយ៉ុងវិជ្ជមាន(កាចុង)ដែលបានពីបាសនិងអ៊ីយ៉ុងអវិជ្ជមាន(អាញ៉ុង)ដែលបានពីអាស៊ីត ។ អំបិលខ្លះរលាយក្នុងទឹកឱ្យមជ្ឈដ្ឋានណឺតដែលមាន pH ស្មើ 7 ដូចជាអំបិល NaCl $KNO_3$... ។ អំបិល $Na_2CO_3$ រលាយក្នុងទឹកឱ្យមជ្ឈដ្ឋានបាសដែលមាន pH ធំជាង 7 ។ អំបិល $NH_4Cl$ រលាយក្នុងទឹកឱ្យមជ្ឈដ្ឋានអាស៊ីតដែល pH តូចជាង 7 ។

អ៊ីយ៉ុងដែលបានពីអាស៊ីតខ្សោយ ឬបាសខ្សោយមានអំពើជាមួយទឹក ឱ្យសូលុយស្យុងដែលមាន pH ធំជាង ឬតូចជាង 7 ។ អំពើរបស់ទឹកជាមួយអ៊ីយ៉ុងនៃអំបិលហៅថា អ៊ីដ្រូលីស ។

### 3.1. អ៊ីដ្រូលីសនៃអាញ៉ុង

អ៊ីដ្រូលីសនៃអាញ៉ុងជាអំពើរវាងអ៊ីយ៉ុងអវិជ្ជមានជាមួយទឹកឱ្យសូលុយស្យុងបាស ។ តាមន័យប្រុងស្ទែត អាញ៉ុងនៃអំបិលជាបាសឆ្លាស់នៃអាស៊ីតដែលបង្កើតវា ។

តាង HA ជាអាស៊ីតខ្សោយដែលមានអំពើជាមួយទឹកឱ្យផលជាអាញ៉ុង $A^-$ និងអ៊ីយ៉ុង $H_3O^+$ ។ សមីការលំនឹង :

$$HA\ (aq) + H_2O\ (\ell) \rightleftharpoons H_3O^+\ (aq) + A^-\ (aq)$$

អាស៊ីត បាស អាស៊ីត បាស

$A^-$ ជាបាសឆ្លាស់នៃអាស៊ីត HA និង $H_2O$ ជាបាសឆ្លាស់នៃអាស៊ីត $H_3O^+$ ។ កន្សោមថេរលំនឹងអ៊ីយ៉ុងកម្ម : $K_a = \frac{[H_3O^+][A^-]}{[HA]}$

អាញ៉ុង $A^-$ ជាបាសឆ្លាស់នៃអាស៊ីតខ្សោយ វាទទួលប្រូតុងពីម៉ូលេគុលទឹកឱ្យផលជាអាស៊ីត និងអ៊ីយ៉ុង $OH^-$ តាមសមីការ :$A^-(aq) + H_2O(\ell) \rightleftharpoons HA(aq) + OH^-(aq)$

អ៊ីដ្រូលីសនៃអាញ៉ុង $A^-$ ធ្វើឱ្យកំហាប់អ៊ីយ៉ុង $OH^-$ កើនឡើងនៅក្នុងសូលុយស្យុង ។ ហេតុដូច្នេះហើយបានជាសូលុយស្យុងក្លាយជាសូលុយស្យុងបាស ។

កាលណាតម្លៃ $K_a$ នៃអាស៊ីត HA កាន់តែតូច(អាស៊ីតកាន់តែខ្សោយ)អាញ៉ុង $A^-$ ចាប់យកប្រូតុងពីម៉ូលេគុលទឹកកាន់តែងាយស្រួល បណ្តាលឱ្យបរិមាណអ៊ីយ៉ុង $OH^-$ កាន់តែច្រើន ។

ដូច្នេះ អាស៊ីត HA កាន់តែខ្សោយ បាសឆ្លាស់ $A^-$ កាន់ខ្លាំង ។

សូដ្យូមកាបូណាតរលាយក្នុងទឹក បែកជាអ៊ីយ៉ុង $Na^+$ និងអ៊ីយ៉ុង $CO_3^{2-}$ ។

$$Na_2CO_3(s) \longrightarrow 2Na^+(aq) + CO_3^{2-}(aq)$$

សូលុយស្យុង $Na_2CO_3$ ជាសូលុយស្យុងបាសខ្លាំង ។ អ៊ីយ៉ុង $Na^+$ គ្មានអំពើជាមួយទឹក តែអ៊ីយ៉ុង $CO_3^{2-}$ ចាប់យកប្រូតុងពីម៉ូលេគុលទឹក ឱ្យផលជាអ៊ីយ៉ុង $HCO_3^-$ (បំបែកជាអ៊ីយ៉ុងបានតិច)និងអ៊ីយ៉ុង $OH^-$ ។

$$CO_3^{2-}(aq) + H_2O(\ell) \rightleftharpoons HCO_3^-(aq) + OH^-(aq)$$

នៅពេលលំនឹងកំហាប់អ៊ីយ៉ុង $OH^-$ កើនឡើង ចំណែកកំហាប់អ៊ីយ៉ុង $H_3O^+$ ថយចុះ តែផលគុណអ៊ីយ៉ុងកម្មនៃទឹក $K_w = [H_3O^+][OH^-]$ នៅរក្សាតម្លៃថេរនៅសីតុណ្ហភាពកំណត់មួយ ។ ដូច្នេះ pH នៃសូលុយស្យុងធំជាង 7 ដែលជា pH សូលុយស្យុងបាស ។

***លំហាត់គំរូ :*** ប៉ូតាស្យូមនីទ្រីត ($KNO_2$) រលាយក្នុងទឹកឱ្យសូលុយស្យុងបាស ។ ហេតុដូចម្តេចបានជាសូលុយស្យុងរបស់វាជាសូលុយស្យុងបាស ? ចូរពន្យល់ ។

***ចម្លើយ :***

ប៉ូតាស្យូមនីទ្រីតរលាយក្នុងទឹកឱ្យផលជាអ៊ីយ៉ុង $K^+$ និងអ៊ីយ៉ុង $NO_2^-$ ។ អ៊ីយ៉ុង $K^+$ គ្មានប្រតិកម្មជាមួយទឹក ។ ចំណែកអ៊ីយ៉ុង $NO_2^-$ មានប្រតិកម្មជាមួយទឹកឱ្យផលជាអ៊ីយ៉ុង $OH^-$ ។

$K^+(aq) + H_2O(\ell) \longrightarrow$ គ្មានប្រតិកម្ម

$$NO_2^-(aq) + H_2O(\ell) \rightleftharpoons HNO_2(aq) + OH^-(aq)$$

ក្នុងសូលុយស្យុងមានកំហាប់ $[OH^-]$ ធំជាងកំហាប់ $[H_3O^+]$ ។ ដូច្នេះសូលុយស្យុងជាសូលុយស្យុងបាស ។

## 3.2. អ៊ីដ្រូលីសនៃកាចុង

អ៊ីដ្រូលីសនៃកាចុងជាអំពើរវាងអ៊ីយ៉ុងវិជ្ជមានជាមួយទឹកឱ្យសូលុយស្យុងអាស៊ីត ។ តាមន័យប្រុងស្ទេត កាចុងនៃអំបិលជាអាស៊ីតឆ្លាស់នៃបាសដែលបង្កើតវា ។ កាចុងក៏អាចផ្តល់ប្រូតុងបានដែរ ។ កាចុងជាអាស៊ីតខ្លាំងកាលណាកាចុងនៃអំបិលនោះបានកើតឡើងពីបាសខ្សោយ ។ កាចុងផ្តល់ប្រូតុងឱ្យទៅម៉ូលេគុលទឹកបង្កើតជាអ៊ីយ៉ុង $H_3O^+$ ។ នៅពេលអ៊ីដ្រូលីសនៃកាចុងមានលំនឹង កំហាប់ $H_3O^+$ កើនឡើង ។

តាង B ដែលជាបាសខ្សោយមានអំពើជាមួយទឹក តាមសមីការតុល្យការ :

$$B\ (aq) + H_2O\ (\ell) \rightleftharpoons BH^+(aq) + OH^-(aq)$$

ថេរលំនឹងអ៊ីយ៉ុងកម្មនៃបាស : $K_b = \frac{[BH^+][OH^-]}{[B]}$

អ៊ីដ្រូលីសនៃកាចុង $BH^+$ គេទទួលបានបាសខ្សោយ B និងអ៊ីយ៉ុង $H_3O^+$ ។

$$\underset{\text{អាស៊ីត}}{BH^+(aq)} + \underset{\text{បាស}}{H_2O\ (\ell)} \rightleftharpoons \underset{\text{អាស៊ីត}}{H_3O^+(aq)} + \underset{\text{បាស}}{B\ (aq)}$$

តម្លៃ $K_b$ នៃបាស B កាន់តែតូច ការផ្តល់ប្រូតុងរបស់ $BH^+$ កាន់តែងាយស្រួល និងនាំឱ្យបរិមាណអ៊ីយ៉ុង $H_3O^+$ កាន់តែច្រើន ។

ដូច្នេះ **បាសកាន់តែខ្សោយ អាស៊ីតឆ្លាស់របស់វាកាន់តែខ្លាំង ។**

***ឧទាហរណ៍*** អាម៉ូញ៉ូមក្លរ ($NH_4Cl$) រលាយក្នុងទឹក វាបំបែកជាអ៊ីយ៉ុងអាម៉ូញ៉ូម ( $NH_4^+$ ) និងអ៊ីយ៉ុងក្លរ ($Cl^-$ ) ។ ហើយសូលុយស្យុងរបស់វាជាសូលុយស្យុងអាស៊ីត ។

$$NH_4Cl\ (s) \longrightarrow NH_4^+(aq) + Cl^-(aq)$$

អ៊ីយ៉ុង $Cl^-$ ដែលជាបាសឆ្លាស់នៃអាស៊ីតខ្លាំង HCl គ្មានអំពើជាមួយទឹកទេ ។ ចំណែកអ៊ីយ៉ុង $NH_4^+$ ដែលជាអាស៊ីតឆ្លាស់នៃបាសខ្សោយ $NH_3$ វាផ្តល់ប្រូតុងឱ្យទៅម៉ូលេគុលទឹកតាមសមីការតុល្យការ

$$NH_4^+(aq) + H_2O\ (\ell) \rightleftharpoons NH_3\ (aq) + H_3O^+(aq)$$

ពេលអ៊ីដ្រូលីសនៃកាចុង $NH_4^+$ មានលំនឹង កំហាប់អ៊ីយ៉ុង $H_3O^+$ កើនឡើង ធ្វើឱ្យសូលុយស្យុងមាន pH តូចជាង 7 ។ ដូច្នេះសូលុយស្យុងជាសូលុយស្យុងអាស៊ីត ។

តារាងទី 3.2 តម្លៃ $K_a$ នៃអាស៊ីតនៅសីតុណ្ហភាព 25°C

| អាស៊ីត | រូបមន្ត | $K_a$ |
| --- | --- | --- |
| អាស៊ីតអាសេទិច | $CH_3COOH$ | $1.8 \times 10^{-5}$ |
| អាស៊ីតផរមិច | $HCOOH$ | $1.7 \times 10^{-4}$ |
| អាស៊ីតភ្លុយអរីឌ្រិច | $HF$ | $6.7 \times 10^{-4}$ |
| អាស៊ីតស៊ុលភីឌ្រិច | $H_2S$ | $1.0 \times 10^{-7}$ |
| អ៊ីយ៉ុងអ៊ីដ្រូសែណូស៊ុលផួ | $HS^-$ | $1.0 \times 10^{-14}$ |
| អាស៊ីតនីត្រឺ | $HNO_2$ | $4.5 \times 10^{-4}$ |
| ផេណុល | $C_6H_5OH$ | $1.3 \times 10^{-10}$ |

តារាងទី 3.3 តម្លៃ $K_b$ នៃបាសនៅសីតុណ្ហភាព 25°C

| បាស | រូបមន្ត | $K_b$ |
| --- | --- | --- |
| អាម៉ូញ៉ាក់ | $NH_3$ | $1.8 \times 10^{-5}$ |
| មេទីលអាមីន | $CH_3NH_2$ | $4.4 \times 10^{-4}$ |
| ពីរីឌីន | $C_5H_5N$ | $2.3 \times 10^{-9}$ |

***សំគាល់ :***

- អំបិលដែលកើតពីអាស៊ីតខ្លាំងនិងបាសខ្លាំង រលាយក្នុងទឹកឱ្យសូលុយស្យុងណឺត ពីព្រោះកាចុងនៃបាសខ្លាំងនិងអាញ៉ុងនៃអាស៊ីតខ្លាំងគ្មានប្រតិកម្មជាមួយទឹក ។

  ***ឧទាហរណ៍ :*** អំបិល $KCl$ , $NaNO_3$ ... ។

- អំបិលដែលកើតពីអាស៊ីតខ្សោយ និងបាសខ្លាំង រលាយក្នុងទឹកឱ្យសុលូយស្យុងបាស ពីព្រោះអាញ៉ុងនៃអំបិលមានប្រតិកម្មអ៊ីដ្រូលីសឱ្យផលជាអ៊ីយ៉ុង $OH^-$ ។

  ***ឧទាហរណ៍ :*** អំបិល $CH_3COONa$ , $HCOONa$ ... ។

- អំបិលដែលកើតពីអាស៊ីតខ្លាំងនិងបាសខ្សោយ រលាយក្នុងទឹកឱ្យសូលុយស្យុងអាស៊ីត ពីព្រោះកាចុងនៃអំបិលមានប្រតិកម្មអ៊ីដ្រូលីសឱ្យផលជាអ៊ីយ៉ុង $H_3O^+$ ។

  ***ឧទាហរណ៍ :*** អំបិល $NH_4Cl$ ... ។

• អំបិលដែលកើតពីអាស៊ីតខ្សោយនិងបាសខ្សោយ រលាយក្នុងទឹកអាចឱ្យសូលុយស្យុងណឺត ឬ សូលុយស្យុងអាស៊ីត ឬសូលុយស្យុងបាស ។

***ឧទាហរណ៍ :*** សូលុយស្យុងអំបិល $CH_3COONH_4$ រលាយក្នុងទឹកឱ្យសូលុយស្យុងណឺត ។

***លំហាត់គំរូ :*** គណនាកំហាប់អ៊ីយ៉ុងអាម៉ូញ៉ូមនៅក្នុងសូលុយស្យុងអាម៉ូញ៉ាក់ ដែលមានកំហាប់ 0.025M ។

***ចម្លើយ :***

សមីការតុល្យការអ៊ីយ៉ុងកម្ម :

| | | | | |
|---|---|---|---|---|
| | $NH_3\ (aq) + H_2O(\ell)$ | $\rightleftharpoons$ | $NH_4^+\ (aq)$ | $+OH^-(aq)$ |
| កំហាប់ដើម | : 0.025M | | 0 | 0 |
| កំហាប់ប្រែប្រួលដោយប្រតិកម្ម | : x | | x | x |
| កំហាប់លំនឹង | : 0.025 − x | | x | x |

$$K_b = \frac{[NH_4^+][OH^-]}{[NH_3]} = \frac{x^2}{0.025 - x} = 1.8 \times 10^{-5}$$

ដោយ x មានតម្លៃតូច នាំឱ្យ $0.025 - x \simeq 0.025$

$x^2 = 4.5 \times 10^{-7}$

$x = 6.7 \times 10^{-4}$

ដូច្នេះ $[NH_4^+] = 6.7 \times 10^{-4}M$ ឬ $6.7 \times 10^{-4} mol.L^{-1}$ ។

## 4. សូលុយស្យុងតំប៉ុង

ល្បាយសូលុយស្យុងនៃអាស៊ីតអាសេទិច ($CH_3COOH$) និងអំបិលសូដ្យូមអាសេតាត ($CH_3COONa$) អាចធ្វើប្រតិកម្មដូចបាសផង និងដូចអាស៊ីតផង ។ កាលណាគេបន្ថែមបរិមាណអាស៊ីត ឬបាសបន្តិចទៅក្នុងសូលុយស្យុងនេះ គេសង្កេតឃើញ pH របស់សូលុយស្យុងស្ទើរតែរក្សាតម្លៃថេរ ។ ល្បាយសូលុយស្យុងអាស៊ីតខ្សោយនិងអំបិលរបស់វាប្រឆាំងនឹងការប្រែប្រួល pH នៃសូលុយស្យុង ។ សូលុយស្យុងបែបនេះហៅថា សូលុយស្យុងតំប៉ុង (រូបទី 3.1) ។




ល្បាយសូលុយស្យុង $CH_3COOH$ និងសូលុយស្យុង $CH_3COONa$ ដែលមានកំហាប់ប្រហែលគ្នា មាន pH = 4.7

បន្ថែមសូលុយស្យុង HCl 1mL ទៅក្នុងសូលុយស្យុង (ក) ។ សូលុយស្យុងមាន pH = 4.6

បន្ថែមសូលុយស្យុង NaOH 1mL ទៅក្នុងសូលុយស្យុង (ក) ។ សូលុយស្យុងមាន pH = 4.8

***រូបទី3.1 បម្រែបម្រួល pH នៅក្នុងសូលុយស្យុងតំប៉ុង***

បើគេបន្ថែមបរិមាណអាស៊ីតបន្តិចទៅក្នុងល្បាយសូលុយស្យុងអាស៊ីតអាសេទិច - សូដ្យូមអាសេតាត អ៊ីយ៉ុង $CH_3COO^-$ និងចូលធ្វើប្រតិកម្មជាមួយអ៊ីយ៉ុង $H_3O^+$ បង្កើតជាម៉ូលេគុលអាស៊ីតអាសេទិច នាំឱ្យកំហាប់អ៊ីយ៉ុង $H_3O^+$ និង pH នៃសូលុយស្យុងពុំមានការប្រែប្រួល ។

$$CH_3COO^-(aq) + H_3O^+(aq) \longrightarrow CH_3COOH\ (aq) + H_2O\ (\ell)$$

បើគេបន្ថែមបរិមាណបាសបន្តិចទៅក្នុងល្បាយសូលុយស្យុងអាស៊ីតអាសេទិច- សូដ្យូមអាសេតាត នោះអ៊ីយ៉ុង $OH^-$ នៃបាសចូលធ្វើប្រតិកម្មជាមួយអ៊ីយ៉ុង $H_3O^+$ ឱ្យផលជាទឹក ។

$$H_3O^+ + OH^- \longrightarrow 2H_2O$$ ។

អាស៊ីតអាសេទិចនៅក្នុងសូលុយស្យុងមានអំពើជាមួយទឹកផ្តល់អ៊ីយ៉ុង $H_3O^+$ ដើម្បីជំនួសអ៊ីយ៉ុង $H_3O^+$ ដែលធ្វើប្រតិកម្មជាមួយអ៊ីយ៉ុង $OH^-$ ។ ដូច្នេះ កំហាប់អ៊ីយ៉ុង $H_3O^+$ ប្រែប្រួលតិចណាស់ ។

$$CH_3COOH\ (aq) + H_2O\ (\ell) \longrightarrow H_3O^+(aq) + CH_3COO^-\ (\ell)$$

សូលុយស្យុងបាសខ្សោយ ដែលមានអំបិលរបស់វារលាយចូលក៏មានលក្ខណៈដូចសូលុយស្យុងអាស៊ីតខ្សោយដែលមានអំបិលរបស់វារលាយចូលដែរ ។ កំហាប់អ៊ីយ៉ុង $H_3O^+$ និង pH នៃសូលុយស្យុងស្ទើរតែថេរ កាលណាគេបន្ថែមអាស៊ីត ឬបាសដែលមានបរិមាណតិចតួចចូល ។

***ឧទាហរណ៍*** : សូលុយស្យុងអាម៉ូញ៉ាក់ (បាសខ្សោយ) មានអំបិលអាម៉ូញ៉ូមក្លរួ ($NH_4Cl$) រលាយចូល ។ អាម៉ូញ៉ូមក្លរួបំបែកជាអ៊ីយ៉ុង $NH_4^+$ និងអ៊ីយ៉ុង $Cl^-$ ។

$$NH_4Cl\ (s) \longrightarrow NH_4^+(aq) + Cl^-(aq)$$

បើគេបន្ថែមបាសចូលទៅក្នុងសូលុយស្យុងនេះ អ៊ីយ៉ុង $NH_4^+$ ឱ្យប្រូតុងទៅអ៊ីយ៉ុង $OH^-$ ហើយក្លាយជាម៉ូលេគុលទឹក ។

$$NH_4^+(aq) + OH^-(aq) \longrightarrow NH_3(aq) + H_2O(\ell)$$

បើគេបន្ថែមអាស៊ីតជំនួសបាសវិញ ។ ម៉ូលេគុលអាម៉ូញាក់ក្នុងសូលុយស្យុងធ្វើប្រតិកម្មជាមួយទឹករំដោះអ៊ីយ៉ុង $OH^-$ ហើយអ៊ីយ៉ុង $OH^-$ ចាប់យកប្រូតុងក៏ក្លាយជាទឹក ។

$$NH_3\ (aq) + H_2O(\ell) \rightleftharpoons NH_4^+\ (aq) + OH^-(aq)$$

$$H_3O^+(aq) + OH^-(aq) \longrightarrow 2H_2O\ (\ell)$$

សូលុយស្យុងតំប៉ុងជាសូលុយស្យុងដែលមានបម្រែបម្រួល pH តិចតួច កាលណាគេបន្ថែមអាស៊ីតខ្លាំង ឬបាសខ្លាំង ឬពង្រាវវា ។

សូលុយស្យុងតំប៉ុងជាល្បាយសូលុយស្យុងអាស៊ីតខ្សោយនិងបាសឆ្លាស់របស់វា ដែលមានកំហាប់ប្រហាក់ប្រហែលគ្នា ឬជាល្បាយសូលុយស្យុងបាសខ្សោយ និងអាស៊ីតឆ្លាស់របស់វា ដែលមានកំហាប់ប្រហាក់ប្រហែលគ្នា។ គេអាចធ្វើសូលុយស្យុងតំប៉ុងដោយយកអាស៊ីតខ្សោយលាយជាមួយបាសឆ្លាស់របស់វា ឬយកបាសខ្សោយលាយជាមួយអាស៊ីតឆ្លាស់របស់វា និងតាមវិធីម្យ៉ាងទៀតដោយយកអាស៊ីតខ្សោយឱ្យមានអំពើជាមួយបាសខ្លាំង ឬបាសខ្សោយមានអំពើជាមួយអាស៊ីតខ្លាំង ។

សូលុយស្យុងតំប៉ុងមានសារៈសំខាន់នៅក្នុងការអនុវត្តផ្នែកគីមី និងឱសថសាស្ត្រ ។ ឈាមមនុស្សជាមជ្ឈដ្ឋានតំប៉ុងធម្មជាតិ ដែលមាន pH នៅចន្លោះ 7.3 ទៅ 7.5 ។ ការប្រែប្រួល pH ខ្លាំងនៅក្នុងខ្លួនយើង នាំឱ្យវិនាសដល់ដំណើរការធម្មតានៃសរីរាង្គរបស់យើង ។ ផលិតផលឱសថ និងគ្រឿងសំអាងជាច្រើនត្រូវបានរក្សាទុកក្នុងមជ្ឈដ្ឋានតំប៉ុងដើម្បីរក្សាប្រសិទ្ធភាព ឬកាត់បន្ថយផលប៉ះពាល់បន្ទាប់បន្សំ ។



រូបទី 3.2 សូលុយស្យុងតំប៉ុង ដែលលក់នៅទីផ្សារ




រូបទី 3.3 សូលុយស្យុងអាស្ពីរីនដាក់ទឹកពុះមាន pH ស្ទើរតែថេរ នៅពេលគេបន្ថែមសូលុយស្យុងអាស៊ីតខ្លាំង ឬសូលុយស្យុងបាសខ្លាំងបន្តិចបន្តួច ។ សូលុយស្យុងនេះ គេហៅថាសូលុយស្យុងតំប៉ុង ។

***លំហាត់គំរូ1:*** ហេតុដូចម្តេចបានជាសូលុយស្យុងខាងក្រោមនេះជាសូលុយស្យុងតំប៉ុង ? ចូរពន្យល់ ។

ក. សូលុយស្យុងមាន 0.100mol នៃ $CH_3COOH$ និង 0.100mol នៃ $CH_3COONa$

ខ. សូលុយស្យុងមាន 0.200mol នៃ $CH_3COOH$ និង 0.100mol នៃ NaOH

គ. សូលុយស្យុងមាន 0.200mol នៃ $CH_3COONa$ និង 0.100mol នៃ HCl

ឃ. សូលុយស្យុងមាន 0.100mol នៃ $NH_3$ និង 0.100mol នៃ $NH_4Cl$ ។

***ចម្លើយ :***

ក. ក្នុងសូលុយស្យុងមានបរិមាណអាស៊ីត $CH_3COOH$ ចំនួន 0.100mol និង $CH_3COONa$ ចំនួន 0.100mol ។ ដូច្នេះ $CH_3COOH$ និងអ៊ីយ៉ុង $CH_3COO^-$ មានកំហាប់ស្មើគ្នា ។

ខ. អាស៊ីត $CH_3COOH$ 0.200mol ធ្វើប្រតិកម្មជាមួយបាសខ្លាំង NaOH ចំនួន 0.100mol ឱ្យ $CH_3COONa$ ។

$$CH_3COOH\ (aq) + NaOH\ (aq) \longrightarrow CH_3COONa\ (aq) + H_2O\ (\ell)$$

ក្រោយប្រតិកម្មក្នុងសូលុយស្យុងមានបរិមាណ $CH_3COOH$ 0.100mol និង $CH_3COO^-$ 0.100mol ។ ដូច្នេះ $CH_3COOH$ និងអ៊ីយ៉ុង $CH_3COO^-$ មានកំហាប់ស្មើគ្នា ។

គ. 0.200mol នៃ $CH_3COONa$ ធ្វើប្រតិកម្មជាមួយ 0.100mol នៃ HCl ឱ្យផលអាស៊ីត $CH_3COOH$ 0.100mol នៅសល់ 0.100mol នៃ $CH_3COONa$ ។ ក្នុងសូលុយស្យុងមានអាស៊ីត $CH_3COOH$ និងអ៊ីយ៉ុង $CH_3COO^-$ ដែលមានកំហាប់ស្មើគ្នា ។

$$CH_3COONa\ (aq) + HCl\ (aq) \longrightarrow CH_3COOH\ (aq) + NaCl\ (aq)$$

ឃ. ក្នុងសូលុយស្យុងមានបាសខ្សោយ $NH_3$ 0.100mol និងអាស៊ីតឆ្លាស់ $NH_4^+$ 0.100mol ។ ដូច្នេះ $NH_3$ និងអ៊ីយ៉ុង $NH_4^+$ មានកំហាប់ស្មើគ្នា ។

***លំហាត់គំរូ2:*** គេយកអាស៊ីតអាសេទិច 0.160mol និងសូដ្យូមអាសេតាត 0.210mol ដាក់ក្នុងកែវបេស៊ែហើយគេបន្ថែមទឹកសុទ្ធឱ្យបានសូលុយស្យុង 1L ។ គណនា pH នៃសូលុយស្យុង ។ គេឱ្យ $\log 1.4 = 0.15$ ។

***ចម្លើយ :***

សមីការលំនឹងអ៊ីយ៉ុងកម្មនៃអាស៊ីតអាសេទិច :

$$CH_3COOH\ (aq) + H_2O\ (\ell) \rightleftharpoons CH_3COO^-\ (aq) + H_3O^+\ (aq)$$

អំបិលសូដ្យូមអាសេតាតរលាយក្នុងទឹក វាបំបែកជាអ៊ីយ៉ុងបានសព្វល្អ ។

$$CH_3COONa\ (s) \longrightarrow CH_3COO^-(aq) + Na^+(aq)$$

0.210M 0.210M 0.210M

វត្តមានអ៊ីយ៉ុង $CH_3COO^-$ ក្នុងសូលុយស្យុងនាំឱ្យមានការរំកិលលំនឹងអ៊ីយ៉ុងកម្មនៃអាស៊ីត ។

$$CH_3COOH(aq) + H_2O(\ell) \rightleftharpoons CH_3COO^-(aq) + H_3O^+(aq)$$

| | $CH_3COOH$ | $CH_3COO^-$ | $H_3O^+$ |
|---|---|---|---|
| កំហាប់ដើម : | 0.160M | 0.210M | |
| កំហាប់ប្រែប្រួលដោយប្រតិកម្ម : | x | x | x |
| កំហាប់លំនឹង : | 0.160 − x | 0.210 + x | x |

$$K_a = \frac{[CH_3COO^-][H_3O^+]}{[CH_3COOH]} = \frac{(0.210 + x)x}{(0.160 - x)}$$

ដោយ x មានតម្លៃតូច គេអាចចោលបាន នាំឱ្យ $(0.210 + x) \simeq 0.210$ និង $(0.160 - x) \simeq 0.160$ ។

$$K_a = \frac{0.210 \times x}{0.160} = 1.8 \times 10^{-5}$$

$$x = 1.4 \times 10^{-5}$$

ដូច្នេះ $[H_3O^+] = 1.4 \times 10^{-5}M$ ឬ $1.4 \times 10^{-5} mol \cdot L^{-1}$

$pH = -\log[H_3O^+] = -\log 1.4 \times 10^{-5}M$ បាន $pH = 5 - \log 1.4 = 4.85$ ។

***លំហាត់គំរូ 3 :*** គណនា pH នៃសូលុយស្យុងអាម៉ូញាក់ ដែលមានកំហាប់ 0.0669M ។ គេឱ្យ : $\log 9.1 = 0.96$ ។

***ចម្លើយ :***

សមីការតុល្យការអ៊ីយ៉ុងកម្មនៃ $NH_3$ :

$$NH_3\ (aq) + H_2O(\ell) \rightleftharpoons NH_4^+\ (aq) + OH^-(aq)$$

| | $NH_3$ | $NH_4^+$ | $OH^-$ |
|---|---|---|---|
| កំហាប់ដើម : | 0.0669M | 0 | 0 |
| កំហាប់ប្រែប្រួលដោយប្រតិកម្ម : | x | x | x |
| កំហាប់លំនឹង : | 0.0669 − x | x | x |

$$K_b = \frac{[NH_4^+][OH^-]}{[NH_3]}$$

$$K_b = \frac{x^2}{(0.0669 - x)} = 1.8 \times 10^{-5}$$

ដោយ x មានតម្លៃតូចអាចចោលបាន នាំឱ្យ $0.0669 - x \simeq 0.0669$

$$K_b = \frac{x^2}{0.0669} = 1.8 \times 10^{-5}$$

$x^2 = 1.2 \times 10^{-6}$ នាំឱ្យ $x = 1.1 \times 10^{-3}$

ថេរអ៊ីយ៉ុងកម្មនៃទឹក : $K_w = [H_3O^+][OH^-]$

$$[H_3O^+] = \frac{K_w}{[OH^-]} = \frac{1.0 \times 10^{-14}}{1.1 \times 10^{-3}} = 9.1 \times 10^{-12} M$$

$pH = -\log[H_3O^+] = -\log 9.1 \times 10^{-12} = 12 - \log 9.1$

$pH = 11.04$ ។

***លំហាត់គំរូ៤:*** គេយកដុំប៉ូតាស្យូមអ៊ីដ្រុកស៊ីត 0.020mol ដាក់ក្នុងល្បាយសូលុយស្យុងមួយដែលមានអាស៊ីតអាសេទិច 0.160mol និងប៉ូតាស្យូមអាសេតាត 0.210mol រលាយចូល ។ សូលុយស្យុងនេះមានមាឌ V = 1L ។ គណនា pH នៃសូលុយស្យុង ។ គេឱ្យ : log1.1 = 0.04

***ចម្លើយ :***

សមីការតាងប្រតិកម្មរវាងអាស៊ីតអាសេទិច និងប៉ូតាស្យូមអ៊ីដ្រុកស៊ីត

$$CH_3COOH\,(aq) + KOH(aq) \longrightarrow CH_3COOK\,(aq) + H_2O(\ell)$$

| | $CH_3COOH$ | $KOH$ | $CH_3COOK$ |
|---|---|---|---|
| កំហាប់ដើម : | 0.160M | 0.020M | 0.210M |
| កំហាប់ប្រែប្រួលដោយប្រតិកម្ម : | 0.020M | 0.020M | 0.020M |
| កំហាប់មុនលំនឹង : | 0.140M | 0.000M | 0.230M |

ក្រោយប្រតិកម្ម នៅក្នុងសូលុយស្យុងមានអាស៊ីតអាសេទិចនៅសល់ 0.140mol និងអ៊ីយ៉ុងអាសេតាតនៅសល់ 0.230mol ។

$$CH_3COOH\,(aq) + H_2O(\ell) \rightleftharpoons CH_3COO^-\,(aq) + H_3O^+\,(aq)$$

| | $CH_3COOH$ | $CH_3COO^-$ | $H_3O^+$ |
|---|---|---|---|
| កំហាប់ដើម : | 0.140M | 0.230M | |
| កំហាប់ប្រែប្រួលដោយប្រតិកម្ម : | x | x | x |
| កំហាប់ពេលលំនឹង : | 0.140 − x | 0.230 + x | x |

$$K_a = \frac{[CH_3COO^-][H_3O^+]}{[CH_3COOH]} = \frac{(0.230 + x)x}{(0.140 - x)}$$

ដោយ x មានតម្លៃតូចគេអាចចោលបាន នាំឱ្យ $0.230 + x \approx 0.230$ និង $0.140 - x \approx 0.140$

គេបាន $K_a = \frac{0.230 \times x}{0.140} = 1.8 \times 10^{-5}$

$x = 1.1 \times 10^{-5}$

$pH = -\log[H_3O^+] = -\log 1.1 \times 10^{-5} = 5 - \log 1.1$

$pH = 4.96$ ។

## មេរៀនសង្ខេប

- ថេរលំនឹងអ៊ីយ៉ុងកម្មនៃអាស៊ីត $K_a$ ក៏ដូចថេរលំនឹង K ដែរ គឺមានតម្លៃថេរនៅសីតុណ្ហភាពកំណត់ណាមួយ តែវាមានតម្លៃថ្មីកាលណាគេប្រែប្រួលសីតុណ្ហភាពប្រព័ន្ធ ។
- នៅសីតុណ្ហភាព 25°C ទឹកសុទ្ធមាន $[H_3O^+] = [OH^-] = 1.0 \times 10^{-7}M$ និង $K_w$ ឬ $K_e = [H_3O^+][OH^-] = 1.0 \times 10^{-14}$ ។
- អ៊ីដ្រូលីសនៃអំបិលជាប្រតិកម្មរវាងអំបិលនិងទឹក ។ អ៊ីដ្រូលីសអាញ៉ុងនៃអំបិលដែលបានពីអាស៊ីតខ្សោយឱ្យផលជាអ៊ីយ៉ុង $OH^-$ ។ អ៊ីដ្រូលីសកាចុងនៃអំបិលដែលបានពីបាសខ្សោយឱ្យផលជាអ៊ីយ៉ុង $H_3O^+$ ។ អាញ៉ុង និងកាចុងដែលបានពីអាស៊ីតខ្លាំងនិងបាសខ្លាំងគ្មានប្រតិកម្មអ៊ីដ្រូលីសទេ ។
- សូលុយស្យុងតំប៉ុងផ្សំដោយល្បាយសូលុយស្យុងអាស៊ីតខ្សោយនិងបាសឆ្លាស់របស់វា ឬល្បាយសូលុយស្យុងបាសខ្សោយនិងអាស៊ីតឆ្លាស់របស់វា ។ សូលុយស្យុងតំប៉ុងមានបម្រែបម្រួល pH តិចតួចកាលណាគេបន្ថែមអាស៊ីតខ្លាំង ឬបាសខ្លាំង ឬពង្រាវសូលុយស្យុង ។

## ? សំណួរនិងលំហាត់

1. តើថេរអ៊ីយ៉ុងកម្មនៃអាស៊ីតប្រែប្រួលដូចម្ដេច ?
2. ចូរសរសេរកន្សោមថេរលំនឹងអ៊ីយ៉ុងកម្មនៃអាស៊ីតខ្សោយ HA ។
3. ដូចម្ដេចហៅថាសូលុយស្យុងតំប៉ុង ?
4. ចូរសរសេរកន្សោមថេរអ៊ីយ៉ុងកម្មនៃទឹក $K_w$ និងឱ្យតម្លៃរបស់វានៅសីតុណ្ហភាព 25°C ។
5. តើសូលុយស្យុងខាងក្រោមនេះជាសូលុយស្យុងតំប៉ុងដែរឬទេ ? បើគេលាយ :
   ក. 20mL នៃសូលុយស្យុងអាស៊ីត $HNO_3$ ដែលមានកំហាប់ 0.5M និង 20mL នៃសូលុយស្យុង $KNO_3$ ដែលមានកំហាប់ 0.5M ។
   ខ. 20mL នៃសូលុយស្យុងអាស៊ីត HCOOH (អាស៊ីតខ្សោយ) ដែលមានកំហាប់ 1.0M និង 20mL នៃសូលុយស្យុង HCOONa ដែលមានកំហាប់ 1.0M ។
   គ. 20mL នៃសូលុយស្យុង $HNO_2$ ដែលមានកំហាប់ 0.5M និង 20mL នៃសូលុយស្យុង KCl ដែលមានកំហាប់ 0.5M ។
6. ចូរបង្ហាញប្រភេទគីមីនៅក្នុងសមីការខាងក្រោម តើណាខ្លះជាអាស៊ីត និងបាសឆ្លាស់របស់វា ?
   ក. $HSO_4^-(aq) + OH^-(aq) \rightleftharpoons SO_4^{2-}(aq) + H_2O(\ell)$

ខ. $H_2PO_4^-(aq) + H_2O(\ell) \rightleftharpoons H_3PO_4(aq) + OH^-(aq)$

គ. $PO_4^{3-}(aq) + H_2O(\ell) \rightleftharpoons HPO_4^{2-}(aq) + OH^-(aq)$

ឃ. $ClO_2^-(aq) + H_3O^+(aq) \rightleftharpoons HClO_2(aq) + H_2O(\ell)$

ង. $C_5H_5NH^+(aq) + OH^-(aq) \rightleftharpoons C_5H_5N(aq) + H_2O(\ell)$

ច. $HS^-(aq) + OH^-(aq) \rightleftharpoons S^{2-}(aq) + H_2O(\ell)$ ។

7. សូលុយស្យុង 0.100M នៃអង្គធាតុខាងក្រោមនេះ តើសូលុយស្យុងណាខ្លះ ជាសូលុយស្យុងអាស៊ីត សូលុយស្យុងបាស និងសូលុយស្យុងណឺត ?

ក. $NH_4ClO_4$ ខ. $Na_2S$ គ. $NaClO_3$ ឃ. $KNO_2$ ង. $CH_3COOLi$

ច. $Li_2CO_3$ ឆ. $NH_4HSO_4$ ជ. $CaCl_2$ ឈ. $KNO_3$ ញ. $NH_4NO_3$ ។

8. គណនា pH នៃសូលុយស្យុងដែលមាន $[H_3O^+] = 1.00 \times 10^{-5}M$ និងសូលុយស្យុងដែលមាន $[OH^-] = 1.00 \times 10^{-5}M$ ។

9. គណនា pH នៃសូលុយស្យុងអាស៊ីតអាសេទិច ($CH_3COOH$) នៅកំហាប់ 0.170M ។

10. គណនា $[H_3O^+]$ នៅក្នុងសូលុយស្យុងផេណុល ($C_6H_5OH$) ដែលមានកំហាប់ 0.125M ។ ថេរអ៊ីយ៉ុងកម្ម $K = 1.3 \times 10^{-6}$ ។ សមីការអ៊ីយ៉ុងកម្មនៃផេណុល :

$C_6H_5OH(aq) + H_2O(\ell) \rightleftharpoons C_6H_5O^-(aq) + H_3O^+(aq)$

11. សូលុយស្យុងអាស៊ីតខ្សោយ HA នៅកំហាប់ 0.400M មាន pH = 2.93 ។ គណនាតម្លៃ $K_a$ នៃអាស៊ីត HA ។

12. ក. គេមានសូលុយស្យុងមេទីលអាមីន ($CH_3NH_2$) ដូចខាងក្រោម :

- សូលុយស្យុង A មានកំហាប់ 0.314M នៃមេទីលអាមីន
- សូលុយស្យុង B មានកំហាប់ 0.100M នៃមេទីលអាមីន
- សូលុយស្យុង C មានកំហាប់ 0.0314M នៃមេទីលអាមីន ។

គណនាភាគរយអ៊ីយ៉ុងកម្ម α នៃសូលុយស្យុងនីមួយៗ ។

ខ. តើភាគរយអ៊ីយ៉ុងកម្មនៃបាសខ្សោយមេទីលអាមីនប្រែប្រួលដូចម្តេច កាលណាសូលុយស្យុងកាន់តែរាវ ។

13. គណនាកំហាប់អ៊ីយ៉ុងអាសេតាតនៅក្នុងសូលុយស្យុង ។ គេដឹងថានៅក្នុង 1L នៃសូលុយស្យុងមានអាស៊ីតអាសេទិច 0.150mol និងអាស៊ីតក្លរីឌ្រិច 0.250mol រលាយចូល ។

## ? សំណួរនិងលំហាត់ជំពូក 4

I. ចូរគូសសញ្ញា ✓ ក្នុងប្រអប់ខាងមុខចម្លើយណាមួយដែលត្រឹមត្រូវ ។

1. គេមានប្រព័ន្ធ : $4NH_3 (g) + 5O_2(g) \underset{2}{\overset{1}{\rightleftharpoons}} 4NO (g) + 6H_2O (g) +$ កម្ដៅ

បើគេបន្ថែមកម្ដៅឱ្យទៅប្រព័ន្ធមានលំនឹង តើប្រព័ន្ធលំនឹងរំកិលទៅតាមទិសដៅណាមួយ ?

☐ ក. ទិសដៅ 1

☐ ខ. ទិសដៅ 2

☐ គ. គ្មានរំកិល ។

2. គេមានសមីការលំនឹង : $2NH_3 (g) \rightleftharpoons 3H_2 (g) + N_2 (g)$

តើកន្សោមថេរលំនឹងណាមួយសរសេរបានត្រឹមត្រូវ ?

☐ ក. $K = \frac{[H_2][N_2]}{[NH_3]}$ ☐ ខ. $K = \frac{[NH_3]}{[H_2][N_2]}$

☐ គ. $K = \frac{[H_2]^3[N_2]}{[NH_3]^2}$ ☐ ឃ. $K = \frac{[NH_3]^2}{[H_2]^2[N_2]}$ ។

3. គេមានសូលុយស្យុង A , B , C និង D ដែលបានមកពីការរំលាយ :

A . 0.400mol នៃ HCl និង 0.200mol នៃ NaOH

B . 0.400mol នៃ $CH_3COOH$ និង 0.400mol នៃ NaOH

C . 0.200mol នៃ $CH_3COONa$ និង 0.200mol នៃ HCl

D . 0.200mol នៃ $CH_3COONa$ និង 0.200mol នៃ $CH_3COOH$

តើសូលុយស្យុងណាមួយជាសូលុយស្យុងតំប៉ុង ?

☐ ក. A ☐ ខ. B

☐ គ. C ☐ ឃ. D ។

II. ចូរបំពេញល្បះឱ្យមានន័យត្រឹមត្រូវ

1. ប្រព័ន្ធដល់ស្ថានភាព . . . . . . កាលណាល្បឿនប្រតិកម្មទៅមកស្មើគ្នា ។

2. សម្ពាធមានឥទ្ធិពលតែទៅលើលំនឹងនៃប្រព័ន្ធដែលមានភាពរូបជា . . . . . . . ហើយចំនួនម៉ូលសរុបនៃអង្គធាតុប្រតិករ . . . . . . ចំនួនម៉ូលសរុបនៃអង្គធាតុកកើត ។

## III. សំណួរត្រិះរិះ

1 ប្រតិកម្មខាងក្រោមនេះមានលំនឹងនៅសីតុណ្ហភាពខ្ពស់ ។

$N_2\ (g)\ +\ O_2\ (g)\ \rightleftharpoons\ 2NO\ (g)$

ចូរសរសេរកន្សោមថេរលំនឹង K ។

2. ប្រតិកម្មរវាង $N_2$ និង $O_2$ តាងដោយសមីការ :

$2N_2\ (g)\ +\ O_2\ (g)\ \rightleftharpoons\ 2N_2O\ (g)$

ចូរសរសេរកន្សោមថេរលំនឹង K ។

3. គេមានប្រព័ន្ធមួយដែលមានសមីការតុល្យការលំនឹង :

$2CO_2\ (g)$ + កម្ដៅ $\rightleftharpoons\ 2CO\ (g)\ +\ O_2(g)$

គេឱ្យប្រព័ន្ធរងនូវឥទ្ធិពលដូចខាងក្រោម តើប្រព័ន្ធលំនឹងរំកិលដូចម្ដេច ?

ក. រំដោះ CO　　　　ខ. បន្ថែម $O_2$

គ. បង្កើនសីតុណ្ហភាព　　　　ឃ. បន្ថែម $CO_2$

ង. បង្កើនមាឌប្រព័ន្ធ　　　　ច. ផ្ដល់កាតាលីករ

4. តើគេអាចប្រើគោលការណ៍ឡឺសាតឺលីយេ ដើម្បីព្យាករណ៍អំពីឥទ្ធិពលនៃការបង្កើនសីតុណ្ហភាពទៅលើល្បាយដែលផ្សំដោយអាសូតនិងអុកស៊ីសែនតែប៉ុណ្ណោះ បានដែរឬទេ ?

$N_2(g)\ +\ 2O_2\ (g)\ \rightleftharpoons\ 2N_2O(g)$ + កម្ដៅ

## IV. លំហាត់

1. ប្រតិកម្មខាងក្រោមនេះប្រព្រឹត្តទៅនៅសីតុណ្ហភាពខ្ពស់ ។

$CO\ (g)\ +\ H_2O\ (g)\ \rightleftharpoons\ CO_2\ (g)\ +\ H_2(g)$

ពេលមានលំនឹងគេដឹងថា : $[CO] = [H_2O] = 0.800 mol\ L^{-1}$

$[CO_2] = [H_2] = 2.00 mol\ L^{-1}$ ។ ចូររកតម្លៃថេរលំនឹងនៃប្រព័ន្ធ ។ **ចម្លើយ** : K = 6.25

2. ប្រតិកម្មរវាងកាបូនម៉ូណូអុកស៊ីត និងចំហាយទឹកឱ្យផលជាឧស្ម័ន $CO_2$ និង $H_2$ ។ ប្រតិកម្មនេះប្រព្រឹត្តទៅនៅសីតុណ្ហភាពខ្ពស់ ។ សមីការតុល្យការប្រតិកម្ម :

$CO\ (g)\ +\ H_2O\ (g)\ \rightleftharpoons\ H_2\ (g)\ +\ CO_2(g)$

គេយក 0.500mol ឧស្ម័ន CO និង 1.00mol ទឹកដាក់ក្នុងធុង 1L ហើយបិទជិតនិងដុតកម្ដៅនៅសីតុណ្ហភាព 1000°C ។ ពេលមានលំនឹងកំហាប់ $[CO_2] = 0.35 mol\ L^{-1}$ ។ គណនាតម្លៃថេរលំនឹង K ។ **ចម្លើយ** : K = 0.686

3. សូលុយស្យុងអាស៊ីតខ្សោយ HA ដែលមានកំហាប់ 0.250M មានកំហាប់អ៊ីយ៉ុង $H_3O^+$ ស្មើ $6.16 \times 10^{-6}$M ។ គណនាតម្លៃ $K_a$ នៃអាស៊ីត HA ។ សមីការអ៊ីយ៉ុងកម្មនៃអាស៊ីត :

$$HA\ (aq) + H_2O\ (\ell) \rightleftharpoons H_3O^+\ (aq) + A^-\ (aq)$$ ។

ចម្លើយ : $K_a = 1.52 \times 10^{-10}$

4. សូលុយស្យុង 0.350M នៃបាសខ្សោយ B មានកំហាប់អ៊ីយ៉ុង $OH^-$ ស្មើ $7.11 \times 10^{-5}$M ។ គណនាតម្លៃ $K_b$ នៃបាស B ។ សមីការតុល្យការអ៊ីយ៉ុងកម្មនៃបាស B :

$$B\ (aq) + H_2O\ (\ell) \rightleftharpoons BH^+\ (aq) + OH^-\ (aq)$$ ។

ចម្លើយ : $K_b = 1.44 \times 10^{-8}$

5. គណនាកំហាប់អ៊ីយ៉ុង $H_3O^+$ នៃសូលុយស្យុងអាស៊ីតផរមិច ដែលមានកំហាប់ 0.400M ។ សមីការតុល្យការអ៊ីយ៉ុងកម្មនៃអាស៊ីត :

$$HCOOH\ (aq) + H_2O\ (\ell) \rightleftharpoons HCOO^-\ (aq) + H_3O^+\ (aq)$$

ថេរអ៊ីយ៉ុងកម្មនៃអាស៊ីត $K_a = 1.7 \times 10^{-4}$ ។

ចម្លើយ : $[\ H_3O^+\ ] = 8.2 \times 10^{-3}$M

6. សូលុយស្យុងអាស៊ីតខ្សោយ HA នៅកំហាប់ 0.100M មាន pH ស្មើ 5.11 ។ គណនាតម្លៃ $K_a$ នៃអាស៊ីត HA ។ ចម្លើយ : $K_a = 6.1 \times 10^{-10}$

7. គណនាកំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូម និង pH នៃសូលុយស្យុងអាម៉ូញ៉ាក់ ដែលមានកំហាប់ 0.747M ។
ចម្លើយ : $[\ H_3O^+\ ] = 2.7 \times 10^{-12} mol\ L^{-1}$ និង $pH = 11.57$

8. សូលុយស្យុងអាស៊ីតខ្សោយ HA នៅកំហាប់ 0.200M មាន pH ស្មើ 3.73 ។ គណនាតម្លៃ $K_a$ នៃអាស៊ីត HA ។

9. សូលុយស្យុងបាសខ្សោយ B នៅកំហាប់ 0.150M មាន pH ស្មើ 10.73 ។ គណនាតម្លៃ $K_b$ នៃបាស B ។

ចម្លើយ : $K_b = 1.9 \times 10^{-6}$

10. គេមានសូលុយស្យុង 1L ដែលក្នុងនោះមាន :

ក. 0.170mol នៃអាស៊ីតភ្លុយអរីឌ្រិច (HF) និង 0.120mol នៃសូដ្យូមភ្លុយអរួ (NaF) ។

ខ. 0.290mol នៃអាស៊ីតភ្លុយអរីឌ្រិច និង 0.120mol នៃសូដ្យូមអ៊ីដ្រុកស៊ីត ។

គណនាកំហាប់អ៊ីយ៉ុងអ៊ីដ្រូញ៉ូម ។

ចម្លើយ : ក. $[\ H_3O^+\ ] = 9.5 \times 10^{-4}$M , ខ. $[\ H_3O^+\ ] = 9.5 \times 10^{-4}$M ។

ជំពូក 5

# ឧស្ម័ន



ខ្យល់ក្តៅនៅក្នុងបាល់ឡុងនេះ អាចធ្វើឱ្យវាហោះឡើងទៅលើបាន ។

# 1 លក្ខណៈឧស្ម័ន

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាលក្ខណៈទូទៅនៃឧស្ម័ន ។
- ពណ៌នានិយមន័យសម្ពាធឧស្ម័ននិងខ្នាតសម្ពាធ ។
- ពន្យល់ពីសម្ពាធឧស្ម័នទាក់ទងនិងស៊ីនេទិចម៉ូលេគុលឧស្ម័ន ។

នៅក្រោមលក្ខខណ្ឌសីតុណ្ហភាពនិងសម្ពាធជាក់លាក់ អង្គធាតុមួយអាចស្ថិតនៅក្នុងភាពរូបណាមួយក្នុងចំណោមភាពរូបទាំងបីគឺ រឹង រាវ និងឧស្ម័ន ។ ***ឧទាហរណ៍ :*** ក្រោមសម្ពាធបរិយាកាស ទឹកអាចស្ថិតនៅជាភាពរាវនៅ 25°C ក្នុងភាពរឹងនៅ 0°C និងក្នុងភាពចំហាយនៅ 100°C ។

តារាងទី 1.1 បង្ហាញពីអង្គធាតុមួយចំនួនដែលស្ថិតនៅភាពរូបជាឧស្ម័ននៅ 25°C និងក្រោមសម្ពាធបរិយាកាសធម្មតា :

**តារាងទី 1.1**

| អង្គធាតុទោល | | អង្គធាតុសមាស | |
|---|---|---|---|
| ម៉ូលេគុលម៉ូណូអាតូម | ម៉ូលេគុលប៉ូលីអាតូម | ម៉ូលេគុលឌីអាតូម | ម៉ូលេគុលប៉ូលីអាតូម |
| He អេល្យូម | $H_2$ ឌីអ៊ីដ្រូសែន | HF អ៊ីដ្រូសែនភ្លុយអរួ | $CO_2$ កាបូនឌីអុកស៊ីត |
| Ne ណេអុង | $N_2$ ឌីនីត្រូសែន | HCl អ៊ីដ្រូសែនក្លរួ | $NH_3$ អាម៉ូញាក់ |
| Ar អាកុង | $O_2$ ឌីអុកស៊ីសែន | HBr អ៊ីដ្រូសែនប្រូមួ | $NO_2$ អាសូតឌីអុកស៊ីត |
| Kr គ្រីបតុង | $F_2$ ឌីភ្លុយអរ | HI អ៊ីដ្រូសែនអ៊ីយ៉ូដួ | $N_2O$ ឌីនីត្រូសែនអុកស៊ីត |
| Xe សេណុង | $Cl_2$ ឌីក្លរ | CO កាបូនម៉ូណូអុកស៊ីត | $SO_2$ ស្ពាន់ធ័រឌីអុកស៊ីត |
| Rn រ៉ាដុង | $Br_2$ ឌីប្រូម | NO អាសូតម៉ូណូអុកស៊ីត | $H_2S$ អ៊ីដ្រូសែនស៊ុលផួ |
| | $O_3$ អូសូន | | HCN អ៊ីដ្រូសែនស្យានួ |
| | | | $CH_4$ មេតាន |

# 1. លក្ខណៈរូបឧស្ម័ន

ឧស្ម័នមានលក្ខណៈរូបមួយដូចគ្នា គឺម៉ូលេគុលវាស្ថិតនៅដាច់ឆ្ងាយពីគ្នាជាងករណីអង្គធាតុរឹង ឬរាវ ។ អង្គធាតុរឹងនិងរាវ ថ្វីបើលក្ខណៈរបស់វាហាក់ដូចជាខុសគ្នាខ្លាំង ប៉ុន្តែអង្គធាតុទាំងពីរមានលំហអន្តរម៉ូលេគុលតូចដូចគ្នា ។ ឯឧស្ម័នទោះបីមានលំហអន្តរម៉ូលេគុលធំជាងអង្គធាតុរាវ ប៉ុន្តែឧស្ម័ននៅមានលក្ខណៈខ្លះដូច ឬស្រដៀងទៅនឹងអង្គធាតុរាវដែរ ។

## 1.1. ឧស្ម័នជាសន្ទនីយ

គេចាត់ទុកឧស្ម័នជាសន្ទនីយ ។ យើងតែងយល់ច្រលំដោយចាត់ទុកពាក្យសន្ទនីយថាជាអង្គធាតុរាវ ។ សន្ទនីយសំដៅទៅលើអ្វីដែលអាចហូរបាន ។ ម៉ូលេគុលឧស្ម័នអាចហូរបានយ៉ាងងាយដោយសារម៉ូលេគុលវាស្ថិតនៅដាច់ឆ្ងាយពីគ្នា ។




ឧស្ម័នអាសូតឌីអុកស៊ីត ($NO_2$) ពណ៌ត្នោតដែលកើតពីប្រតិកម្មរវាង ($HNO_3$) និង (Cu) ហូរទៅផ្នែកខាងលើនៃបំពង់សាក

*រូបទី 1.1 ប្រតិកម្មរវាងទង់ដែងនិងអាស៊ីតនីទ្រិច*

## 1.2. ដង់ស៊ីតេ

ឧស្ម័នមានដង់ស៊ីតេតូចណាស់ធៀបនឹងអង្គធាតុរឹងឬរាវ ។ បើយើងពិនិត្យអាតូមសូដ្យូមក្នុងភាពរូបរឹង រាវ និងចំហាយ យើងសង្កេតឃើញថា ក្នុងមាឌប៉ុនគ្នា សូដ្យូមរឹងមានចំនួនអាតូមច្រើនជាងសូដ្យូមរាវ ហើយចំនួនអាតូមដែលមានតិចជាងគេ គឺចំហាយសូដ្យូម ។ ក្នុងភាពរឹងនិងរាវអាតូមសូដ្យូមស្ថិតនៅជិតៗគ្នា ។ ក្នុងភាពចំហាយអាតូមសូដ្យូមនៅឆ្ងាយដាច់ពីគ្នា ធ្វើឱ្យមាឌដែលអាតូមតាំងនៅ មួយចំណែកធំជាលំហទទេ ។ នេះហើយជាមូលហេតុដែលនាំឱ្យឧស្ម័នមានដង់ស៊ីតេតូច ។




*រូបទី 1.2 ដង់ស៊ីតេអាតូមសូដ្យូមនៅភាពរឹង រាវ និងឧស្ម័ន*

## 1.3. ឧស្ម័នអាចបណ្ណែនបាន

ប្រសិនបើយើងដាក់អង្គធាតុរាវ ឧទាហរណ៍ទឹក នៅក្នុងសីរ៉ាំងមួយ រួចយកម្រាមដៃបិតចុងម្ខាង ហើយព្យាយាមរុញដងសីរ៉ាំង (ដូចរូប) យើងមិនអាចធ្វើឱ្យដងសីរ៉ាំងផ្លាស់ទីបានទេ ។

ប៉ុន្តែប្រសិនបើក្នុងសីរ៉ាំងមានខ្យល់វិញ តាមរបៀបដដែលយើងអាចធ្វើឱ្យដងសីរ៉ាំងផ្លាស់ទីបាន គឺគេអាចធ្វើឱ្យមាឌខ្យល់រួមតូចជាងមុន ។

ដូចនេះឧស្ម័នអាចបណ្ណែនបានគឺគេអាចរុញភាគល្អិតឧស្ម័នឱ្យនៅជិតគ្នាជាងមុនជាហេតុធ្វើឱ្យលំហដែលតាំងនៅរបស់ឧស្ម័នត្រូវតូចជាងមាឌដើម ។

ហេតុនេះប្រសិនបើគេបង្កើនសម្ពាធតែបន្តិច នោះភាគល្អិតឧស្ម័ននិងរិតជិតគ្នាដែលធ្វើឱ្យមាឌឧស្ម័នថយចុះ ។




*រូបទី 1.3 មាឌឧស្ម័នថយចុះដោយម៉ូលេគុលរិតទៅជិតគ្នាជាងមុន*

## 1.4. ឧស្ម័នសាយភាយបំពេញវត្ថុដែលផ្ទុកវា

អង្គធាតុរឹងមានមាឌនិងរាងជាក់លាក់ ។ អង្គធាតុរាវមានមាឌជាក់លាក់ ប៉ុន្តែមានរាងប្រែប្រួលទៅតាមវត្ថុដែលផ្ទុកវា ។ ផ្ទុយទៅវិញឧស្ម័នគ្មានរាងនិងមាឌជាក់លាក់ទេ ។ ម៉ូលេគុលវាអាចសាយភាយបំពេញវត្ថុដែលផ្ទុកវា ។

***ពិសោធន៍ :*** យកដបមួយដាក់សូលុយស្យុង $HNO_3$ បន្តិច រួចដាក់បំណែកទង់ដែងមួយដុំតូច ( សមល្មមធ្វើប្រតិកម្មអស់ ) បន្ទាប់មកយកថង់ប្លាស្ទិចចងមាត់ដបឱ្យជាប់កុំឱ្យឧស្ម័នភាយចេញបាន ។ ពេលប្រតិកម្មចប់ យកដបមួយទៀតដាក់ពីលើឱ្យមាត់ដបភ្ជាប់គ្នា រួចទំលុះថង់ប្លាស្ទិច ។




*រូបទី 1.4 ឧស្ម័នពណ៌ត្នោតសាយភាយបំពេញដបទាំងពីរ*

***សង្កេត :*** គេឃើញឧស្ម័នពណ៌ត្នោត ភាយចេញទៅបំពេញដបទី2 រហូតពេញដបទាំងពីរ ។

***បំណកស្រាយ :*** ម៉ូលេគុលឧស្ម័នធ្វើចលនាដោយល្បឿនយ៉ាងលឿន ហើយបែកខ្ញែកទៅឆ្ងាយ ដែលវាមិនអាចមានទំនាញរវាងគ្នាដូចភាគល្អិតនៃអង្គធាតុរឹង ឬរាវ ។

***សន្និដ្ឋាន :*** ឧស្ម័នអាចសាយភាយដើម្បីបំពេញមាឌដែលទំនេរ ។

## 2. សម្ពាធឧស្ម័ន

### 2.1. សម្ពាធឧស្ម័ន

ឧស្ម័នបន្ថែមសម្ពាធទៅលើផ្ទៃប៉ះ ។ ពិសោធន៍ងាយៗដែលបង្ហាញពីអត្ថិភាពនៃសម្ពាធឧស្ម័ន :

- សប់ពោះវៀនកង់មួយឱ្យតឹង រួចយកម្រាមដៃទៅបិទរន្ធ នោះយើងនឹងដឹងថា មានអ្វីដែលហាក់ដូចជាច្រានម្រាមដៃយើង ។
- យកបំពង់រាង U ដែលមានដាក់ទឹកពណ៌ ។ ផ្ទៃស្រឡះនៃទឹកពណ៌មានកម្ពស់ស្មើគ្នា ។ យើងយកពីស្តុងមួយទៅដាក់នៅលើផ្នែកម្ខាងនៃបំពង់ ។ បើគេសង្កត់ពីស្តុងចុះបន្តិច គេឃើញផ្ទៃស្រឡះនៃទឹកពណ៌ប្រែប្រួលបានកម្ពស់ h ។ នេះបណ្តាលមកពីសម្ពាធខ្យល់ដែលត្រូវបង្ខាំងកើនឡើង ។ កម្ពស់ h តំណាងតម្លៃសម្ពាធនៃឧស្ម័ន ។




*រូបទី 1.5 ផ្ទៃស្រឡះនៃអង្គធាតុរាវមានកម្ពស់ស្មើគ្នា ផ្ទៃស្រឡះនៃអង្គធាតុរាវប្រែប្រួលបានកម្ពស់ h*

### 2.2. សម្ពាធបរិយាកាស

បរិយាកាសនៃផែនដី គឺជាខ្យល់ដែលជាល្បាយនៃឧស្ម័នសំខាន់ពីរ គឺអុកស៊ីសែន 21 % អាសូត 78 % និងឧស្ម័នផ្សេងៗទៀត 1 % ដូចជាចំហាយទឹក កាបូនឌីអុកស៊ីត ឧស្ម័នកម្រ ... ។ ដូចឧស្ម័នផ្សេងៗទៀតដែរ ខ្យល់ដែលនៅព័ទ្ធជុំវិញយើង និងវត្ថុផ្សេងៗបង្កើតសម្ពាធមួយហៅថា “ សម្ពាធបរិយាកាស ”។ មនុស្សយើងបានផ្សាំខ្លួនទៅតាមសម្ពាធខ្យល់ដែលនៅជុំវិញខ្លួន ដែលជាទូទៅយើងមិនបានដឹងថាមានសម្ពាធទេ ។

***ពិសោធន៍ :*** ពិសោធន៍ងាយ ដែលបង្ហាញពីអត្ថិភាពនៃសម្ពាធបរិយាកាស :

យើងរំកិលក្រដាសកាតុងពីលើមាត់កែវដែលមានទឹកពេញហៀរដោយប្រុងប្រយ័ត្នមិនឱ្យមានសល់ខ្យល់ រួចត្រឡប់ឱ្យមាត់កែវចុះក្រោម ។ ទឹកមិនបានហៀរចេញទេ ដោយសារសម្ពាធបរិយាកាសមានអំពើលើក្រដាស ហើយទឹកមិនមានទម្ងន់គ្រប់គ្រាន់ ដើម្បីឱ្យក្រដាសកាតុងផ្ដាច់ចេញបាន ។



រូបទី 1.6 ពិសោធន៍បង្ហាញពីអត្ថិភាពនៃសម្ពាធបរិយាកាស

អាតូមនិងម៉ូលេគុលឧស្ម័ននៅក្នុងបរិយាកាសដូចគ្នាទៅនឹងរូបធាតុដែលមានម៉ាសទាំងឡាយដែរគឺរងនូវទំនាញរបស់ផែនដី ។ ឧស្ម័នផ្លាស់ទីសំដៅទៅផែនដី ធ្វើឱ្យម៉ូលេគុលប៉ះទង្គិចរវាងគ្នានិងទង្គិចទៅនឹងផែនដី ។ ទង្គិចនេះបណ្ដាលឱ្យមានសម្ពាធ ។ ឧស្ម័នប្រមូលផ្ដុំនៅជិតស្រទាប់ផែនដីជាងនៅរយៈកម្ពស់ខ្ពស់ ។ ដូច្នេះដង់ស៊ីតេខ្យល់ថយចុះកាលណារយៈកម្ពស់កាន់តែកើន ។ សម្ពាធកាន់តែខ្លាំងកាលណាយើងកាន់តែមកជិតផ្ទៃផែនដី ។



រូបទី 1.7 ទង្គិចនៃម៉ូលេគុលឧស្ម័នទៅនឹងផ្ទៃផែនដី

យើងតែងកត់សំគាល់ថា ត្រចៀកហ៊ឹងពេលដែលយើងឡើងទៅរយៈកម្ពស់ខ្ពស់ ឬពេលធ្វើដំណើរតាមយន្តហោះ ។ ត្រចៀកហ៊ឹងបណ្ដាលមកពីដង់ស៊ីតេខ្យល់ប្រែប្រួល ។ ខ្យល់ដែលនៅក្នុង

ត្រចៀកបានប្តូរសម្ពាធឱ្យដូចសម្ពាធបរិយាកាសខាងក្រៅ ។ តម្លៃនៃសម្ពាធបរិយាកាស អាស្រ័យទៅនិងលក្ខខណ្ឌទឹកន្លែង សីតុណ្ហភាព និងអាកាសធាតុ ។

## 2.3. រង្វាស់សម្ពាធឧស្ម័ន

### ក. និយមន័យ

សម្ពាធ គឺជាកម្លាំងដែលផ្តល់ក្នុងមួយខ្នាតផ្ទៃ ។ ទម្រមួយដែលមានផ្ទៃ S រងនូវទង្គិចពីម៉ូលេគុលឧស្ម័នដែលមានចលនាគ្មានសណ្តាប់ធ្នាប់ ។ ទង្គិចនៃម៉ូលេគុលបង្កើតជាកម្លាំងផ្គួបដែលកែងទៅនិងទម្រ S ។



រូបទី 1.8 ទង្គិចនៃម៉ូលេគុលឧស្ម័នទៅនិងទម្រ

សម្ពាធឧស្ម័នគឺ : $P = \frac{F}{S}$

ក្នុងប្រព័ន្ធខ្នាតអន្តរជាតិ (SI) , F គិតជាញូតុន (N) S គិតជា $m^2$ និង P គិតជាប៉ាស្កាល់ (Pa) ។

ដែល $1Pa = 1N\ m^{-2}$

***សំគាល់*** : សម្ពាធ 1Pa ខ្សោយណាស់ គឺហាក់ដូចជាយើងយកម៉ាស 100g ទៅពង្រាយយ៉ាងស្មើលើផ្ទៃ $1m^2$ ។ ក្នុងន័យនេះហើយគេនិយមប្រើពហុគុណនៃប៉ាស្កាល់ ។

1 បារ (bar) = $10^5$Pa និង 1 មីលីបារ (mbar) = 100Pa

### ខ. ឧបករណ៍រង្វាស់សម្ពាធ

គេប្រើឧបករណ៍ឈ្មោះ ម៉ាណូម៉ែត ដើម្បីវាស់សម្ពាធឧស្ម័ន ។ គេដឹងពីកម្រិតសម្ពាធឧស្ម័នដោយផ្អែកលើបម្លាស់ទី h របស់អង្គធាតុរាវដែលដាក់ក្នុងបំពង់ ។ ក្រៅពីទឹកគេអាចប្រើអង្គធាតុរាវផ្សេងៗ ប៉ុន្តែគេនិយមប្រើបារតព្រោះបារតមានដង់ស៊ីតេធៀបនឹងទឹកគឺ 13.6 ដង ដែលធ្វើឱ្យកម្ពស់ h មិនសូវមានតម្លៃធំដូចករណីប្រើទឹកទេ ។



រូបទី 1.9 ម៉ាណូម៉ែត

***សំគាល់*** : ម៉ាណូម៉ែតប្រភេទនេះ មិនអាចវាស់បានសម្ពាធដាច់ខាតរបស់ឧស្ម័នទេ ប៉ុន្តែជាផល

សងរវាងសម្ពាធឧស្ម័នដែលអនុវត្តនៅផ្នែកម្ខាងនៃបំពង់និងសម្ពាធខ្យល់ដែលមានអំពើនៅផ្នែកម្ខាងទៀត ។

ម៉ាណូម៉ែតមានច្រើនប្រភេទដែលខុសគ្នា ដោយសាររូបរាងនិងរបៀបដំណើរការ ដូចជាម៉ាណូម៉ែតដែលដាក់ភ្ជាប់នឹងដបឧស្ម័នដែលគេបណ្តែន ឬម៉ាណូម៉ែតដែលដាក់ភ្ជាប់ទៅនឹងឧបករណ៍សប់កង់រថយន្ត ។ ម៉ាណូម៉ែតប្រភេទនេះ គិតជាបារសម្រាប់វាស់សម្ពាធឧស្ម័នដែលលើស (ក្នុងដប ឬក្នុងកង់) ធៀបនឹងសម្ពាធបរិយាកាស ។




*រូបទី 1.10 ដបធ្វើពីដែកថែបផ្ទុកអុកស៊ីសែនបណ្តែន*

ដប $O_2$ មិនទាន់ប្រើមានសម្ពាធ 200bars មានន័យថា ឧស្ម័នក្នុងដបមានមាឌ 200 ដងនៃមាឌដប កាលណា $O_2$ ត្រូវបានប្រើប្រាស់សម្ពាធថយចុះ ។ កាលណាសម្ពាធថយដល់សូន្យមានន័យថា សម្ពាធ $O_2$ ក្នុងដបស្មើនឹងសម្ពាធបរិយាកាស ដូច្នេះគេត្រូវបំពេញ $O_2$ ជាថ្មី ។




*រូបទី 1.11 ម៉ាណូម៉ែតវាស់សម្ពាធខ្យល់កង់រថយន្ត*

ម៉ាណូម៉ែតចង្អុល 2.2bars មានន័យថា ៖

- សម្ពាធលើសនៃខ្យល់ខាងក្នុងកង់គឺ 2.2bars
- សម្ពាធនៃខ្យល់ខាងក្នុងកង់គឺ ៖

2.2bars + 1bar (សម្ពាធបរិយាកាស) = 3.2bars ។

ឧបករណ៍សម្រាប់វាស់សម្ពាធបរិយាកាសមានឈ្មោះថា “ បារ៉ូម៉ែត ” ។ បារ៉ូម៉ែតសាមញ្ញជាបំពង់កែវមួយមានប្រវែង 1m មានចុងម្ខាងបិទជិតបំពេញដោយបារត ។ ចុងម្ខាងទៀតដែលចំហត្រូវផ្កាប់ចូលទៅក្នុងផើងបារតមួយ ។ បារតក្នុងបំពង់កែវមួយចំនួនហូរចេញពីបំពង់កែវបង្កើតបានជាសុញ្ញកាសនៅកំពូលខាងលើ ។ ទម្ងន់បារតក្នុងបំពង់កែវត្រូវបានទ្រទ្រង់ដោយសម្ពាធបរិយាកាសដែលមានអំពើលើផ្ទៃបារតក្នុងផើង ។ នៅនីវ៉ូទឹកសមុទ្រ (រយៈកម្ពស់សូន្យ)សសរបារតមានកម្ពស់ប្រហែល 760mm ។ សម្ពាធនេះហៅថា សម្ពាធ 1 អាត់ម៉ូស្វែ




*រូបទី 1.12 ពិសោធន៍របស់តូរីសែលី*

(atm) ។ 1mm របស់សសរបារតអាចហៅថា 1 ត័រ (torr) ដែលបានមកពីឈ្មោះរូបវិទូអ៊ីតាលី Evangelista Torricelli ដែលជាអ្នកបង្កើតបារ៉ូម៉ែត ។

ដើម្បីសិក្សាអំពីឥទ្ធិពលនៃបម្រែបម្រួលសីតុណ្ហភាពនិងសម្ពាធទៅលើឧស្ម័ន អ្នកវិទ្យាសាស្ត្របានកំណត់លក្ខខណ្ឌមួយហៅថា ស្តង់ដាសីតុណ្ហភាពនិងសម្ពាធ (STP) ដែលគិតនៅ 0°C និង 1atm ។

តារាងទី 1.2 តារាងខ្នាតផ្សេងៗនៃសម្ពាធ

| ខ្នាត | អក្សរកាត់ | តម្លៃសមមូលនឹង Pa |
|---|---|---|
| អាត់ម៉ូស្វែ | atm | 1atm = 101 325Pa |
| បារ (Bar) | bar | 1bar = 100 025Pa<br>$1bar = 10^5 Pa$ |
| មីលីម៉ែតបារត | mmHg | 1mmHg = 133.322Pa |
| ប៉ាស្កាល់ | Pa | |
| ផោនក្នុង 1 អ៊ិញការេ | psi | $1psi = 6.89286 \times 10^3 Pa$ |
| ត័រ | torr | 1torr = 133.322Pa |




*រូបទី 1.13 បារ៉ូម៉ែតបារត បារ៉ូម៉ែតនេះចង្អុលសម្ពាធបរិយាកាសដែលស្មើនឹង 770mmHg*

***ឧទាហរណ៍ :*** ចូរបំលែង 1atm ទៅជាមីលីម៉ែតបារត (ដោយប្រើតារាង) ។

**ចម្លើយ**

យើងដឹងថា $1atm = 101\ 325Pa$ ឬ $Pa = \frac{1atm}{101\ 325}$

$1mmHg = 133.322Pa$ ឬ $Pa = \frac{1mmHg}{133.322}$

គេបាន $\frac{1atm}{101\ 325} = \frac{1mmHg}{133.322}$

$1atm = \frac{101\ 325}{133.322} \times 1mmHg = 760.0mmHg$ ។

**លំហាត់អនុវត្តន៍**

បារ៉ូម៉ែតមួយចង្អុលសម្ពាធ 776mmHg ។ ចូរបំលែងសម្ពាធនេះជាបារ (bar) ។

ចម្លើយ : 1.034bars ។

# ៣. ទ្រឹស្តីស៊ីនេទិច - ម៉ូលេគុល

បច្ចុប្បន្នគេពន្យល់លក្ខណៈឧស្ម័នដោយផ្អែកទៅលើទ្រឹស្តីស៊ីនេទិច-ម៉ូលេគុល ។ ទ្រឹស្តីនេះ គឺជាគំរូដែលប្រើសម្រាប់ព្យាករណ៍លក្ខណៈរបស់ឧស្ម័ន ។




*រូបទី 1.14 ខ្សែកោងបង្ហាញថា ភាពខុសគ្នានៃសីតុណ្ហភាព 10°c បានធ្វើឱ្យថាមពលស៊ីនេទិចមធ្យមកើន*

ឧស្ម័នបង្កឡើងពីអាតូមឬម៉ូលេគុលដែលនៅឃ្លាតគ្នាដោយចម្ងាយមួយធំជាងវិមាត្ររបស់វា ។ គេអាចចាត់ទុកភាគល្អិតរបស់ឧស្ម័នថាជាចំណុចរូបធាតុ ។ ម៉ូលេគុលឧស្ម័នមានម៉ាស ប៉ុន្តែមាឌរបស់វាអាចចោលបាន ។ គំនិតនេះហើយដែលអាចពន្យល់បានពីលក្ខណៈហូរបាននិងអាចបណ្ណែនបានរបស់ឧស្ម័ន ។

អាតូម ឬម៉ូលេគុលឧស្ម័ន មានចលនាដោយឥតឈប់ឈរនិងគ្មានសណ្តាប់ធ្នាប់ ។ ជួនកាលភាគល្អិតរបស់វាខិតទៅជិតគ្នា ឬឆ្លងកាត់គ្នា ដោយសារភាគល្អិតវាស្ថិតនៅឆ្ងាយៗពីគ្នាជាងករណីអង្គធាតុរឹង ឬរាវ ។ ជួនកាលវារងនូវទង្គិចជាមួយម៉ូលេគុលគ្នាវា ឬទង្គិចជាមួយជញ្ជាំងនៃឧបករណ៍ដែលផ្ទុកវា នេះហើយជាមូលហេតុនៃសម្ពាធ ។ ទង្គិចនេះ ជាទង្គិចខ្ទាត ហើយក្នុងពេលនោះថាមពលត្រូវបានប្តូរគ្នា ។ ប៉ុន្តែទោះជាយ៉ាងណាថាមពលនៃប្រព័ន្ធនៅមានតម្លៃថេរ ។

ម៉ូលេគុលឧស្ម័នជានិច្ចកាលមានចលនាឥតសណ្តាប់ធ្នាប់ ។ តម្លៃមធ្យមនៃថាមពលស៊ីនេទិចរបស់ចលនាឥតសណ្តាប់ធ្នាប់សមាមាត្រទៅនឹងសីតុណ្ហភាពដាច់ខាត (សីតុណ្ហភាពកែលវិន) ។ កម្តៅបង្កើនថាមពលនៃចលនាឥតសណ្តាប់ធ្នាប់នេះ ។ ប៉ុន្តែចលនាម៉ូលេគុលទាំងឡាយមិនមានល្បឿនដូចគ្នាទេ ។ ដោយសារលទ្ធផលនៃទង្គិចច្រើនដងម៉ូលេគុលទាំងឡាយមានល្បឿនខុសៗគ្នា ។

## សង្ខេបមេរៀន

- អង្គធាតុមួយអាចស្ថិតក្នុងភាពរូបមួយ (រឹង រាវ ឬឧស្ម័ន) អាស្រ័យទៅនឹងលក្ខខណ្ឌសីតុណ្ហភាព ឬសម្ពាធជាក់លាក់មួយ ។
- អង្គធាតុមួយចំនួនអាចស្ថិតនៅជាភាពឧស្ម័ននៅសីតុណ្ហភាព 25°C និងក្រោមសម្ពាធបរិយាកាស ។ ឧស្ម័នទាំងឡាយមានលក្ខណៈរួមមួយ គឺមានលំហអន្តរម៉ូលេគុលធំ បើប្រៀបធៀបទៅនឹងវិមាត្រម៉ូលេគុល ។ ឧស្ម័នមានដង់ស៊ីតេតូច អាចបណ្ណែនបាន អាចសាយភាយបំពេញវត្ថុដែលផ្ទុកវា និងជាសន្ទនីយ ។
- ម៉ូលេគុលឧស្ម័នធ្វើចលនាយ៉ាងរហ័ស គ្មានសណ្តាប់ធ្នាប់ជាហេតុនាំឱ្យកើតមានទង្គិចរវាងម៉ូលេគុល និងម៉ូលេគុលព្រមទាំងទង្គិចជាមួយជញ្ជាំងវត្ថុដែលផ្ទុកវា ដែលបង្កើតជាសម្ពាធ ។
  - ទង្គិចរវាងម៉ូលេគុល $O_2$ និង $N_2$ នៃខ្យល់ទៅនឹងផ្ទៃផែនដី បង្កើតបានជាសម្ពាធបរិយាកាស
  - ម៉ាណូម៉ែត ជាឧបករណ៍សម្រាប់វាស់សម្ពាធឧស្ម័ន ។
  - បារ៉ូម៉ែត ជាឧបករណ៍សម្រាប់វាស់សម្ពាធបរិយាកាស ។
  - សម្ពាធបរិយាកាសប្រែប្រួលទៅតាមរយៈកម្ពស់ សម្ពាធថយចុះ កាលណារយៈកម្ពស់កាន់តែកើនឡើង ។ នៅនីវ៉ូទឹកសមុទ្រសសរបារតក្នុងបារ៉ូម៉ែតមានកម្ពស់ប្រហែល 760mm ។ សម្ពាធនេះមានឈ្មោះថា 1 អាត់ម៉ូស្វែ (1atm) ។
  - ដោយសារការរងនូវទង្គិចជាញយដង ម៉ូលេគុលឧស្ម័នមិនមានល្បឿនដូចគ្នាទេ ។

## សំណួរនិងលំហាត់

1. តើលក្ខណៈណារបស់ឧស្ម័នដែលធ្វើឱ្យវាខុសពីអង្គធាតុរឹង ឬរាវ ?
2. ហេតុអ្វីបានជាគេចាត់ទុកឧស្ម័នជាសន្ទនីយ ?
3. តើមានអ្វីកើតឡើងទៅលើអាតូម ឬម៉ូលេគុលឧស្ម័ននៅពេលគេបណ្ណែន ?
4. តើលក្ខណៈដែលឧស្ម័នអាចបំពេញវត្ថុដែលផ្ទុកវាខុសប្លែកដូចម្តេចពីអង្គធាតុរឹង ឬរាវ ?
5. សម្ពាធរបស់ចំហាយទឹកនៅសីតុណ្ហភាព 50°C គឺ 12.33kPa (គីឡូប៉ាស្កាល់) តើសម្ពាធនេះត្រូវនឹងប៉ុន្មានមីលីម៉ែតបារត ?
6. សម្ពាធបរិយាកាសនៅលើកំពូលភ្នំមួយគឺ 58kPa ។ តើសម្ពាធនេះត្រូវនឹងប៉ុន្មានអាត់ម៉ូស្វែ ?
7. ម៉ាណូម៉ែតរបស់ឧបករណ៍សប់កង់មួយចង្អុល 28psi ។ សម្ពាធបរិយាកាសគឺ 14psi ។ ចូររកសម្ពាធក្នុងកង់ជា kPa ?

មេរៀនទី

# 2 ច្បាប់ឧស្ម័ន

**ចប់មេរៀននេះ សិស្សអាច**

- ពោលច្បាប់ប៊យ(Boyle) និងអនុវត្តច្បាប់ប៊យក្នុងការគណនាលំហាត់ ។
- ពោលច្បាប់សាល(Charles) និងអនុវត្តច្បាប់សាលក្នុងការគណនាលំហាត់ ។
- ពោលច្បាប់កាយ-លុយសាក់(Gay-Lussac) និងអនុវត្តច្បាប់កាយ-លុយសាក់ក្នុងការគណនាលំហាត់ ។
- ពោលច្បាប់អាវ៉ូកាដ្រូ(Avogadro) និងអនុវត្តច្បាប់អាវ៉ូកាដ្រូក្នុងការកំណត់រករូបមន្តគីមីនៃអង្គធាតុសមាស ។

## 1. ទំនាក់ទំនងរវាងសម្ពាធ-មាឌ

ក្នុងមេរៀនទី 1 ជំពូកទី 5 យើងបានសិក្សាពីសម្ពាធនៃឧស្ម័ន និងភាពអាចបង្រួម និងពង្រីកបាននៃឧស្ម័ន ។ នៅឆ្នាំ 1662 អ្នកវិទ្យាសាស្ត្រអង់គ្លេសឈ្មោះ ***រ៉ូបឺតប៊យ*** (Robert Boyle) បានសិក្សាពីទំនាក់ទំនងរវាងសម្ពាធនិងមាឌឧស្ម័ន ។ គាត់បានរកឃើញថា សម្ពាធនៃឧស្ម័ននៅក្នុងប្រអប់បិទជិត កើនឡើងកាលណាមាឌឧស្ម័ននោះថយចុះ ហើយផលគុណរវាងសម្ពាធ P និងមាឌ V រក្សាតម្លៃថេរនៅសីតុណ្ហភាពថេរ ។ ក្នុងតារាងទី 2-1 ជាទិន្នន័យបានពីការពិសោធដែលអនុវត្តតាមប៊យនៅសីតុណ្ហភាពថេរ ។

តារាងទី 2.1 : ទិន្នន័យទំនាក់ទំនងសម្ពាធ-មាឌនៃឧស្ម័ននៅសីតុណ្ហភាពថេរ

| សម្ពាធ (P) | មាឌ (V) | P · V(kPa × L) |
|---|---|---|
| 100 kPa | 0.500L | 50.0 |
| 150 kPa | 0.334L | 50.1 |
| 200 kPa | 0.250L | 50.0 |
| 250 kPa | 0.200L | 50.0 |
| 300 kPa | 0.167L | 50.1 |



*រូបទី2.1 ក. ម៉ូលេគុលឧស្ម័នសាយភាយពេញស៊ីឡាំងនៃម៉ាស៊ីន*

*ខ. ពេលមាឌឧស្ម័ននៅក្នុងស៊ីឡាំងថយចុះ ធ្វើឱ្យការទង្គិចនៃម៉ូលេគុលកាន់តែច្រើន ជាហេតុនាំឱ្យសម្ពាធឧស្ម័នកើនឡើង ។*

រូបទី 2.1 បង្ហាញពីម៉ូលេគុលឧស្ម័ននៅក្នុងស៊ីឡាំងនៃម៉ាស៊ីន តើមានអ្វីកើតឡើងនៅពេលវារួមមាឌ (វត្ថុបណ្ណែន)? នៅពេលមាឌឧស្ម័នថយចុះ កំហាប់ និងសម្ពាធនៃឧស្ម័នកើនឡើង ។ បញ្ញត្តិស្ដីពីទំនាក់ទំនងច្រាសគ្នារវាងសម្ពាធនិងមាឌ ដែលរកឃើញដោយលោក ***រ៉ូប៊ឺតប៊ិយ***បង្ហាញដោយក្រាបក្នុងរូបទី 2.2 ។

***ច្បាប់ប៊ិយ :*** "បរិមាណកំណត់នៃឧស្ម័នមួយនៅសីតុណ្ហភាពថេរ មាឌនៃឧស្ម័នកើនឡើង កាលណាសម្ពាធនៃឧស្ម័នថយចុះ និងមាឌនៃឧស្ម័នថយចុះ កាលណាសម្ពាធនៃឧស្ម័នកើនឡើង " ។

ក្នុងតារាងទី 2.2 បង្ហាញពីផលគុណរវាងសម្ពាធនិងមាឌឧស្ម័នរក្សាតម្លៃថេរនៅសីតុណ្ហភាពថេរ ។

$$PV = k \quad (\text{ថេរ})$$

បើសីតុណ្ហភាពនិងបរិមាណឧស្ម័នមិនប្រែប្រួល នោះផលគុណ PV ក៏មិនប្រែប្រួលដែរ ។ នាំឱ្យគេបានសមីការ :

$$P_1V_1 = P_2V_2$$




*រូបទី 2.2 : ក្រាបបង្ហាញពីទំនាក់ទំនងច្រាសគ្នារវាងសម្ពាធឧស្ម័ននៅសីតុណ្ហភាពថេរ*

***លំហាត់គំរូ*** : ឧស្ម័នមួយមានមាឌ 1.00L នៅសម្ពាធ 1.00atm ។ គេឱ្យឧស្ម័ននោះរងនូវសម្ពាធ 2.00atm និងសីតុណ្ហភាពថេរ ។ ចូរកំណត់រកមាឌថ្មីនៃឧស្ម័ន ។

***ចម្លើយ :***

សម្ពាធនិងមាឌដើម : $P_1 = 1.00atm$ និង $V_1 = 1.00L$

សម្ពាធនិងមាឌថ្មី : $P_2 = 2.00atm$ និង $V_2 = ?$

តាមទំនាក់ទំនង : $P_1V_1 = P_2V_2$

$$V_2 = \frac{P_1V_1}{P_2} = \frac{(1.00atm)(1.00L)}{2.00atm}$$

$V_2 = 0.50L$ ។

**លំហាត់អនុវត្តន៍**

1. គេយកឧស្ម័នអុកស៊ីសែនដែលមានមាឌ 500mL នៅសម្ពាធ 1.00atm ទៅបង្រួមមាឌឱ្យនៅត្រឹម 100mL ។ ចូរកំណត់រកសម្ពាធថ្មីនៃឧស្ម័នអុកស៊ីសែន ?
2. ខ្យល់នៅក្នុងសឺរ៉ាំងបិទជិតមួយមានមាឌ 9.80mL នៅសម្ពាធ 64.00kPa ។ គេសង្កត់ដងសឺរ៉ាំងរហូត គេទទួលបានសម្ពាធ 94.20kPa ។ ចូរកំណត់រកមាឌថ្មីនៃខ្យល់ ។ ឧបមាថាសីតុណ្ហភាពនៃខ្យល់មិនប្រែប្រួល ។

# 2. ទំនាក់ទំនាក់រវាងសីតុណ្ហភាព-មាឌ

## 2.1. ពិសោធន៍

គេយកប៉េងប៉ោង A និង B ផ្លុំខ្យល់បញ្ចូលដោយធ្វើយ៉ាងណាឱ្យមាឌរបស់វាប្រហាក់ប្រហែលគ្នា (រូបទី 2.3 ក.) ។ បន្ទាប់មកគេយកប៉េងប៉ោង B ទៅដាក់ក្នុងឆ្នាំងដែលមានចំហាយទឹកពុះ(រូបទី 2.3 ខ) ។ គេសង្កេតឃើញប៉េងប៉ោង B មានទំហំធំជាងប៉េងប៉ោង A ។ បើគេយកប៉េងប៉ោង B ចេញពីក្នុងឆ្នាំង ហើយទុកឱ្យត្រជាក់ដូចសីតុណ្ហភាពដើមវិញ គេសង្កេតឃើញប៉ោង A និង B មានទំហំប៉ុនគ្នាដដែល (រូបទី 2.3 គ) ។

ដូច្នេះឧស្ម័នរីកមាឌកាលណាវាប៉ះកម្តៅនិងរួមមាឌកាលណាប៉ះត្រជាក់ ។




*រូបទី 2.3 : ពិសោធន៍ការរីកនិងការរួមមាឌនៃឧស្ម័ននៅតាមសីតុណ្ហភាព ។*

## 2.2. ច្បាប់សាល (Charles)

នៅឆ្នាំ 1787 អ្នករូបវិទ្យាជនជាតិបារាំងឈ្មោះ ហ្សាក់ សាល (Jacques Charles 1746-1823) បានរកឃើញថាមាឌឧស្ម័នសមាមាត្រទៅនឹងសីតុណ្ហភាពដែលគិតជាខ្នាតកែលវិន K ក្នុងលក្ខខណ្ឌសម្ពាធឧស្ម័នមិនប្រែប្រួល ។

*ច្បាប់សាល* : "បរិមាណកំណត់នៃឧស្ម័នមួយនៅសម្ពាធថេរ មាឌនៃឧស្ម័នកើនឡើងកាលណាសីតុណ្ហភាពកើនឡើងនិងមាឌឧស្ម័នថយចុះកាលណាសីតុណ្ហភាពថយចុះ " ។

តាមទ្រឹស្តីស៊ីនេទិច-ម៉ូលេគុល ភាគល្អិតនៃឧស្ម័នធ្វើចលនាកាន់តែលឿន កាលណាសីតុណ្ហភាពកាន់តែធំ ជាហេតុធ្វើឱ្យភាគល្អិតនៃឧស្ម័នទៅទង្គិចនឹងជញ្ជាំងវត្ថុដែលផ្ទុកវាដោយកម្លាំងកាន់តែខ្លាំង និងកាន់តែច្រើន ។ ការប៉ះទង្គិចយ៉ាងខ្លាំងម្តងហើយម្តងទៀតរវាងភាគល្អិតនៃឧស្ម័នទៅនឹងជញ្ជាំងវត្ថុផ្ទុកវា ធ្វើឱ្យមាឌវត្ថុដែលផ្ទុករីកមាឌធំឡើង ដូចករណីប៉េងប៉ោង ។ ផ្ទុយទៅវិញមាឌឧស្ម័នថយចុះ កាលណាសីតុណ្ហភាពនៃឧស្ម័នចុះត្រជាក់ គឺដោយសារថាមពលស៊ីនេទិចមធ្យមនៃភាគល្អិតឧស្ម័នថយចុះ ។

តារាងទី 2.2 ជាទិន្នន័យដែលទទួលបានពីការពិសោធ ទំនាក់ទំនងរវាងសីតុណ្ហភាព-មាឌនៃឧស្ម័ន ដែលអនុវត្តតាម ហ្សាក់សាល ។

**តារាងទី 2.2 : ទិន្នន័យនៃទំនាក់ទំនងរវាងសីតុណ្ហភាព-មាឌនៅសម្ពាធថេរ**

| សីតុណ្ហភាព | សីតុណ្ហភាព (T) | មាឌ (V) | V/T (mL/K) |
|---|---|---|---|
| 0°C | 273K | 400mL | 1.46 |
| 100°C | 373K | 548mL | 1.47 |
| 200°C | 473K | 692mL | 1.46 |
| 300°C | 573K | 840mL | 1.46 |

តាមរយៈទិន្នន័យក្នុងតារាងទី 2.2 គេអាចសង់ក្រាបដែលបង្ហាញពីសមាមាត្ររវាងមាឌនិងសីតុណ្ហភាពនៃឧស្ម័ន ។




*រូបទី 2.4 : ក្រាបបង្ហាញពីទំនាក់ទំនងរវាងមាឌនិងសីតុណ្ហភាពនៃឧស្ម័ន*

បើគេបន្ថយបន្ទាត់ឱ្យដល់សូន្យដាច់ខាត (0 K) នោះមាឌឧស្ម័ននិងក្លាយទៅជាសូន្យដែរ ។ តើមាឌឧស្ម័នអាចស្មើសូន្យនៅសីតុណ្ហភាពសូន្យដាច់ខាតដែរឬទេ ? តាមពិតឧស្ម័នក្លាយទៅជាអង្គធាតុរាវនិងអង្គធាតុរឹង មុនពេលសីតុណ្ហភាពចុះទៅដល់សូន្យដាច់ខាត ។ ដូច្នេះអង្គធាតុរាវ ឬរឹងមិនអាចរួមមាឌបានទេ ។ នៅសូន្យដាច់ខាតម៉ូលេគុលទាំងអស់ស្ទើរតែគ្មានចលនា ។

តាមទិន្នន័យក្នុងតារាងទី 2.2 គេសង្កេតឃើញថា ផលចែករវាងមាឌនិងសីតុណ្ហភាពមានតម្លៃថេរ កាលណាសម្ពាធឧស្ម័នមានតម្លៃថេរ ។ ដូច្នេះតាមច្បាប់សាលគេអាចសរសេរសមីការ :

$$\frac{V}{T} = k \quad (\text{ថេរ})$$

បើផលចែក $\frac{V}{T}$ រក្សាតម្លៃថេរនៅគ្រប់លក្ខខណ្ឌ នោះច្បាប់សាលអាចសំដែងដូចទំនាក់ទំនងខាងក្រោមនេះផងដែរ : $\frac{V_1}{T_1} = \frac{V_2}{T_2}$ ។

***លំហាត់គំរូ :*** ប៉េងប៉ោងមួយផ្ទុកខ្យល់ 2000mL នៅសីតុណ្ហភាព 27°C ។ គេយកប៉េងប៉ោងនោះទៅដាក់ក្នុងទូទឹកកកដែលមានសីតុណ្ហភាព –15°C ។ ចូរកំណត់រកមាឌប៉េងប៉ោងនៅក្នុងទូទឹកកក ។ ឧបមាថាសម្ពាធខ្យល់មិនប្រែប្រួល ។

***ចម្លើយ :***

ប្តូរខ្នាតសីតុណ្ហភាពពីអង្សាសេលស៊ីុសទៅកែលវិន

$T_1 = 27°C + 273 = 300K$

$T_2 = -15°C + 273 = 258K$

មាឌនិងសីតុណ្ហភាពដើម : $V_1 = 2000mL$ , $T_1 = 300K$

មាឌនិងសីតុណ្ហភាពថ្មី : $V_2 = ?$ , $T_2 = 258K$

តាមទំនាក់ទំនងរវាងមាឌនិងសីតុណ្ហភាព :

$$\frac{V_1}{T_1} = \frac{V_2}{T_2}$$

$$V_2 = \frac{V_1 T_2}{T_1} = \frac{2000mL \times 258K}{300K}$$

$V_2 = 1720mL$ ។

## លំហាត់អនុវត្តន៍

1. គេបញ្ចូលឧស្ម័នអេល្យូម 1.5L ទៅក្នុងប៉េងប៉ោងមួយនៅសីតុណ្ហភាព 315.0K ។ គេយកប៉េងប៉ោងនោះទៅដាក់ក្នុងអាសូតរាវដែលមានសីតុណ្ហភាព 80.0K ។ ចូរកំណត់រកមាឌឧស្ម័នអេល្យូមក្នុងប៉េងប៉ោងនៅសីតុណ្ហភាពដ៏ត្រជាក់នោះ ។ លក្ខខណ្ឌសម្ពាធនៃឧស្ម័នមិនប្រែប្រួល ។
2. ឧស្ម័នអ៊ីដ្រូសែននៅក្នុងប៉េងប៉ោងមួយមានមាឌ 625mL នៅសីតុណ្ហភាព 25°C ។ ចូរកំណត់រកមាឌប៉េងប៉ោង កាលណាគេយកវាទៅដាក់ក្នុងមជ្ឈដ្ឋានដែលមានសីតុណ្ហភាព 80°C ។ ឧបមាថា សម្ពាធឧស្ម័នមិនប្រែប្រួល ។

## 3. ទំនាក់ទំនងរវាងសីតុណ្ហភាព-សម្ពាធ

យើងបានដឹងហើយថា សម្ពាធនៃឧស្ម័នកើតឡើងពីការប៉ះទង្គិចរវាងភាគល្អិតនៃឧស្ម័នទៅនិងផ្ទៃនៃវត្ថុដែលផ្ទុកវា ។ ថាមពលស៊ីនេទិចមធ្យមនៃភាគល្អិតសមាមាត្រទៅនិងសីតុណ្ហភាពដាច់ខាតមធ្យម ។ បើសីតុណ្ហភាពដាច់ខាតនៃភាគល្អិតរបស់ឧស្ម័នមានពីរដង នោះថាមពលស៊ីនេទិចមធ្យមរបស់ភាគល្អិតនៃឧស្ម័នក៏មានពីរដងដែរ ។ រូបទី 2.5 បរិមាណឧស្ម័ននៅក្នុងដបមិនប្រែប្រួល បើការប៉ះទង្គិចផ្តល់ថាមពលទ្វេដងនោះសម្ពាធផ្តល់ដោយឧស្ម័នក៏ទ្វេដងដែរ ។




*រូបទី 2.5 កាលណាមាឌរបស់ឧស្ម័នមិនប្រែប្រួល សម្ពាធឧស្ម័នកើនឡើងទៅតាមសីតុណ្ហភាព ។*

***ច្បាប់កាយ លុយសាក់ :*** កាយ លុយសាក់ បានសិក្សាពីទំនាក់ទំនងរវាងសីតុណ្ហភាពនិងសម្ពាធនៃឧស្ម័នហើយបានបង្កើតច្បាប់ " នៅមាឌថេរ សម្ពាធនៃឧស្ម័នសមាមាត្រទៅនឹងសីតុណ្ហភាពដាច់ខាត " ។

រូបទី 2.6 ជាក្រាបបង្ហាញពីបម្រែបម្រួលសម្ពាធជាមួយនឹងសីតុណ្ហភាពនៃឧស្ម័ន ដែលមានមាឌថេរ ។ ក្រាបជាបន្ទាត់ដែលមានមេគុណប្រាប់ទិសវិជ្ជមាន ហើយក្នុងនោះបង្ហាញពីសីតុណ្ហភាព និងសម្ពាធដែលសមាមាត្រនឹងគ្នា ។




*រូបទី 2.6 ក្រាបបង្ហាញពីទំនាក់ទំនងរវាងសីតុណ្ហភាពនិងសម្ពាធនៃឧស្ម័ននៅមាឌថេរ*

ដោយសម្ពាធសមាមាត្រនិងសីតុណ្ហភាពដាច់ខាត នៅមាឌឧស្ម័នថេរនាំឱ្យគេបានសមីការ :

$P = kT$ ឬ $\frac{P}{T} = k$ ( ថេរ)

បើបរិមាណនិងមាឌឧស្ម័នមិនប្រែប្រួល គេបានសមីការ : $\frac{P_1}{T_1} = \frac{P_2}{T_2}$ ។

***លំហាត់គំរូ :*** ធុងឧស្ម័នមួយផ្ទុកឧស្ម័ននៅសម្ពាធ 120.0kPa នៅសីតុណ្ហភាព 20°C ។ ធុងនោះត្រូវកម្តៅធ្វើឱ្យសីតុណ្ហភាពឡើងដល់ 50°C ។ គណនាសម្ពាធឧស្ម័ននៅសីតុណ្ហភាព 50°C ។

*ចម្លើយ :*

ប្តូរខ្នាតសីតុណ្ហភាពពីសែលស្យុសទៅកែលវិន

$T_1 = 20°C + 273 = 293K$

$T_2 = 50°C + 273 = 323K$

សម្ពាធនិងសីតុណ្ហភាពដើម

$P_1 = 120.0kPa$ , $T_1 = 293K$

សម្ពាធនិងសីតុណ្ហភាពថ្មី

$P_2 = ?$ , $T_2 = 323K$

តាមសមីការទំនាក់ទំនងសីតុណ្ហភាពនិងសម្ពាធ

$$\frac{P_1}{T_1} = \frac{P_2}{T_2}$$

$$P_2 = \frac{P_1 \times T_2}{T_1}$$

$$P_2 = \frac{(120.0kPa)(323K)}{293K}$$

$P_2 = 132.2kPa$ ។

**លំហាត់អនុវត្តន៍**

1. នៅសីតុណ្ហភាព 130°C ធុងឧស្ម័នអុកស៊ីសែនមួយមានសម្ពាធ 1.10atm ។ តើសម្ពាធរបស់ធុងឡើងដល់ប៉ុន្មាន កាលណាសីតុណ្ហភាពរបស់វាឡើងដល់ 205°C ?
2. ធុងឧស្ម័នអាសូតមួយមានសម្ពាធ 1.20atm នៅសីតុណ្ហភាព 130°C ។ គេយកធុងនោះទៅដាក់នៅកន្លែងដែលមានសីតុណ្ហភាពត្រជាក់ គេដឹងថា សម្ពាធរបស់ឧស្ម័ននៅក្នុងធុងចុះមកត្រឹម 0.90atm ។ តើសីតុណ្ហភាពថ្មីរបស់វាត្រូវនឹងប៉ុន្មាន ? ឧបមាថា មានឧស្ម័នមិនប្រែប្រួល ។

# ពិសោធន៍ទំនាក់ទំនងរវាងសីតុណ្ហភាព-សម្ពាធ

- **វត្ថុបំណង**

បង្ហាញឱ្យឃើញថាសម្ពាធឧស្ម័នកើនឡើង កាលណាសីតុណ្ហភាពកើនឡើង សម្ពាធឧស្ម័នថយចុះ កាលណាសីតុណ្ហភាពថយចុះនៅលក្ខខណ្ឌមាឌថេរ ។

- **សម្ភារៈ**
  - កែវបាឡុង 0.5L (ឬកែវតែ) 1
  - ចង្ក្រានហ្គាស 1
  - កំសៀវទឹក 1
  - កាធុនជ័រចំណុះប្រហែល 3L 2
  - ទឹកកក 1kg
  - ទឹក 3L
- **ដំណើរការពិសោធ**
  - ដាក់ទឹកក្នុងកំសៀវប្រហែល 1L និងដាំឱ្យពុះ ហើយចាក់ទឹកក្តៅនេះទៅក្នុងកាធុនជ័រ ។ យកទឹកកកដាក់ក្នុងកាធុនជ័រមួយទៀត ហើយចាក់ទឹកត្រជាក់ចូល ។
  - យកស្បែកប៉េងប៉ោងទៅគ្របមាត់កែវបាឡុង(ឬកែវតែ)និងរឹតកៅស៊ូកងឱ្យជិត(មើលរូប 2.7ក)
  - យកកែវបាឡុងដែលពាសដោយស្បែកប៉េងប៉ោងទៅដាក់ក្នុងកាធុនទឹកក្តៅនិងបន្ទាប់មកទៅដាក់ក្នុងកាធុនទឹកកក ។



ក. កែវបាឡុងពាសស្បែកប៉េងប៉ោង ខ. កែវបាឡុងត្រាំក្នុងទឹកក្តៅ គ. កែវបាឡុងត្រាំក្នុងទឹកកក

*រូបទី2.7 ពិសោធន៍ទំនាក់ទំនងរវាងសម្ពាធ-សីតុណ្ហភាព ។*

• កត់ត្រាលទ្ធផលពិសោធន៍

គ្រូណែនាំសិស្សឱ្យសង្កេតស្បែកប៉េងប៉ោង ដែលពាសមាត់កែវបាឡុងនៅពេលកែវបាឡុងនៅក្នុងសីតុណ្ហភាពបន្ទប់រៀន ត្រាំទឹកក្ដៅ និងត្រាំទឹកកក ហើយកត់ត្រាហេតុការណ៍ដែលកើតឡើងដាក់ក្នុងតារាងទី 2.3 ។

តារាងទី 2.3

| កែវបាឡុងក្នុងសីតុណ្ហភាពបន្ទប់ | កែវបាឡុងក្នុងទឹកក្ដៅ | កែវបាឡុងក្នុងទឹកត្រជាក់ |
|---|---|---|
| ................ | ................ | ................ |
| ................ | ................ | ................ |
| ................ | ................ | ................ |

• សំណួរពិភាក្សា

ក. ហេតុដូចម្ដេចបានជាស្បែកប៉េងប៉ោងមានផ្ទៃរាបស្មើនៅពេលកែវបាឡុងនៅក្នុងសីតុណ្ហភាពបន្ទប់ ?

ខ. ហេតុដូចម្ដេចបានជាស្បែកប៉េងប៉ោងមានផ្ទៃប៉ោងនៅពេលកែវបាឡុងត្រាំទឹកក្ដៅ ?

គ. ហេតុដូចម្ដេចបានជាស្បែកប៉េងប៉ោងមានផ្ទៃផតនៅពេលកែវបាឡុងត្រាំទឹកត្រជាក់ ?

ឃ. ចូរសន្និដ្ឋានពីទំនាក់ទំនងរវាងសម្ពាធ- សីតុណ្ហភាពក្នុងលក្ខខណ្ឌមាឌថេរ ។

## 4. ទំនាក់ទំនងរវាងមាឌ-ម៉ូល

នៅឆ្នាំ1811 អ្នកវិទ្យាសាស្ត្រជនជាតិអ៊ីតាលីឈ្មោះ *អាវ៉ូកាដ្រូ* (Avogadro) បានលើកឡើងនូវគំនិតមួយ : គ្រប់ឧស្ម័នទាំងអស់ដែលមានមាឌប៉ុនគ្នានិងនៅលក្ខខណ្ឌដូចគ្នា មានចំនួនភាគល្អិតស្មើគ្នា។ ក្នុងរូបទី 2.8 បង្ហាញពីមាឌស្មើគ្នានៃឧស្ម័នអាសូត អុកស៊ីសែន និងកាបូនឌីអុកស៊ីត ដែលនៅក្នុងនោះមានចំនួនម៉ូលេគុលស្មើគ្នា។




*រូបទី2.8 : សីតុណ្ហភាពនិងសម្ពាធដូចគ្នា ប៉េងប៉ោងដែលមានមាឌប៉ុនគ្នាមានចំនួនម៉ូលេគុលស្មើគ្នា*

ដោយសារគំនិតអាវ៉ូកាដ្រូនេះ គេអាចកំណត់រកម៉ាសម៉ូលេគុលនៃអង្គធាតុបានយ៉ាងងាយ ។ តែការយល់ដឹងរបស់អាវ៉ូកាដ្រូនៅសម័យនោះ គេពុំបានទទួលស្គាល់ថាត្រឹមត្រូវនោះទេ ។ ពីព្រោះអ្នកវិទ្យាសាស្ត្រនាសម័យនោះ គេពុំទាន់ស្គាល់ពីការខុសគ្នារវាងអាតូម និងម៉ូលេគុលទេ ។ ក្រោយមក ***កានីសារ៉ូ*** (Cannizzaro) អ្នកគីមីវិទ្យាជនជាតិអ៊ីតាលីបានអនុវត្តគោលការណ៍អាវ៉ូកាដ្រូ បានកំណត់រកឃើញរូបមន្តពិតប្រាកដនៃឧស្ម័នដែលជាអង្គធាតុសមាសខ្លះៗ ។ គំនិតអាវ៉ូកាដ្រូនេះ ត្រូវបានគេទទួលស្គាល់ថាត្រឹមត្រូវ ហើយបង្កើតជាច្បាប់អាវ៉ូកាដ្រូ :

**ច្បាប់អាវ៉ូកាដ្រូ**

**នៅលក្ខខណ្ឌសីតុណ្ហភាពនិងសម្ពាធដូចគ្នា គ្រប់ឧស្ម័នទាំងអស់ដែលមានមាឌប៉ុនគ្នាមានចំនួនម៉ូលេគុលស្មើគ្នា ។**

តាមរយៈច្បាប់នេះ អ្នកគីមីវិទ្យាបានរកឃើញរូបមន្តនៃសមាសធាតុគីមីជាលើកដំបូង ។ នៅឆ្នាំ 1858 ***កានីសារ៉ូ*** បានប្រើច្បាប់អាវ៉ូកាដ្រូ ដើម្បីទាញរករូបមន្តត្រឹមត្រូវរបស់ទឹកគឺ $H_2O$ ។

ច្បាប់អាវ៉ូកាដ្រូ ក៏មានន័យផងដែរថា មាឌឧស្ម័នសមាមាត្រនឹងចំនួនម៉ូលនៃឧស្ម័ននៅសីតុណ្ហភាពនិងសម្ពាធដូចគ្នា ។ ទំនាក់ទំនងនេះត្រូវសំដែងដោយសមីការ :

$V = k \cdot n$

$k$ : ថេរសមាមាត្រ

$n$ : ចំនួនម៉ូលឧស្ម័ន

ប៉ុន្តែមាឌនៃឧស្ម័នក៏ប្រែប្រួលទៅតាមសីតុណ្ហភាពនិងសម្ពាធផងដែរ ។ ដើម្បីវាស់មាឌឧស្ម័ន គេត្រូវដឹងអំពីលក្ខខណ្ឌសីតុណ្ហភាពនិងសម្ពាធ ។

***ឧទាហរណ៍*** អាកុងជាឧស្ម័នឋិតនៅជាភាពអាតូម ។ មួយម៉ូលអាតូមអាកុងមានម៉ាស 39.95g/mol ។ នៅសីតុណ្ហភាព 0°C និងសម្ពាធ 1atm អាកុង 39.95g មានមាឌ 22.4L ។

ដូច្នេះឧស្ម័នមួយម៉ូលមានមាឌ 22.4L នៅលក្ខខណ្ឌស្តង់ដានៃសីតុណ្ហភាពនិងសម្ពាធ ។ ម៉ាសនៃឧស្ម័ន 22.4L នៅសីតុណ្ហភាព 0°C និងសម្ពាធ 1atm ស្មើនឹងម៉ាសម៉ូលនៃឧស្ម័ន ។

## សង្ខេបមេរៀន

- បរិមាណកំណត់នៃឧស្ម័នមួយនៅសីតុណ្ហភាពថេរ មាឌឧស្ម័នកើនឡើងកាលណាសម្ពាធឧស្ម័នថយចុះនិងមាឌឧស្ម័នថយចុះកាលណាសម្ពាធឧស្ម័នកើនឡើង(ច្បាប់បិយ) ។ ទំនាក់ទំនងរវាងសម្ពាធ-មាឌ តាងដោយសមីការ : $P_1V_1 = P_2V_2$ ។
- បរិមាណកំណត់នៃឧស្ម័នមួយនៅសម្ពាធថេរ កាលណាមាឌឧស្ម័នកើនឡើងសីតុណភាពឧស្ម័នក៏កើនឡើងដែរ និងកាលណាមាឌឧស្ម័នថយចុះសីតុណ្ហភាពឧស្ម័នក៏ថយចុះដែរ(ច្បាប់សាល) ។ ទំនាក់ទំនងរវាងមាឌ-សីតុណ្ហភាពតាងដោយសមីការ : $\frac{V_1}{T_1} = \frac{V_2}{T_2}$ ។
- សម្ពាធនៃឧស្ម័នដែលនៅមាឌថេរ សមាមាត្រទៅនឹងសីតុណ្ហភាពដាច់ខាត (ច្បាប់កាយ-លុយសាក់) ។ ទំនាក់ទំនងរវាងសម្ពាធ-សីតុណ្ហភាពតាងដោយសមីការ : $\frac{P_1}{T_1} = \frac{P_2}{T_2}$ ។
- នៅលក្ខខណ្ឌសីតុណ្ហភាពនិងសម្ពាធដូចគ្នា គ្រប់ឧស្ម័នទាំងអស់ដែលមានមាឌប៉ុនគ្នា មានចំនួនម៉ូលេគុលស្មើគ្នាដែរ(ច្បាប់អាវ៉ូកាដ្រូ) ។ នៅលក្ខខណ្ឌស្តង់ដានៃសីតុណ្ហភាព (0°C) និងសម្ពាធ (1atm) ឧស្ម័នមួយម៉ូលមានមាឌ 22.4L ។

## សំណួរនិងលំហាត់

1. តើច្បាប់ឧស្ម័នណាមួយដែលនិយាយពីទំនាក់ទំនងរវាងសម្ពាធនិងមាឌ? ចូរប្រាប់ពំនោលច្បាប់ ។
2. តើច្បាប់ឧស្ម័នណាមួយ ដែលនិយាយពីទំនាក់ទំនងមាឌនិងសីតុណ្ហភាពដាច់ខាត ? ចូរប្រាប់ពំនោលច្បាប់ ។
3. តើច្បាប់ឧស្ម័នណាមួយ ដែលនិយាយពីទំនាក់ទំនងសម្ពាធនិងសីតុណ្ហភាពដាច់ខាត ? ចូរប្រាប់ពុំនោលច្បាប់ ។
4. ចូរប្រាប់ពំនោលច្បាប់អាវ៉ូកាដ្រូ ។ នៅលក្ខខណ្ឌស្តង់ដានៃសីតុណ្ហភាពនិងសម្ពាធ តើឧស្ម័នមួយម៉ូលមានមាឌប៉ុន្មាន ?
5. ហេតុដូចម្តេចបានជាបំពង់បាញ់ទឹកអប់នៅក្នុងរថយន្តអាចផ្ទុះ កាលណាគេចតរថយន្តចោលហាលថ្ងៃក្តៅខ្លាំង ?
6. ចូរកំណត់រកមាឌឧស្ម័ន $NO_2$ ដែលមានចំនួនម៉ូលេគុលស្មើនឹងចំនួនម៉ូលេគុលនៃឧស្ម័នអ៊ីដ្រូសែន 100mL នៅលក្ខខណ្ឌសីតុណ្ហភាពនិងសម្ពាធដូចគ្នា ។

7. ឧស្ម័នមួយមានមាឌ 3.00L នៅសីតុណ្ហភាព 25°C និងសម្ពាធ 1.00atm ។ ចូរកំណត់រកមាឌឧស្ម័ននេះនៅសម្ពាធ 20.00atm ឧបមាថាសីតុណ្ហភាពនៃឧស្ម័នរក្សាតម្លៃថេរ ។

8. ខ្យល់សមុទ្រមួយដុំ ដែលមានមាឌ $8.0 \times 10^5$L នៅសម្ពាធ 775mmHg បានធ្វើដំណើរពីសមុទ្រទៅកំពូលភ្នំមួយដែលមានសម្ពាធ 622mmHg ។ ចូររកមាឌខ្យល់នៅពេលវាទៅដល់កំពូលភ្នំ ។ សន្មតសីតុណ្ហភាពខ្យល់មិនប្រែប្រួល ។

9. ប៉េងប៉ោងមួយមានមាឌ 480mL នៅសម្ពាធ 1.0atm ។ គេយកប៉េងប៉ោងនោះទៅដាក់ក្នុងជម្រៅទឹកសមុទ្រដែលមានសម្ពាធ 4.0atm ។
តើមាឌខ្យល់នៅក្នុងប៉េងប៉ោងនោះមានប៉ុន្មាន ? សន្មតសីតុណ្ហភាពខ្យល់មិនប្រែប្រួល ។

10. គេមានឧស្ម័នអុកស៊ីសែន 8.00L នៅសីតុណ្ហភាព 27°C និងសម្ពាធ 1atm ។ គេយកឧស្ម័ននេះទៅបញ្ចុះសីតុណ្ហភាពរហូតដល់ –50°C នៅសម្ពាធ 1atm ដែរ ។ ចូរកំណត់រកមាឌឧស្ម័ននៅសីតុណ្ហភាពថ្មី ។

11. គេមានខ្យល់ 2.50L នៅសីតុណ្ហភាព 200°C ។ គេយកខ្យល់នោះទៅដាក់ត្រង់កន្លែងត្រជាក់ មាឌរបស់វាថយចុះនៅត្រឹម 2.20L ។ តើសីតុណ្ហភាពត្រង់កន្លែងត្រជាក់នេះមានប៉ុន្មានអង្សាសែលស៊ុស ? ឧបមាថា សម្ពាធខ្យល់មិនប្រែប្រួល ។

12. ឧស្ម័នមួយមានមាឌ 10.0L មានសម្ពាធ 80.0kPa នៅសីតុណ្ហភាព 27.0°C ។ តើសម្ពាធរបស់ឧស្ម័នមានប៉ុន្មាន kPa កាលណាសីតុណ្ហភាពឡើងដល់ 125°C ? ឧបមាថាមាឌឧស្ម័នមិនប្រែប្រួល ។

13. ធុងឧស្ម័នអ៊ីដ្រូសែនមួយមានសម្ពាធ 122kPa នៅសីតុណ្ហភាព 25°C ។ តើសីតុណ្ហភាពរបស់ធុងត្រូវនឹងប៉ុន្មានដឺក្រេសែលស៊ុស បើគេឱ្យធុងអ៊ីដ្រូសែនមានសម្ពាធរហូតដល់ 204kPa ? ឧបមាថា មាឌឧស្ម័នមិនប្រែប្រួល ។

14. ខ្យល់នៅក្នុងសំបកកង់ឡានមួយវាស់ឃើញសម្ពាធ 30.0psi នៅសីតុណ្ហភាព 20°C ។ ក្រោយពីរថយន្តបើកបរយ៉ាងលឿន មួយរយៈមកសំបកកង់ឡានឡើងកម្ដៅរហូតដល់ 50°C ។ តើសម្ពាធកង់ឡានឡើងដល់ប៉ុន្មាន psi ? សំគាល់ : $1\text{psi} = 6.89286 \times 10^3\text{Pa}$

15. ឧស្ម័នអាសូតមានមាឌ 330mL នៅសីតុណ្ហភាព 273K ។ គេដុតកម្ដៅឧស្ម័ននេះរហូតគេទទួលបានមាឌ 400mL ។ តើឧស្ម័ននេះមានសីតុណ្ហភាពប៉ុន្មាន? ឧបមាថាសម្ពាធឧស្ម័នមិនប្រែប្រួល ។

16. ធុងឧស្ម័នមួយផ្ទុកឧស្ម័នអុកស៊ីសែន 30L នៅសម្ពាធ 15atm ។ តើឧស្ម័នអុកស៊ីសែនមានមាឌប៉ុន្មាន កាលណាឧស្ម័ននេះភាយចូលទៅក្នុងបរិយាកាសដែលមានសម្ពាធ 0.90atm ?

មេរៀនទី

# 3 សមាសភាពម៉ូលេគុលនៃឧស្ម័ន

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាពីទំនាក់ទំនងរវាងលក្ខណៈឧស្ម័ន និងរូបមន្តគីមី ដូចជាច្បាប់គ្រាហាំនៃបន្សាយ ច្បាប់កាយលុយសាក់នៃការផ្សំមាឌ និងច្បាប់ដាល់តុននៃសម្ពាធដោយភាគឬផ្នែក ។
- ដោះស្រាយលំហាត់ដោយប្រើច្បាប់ឧស្ម័នបរិសុទ្ធ ។
- អនុវត្តន៍ចំណេះដឹងនៃប្រតិកម្មស្ទើស្សូមេទ្រី សម្រាប់ដោះស្រាយលំហាត់ ។

## 1. ច្បាប់ឧស្ម័នបរិសុទ្ធ

យើងបានសិក្សារួចហើយពីច្បាប់ទាំងឡាយរបស់ឧស្ម័ន ដូចបានសង្ខេបនៅក្នុងតារាងទី 5.6 ខាងក្រោម ។ ច្បាប់បិយ ( Boylés ) ពណ៌នាអំពីទំនាក់ទំនងរវាងសម្ពាធ និងមាឌរបស់ឧស្ម័ន ។ ច្បាប់សាល (Clarles ) ពណ៌នាពីទំនាក់ទំនងរវាងមាឌ និងសីតុណ្ហភាពដាច់ខាតរបស់ឧស្ម័ន ។ ច្បាប់កាយលុយសាក់ (Gay Lussac ) ពណ៌នាពីទំនាក់ទំនងរវាងសម្ពាធ និងសីតុណ្ហភាពដាច់ខាតរបស់ឧស្ម័ននិងច្បាប់អាវ៉ូកាដ្រូ (Avogadro ) ទាក់ទងមាឌទៅនឹងចំនួនម៉ូលរបស់ឧស្ម័ន ។

តារាងទី 3.1 : ច្បាប់គ្រឹះសំខាន់ៗរបស់ឧស្ម័ន

| | |
|---|---|
| ច្បាប់បិយ | $P_1V_1 = P_2V_2$ |
| ច្បាប់សាល | $\frac{V_1}{T_1} = \frac{V_2}{T_2}$ |
| ច្បាប់កាយលុយសាក់ | $\frac{P_1}{T_1} = \frac{P_2}{T_2}$ |
| ច្បាប់អាវ៉ូកាដ្រូ | $V = kn$ |

នៅគ្រប់លក្ខខណ្ឌទាំងអស់ គ្មានឧស្ម័នណាដែលគោរពបានតាមច្បាប់ទាំងបួននេះទេ ។ ជាលទ្ធផលគេបានសន្មតយកគំរូឧស្ម័នមួយគឺ ឧស្ម័នបរិសុទ្ធដែលពិសេសស្របតាមច្បាប់ទាំងនេះ ។ ឧស្ម័នបរិសុទ្ធមិនដូចឧស្ម័នពិតទេ វាមិនកំណជារាវនៅសីតុណ្ហភាពទាបទេ ម៉ូលេគុលវាមិនមានទំនាញ ឬច្រានរវាងគ្នាទេ ហើយមាឌរបស់វាអាចចោលបាន បើធៀបទៅនឹងមាឌនៃឧបករណ៍ដែលផ្ទុកវា ។

## 1.1. ច្បាប់ឧស្ម័នបរិសុទ្ធទាក់ទងនិងប៉ារ៉ាម៉ែតទាំងបួននៃឧស្ម័ន

ការប្រើប្រាស់ច្បាប់មូលដ្ឋានឧស្ម័នទាក់ទងទៅនិងប៉ារ៉ាម៉ែតទាំងបួនរបស់ឧស្ម័នគឺ សម្ពាធ (P) មាឌ (V) សីតុណ្ហភាពដាច់ខាត (T) និងចំនួនម៉ូល (n) ។ ច្បាប់ប៊ិយ ច្បាប់សាល ច្បាប់កាយលុយសាក់ និងច្បាប់អាវ៉ូកាដ្រូ អាចបញ្ចូលគ្នាទៅជាសមីការមួយដែលមានទំនាក់ទំនងទៅនិងប៉ារ៉ាម៉ែតបួន (P) , (V) , (T) និង (n) សម្រាប់គ្រប់ឧស្ម័ន ។ ទំនាក់ទំនងនេះហៅថា " ច្បាប់ឧស្ម័នបរិសុទ្ធ " ។ ច្បាប់ឧស្ម័នបរិសុទ្ធ ពណ៌នាពីទំនាក់ទំនងគណិតវិទ្យានៃសម្ពាធ (P) មាឌ (V) សីតុណ្ហភាព (T) ថេរឧស្ម័ន (R) និងចំនួនម៉ូល (n) របស់ឧស្ម័ន ។

$$PV = nRT$$

R គឺជាថេរសមាមាត្រ ។ តម្លៃ R ដែលប្រើនៅក្នុងការគណនាអាស្រ័យទៅលើខ្នាតដែលប្រើសម្រាប់សម្ពាធ និងមាឌគឺ គីឡូប៉ាស្កាល់ kPa និងលីត្រ L ពេលប្រើច្បាប់ឧស្ម័នបរិសុទ្ធ ។ ដូច្នេះតម្លៃដែលប្រើសម្រាប់ R គឺ :

$$R = \frac{8.314\,L\ kPa}{mol\ K}$$

បើសម្ពាធគិតជា atm នោះតម្លៃ R គឺ 0.0821(L atm)/(mol K) ច្បាប់ឧស្ម័នបរិសុទ្ធពណ៌នាពីលក្ខណៈរបស់ឧស្ម័នពិតនៅសីតុណ្ហភាពបន្ទប់ និងសម្ពាធបរិយាកាស ។ ក្រោមលក្ខខណ្ឌទាំងនេះមាឌភាគល្អិតរបស់វា និងកម្លាំងទំនាញរវាងគ្នាអាចចោលបាន ។ លក្ខណៈឧស្ម័នក្នុងករណីនេះស្រដៀងគ្នាទាំងស្រុងទៅនិងឧស្ម័នបរិសុទ្ធដែលផ្តល់លទ្ធផលដោយច្បាប់ឧស្ម័នបរិសុទ្ធ ។ ដូច្នេះកាលណាមាឌ




*រូបទី 3.1 គម្លាតឧស្ម័នពិតពីលក្ខណៈបរិសុទ្ធ*

ឧស្ម័នពិតថយចុះ ការប្រទាញគ្នារវាងភាគល្អិតនៃឧស្ម័នពីមួយទៅមួយទៀតកាន់តែខ្លាំងនិងមាឌវាតិចជាងមាឌដែលបានព្រាងទុកតាមច្បាប់ឧស្ម័នបរិសុទ្ធ ។ នៅសម្ពាធខ្ពស់ខ្លាំងមាឌរបស់ភាគល្អិតទាំងនោះនៅកៀកគ្នានិងមាឌសរុប ។ ដូច្នេះមាឌជាក់ស្តែងត្រូវខ្ពស់ជាងមាឌតាមការគណនា ។ ចំពោះឧស្ម័នបរិសុទ្ធផលធៀប $\frac{PV}{nRT}$ ស្មើ 1 ដែលបង្ហាញដោយបន្ទាត់ដាច់ក្នុងរូបទី 3.1 ។ ឧស្ម័នពិតមានគម្លាតបន្តិចបន្តួចពីច្បាប់ឧស្ម័នបរិសុទ្ធ ហើយកាន់តែច្រើននៅពេលដែលសម្ពាធកាន់តែខ្ពស់ខ្លាំង ។ ទំនាក់ទំនងនេះបង្ហាញក្នុងរូបទី 3.1 ។

***លំហាត់គំរូ :*** តើមានឧស្ម័នប៉ុន្មានម៉ូលដែលស្ថិតក្នុង 22.4L នៅសម្ពាធ 101.325kPa និងសីតុណ្ហភាព 0°C ?

***ចម្លើយ :***

រកចំនួនម៉ូលឧស្ម័ន

យើងដឹង $V = 22.4L$ , $P = 101.325kPa$ , $t = 0°C$ , $n = ?$

ប្តូរពីអង្សាសែលស្យុសទៅអង្សាកែលវិន $0°C + 273 = 273K$

តាមច្បាប់ឧស្ម័នបរិសុទ្ធ $PV = nRT$

$$(101.325kPa)(22.4L) = n\left(\frac{8.314L.kPa}{mol.K}\right)(273K)$$

$$n = \frac{(101.325kPa)(22.4L)}{\left(\frac{8.314L.kPa}{mol.K}\right)(273K)} = \underline{1.00mol}$$ ។

**លំហាត់អនុវត្តន៍**

1. កំប៉ុងមួយមានមាឌ 555mL និងសម្ពាធ 600kPa នៅសីតុណ្ហភាព 20°C ។ រកចំនួនម៉ូលឧស្ម័នដែលផ្ទុកក្នុងកំប៉ុងនេះ ។
2. គេដាក់ឧស្ម័នអាសូត 43mol ទៅក្នុងដបមួយដែលមានមាឌ 65L នៅសីតុណ្ហភាព 5°C ។ គណនាសម្ពាធឧស្ម័ននេះ ។

## 2. លក្ខណៈ និងរូបមន្តគីមីរបស់ឧស្ម័ន

យើងបានសិក្សារួចហើយពីលក្ខណៈរបស់ឧស្ម័ន ។ គ្មានការគណនាណាមួយដែលមិនអាស្រ័យលើការស្គាល់ឧស្ម័នដែលទាក់ទងនោះឡើយ ។ ក្នុងលំហាត់គំរូខាងលើយើងកំណត់ចំនួនម៉ូលរបស់ឧស្ម័ន ហើយការគណនាអាចធ្វើដូចគ្នាមិនចំពោះឧស្ម័ន ឬល្បាយឧស្ម័នណាមួយដែលទាក់ទងឡើយ ។ យើងពិចារណាពីស្ថានភាពដែលចាំបាច់ត្រូវស្គាល់ដូចជាម៉ាសម៉ូលវាជាដើម ។

### 2.1. បន្សាយឧស្ម័ន (Diffusion)

សារធាតុសំអាតផ្ទះបាយ ឬបន្ទប់ទឹកភាគច្រើនជាសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីត (NaOH) ឬសូលុយស្យុងឧស្ម័នអាម៉ូញ៉ាក់ ($NH_3$) ។ ពេលយើងបើកគម្រប ក្លិនឧស្ម័នអាម៉ូញ៉ាក់សាយភាយពេញផ្ទៃបន្ទប់ នេះបណ្តាលមកពីម៉ូលេគុលដែលមានក្លិនធ្វើដំណើរដោយល្បឿនលឿនទៅគ្រប់កន្លែងហើយលាយជាមួយម៉ូលេគុលឧស្ម័នក្នុងខ្យល់លំនាំនេះហៅថា " បន្សាយ " ។



*រូបទី 3.2 បន្សាយឧស្ម័ន $NH_3$ និង HCl*

ក្នុងពេលបន្សាយសារធាតុផ្លាស់ប្តូរពីតំបន់ដែលមានកំហាប់ធំទៅតំបន់ដែលមានកំហាប់តូច ។ ឧស្ម័នដែលស្រាលអាចបន្សាយលឿនជាងឧស្ម័នធ្ងន់ ។ ដោយ $NH_3$ ស្រាលជាង វាបន្សាយលឿនជាង HCl បង្កើតជាអង្គធាតុរឹង ($NH_4Cl$) លេចឡើងនៅក្បែរកដប (HCl) ។

### 2.2. រំហួរឧស្ម័ន (Effusion)

ការឆ្លងកាត់នៃភាគល្អិតឧស្ម័នតាមរន្ធតូចមួយហៅថា "រំហួរ " ។ រូបទី 3.3 នេះបង្ហាញពីរំហួរឧស្ម័នពីតំបន់ដែលមានសម្ពាធខ្ពស់ (ឆ្វេង) ទៅតំបន់សម្ពាធទាបតាមរន្ធតូច ។ ***ឧទាហរណ៍ :*** សំបកកង់ពេលមុតដែកគោល ខ្យល់នៅក្នុងសំបកនោះហួរចេញមកក្រៅតាមប្រហោងដែលមុតនោះ ។ នៅឆ្នាំ 1832 អ្នកវិទ្យាសាស្ត្រជនជាតិស្កុតឡិនឈ្មោះ ថូម៉ាស ក្រាហាំ (Thomas Graham) បានសិក្សាលំអិតពីលំនាំ




*រូបទី 3.3 រំហួរឧស្ម័នតាមរន្ធតូច*

នេះ ហើយកំណត់ថា " នៅសីតុណ្ហភាពនិងសម្ពាធថេរ ល្បឿននៃរំហូរឧស្ម័ន ច្រាសសមាមាត្រទៅនិងឫសការេនៃម៉ាសម៉ូលរបស់ឧស្ម័ន " ។ បច្ចុប្បន្ននេះ គេស្គាល់ថាជា ច្បាប់គ្រាហាំ នៃបន្សាយ ។

តាងដោយ : $\frac{V_A}{V_B} = \sqrt{\frac{M_B}{M_A}}$

$V_A$ . $V_B$ ជាល្បឿនបន្សាយរបស់ឧស្ម័ន A និង B ហើយ $M_A$ និង $M_B$ ជាម៉ាសម៉ូលរបស់ឧស្ម័ន A និង B ។

***ឧទាហរណ៍ :*** ប្រៀបធៀបល្បឿននៃលំហូររបស់ $H_2$ ជាមួយនឹង $O_2$

$$\frac{V_{H_2}}{V_{O_2}} = \sqrt{\frac{M_{O_2}}{M_{H_2}}} = \frac{32g/mol}{2g/mol} = \sqrt{16} = 4$$

ឧស្ម័នអ៊ីដ្រូសែនហូរលឿនជាងឧស្ម័នអុកស៊ីសែន 4 ដង ។ ភាគល្អិតឧស្ម័នដែលមានម៉ាសម៉ូលតូចធ្វើដំណើរលឿនជាងភាគល្អិតឧស្ម័នដែលមានម៉ាសម៉ូលធំ ។ តាមទ្រឹស្តីស៊ីនេទិចនៃម៉ូលេគុល ភាគល្អិតឧស្ម័នដែលឋិតនៅសីតុណ្ហភាពដូចគ្នា មានថាមពលស៊ីនេទិចមធ្យមស្មើគ្នា ។ ដូច្នេះថាមពលស៊ីនេទិចនៃឧស្ម័នពីរនៅសីតុណ្ហភាពដូចគ្នានឹងស្មើគ្នា : $\frac{1}{2}M_A V^2{}_A = \frac{1}{2}M_B V^2{}_B$ ។

***លំហាត់គំរូ :*** ម៉ូលេគុលឧស្ម័នអុកស៊ីសែន មានល្បឿនមធ្យម 480m/s នៅសីតុណ្ហភាពបន្ទប់ ។ រកល្បឿនមធ្យមនៃម៉ូលេគុលស្ពាន់ធ័រអ៊ិចសាភ្លុយអរួ $SF_6$ នៅសីតុណ្ហភាពដូចគ្នា ។

***ចម្លើយ :***

តាមបម្រាប់យើងមាន : $V_{O_2} = 480m/s$

$V_{SF_6} = \ ?\ m/s$

តាមច្បាប់គ្រាហាំនៃបន្សាយ : $\frac{V_{SF_6}}{V_{O_2}} = \sqrt{\frac{M_{O_2}}{M_{SF_6}}}$

ម៉ាសម៉ូល $O_2 = 2(16g/mol) = 32g/mol$

ម៉ាសម៉ូល $SF_6 = 32g/mol + 6(19g/mol) = 146g/mol$

យើងបាន $\frac{V_{SF_6}}{V_{O_2}} = \sqrt{\frac{32g/mol}{146g/mol}}$

$$V_{SF_C} = (480m/s)\sqrt{\frac{32g/mol}{146g/mol}}$$

$$= 480m/s \times 0.47 = \boxed{220m/s}$$ ។

**លំហាត់អនុវត្តន៍**

1. នៅសីតុណ្ហភាពដូចគ្នា ម៉ូលេគុលរវាង $O_2$ និង $N_2$ តើម៉ូលេគុលណាមួយដែលធ្វើដំណើរលឿនជាង ? តើល្បឿនប៉ុន្មាន ?
2. អាតូមសេណុង Xe មានល្បឿនមធ្យមស្មើនិង 240m/s នៅសីតុណ្ហភាពបន្ទប់ ។ តើនៅសីតុណ្ហភាពដូចគ្នា ម៉ូលេគុល $H_2$ មានល្បឿនប៉ុន្មាន ?
3. តើម៉ាសម៉ូលេគុលរបស់ឧស្ម័នមានប៉ុន្មាន ប្រសិនបើវាបន្សាយបាន 0.907 ដងនៃល្បឿនរបស់ឧស្ម័នអាកុង Ar ។

នៅឆ្នាំ1808 លោក យូសេប កាយលុយសាក់ (Joseph Gay-Lussac) បានរកឃើញថា បើគេរក្សាសីតុណ្ហភាពនិងសម្ពាធឱ្យនៅថេរ ឧស្ម័នមានប្រតិកម្មសមាមាត្រនឹងចំនួនមាឌរបស់វា ដែលហៅថា " ច្បាប់កាយលុយសាក់នៃការផ្សំមាឌ " ។ *ឧទាហរណ៍* ឧស្ម័នអ៊ីដ្រូសែនក្លរួបានពីប្រតិកម្មឧស្ម័នអ៊ីដ្រូសែន និងឧស្ម័នក្លរ ។ លោកកាយលុយសាក់បានបង្ហាញក្នុងពិសោធន៍ថា ឧស្ម័នអ៊ីដ្រូសែន 1 មាឌមានប្រតិកម្មជាមួយឧស្ម័នក្លរ 1 មាឌបង្កើតបាន 2 មាឌឧស្ម័នអ៊ីដ្រូសែនក្លរួ(រូបទី 3.4) ។




*រូបទី3.4 ម៉ូលេគុលអ៊ីដ្រូសែនផ្សំជាមួយម៉ូលេគុលក្លរតាមផលធៀប 1 : 1*

ចំពោះប្រតិកម្មឧស្ម័នអ៊ីដ្រូសែនជាមួយឧស្ម័នអុកស៊ីសែន បង្កើតបានជាចំហាយទឹក ។

គីមីវិទូជនជាតិអ៊ីតាលីឈ្មោះ ស្តានីស្លាវ កានីសារ៉ូ (Stanislao Cannizzaro) បានបង្ហាញថា អុកស៊ីសែនជាធាតុឌីអាតូម ដូចនេះរូបមន្តទឹកគឺ $H_2O$ ។ មុនពេលគេស្គាល់ម៉ាសអាតូម គីមីវិទូគ្រាន់តែបានកំណត់ទំនាក់ទំនងនៃទម្ងន់ប៉ុណ្ណោះ ។ ***ឧទាហរណ៍ :*** 1g នៃអ៊ីដ្រូសែនអាចមានប្រតិកម្មជាមួយ 8g នៃអុកស៊ីសែនដើម្បីបង្កើតទឹក ដូច្នេះគាត់បានសន្មតថា អាតូមអុកស៊ីសែនធ្ងន់ជាងអាតូមអ៊ីដ្រូសែន 8 ដង ។ រហូតដល់ពាក់កណ្តាលសតវត្សទី 18 ទើបគីមីវិទូស្គាល់រូបមន្តត្រឹមត្រូវរបស់ទឹក ។

## 3. ច្បាប់ដាល់តុននៃសម្ពាធដោយភាគឬផ្នែក

នៅឆ្នាំ1805 លោក ដាល់តុន បានបង្ហាញថា ក្នុងល្បាយនៃឧស្ម័ន ឧស្ម័ននីមួយៗប្រើសម្ពាធផ្ទាល់របស់វា ដូចវាឋិតនៅតែឯងដោយគ្មានឧស្ម័នដទៃនៅលាយឡំ ។ សម្ពាធរបស់ឧស្ម័ននីមួយៗ នៅក្នុងល្បាយហៅថា " សម្ពាធដោយភាគឬផ្នែក " ។ សម្ពាធសរុបរបស់ល្បាយនៃឧស្ម័ន គឺជាផលបូកសម្ពាធ

ដោយផ្នែកនៃឧស្ម័ន ។ គោលការណ៍នេះ គឺជា " ច្បាប់ដាល់តុននៃសម្ពាធដោយភាគឬផ្នែក " ។

$$P_{សរុប} = P_A + P_B + P_C$$

$P_{សរុប}$ គឺជាសម្ពាធសរុប ហើយ $P_A$ , $P_B$ និង $P_C$ ជាសម្ពាធដោយផ្នែករបស់ឧស្ម័ននីមួយៗ ។

ច្បាប់ដាល់តុននៃសម្ពាធដោយផ្នែក " សម្ពាធសរុបនៃល្បាយឧស្ម័នស្មើនឹងផលបូកសម្ពាធដោយផ្នែកនៃឧស្ម័នដែលចូលផ្សំ " ។

***លំហាត់គំរូ :***

គេដាក់ឧស្ម័ន $H_2$ , $O_2$ និង $N_2$ ដែលធាតុនីមួយៗមានម៉ាស 1.00g (មួយក្រាម)ទៅក្នុងកំប៉ុងមួយដែលមានមាឌ 10L នៅសីតុណ្ហភាព 125°C ។ យើងសន្មតថាវាជាឧស្ម័នបរិសុទ្ធ ។ ចូរគណនាសម្ពាធសរុបនៃល្បាយឧស្ម័ននេះ ។ ( H = 1 , O = 16 និង N = 14 ) ។

***ចម្លើយ :***

រកចំនួនម៉ូលរបស់ឧស្ម័ននីមួយៗ

$$n_{H_2} = 1\text{mol} \times \frac{1.00\text{g}}{2(1.00)\text{g}} = 0.495\text{mol}$$

$$n_{O_2} = 1\text{mol} \times \frac{1.00\text{g}}{2(16.00)\text{g}} = 0.0313\text{mol}$$

$$n_{N_2} = 1\text{mol} \times \frac{1.00\text{g}}{2(14.00)\text{g}} = 0.0357\text{mol}$$

រកសម្ពាធដោយភាគរបស់ឧស្ម័ននីមួយៗ

$$T = 125 + 273 = 398\text{K}$$

$$P_{H_2} = \frac{n_{H_2} RT}{V}$$

$$= \frac{(0.495\text{mol})(0.0812\text{L atm K}^{-1}\text{mol}^{-1})(398\text{K})}{10.0\text{L}} = 1.62\text{atm}$$

$$P_{O_2} = \frac{n_{O_2} RT}{V}$$

$$P_{O_2} = \frac{(0.0313\text{mol})(0.0812\text{L atm K}^{-1}\text{mol}^{-1})(398\text{K})}{10.0\text{L}} = 0.102\text{atm}$$

$$P_{N_2} = \frac{n_{N_2} RT}{V}$$

$$P_{N_2} = \frac{(0.0357\text{mol})(0.0812\text{L atm K}^{-1}\text{mol}^{-1})(398\text{K})}{10.0\text{L}} = 0.117\text{atm}$$

សម្ពាធសរុប

$P_{សរុប} = P_{H_2} + P_{O_2} + P_{N_2}$

$= 1.62atm + 0.102atm + 0.117atm$

$= 1.84atm$

$n_{សរុប} = n_{H_2} + n_{O_2} + n_{N_2}$

$= 0.495atm + 0.0313atm + 0.0357atm$

$= 0.562mol$

$$P_{សរុប} = \frac{n_{សរុប} RT}{V}$$

$$= \frac{(0.562mol)(0.0812L\ atm\ K^{-1}mol^{-1})(398K)}{10.0L}$$

$= 1.84atm$ ។

## 4. ស្តើស្យូមេត្រីឧស្ម័ន

ឧបមាថាយើងមានឧស្ម័នបរិសុទ្ធ 1.mol នៅ 0°C (273K) និង 1 atm (អាត់ម៉ូស្វ៊ែ) តាមច្បាប់ឧស្ម័នបរិសុទ្ធ មាឌរបស់ឧស្ម័នគឺ :

$$V = \frac{nRT}{P} = \frac{(1.0mol)(0.0812L\ atm\ K^{-1}mol^{-1})(273K)}{1.0atm} = 22.42L$$

មាឌ 22.42L នេះហៅថា មាឌម៉ូលរបស់ឧស្ម័នបរិសុទ្ធ ។ នៅលក្ខខណ្ឌ 0°C និង 1 atm (អាត់ម៉ូស្វ៊ែ) ហៅថា សីតុណ្ហភាពនិងសម្ពាធស្តង់ដា (Standard Temperature and Pressure : STP) ។

***ឧទាហរណ៍*** : មាឌម៉ូលរបស់ឧស្ម័នបរិសុទ្ធគឺ 22.42L នៅ STP ។ ច្បាប់ឧស្ម័នបរិសុទ្ធទាក់ទងទៅនឹងបរិមាណសារធាតុឧស្ម័នជាម៉ូល (n) ជាមួយនិងសម្ពាធ មាឌ និងសីតុណ្ហភាព ។ យើងអាចប្រើច្បាប់នេះសម្រាប់គណនាប្រតិកម្មដែលមានឧស្ម័នចូលរួម ។ សមាមាត្រនៃមាឌរបស់ឧស្ម័នត្រូវដូចគ្នានិងសមាមាត្រជាម៉ូលរបស់វាក្នុងសមីការលំនឹង ។ តាមច្បាប់អាវ៉ូកាដ្រូ សមាមាត្រជាម៉ូលរបស់ឧស្ម័នពីរនៅ

សីតុណ្ហភាពនិងសម្ពាធដូចគ្នាគឺ ដូចគ្នាទៅនិងសមាមាត្រជាមាឌនៃឧស្ម័នទាំងពីរនោះដែរ ។

***ឧទាហរណ៍*** : សមីការប្រតិកម្មផលិតអាម៉ូញ៉ាក់

$$3H_2(g) + N_2(g) \longrightarrow 2NH_3(g)$$

ដូច្នេះ ឧស្ម័ន $H_2$ 3L មានប្រតិកម្មជាមួយឧស្ម័ន $N_2$ 1L ឱ្យផលជាឧស្ម័ន $NH_3$ 2L និងគ្មាននៅសល់ $H_2$ ឬ $N_2$ ទេ ។

***ឧទាហរណ៍ :*** អគ្គិសនីវិភាគទឹក បង្ហាញដោយសមីការ :

$2H_2O(\ell)$ + ចរន្តអគ្គិសនី $\longrightarrow 2H_2(g) + O_2(g)$

មាឌរបស់ឧស្ម័ន $H_2$ ដែលកកើតត្រូវស្មើនឹងពីរដងមាឌឧស្ម័ន $O_2$ ព្រោះចំនួនម៉ូល $H_2$ មានពីរដងច្រើនជាងចំនួនម៉ូលរបស់ $O_2$ (រូបទី 3.5) ។ ដូច្នេះ ប្រសិនបើយើងដឹងចំនួនម៉ូលរបស់ឧស្ម័ន យើងអាចប្រើច្បាប់ឧស្ម័នបរិសុទ្ធដើម្បីគណនាមាឌរបស់ឧស្ម័នដែលចូលរួមក្នុងប្រតិកម្មនេះបាន ។



***រូបទី 3.5 : អគ្គិសនីវិភាគទឹក***

***លំហាត់គំរូ :*** តើមានឧស្ម័នអ៊ីដ្រូសែនប៉ុន្មានលីត្រដែលកកើតនៅ 280.0K និង 96.0kPa បើគេដាក់សូដ្យូមចំនួន 1.74mol ឱ្យមានប្រតិកម្មជាមួយទឹក ?

***ចម្លើយ :***

សមីការតាងប្រតិកម្ម

$$2Na(s) + 2H_2O(\ell) \longrightarrow 2NaOH(aq) + H_2(g)$$

យើងមាន :

T = 280K , P = 96.0kPa , R = 8.314L.kPa/mol.K , n = ?mol , V = ? L

ចំនួនម៉ូល $H_2$ ចូលរួមប្រតិកម្ម

$$n_{H_2} = 1.74\text{mol} \times \frac{1}{2} = 0.870\text{mol } H_2$$

តាមរូបមន្ត $PV = nRT \Rightarrow V = \frac{nRT}{P}$

មាឌឧស្ម័ន $H_2$ ដែលកកើត

$$V_{H_2} = \frac{(0.870\text{mol})(8.314\text{L.kPa K}^{-1}\text{mol}^{-1})(280\text{K})}{(96.0\text{kPa})}$$

$$\boxed{V_{H_2} = 21.1\text{L}}$$ ។

## សង្ខេបមេរៀន

- ច្បាប់ឧស្ម័នបរិសុទ្ធពណ៌នាពីទំនាក់ទំនងគណិតវិទ្យានៃសម្ពាធ (P) មាឌ (V) សីតុណ្ហភាព (T) ថេរឧស្ម័ន (R) និងចំនួនម៉ូល (n) របស់ឧស្ម័ន ។

  $PV = nRT$

- ចលនារបស់ភាគល្អិតពីតំបន់ដែលមានដង់ស៊ីតេខ្ពស់ទៅតំបន់ដែលមានដង់ស៊ីតេទាបហៅថា " បន្សាយ " ។
- ការឆ្លងកាត់របស់ភាគល្អិតឧស្ម័ន តាមរន្ធតូច ឬចន្លោះប្រហោងតូចហៅថា "រំហូរ " ។
- ច្បាប់ក្រាហាំនៃបន្សាយ : ល្បឿនបន្សាយរបស់ឧស្ម័នច្រាសសមាមាត្រនឹងឫសការ៉េនៃដង់ស៊ីតេ ឬម៉ាសម៉ូលរបស់ឧស្ម័ន ។

  $\frac{V_A}{V_B} = \sqrt{\frac{d_B}{d_A}}$ ឬ $\frac{V_A}{V_B} = \sqrt{\frac{M_B}{M_A}}$

- ច្បាប់ដាល់តុននៃសម្ពាធដោយភាគឬផ្នែក : សម្ពាធសរុបនៃល្បាយឧស្ម័នស្មើនឹងផលបូកសម្ពាធដោយផ្នែកនៃឧស្ម័នដែលចូលផ្សំ ។

  $P_{សរុប} = P_A + P_B + P_C$

## សំណួរនិងលំហាត់

1. តើច្បាប់ឧស្ម័នណាខ្លះដែលផ្សំបញ្ចូលក្នុងច្បាប់ឧស្ម័នបរិសុទ្ធ ?
2. ពណ៌នាពីច្បាប់ឧស្ម័នបរិសុទ្ធ និងសរសេរសមីការ ។
3. ចូរឱ្យពំនោលច្បាប់ដាល់តុននៃសម្ពាធដោយផ្នែក និងសរសេរសមីការ ។
4. តើសម្ពាធសរុបរបស់ឧស្ម័នទាក់ទងនឹងសម្ពាធដោយផ្នែករបស់ឧស្ម័ន ដែលផ្សំក្នុងល្បាយដូចម្តេច ?
5. នៅក្នុងលំហាត់ស្តូកីយូមេទ្រី តើមានទំនាក់ទំនងដូចម្តេចរវាងម៉ូល និងមាឌ ?
6. ពណ៌នាដោយពាក្យខ្លួនឯងពីលំនាំនៃបន្សាយ ។
7. តើឧស្ម័នអាកុង Ar ប៉ុន្មានម៉ូលដែលមានក្នុង 20.0L នៅ 25°C និងសម្ពាធ 96.8kPa ?
8. ចូររកមាឌរបស់ឧស្ម័នអាម៉ូញ៉ាក់ $NH_3$ ដែលកកើតពីប្រតិកម្ម 22.5L នៃឧស្ម័នអ៊ីដ្រូសែនជាមួយអាសូត ?

   $N_2(g) + 3H_2(g) \rightleftharpoons 2NH_3(g)$

9. រកចំនួនម៉ូលរបស់ឧស្ម័នស្ពាន់ធ័រឌីអុកស៊ីតដែលមានក្នុងឧបករណ៍ផ្ទុកចំណុះ 4.0L នៅ 450K និងសម្ពាធ 5.0kPa ?

10. រកម៉ាសសូដ្យូមចាំបាច់ត្រូវប្រើ ដើម្បីផលិត 2.24L ឧស្ម័នអ៊ីដ្រូសែននៅសីតុណ្ហភាព 23°C និងក្រោមសម្ពាធ 92.5kPa ។

$2Na(s) + 2H_2O(\ell) \qquad 2NaOH(aq) + H_2(g)$

## សំណួរនិងលំហាត់ជំពូក 5

I. ចូរគូសសញ្ញា ✓ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវមានតែមួយគត់

1. នៅរយៈកម្ពស់ខ្ពស់ត្រចៀកយើងហ៊ឹងនេះបណ្ដាលមកពី :

☐ ក. សម្ពាធបរិយាកាសខាងក្រៅកើនឡើង ☐ ខ. ខ្យល់ខាងក្រៅហូរចូលក្នុងត្រចៀក

☐ គ. ខ្យល់ក្នុងត្រចៀកហូរទៅក្រៅ ☐ ឃ. សម្ពាធបរិយាកាសខាងក្រៅថយចុះ

2. នៅលក្ខខណ្ឌស្តង់ដានៃសីតុណ្ហភាព និងសម្ពាធ(STP) ឧស្ម័នអ៊ីដ្រូសែន 1mol មានមាឌ :

☐ ក. 1.12L ☐ ខ. 11.12L

☐ គ. 22.4L ☐ ឃ. 25L

3. ឧស្ម័នដែលមានលក្ខណៈដូចពណ៌នាក្នុងទ្រឹស្តីស៊ីនេទិចនៃម៉ូលេគុលហៅថា ឧស្ម័នបរិសុទ្ធ ។ តើឧស្ម័នណាមួយដែលជិតបរិសុទ្ធជាងគេ ?

☐ ក. អេល្យូម ☐ ខ. អ៊ីដ្រូសែន

☐ គ. អុកស៊ីសែន ☐ ឃ. សេណុង

4. តើទ្រឹស្តីស៊ីនេទិចម៉ូលេគុលពណ៌នាដូចម្តេចពីឧស្ម័នបរិសុទ្ធ ?

☐ ក. វាមានទម្ងន់ និងតាំងក្នុងលំហ

☐ ខ. វាមានចលនាឥតឈប់ឈរ និងគ្មានសណ្តាប់ធ្នាប់

☐ គ. វាមានដង់ស៊ីតេធៀបនឹងអង្គធាតុរាវ និងរឹង

☐ ឃ. វាមានកម្លាំងទំនាញនិងចម្រានទៅលើធាតុមួយទៀត ។

## II. ចូរបំពេញល្បះខាងក្រោមឱ្យមានន័យត្រឹមត្រូវ

1. នៅនីវ៉ូទឹកសមុទ្រ សម្ពាធបរិយាកាសមានតម្លៃ . . . atm ដែលត្រូវនឹងកម្ពស់សសរបារត . . . . . mm ។

2. នៅសីតុណ្ហភាព និងសម្ពាធ . . . កាលណាមានឧស្ម័នប៉ុនគ្នានោះចំនួនម៉ូលេគុល . . . ។

3. តាមទ្រឹស្ដីស៊ីនេទិចម៉ូលេគុល ភាគល្អិតនៃឧស្ម័នធ្វើចលនាកាន់តែលឿន កាលណាសីតុណ្ហភាព . . . ជាហេតុធ្វើឱ្យភាគល្អិតនៃឧស្ម័នទៅ . . . និងជញ្ជាំងវត្ថុដែលផ្ទុកវាដោយកម្លាំង . . . . ។

4. សម្ពាធសរុបនៃ . . . ឧស្ម័នស្មើនឹង . . . សម្ពាធដោយផ្នែកនៃ . . . ដែលចូលផ្សំ ។

5. តាមច្បាប់អាវ៉ូកាដ្រូ សមាមាត្រជាម៉ូលរបស់ . . . នៅសីតុណ្ហភាព និង . . . គឺដូចគ្នាទៅនិងសមាមាត្រជា . . . នៃឧស្ម័នទាំងពីរនោះដែរ ។

## III. សំណួរត្រិះរិះ

1. ពេលអ្នកបើកបរលើផ្លូវក្រោមកម្ដៅខ្លាំង សម្ពាធខ្យល់នៅក្នុងកង់កើនឡើង ។ ចូរពន្យល់ ។
2. តាមទ្រឹស្ដីស៊ីនេទិចម៉ូលេគុល ចូរពន្យល់ហេតុដូចម្ដេចបានជាសម្ពាធបរិយាកាសធំនៅកម្ពស់ទាបជាងនៅរយៈកម្ពស់ខ្ពស់ ។
3. ហេតុដូចម្ដេចបានជាសម្ពាធឧស្ម័នកើនឡើង កាលណាគេបង្រួមមាឌរបស់វា ។
4. ចូរពន្យល់ច្បាប់សាលតាមទ្រឹស្ដីស៊ីនេទិច-ម៉ូលេគុល ។
5. តើមាឌ និងសម្ពាធឧស្ម័នមានទំនាក់ទំនងគ្នាយ៉ាងដូចម្ដេច បើសីតុណ្ហភាពរបស់វាមិនប្រែប្រួល ?
6. ចូរពន្យល់ ហេតុអ្វីបានជាប៉េងប៉ោងដែលដាក់ឧស្ម័នអេល្យូម ធូរលឿនជាជាងប៉េងប៉ោងដែលដាក់ខ្យល់ ?
7. ឧស្ម័ន $NH_3$ មានប្រតិកម្មជាមួយឧស្ម័ន HCl បង្កើតបានអង្គធាតុរឹង $NH_4Cl$ តាងដោយសមីការ :

$$NH_3(g) + HCl(g) \longrightarrow NH_4Cl(s)$$

គេដាក់សំឡីជ្រើមដោយ $NH_3$ នៅខាងចុងបំពង់កែវខាងឆ្វេង រួចដាក់សំឡីដែលជ្រើមដោយ HCl នៅខាងចុងបំពង់កែវខាងស្ដាំ ។ តើអាម៉ូញ៉ូមក្លរួ ដែលកកើតចិតនៅត្រង់ចំណុចណា ? a , b ឬ c ? ចូរពន្យល់ ។



IV. លំហាត់

1. កង់រថយន្តមួយមានមាឌ 80L ។ នៅពេលសប់កង់មាំណូម៉ែតចង្អុលសម្ពាធ 2atm ។ តើមានម៉ាសខ្យល់ប៉ុន្មាននៅក្នុងកង់ បើនៅលក្ខខណ្ឌប្រក្រតីនៃសីតុណ្ហភាព និងសម្ពាធ (25°C , 1atm) ខ្យល់មានម៉ាស $1.2Kg/m^3$ ។ ចម្លើយ : 0.19Kg

2. អ្នកមុជទឹកម្នាក់បានមុជទឹកជម្រៅ 70m ដែលនៅទីនោះមានសម្ពាធ 7.5atm ។ គាត់បានបញ្ចេញពពុះមួយដែលមានមាឌ 50.0mL ។ តើពពុះនោះមានមាឌប៉ុន្មាន កាលណាវាមកដល់ផ្ទៃទឹកដែលមានសម្ពាធ 1atm ?

3. ឧស្ម័នមួយមានមាឌ 8.44L នៅសីតុណ្ហភាព 65°C ។ គេយកឧស្ម័ននោះទៅដាក់ត្រង់កន្លែងថ្មីមួយ គេឃើញមាឌឧស្ម័នថយចុះមកនៅត្រឹម 7.74L ។ ចូរកំណត់រកសីតុណ្ហភាពថ្មីនៃឧស្ម័ន ឧបមាថា សម្ពាធឧស្ម័នមិនប្រែប្រួល ។

4. ឧស្ម័នអេល្យូមមួយអាចបញ្ចេញសម្ពាធ 100kPa នៅសីតុណ្ហភាព 25°C ។ គេយកឧស្ម័ននោះទៅដាក់ក្នុងអាសូតរាវ ។ ដែលមានសីតុណ្ហភាព –196°C ។ ចូរកំណត់រកសម្ពាធរបស់ឧស្ម័នអេល្យូមក្នុងអាសូតរាវ ឧបមាថា មាឌឧស្ម័នមិនប្រែប្រួល ។ ចម្លើយ : 26kPa

5. ស៊ីឡាំងមួយមានចំណុះ $50.0dm^3$ គេផ្ទុកឧស្ម័នអេល្យូម 20.0g និងឧស្ម័នអុកស៊ីសែន 70.0g នៅសីតុណ្ហភាព 20°C ។

ក. រកសម្ពាធដោយផ្នែករបស់ល្បាយឧស្ម័ននីមួយៗក្នុងសម្ពាធបរិយាកាស ។ ចម្លើយ

ខ. រកសម្ពាធសរុបរបស់ល្បាយ ។ ចម្លើយ

ជំពូក 6

# គីមីសរីរាង្គ

សមាសធាតុសរីរាង្គមានសារៈសំខាន់ណាស់ក្នុងជីវភាពរស់នៅ ដូចជាចំណីអាហារ ថ្នាំពេទ្យ សាប៊ូ សារធាតុជម្រះ ជីរសម្រាប់កសិកម្មនិងវត្ថុប្រើប្រាស់ជាច្រើនផ្សេងៗទៀត ។

សមាសធាតុសរីរាង្គខ្លះ ជាសមាសធាតុធម្មជាតិ ខ្លះទៀតជាសមាសធាតុសំយោគ ។ សមាសធាតុខ្លះមានទម្រង់ងាយ ខ្លះទៀតមានទម្រង់សាំញ៉ាំ ដូចជាទម្រង់របស់ប្រូតេអ៊ីនជាដើម ។



គំរូតាងទម្រង់ប្រូតេអ៊ីនមួយ

មេរៀនទី

# 1 អេស្ទែ ខ្លាញ់និងប្រេង

**ចប់មេរៀននេះ សិស្សអាច**

- ❑ សរសេរនិងហៅឈ្មោះអេស្ទែ ។
- ❑ រៀបរាប់លក្ខណៈរូបនិងទង្វើអេស្ទែ ។
- ❑ ពន្យល់និងសរសេរប្រតិកម្មគីមីទាំងឡាយរបស់អេស្ទែ ។
- ❑ សរសេរទម្រង់និងប្រតិកម្មគីមីរបស់ខ្លាញ់និងប្រេង ។
- ❑ ពន្យល់ពីទម្រង់និងលក្ខណៈជំរះរបស់សាប៊ូនិងសារធាតុជម្រះក្អែល ។
- ❑ ពណ៌នាពីថ្នាំលាប ។

នៅថ្នាក់ទី 11 យើងបានសិក្សាពីអាស៊ីតកាបុកស៊ីលិចនិងបានស្គាល់អង្គធាតុមួយដែលកើតឡើងពីប្រតិកម្មរវាងអាស៊ីតនិងអាល់កុលមានឈ្មោះថា អេស្ទែ ។ យើងនឹងសិក្សាលំអិតបន្តនៅមេរៀននេះ ។

## 1. អេស្ទែ

អេស្ទែ ជាអង្គធាតុស្រលាយនៃអាស៊ីតកាបុកស៊ីលិច (R – COOH) ដែលបានពីការជំនួសក្រុម (–OH) របស់អាស៊ីតដោយក្រុម (–OR') របស់អាល់កុល ។

អេស្ទែមានរូបមន្តទូទៅ 

 បង្គុំនាទីអេស្ទែ

*សំគាល់ :*

R អាចជាអាតូមអ៊ីដ្រូសែន ឬរ៉ាឌីកាល់អ៊ីដ្រូកាបួ ។

R' ជារ៉ាឌីកាល់អ៊ីដ្រូកាបួ ។

បើ R និង R' ជារ៉ាឌីកាល់អ៊ីដ្រូកាបួខ្សែបើក គេបានអេស្ទែអាលីផាទិច ។

បើ R និង R' មានវង់បង់សែន គេបានអេស្ទែប្រហើរ ឬអារ៉ូម៉ាទិច ។

## 1.1. នាមវលី

ដោយអេស្ទែមានដើមកំណើតពីអាស៊ីតនិងអាល់កុល ដូចនេះដើម្បីហៅឈ្មោះអេស្ទែគេត្រូវ :

ទី 1 ហៅឈ្មោះរ៉ាឌីកាល់ R' របស់អាល់កុលដែលភ្ជាប់ដោយសម្ព័ន្ធមួយជាន់ទៅនឹងអាតូមអុកស៊ីសែន ។

ទី 2 ហៅឈ្មោះអាស៊ីត ដោយលុបពាក្យអាស៊ីតនិងប្តូរបច្ច័យបទអូអ៊ិចទៅជាអូអាត ។

***ឧទាហរណ៍***

$CH_3-\underset{\underset{O}{\|}}{C}-O-C_2H_5$

អេទីលអេតាណូអាត ឬ អេទីលអាសេតាត



អេទីលបង់សូអាត



ផេនីលអេតាណូអាត ឬ ផេនីលអាសេតាត

***សំគាល់ :***

ក្នុងករណីដែល R ឬ R' មានខ្នែង :

- បើរ៉ាឌីកាល់អាល់កុល R' មានខ្នែង ត្រូវបង់លេខ 1 ឱ្យទៅអាតូម C ដែលភ្ជាប់ដោយសម្ព័ន្ធមួយជាន់ទៅនឹងអាតូមអុកស៊ីសែន ។
- បើរ៉ាឌីកាល់អាស៊ីតមានខ្នែង ត្រូវបង់លេខ 1 ឱ្យទៅអាតូម C នៃបង្គុំកាបូនីល ។

***ឧទាហរណ៍***

$\overset{4}{CH_3}-\underset{\underset{CH_3}{|}}{\overset{3}{CH}}-\overset{2}{CH_2}-\underset{\underset{O}{\|}}{\overset{1}{C}}-O-\overset{1}{CH_2}-\underset{\underset{CH_3}{|}}{\overset{2}{CH}}-\overset{3}{CH_3}$

2– មេទីលប្រូពីល 3– មេទីលប៊ុយតាណូអាត

**លំហាត់អនុវត្តន៍**

1. ចូរឱ្យឈ្មោះសមាសធាតុដូចតទៅ :

ក. $H-\underset{\underset{O}{\|}}{C}-O-C_2H_5$

ខ. $CH_3-CH_2-CH_2-\underset{\underset{O}{\|}}{C}-O-C_2H_5$

គ. $CH_3-\underset{\underset{O}{\|}}{C}-O-\underset{\underset{CH_3}{|}}{CH}-CH_2-CH_3$

2. ចូរសរសេររូបមន្តរបស់សមាសធាតុដូចតទៅ :

ក. n– ប៊ុយទីលអាសេតាត

ខ. អេទីល 2– មេទីលប្រូប៉ាណូអាត

គ. ប្រូពីលបង់សូអាត ។

## ៤.២. លក្ខណរូប

- ក. អេស្ទែភាគច្រើនមានក្នុងធម្មជាតិ ។ ភាគច្រើននៃអេស្ទែដែលមានម៉ាសម៉ូលេគុលតូច ងាយហើរនិងមានក្លិនក្រអូបជាទីគាប់ចិត្ត ។ រសក្រអូបប្រហើរនៃផ្កានិងផ្លែឈើជាច្រើន កើតឡើងដោយសារវត្តមានអេស្ទែនៅក្នុងនោះ ។ ល្បាយនៃអេស្ទែ ត្រូវបានប្រើប្រាស់ជាគ្រឿងក្រអូបសម្រាប់ធ្វើជាទឹកអប់ ក្នុងទឹកនំ បង្អែម ភេសជ្ជៈ ។ អេស្ទែខ្លះដូចជាអេទីលអាសេតាត ត្រូវបានប្រើជាធាតុរំលាយ ។



រូបទី 1.1 ក.ក្លិនរបស់ចេកទុំបានមកពីអេស្ទែ 3-មេទីលប៊ុយទីលអាសេតាត ខ.ក្លិនរបស់ម្នាស់ទុំបានមកពីអេស្ទែ មេទីលប៊ុយតាណូអាត គ.ក្លិនរបស់ក្រូចបានមកពីអេស្ទែ អុកទីលអាសេតាត

- អេស្ទែ មិនអាចបង្កើតសម្ព័ន្ធអ៊ីដ្រូសែនរវាងម៉ូលេគុលបានទេ ។ ប៉ុន្តែដោយម៉ូលេគុលអេស្ទែមានភាពប៉ូលែខ្សោយ  ទំនាញប៉ូលនិងប៉ូលរវាងម៉ូលេគុល ធ្វើឱ្យអេស្ទែមានចំណុចរំពុះខ្ពស់ជាងអ៊ីដ្រូកាបួ តែទាបជាងអាល់កុលដែលមានម៉ាសម៉ូលប្រហែលគ្នា ។

**ឧទាហរណ៍**

| ឈ្មោះ | មេទីលប៊ុយតាន | អេទីលអាសេតាត | ប៊ុយតាន-2-អុល |
|---|---|---|---|
| រូបមន្ត | $CH_3-CH(CH_3)-CH_2-CH_3$ | $CH_3-COO-CH_2-CH_3$ | $CH_3-CHOH-CH_2-CH_3$ |
| ម៉ាសម៉ូល $g\ mol^{-1}$ | 72 | 88 | 74 |
| ចំណុចរំពុះ | 28°C | 57°C | 99°C |

- អេស្ទែ អាចបង្កើតសម្ព័ន្ធអ៊ីដ្រូសែន ជាមួយអង្គធាតុដែលមានក្រុម (–OH) ដូចជា ទឹក អាល់កុល អាស៊ីតកាបុកស៊ីលិច។ ហេតុនេះហើយបានជាអេស្ទែអាចរលាយក្នុងទឹកបាន ។ អេទីលអាសេតាតអាចរលាយបាន 33g ក្នុងទឹក 100g ។ ភាពរលាយក្នុងទឹករបស់អេស្ទែថយចុះ កាលណាចំនួនអាតូមកាបូនក្នុងម៉ូលេគុលកើន ។

## 1.3. លក្ខណៈគីមីរបស់អេស្ទែ

### ក. អ៊ីដ្រូលីស

ប្រតិកម្មសំខាន់របស់អេស្ទែ គឺអ៊ីដ្រូលីសដែលជាប្រតិកម្មរវាងអេស្ទែនិងទឹកបង្កើតបានជាអាស៊ីត និងអាល់កុលវិញ។

$$R-\underset{\underset{O}{\|}}{C}-O-R' + H-OH \rightleftharpoons R-\underset{\underset{O}{\|}}{C}-OH + R'OH$$

$$CH_3-\underset{\underset{O}{\|}}{C}-O-C_2H_5 + H_2O \rightleftharpoons CH_3-\underset{\underset{O}{\|}}{C}-OH + C_2H_5OH$$

អេទីលអេតាណូអាត អាស៊ីតអេតាណូអ៊ិច អេតាណុល

ប្រតិកម្មនេះ ជាប្រតិកម្មយឺតនិងទៅមក។ ដើម្បីបង្កើនល្បឿនប្រតិកម្ម គេអាចធ្វើអ៊ីដ្រូលីសអេស្ទែ ដោយដុតកម្ដៅនិងប្រើកាតាលីករអាស៊ីត។

### ខ. សាប៊ូកម្ម

បើគេកម្ដៅល្បាយអេស្ទែនិងសូលុយស្យុងប៉ូតាស្យូមអ៊ីដ្រុកស៊ីតឬសូលុយស្យុងសូដ្យូមអ៊ីដ្រុកស៊ីត រហូតដល់ពុះ អេស្ទែបានបំលែងទៅជាអំបិលនៃអាស៊ីតនិងអាល់កុលវិញ។ ប្រតិកម្មនេះមានឈ្មោះថា សាប៊ូកម្ម។

$$R-\underset{\underset{O}{\|}}{C}-O-R' + Na^+ + OH^- \longrightarrow R-\underset{\underset{O}{\|}}{C}-O^- + Na^+ + R'-OH$$

អេស្ទែ សូដ្យូមអ៊ីដ្រុកស៊ីត អំបិលនៃអាស៊ីត អាល់កុល

***ឧទាហរណ៍ :***

$$CH_3-\underset{\underset{O}{\|}}{C}-O-C_2H_5 + Na^+ + OH^- \longrightarrow CH_3-\underset{\underset{O}{\|}}{C}-O^- + Na^+ + C_2H_5OH$$

អេទីលអេតាណូអាត សូដ្យូមអេតាណូអាត អេតាណុល

### គ. ប្រតិកម្មជាមួយអាម៉ូញ៉ាក់ ($NH_3$)

អាម៉ូញ៉ាក់បំលែងអេស្ទែជាអាមីតនិងអាល់កុល

$$R-\underset{\underset{O}{\|}}{C}-O-R' + NH_3 \longrightarrow R-\underset{\underset{O}{\|}}{C}-NH_2 + R'OH$$

អេស្ទែ អាម៉ូញ៉ាក់ អាមីត អាល់កុល

$$H-\underset{\underset{O}{\|}}{C}-O-C_2H_5 + NH_3 \longrightarrow H-\underset{\underset{O}{\|}}{C}-NH_2 + C_2H_5OH$$

អេទីលមេតាណូអាត មេតាណាមីត អេតាណុល

អាមីត គឺជាអង្គធាតុស្រលាយនៃអាស៊ីតកាបុកស៊ីលិច ដែលយើងនិងសិក្សានៅពេលក្រោយ។

### ឃ. ប្រតិកម្មរេដុកម្មអេស្ទែ

អេស្ទែអាចរងរេដុកម្មជាអាល់កុលនៅចំពោះមុខកាតាលីករ ដូចជាល្បាយនៃអុកស៊ីតរបស់ទង់ដែងនិងក្រូម (ឬហៅថាទង់ដែងក្រូមីត) ឬជាលីចូម អាលុយមីញ៉ូមអ៊ីដ្រូ ($LiAlH_4$) ។

$$R-\underset{\underset{O}{\|}}{C}-O-R' \;+\; 2H_2 \xrightarrow[\text{សីតុណ្ហភាពនិងសម្ពាធខ្ពស់}]{CuO\ ,\ CuCr_2O_4} R-CH_2OH \;+\; R'OH$$

***ឧទាហរណ៍ :***

$$CH_3-CH_2-\underset{\underset{O}{\|}}{C}-O-C_2H_5 \;+\; 2H_2 \xrightarrow[t^\circ \text{ និង } P \text{ ខ្ពស់}]{CuO\ ,\ CuCr_2O_4} CH_3-CH_2-CH_2OH \;+\; C_2H_5OH$$

អេទីលប្រូប៉ាណូអាត ប្រូប៉ាន -1 អុល អេតាណុល

**លំហាត់អនុវត្តន៍**

សរសេរសមីការនិងប្រាប់ឈ្មោះផលិតផលកកើតនៅពេលគេធ្វើប្រតិកម្មរវាងមេទីលប្រូប៉ាណូអាតជាមួយនិង :

ក. $H_2O$ ខ. $NaOH$ គ. $NH_3$ ឃ. $H_2$ (មានកាតាលីករ)

## 1.4. ចង្កើអេស្ទែ

អេស្ទែអាចធ្វើឡើងតាមវិធីពីរបែប :

### ក. អេស្ទែកម្ម

គឺជាប្រតិកម្មរវាងអាស៊ីតកាបុកស៊ីលិចនិងអាល់កុលបង្កើតជាអេស្ទែនិងទឹក ។ ប្រតិកម្មនេះជាប្រតិកម្មទៅមកនិងប្រើអាស៊ីតស៊ុលផួរិច ឬអាស៊ីតក្លរីឌ្រិចជាកាតាលីករ ។

$$R-\underset{\underset{O}{\|}}{C}-OH \;+\; HO-R' \underset{}{\overset{H^+}{\rightleftharpoons}} R-\underset{\underset{O}{\|}}{C}-O-R' \;+\; H_2O$$

អាស៊ីតកាបុកស៊ីលិច អាល់កុល អេស្ទែ

$$CH_3-\underset{\underset{O}{\|}}{C}-OH \;+\; \underset{\text{មេតាណុល}}{HO-CH_3} \overset{H^+}{\rightleftharpoons} CH_3-\underset{\underset{O}{\|}}{C}-O-CH_3 \;+\; H_2O$$

អាស៊ីតអាសេទិច មេទីលអេតាណូអាត ឬមេទីលអាសេតាត

## ខ. ប្រតិកម្មរវាងអានីឌ្រីតអាស៊ីតឬអាស៊ីលក្លរួនិងអាល់កុល

ប្រតិកម្មរវាងអាល់កុលនិងអាស៊ីតកាបុកស៊ីលិចប្រព្រឹត្តទៅយឺតនិងជាប្រតិកម្មទៅមក ។ ហេតុនេះគេនិយមប្រើអានីឌ្រីតអាស៊ីតឬអាស៊ីលក្លរួជំនួសវិញ ព្រោះវាសកម្មជាងអាស៊ីតកាបុកស៊ីលិច ។

$$R-\underset{\underset{O}{\|}}{C}-O-\underset{\underset{O}{\|}}{C}-R + R'-OH \longrightarrow R-\underset{\underset{O}{\|}}{C}-O-R' + R-\underset{\underset{O}{\|}}{C}-OH$$

អានីឌ្រីតអាស៊ីត អាល់កុល អេស្ទែ អាស៊ីតកាបុកស៊ីលិច

$$CH_3-\underset{\underset{O}{\|}}{C}-O-\underset{\underset{O}{\|}}{C}-CH_3 + CH_3OH \longrightarrow CH_3-\underset{\underset{O}{\|}}{C}-O-CH_3 + CH_3-\underset{\underset{O}{\|}}{C}-OH$$

អានីឌ្រីតអាសេទិច មេតាណុល មេទីលអាសេតាត អាស៊ីតអាសេទិច

$$R-\underset{\underset{O}{\|}}{C}-Cl + R'-OH \longrightarrow R-\underset{\underset{O}{\|}}{C}-O-R' + HCl$$

អាស៊ីលក្លរួ អាល់កុល អេស្ទែ អ៊ីដ្រូសែនក្លរួ

$$CH_3-\underset{\underset{O}{\|}}{C}-Cl + CH_3-OH \longrightarrow CH_3-\underset{\underset{O}{\|}}{C}-O-CH_3 + HCl$$

អាសេទីលក្លរួ មេតាណុល មេទីលអាសេតាត អ៊ីដ្រូសែនក្លរួ

**លំហាត់អនុវត្តន៍**

1. ចូរសរសេរសមីការនិងប្រាប់ឈ្មោះអេស្ទែ ដែលសំយោគឡើងតាមប្រតិកម្ម :
   - ក. ប្រូពីលអាល់កុលនិងអាស៊ីតមេតាណូអ៊ិច
   - ខ. អេទីលអាល់កុលនិងអានីឌ្រីតអាសេទិច
   - គ. មេទីលអាល់កុលនិងប្រូប៉ាណូអ៊ីលក្លរួ
2. តើគេទទួលបានអេស្ទែប៉ុន្មានក្រាម តាមប្រតិកម្មរវាងអាស៊ីតប្រូប៉ាណូអ៊ិច 500mL នៅកំហាប់ $0.5 mol \cdot L^{-1}$ ជាមួយមេតាណុល បើទិន្នផលនៃប្រតិកម្មមាន 67 % ។

## 1.5. អេស្ទែសំខាន់ៗ : អាស្ពីរីន



មេទីលបង់សូអាត



អាស៊ីតសាលីស៊ីលិច



មេទីលសាលីស៊ីឡាត



អាស៊ីតអាសេទីលសាលីស៊ីលិច(អាស្ពីរីន)

មេទីលបង់សូអាតនិងមេទីលសាលីស៊ីឡាត គឺជាអេស្ទែប្រហើរពីរដែលគេប្រើប្រាស់ច្រើននៅក្នុងឧស្សាហកម្មផលិតទឹកអប់ ។

អាស៊ីតសាលីស៊ីលិច សូដ្យូមសាលីស៊ីឡាត និងអាស៊ីតអាសេទីលសាលីស៊ីលិចមានអំពើ (ផ្នែកឱសថសាស្ត្រ)ប្រហាក់ប្រហែលគ្នា។ វាអាចបញ្ចុះកម្ដៅខ្លួនមនុស្សក្នុងករណីមានជំងឺគ្រុន ប្រឆាំងនិងការរលាកនិងបំបាត់ការឈឺចាប់ ដែលត្រូវនិងប្រភេទជំងឺមួយចំនួនដូចជា ឈឺក្បាល រុយម៉ាទីស ឈឺសរសៃប្រសាទ ។

អាស្ពីរីន ឬអាស៊ីតអាសេទីលសាលីស៊ីលិច ត្រូវបានសំយោគចេញពីអាស៊ីតសាលីស៊ីលិចនិងអានីឌ្រីតអាសេទិច :



អាស៊ីតសាលីស៊ីលិច  អានីឌ្រីតអាសេទិច  អាស៊ីតអាសេទីលសាលីស៊ីលិច(អាស្ពីរីន)  អាស៊ីតអាសេទិច

មនុស្សបានប្រើប្រាស់អាស្ពីរីនជាយូរណាស់មកហើយនិងចាត់ទុកវាជាឱសថមួយសាមញ្ញ ។ រហូតមកដល់ឆ្នាំ1971 ទើបគេបានរកឃើញនូវអំពើដ៏មានសារៈសំខាន់របស់អាស្ពីរីន ។ អាស្ពីរីនមានឥទ្ធិពលក្នុងការការពារនិងព្យាបាលជំងឺស្ទះសរសៃបេះដូង គ្រោះថ្នាក់សរសៃបេះដូងនិងសរសៃខួរក្បាល និងការពារជំងឺភ្នែកឡើងបាយ ។

## 2. ខ្លាញ់និងប្រេង

ខ្លាញ់និងប្រេងមានច្រើននៅក្នុងធម្មជាតិ ។ វាជាធាតុបង្កសំខាន់ដែលមានក្នុងកោសិកាខ្លាញ់សត្វនិងរុក្ខជាតិ ។ ខ្លាញ់បានពីសត្វ ឯប្រេងបានពីរុក្ខជាតិ ។

### 2.1. សមាសភាព

ទោះបីខ្លាញ់ជាអង្គធាតុរឹង ឯប្រេងជាអង្គធាតុរាវ ប៉ុន្តែអង្គធាតុទាំងពីរមានទម្រង់គ្រឹះដូចគ្នា គឺជាទ្រីអេស្ទែដែលកើតពីគ្លីសេរ៉ុល ឬ 1,2,3– ប្រូប៉ានទ្រីអុល ($CH_2OH-CHOH-CH_2OH$) និងអាស៊ីតខ្លាញ់ ។ ទ្រីអេស្ទែនេះហៅថា ទ្រីគ្លីសេរីត ។

គំនូសបំប្រួញតាងកំណត់ទ្រីគ្លីសេរីត



គ្លីសេរ៉ុល អាស៊ីតកាបុកស៊ីលិច ទ្រីគ្លីសេរីត(ខ្លាញ់ឬប្រេង)

*សំគាល់ :*

- រ៉ាឌីកាល់ R របស់អាស៊ីតអាចដូចគ្នាទាំងបី ឬខុសគ្នាទាំងបី ឬមានមួយខុសគេ
- បើ R ឆ្អែត → ទ្រីគ្លីសេរីតភាគច្រើនរឹង (ខ្លាញ់)
- បើ R មិនឆ្អែត → ទ្រីគ្លីសេរីតរាវ (ប្រេង)

ដូចនេះ ខ្លាញ់មានផ្ទុកបរិមាណដ៏ច្រើននៃអាស៊ីតឆ្អែត ឯប្រេងវិញផ្ទុកដោយអាស៊ីតមិនឆ្អែតដែលមានសម្ព័ន្ធពីរជាន់ ។

អាស៊ីតខ្លាញ់(សិក្សានៅថ្នាក់ទី 11 )គឺជាអាស៊ីតកាបុកស៊ីលិចដែលគេទាញចេញពីខ្លាញ់និងប្រេង ។ វាមានខ្សែកាបូនវែងគ្មានខ្នែង ហើយភាគច្រើនមានអាតូមកាបូនចាប់ពី 12 ឡើងទៅ ។ អាស៊ីតប៉ាល់មីទិច និងស្តេអារិច គឺជាអាស៊ីតដែលគេជួបប្រទះញឹកញយនៅក្នុងខ្លាញ់រឹង នៅសីតុណ្ហភាពបរិយាកាស (ប្រហែល 25°C )និងនៅក្នុងខ្លួនមនុស្ស (37°C) ។

តារាងទី 1.1 ខាងក្រោមគឺជាអាស៊ីតខ្លាញ់មួយចំនួនដែលគេជួបប្រទះញឹកញយ :

ក. អាស៊ីតខ្លាញ់ឆ្អែត

| អាស៊ីតឆ្អែត | ចំនួនអាតូម C | រូបមន្ត | ចំណុចរលាយ |
|---|---|---|---|
| អាស៊ីត ប៉ាល់មីទិច | 16 | $CH_3-(CH_2)_{14}-COOH$ | 62.9°C |
| អាស៊ីត ស្តេអារិច | 18 | $CH_3-(CH_2)_{16}-COOH$ | 69.6°C |
| អាស៊ីត អារ៉ាស៊ីឌិច | 20 | $CH_3-(CH_2)_{18}-COOH$ | 75.4°C |

## ១. អាស៊ីតខ្លាញ់មិនឆ្អែត

| អាស៊ីតមិនឆ្អែត | ចំនួនអាតូម C | រូបមន្ត | ចំណុចរលាយ |
|---|---|---|---|
| អាស៊ីត អូលេអ៊ិច | 18 | $CH_3-(CH_2)_7-CH=CH-(CH_2)_7-COOH$ | 13°C |
| អាស៊ីត លីណូលេអ៊ិច | 18 | $CH_3-(CH_2)_4-CH=CH-CH_2-CH=CH-(CH_2)_7-COOH$ | −5°C |
| អាស៊ីត លីណូលេនិច | 18 | $CH_3-CH_2-CH=CH-CH_2-CH=CH-CH_2-CH=CH-(CH_2)_7-COOH$ | −11°C |
| អាស៊ីត អារ៉ាស៊ីដូនិច | 20 | $CH_3-(CH_2)_3-CH=CH-CH_2-CH=CH-CH_2-CH=CH-CH_2-CH=CH-(CH_2)_4-COOH$ | −16°C |

## 2.2. លក្ខណៈ

ខ្លាញ់និងប្រេងទាំងអស់ស្រាលជាងទឹក មិនរលាយក្នុងទឹក តែអាចរលាយបានក្នុងឌីក្លរ៉ូអេតាន អេទែ បង់សែន ប្រេងសាំង កាបូនតេត្រាក្លរួ ឌីក្លរ៉ូអេទីឡែន ។

សីតុណ្ហភាពរលាយរបស់ទ្រីគ្លីសេរីតថយចុះ ចំពោះវត្ថុមានសម្ព័ន្ធពីរជាន់ក្នុងម៉ូលេគុល ដូចជាទ្រីគ្លីសេរីតនៃអាស៊ីតអូលេអ៊ិចអាចក្លាយជារឹងតែនៅសីតុណ្ហភាពទាបជាងខ្លួនមនុស្ស ។ កាលណាសម្ព័ន្ធពីរជាន់មានកាន់តែច្រើន សីតុណ្ហភាពរលាយកាន់តែទាប ។ គេជួបប្រទះអាស៊ីតដែលមានសម្ព័ន្ធពីរជាន់ច្រើននៅក្នុងប្រេងល្ង ប្រេងសណ្តែកដី ។

### ក. អ៊ីដ្រូសែនកម្ម

ប្រេងរុក្ខជាតិដែលមានភាពមិនឆ្អែតខ្លាំងអាចបំលែងទៅជាខ្លាញ់រឹងហៅថា ម៉ាការីនឬប៊ឺររុក្ខជាតិ តាមប្រតិកម្មអ៊ីដ្រូសែនកម្មប្រេងនៅចំពោះមុខកាតាលីករ Ni ឬ Pt ។ សម្ព័ន្ធពីរជាន់ មួយផ្នែក ឬទាំងស្រុងបានទទួលប្រតិកម្មបូក ហើយប្រេងរាវក៏ក្លាយជារឹង ។ ម៉ាការីន ច្រើនផលិតចេញពីប្រេងសណ្តែកសៀង ឬប្រេងពោត ។

គំនូសបំប្រួញ តាងប្រតិកម្មអ៊ីដ្រូសែនកម្ម គ្លីសេរ៉ុលទ្រីអូលេអាត :

$$\begin{array}{l} CH_2-O-CO-(CH_2)_7-CH=CH-(CH_2)_7-CH_3 \\ | \\ CH-O-CO-(CH_2)_7-CH=CH-(CH_2)_7-CH_3 + 3H_2 \xrightarrow{Ni} \\ | \\ CH_2-O-CO-(CH_2)_7-CH=CH-(CH_2)_7-CH_3 \end{array} \quad \begin{array}{l} CH_2-OCO-(CH_2)_{16}-CH_3 \\ | \\ CH-OCO-(CH_2)_{16}-CH_3 \\ | \\ CH_2-OCO-(CH_2)_{16}-CH_3 \end{array}$$

គ្លីសេរីលទ្រីអូលេអាត(រាវ) → គ្លីសេរីលទ្រីស្តេអារ៉ាត(រឹង)

ការស្រាវជ្រាវខាងវេជ្ជសាស្ត្របានបង្ហាញថា នៅក្នុងខ្លួនមនុស្សអេស្ទែដែលកើតពីកូឡេស្តេរ៉ុលនិងអាស៊ីតខ្លាញ់ឆ្អែត ជាអង្គធាតុរឹងដែលកកនៅតាមជញ្ជាំងសរសៃឈាមបង្កឱ្យមានជំងឺបេះដូងនិងជំងឺសរសៃឈាម ។ ហេតុនេះហើយបានជាឱសថការីណែនាំឱ្យប្រើប្រេងរុក្ខជាតិដែលមានអាស៊ីតខ្លាញ់មិនឆ្អែតជំនួសខ្លាញ់សត្វនិងម៉ាការីនដែលសម្បូរទៅដោយអាស៊ីតឆ្អែតនៅក្នុងអាហារ ។



រូបទី 1.2 ប្រអប់ម៉ាការីន (ឬហៅថា ប៊ឺរ)

## ១. អ៊ីដ្រូលីសខ្លាញ់ ឬប្រេង

នៅពេលគេដុតកម្ដៅល្បាយខ្លាញ់ ឬប្រេងជាមួយសូលុយស្យុងបាស ទ្រីគ្លីសេរីតបានបំលែងទៅជាគ្លីសេរ៉ុល និងអំបិលនៃអាស៊ីតខ្លាញ់ ។ ប្រតិកម្មនេះហៅថា សាប៊ូកម្មដែលគេប្រើនៅក្នុងឧស្សាហកម្មធ្វើសាប៊ូ គ្លីសេរីន និងអាស៊ីតសរីរាង្គ ។

***ឧទាហរណ៍*** : សាប៊ូកម្មនៃទ្រីប៉ាល់មីទីន

$$\begin{array}{l} CH_2-O-CO-(CH_2)_{14}-CH_3 \\ | \\ CH-O-CO-(CH_2)_{14}-CH_3 \\ | \\ CH_2-O-CO-(CH_2)_{14}-CH_3 \end{array} + 3NaOH \longrightarrow \begin{array}{l} CH_2-OH \\ | \\ CH-OH \\ | \\ CH_2-OH \end{array} + 3CH_3-(CH_2)_{14}-COO^- \ Na^+$$

ទ្រីប៉ាល់មីទីន — គ្លីសេរ៉ុល — សូដ្យូមប៉ាល់មីតាត(សាប៊ូ)

## 2.3. បំលែងខ្លាញ់ក្នុងសារពាង្គកាយ

ខ្លាញ់និងប្រេង ជាអាហារដែលផ្ដល់ថាមពលកម្ដៅច្រើនជាងប្រូតេអ៊ីននិងកាបូនអ៊ីដ្រាត ។ ប្រដាប់រំលាយអាហារមិនអាចស្រូបយកខ្លាញ់និងប្រេងដោយផ្ទាល់បានឡើយ ។ ក្រោមអំពើរបស់រសលំពែងនិងរសពោះវៀន ខ្លាញ់- ប្រេងក៏រងអ៊ីដ្រូលីសក្លាយជាអាស៊ីតខ្លាញ់និងគ្លីសេរ៉ុល ដែលអាចស្រូបយកដោយស្រទាប់ពោះវៀន ។ បន្ទាប់មកក៏សំយោគទៅជាទ្រីគ្លីសេរីតរបស់សារពាង្គកាយដែលត្រូវស្តុកទុកក្នុងកោសិកាខ្លាញ់ ។ នៅទីនោះ ទ្រីគ្លីសេរីតត្រូវបញ្ជូនទៅឱ្យសរីរាង្គដទៃទៀតក្នុងសារពាង្គកាយដែលវាត្រូវរងអ៊ីដ្រូលីសនិងអុកស៊ីតកម្មរហូតក្លាយជាឧស្ម័នកាបូនិចនិងទឹក ។ ប្រតិកម្មនេះបញ្ចេញកម្ដៅដែលផ្ដល់ឱ្យសារពាង្គកាយនូវថាមពលគ្រប់គ្រាន់សម្រាប់ទ្រទ្រង់សកម្មភាពជីវិត ។

## 2.4. សាប៊ូ

សាប៊ូដែលប្រើប្រាស់ប្រចាំថ្ងៃ ជាអំបិលសូដ្យូមនៃអាស៊ីតកាបុកស៊ីលិចដែលមានខ្សែកាបូនយ៉ាងវែង(មានកាបូនពី12 ទៅ18) ។ អំបិលប៉ូតាស្យូមបង្កើតជាសាប៊ូដែលមានលក្ខណៈទន់និងងាយរលាយ ។

អំបិលអាលុយមីញ៉ូមនៃអាស៊ីតខ្លាញ់បង្កើតបានជាជែល (gel) ដែលគេប្រើជាខ្លាញ់សម្រាប់លាបម៉ាស៊ីន និងគ្រឿងខ្ចៅផ្សេងៗ ។ អំបិលកាល់ស្យូម ឬម៉ាញ៉េស្យូម ឬស័ង្កសីនៃអាស៊ីតខ្លាញ់មិនរលាយក្នុងទឹកទេ ។

***អំពើរបស់សាប៊ូទៅលើស្នាមប្រឡាក់*** : ស្នាមប្រឡាក់ភាគច្រើននៅលើសម្លៀកបំពាក់ ឬស្បែក គឺជាប្រេង ឬខ្លាញ់ ។ ប្រសិនបើប្រេង ឬខ្លាញ់ត្រូវបានដកចេញភាគល្អិតនៃស្នាមប្រឡាក់នឹងត្រូវបាន លាងជម្រះ ។ មុខងារសំអាតរបស់សាប៊ូទាក់ទងទៅនឹងទម្រង់គីមីរបស់វា ។ បើយើងពិនិត្យម៉ូលេគុល សាប៊ូ វាមានផ្នែកប៉ូលែ ឬអ៊ីយ៉ុង ប៉ុន្តែខ្សែកាបូនយ៉ាងវែងមិនមានភាពប៉ូលែទេ

$$\underbrace{CH_3-CH_2-CH_2-CH_2-CH_2-CH_2-CH_2-CH_2-CH_2-CH_2-CH_2-CH_2-CH_2-CH_2-CH_2}_{\text{អ៊ីដ្រូផូប(មិនចូលចិត្តទឹក)(មិនប៉ូលែ)}}-\underbrace{COO^- \; Na^+}_{\text{អ៊ីដ្រូភីល(ប៉ូលែ)(ចូលចិត្តទឹក)}}$$

គេតាងម៉ូលេគុលសាប៊ូដោយ 


ផ្នែកខាងចុងដែលមានអ៊ីយ៉ុង $-COO^-$ បន្ទុកវាមានទំនោរខ្លាំងចូលចិត្តធាតុរំលាយប៉ូលែ ដូចជា ទឹក ។ គេថាវាមានលក្ខណៈអ៊ីដ្រូភីល(ចូលចិត្តទឹក) ។ ឯផ្នែកខ្សែកាបូន វាមានទំនោរចូលចិត្តខ្លាញ់ ឬ ប្រេង គេថាវាមានលក្ខណៈអ៊ីដ្រូផូប (មិនចូលចិត្តទឹក) ។ នៅពេលគេក្រឡុកសាប៊ូជាមួយទឹក សាប៊ូ បំបែកខ្លួនបង្កើតជាផ្នែកតូចៗហៅថា **មីសែល** ដែលមានផ្នែកខាងអ៊ីយ៉ុងស្ថិតនៅផ្នែកខាងក្រៅរបស់ មីសែល ដែលវាអាចមានទំនាញជាមួយម៉ូលេគុលទឹក ឯផ្នែកខ្សែកាបូនត្រូវបានផ្ដុំគ្នាគេចចេញពីទឹក ចូលទៅផ្នែកខាងក្នុងរបស់មីសែល ។ ដោយផ្នែកខាងក្រៅមានបន្ទុក (– ) ច្រើន ទើបមីសែលច្រាន គ្នាទៅវិញទៅមក ។




***រូបទី 6.3 ក. អ៊ីយ៉ុងកាបុកស៊ីឡាត នៃសាប៊ូមួយ*** ***ខ. កំណាមីសែល*** ***គ. អំពើរបស់សាប៊ូលើស្នាមប្រឡាក់***

សម្លៀកបំពាក់ ឬដៃដែលប្រឡាក់ភាគច្រើនជាទឹកដែលស្អិតភ្ជាប់ជាមួយខ្លាញ់ ឬប្រេង ដែលមិន

រលាយក្នុងទឹក ។ ម៉ូលេគុលសាប៊ូទៅហ៊ុមព័ទ្ធតំណក់តូចៗនៃប្រេង ឬខ្លាញ់ ដោយសារផ្នែកខ្សែកាបូនដែលរលាយក្នុងខ្លាញ់ ឬប្រេង ។ បែបនេះហើយទើបខ្លាញ់ ឬប្រេងត្រូវបានផ្តាច់ចេញនិងត្រូវលាងសំអាតដោយសារទឹក ។

## 2.5. សារធាតុជម្រះក្អែល (Detergent)

សារធាតុជម្រះក្អែល ជាប្រភេទម៉ូលេគុលដែលអាចបង្កើតមីសែលក្នុងទឹកនិងអាចហ៊ុមព័ទ្ធផ្តាច់យកខ្លាញ់ ឬប្រេងបាន ។ សារធាតុជម្រះក្អែលដូចគ្នាទៅនិងសាប៊ូដែរ គឺម៉ូលេគុលវាមានផ្នែកអ៊ីយ៉ុងនិងខ្សែកាបូនវែង ។

សារធាតុជម្រះក្អែលអាចប្រើប្រាស់នៅក្នុងទឹករឹងបាន ដោយវាមិនបង្កើតកករជាមួយនឹងអ៊ីយ៉ុងកាល់ស្យូម ឬម៉ាញេស្យូម ឬស័ង្កសីទេ ។ សារធាតុជម្រះក្អែលសំយោគមានច្រើនប្រភេទដែលគេផលិតក្នុងឧស្សាហកម្មប៉ុន្តែគេនិយមប្រើសូដ្យូមអាល់គីលបង់សែនស៊ុលផូណាត ។



R អាចមានអាតូមកាបូនពី 12 ទៅ 18

សូដ្យូមអាល់គីលបង់សែនស៊ុលផូណាត

សារធាតុនេះបានមកពីប្រតិកម្មរវាងអាស៊ីតស៊ុលផួរិចលើអាល់គីលបង់សែន និងបន្ទាប់មកធ្វើប្រតិកម្មជាមួយសូលុយស្យុងបាស :



អាល់គីលអ៊ីដ្រូសែនស៊ុលផាត ជាប្រភេទមួយផ្សេងទៀតនៃសារធាតុជម្រះក្អែល ។ អាល់កុលដែលមានខ្សែកាបូនវែង ដូចជាឡូរីអាល់កុលធ្វើប្រតិកម្មជាមួយអាស៊ីតស៊ុលផួរិចឱ្យផលអាល់គីលអ៊ីដ្រូសែនស៊ុលផាត ។ ក្រោយពីបន្សាបជាមួយសូត គេទទួលបានជាអំបិលសូដ្យូមដែលជាសារធាតុជម្រះក្អែល ។

$$CH_3-(CH_2)_{10}-CH_2OH + HO-SO_3H \longrightarrow CH_3-(CH_2)_{10}-CH_2OSO_3H + H_2O$$

ឡូរីអាល់កុល(ឬដូដេកាន -1- អុល) ឡូរីអ៊ីដ្រូសែនស៊ុលផាត

$$CH_3-(CH_2)_{10}-CH_2OSO_3H + NaOH \longrightarrow CH_3-(CH_2)_{10}-CH_2OSO_3^- - Na^+ + H_2O$$

ឡូរីអ៊ីដ្រូសែនស៊ុលផាត សូដ្យូមឡូរីស៊ុលផាត

សូដ្យូមឡូរី ស៊ុលផាត ជាសារធាតុជម្រះក្អែលដ៏ល្អ ដោយសារវាជាអំបិលនៃអាស៊ីតខ្លាំង សូលុយ

ស្បុងរបស់វាស្ទើរតែណឹត ។ ចំពោះសាប៊ូវិញ ស្ងួលុយស្បុងក្នុងទឹកជាស្ងួលុយស្បុងបាស ។ ស្ងួលុយស្បុងបាសមានផលអាក្រក់ចំពោះសាច់កំណាត់មួយចំនួន ។ បច្ចុប្បន្នបញ្ហាកង្វក់បរិស្ថាន (ទឹក)ដែលបង្កដោយសាប៊ូត្រូវបានដោះស្រាយ ដោយគេប្រើសារធាតុជម្រះក្អែលសំយោគជំនួសសាប៊ូ ។

## 2.6. ថ្នាំលាប

ថ្នាំលាបផ្សំដោយសារធាតុសំខាន់គឺ

- សារធាតុភ្ជាប់ ដែលអាចស្អិតភ្ជាប់ទៅនឹងផ្ទៃដែលត្រូវលាប បង្ខាំងជាតិពណ៌ឱ្យនៅក្នុងកន្លែងរបស់វានិងជារនាំងការពារសំណើម ។
- ជាតិពណ៌ ដែលផ្តល់ពណ៌ឱ្យទៅថ្នាំលាប ជាអ្នកស្រោបនិងការពារអនុភាពរបស់ថ្នាំ ។
- ធាតុរំលាយ សម្រាប់ជួយសម្រួលនៅពេលលាបថ្នាំនិងបន្ទាប់មកត្រូវហួតអស់ ។

សារធាតុភ្ជាប់ មួយដែលគេនិយមប្រើជាងគេ គឺប្រេងថ្ពៃ ។ មួយផ្នែកធំនៃប្រេងនេះ បង្កឡើងដោយអាស៊ីតមិនឆ្អែត ។

នៅពេលប៉ះខ្យល់ ភាពមិនឆ្អែត (ជាពិសេសកាលណាម៉ូលេគុលមានសម្ព័ន្ធពីរជាន់លើសពីមួយ) ក៏ធ្វើប្រតិកម្មជាមួយ $O_2$ នៃខ្យល់ បង្កើតជាផ្ទៃស្ងួត ។ លំនាំនេះទាក់ទងទៅនឹងប្រតិកម្មពីរ គឺអុកស៊ីតកម្មនិងប៉ូលីមែកម្ម ។

ជាតិពណ៌ ជាអង្គធាតុសរីរាង្គឬអសរីរាង្គស្ថិតនៅជាកករវិលវល់នៅក្នុងថ្នាំស្ងួត ដែលផ្ទុកដោយធាតុរំលាយនិងសារធាតុសំងួត ។

ធាតុរំលាយ ជាញឹកញយ គឺជាល្បាយឆាប់ហើរនៃប្រេងអ៊ីដ្រូកាបួ(ប្រេងកាត) ។ ក្រៅពីនេះទៀតសារធាតុសំងួត ជាស្ងួលុយស្បុងនៃអំបិលលោហៈដូចជា Co , Mn , Pb ដែលមានលក្ខណៈជាកាតាលីករ ។

ថ្នាំដែលលាបជាស្រទាប់មួយស្តើង នៅពេលប៉ះខ្យល់ធាតុរំលាយក៏ហួត ហើយរ៉ាឌីកាល់ R ដែលមានភាពមិនឆ្អែត ក៏ធ្វើអុកស៊ីតកម្មនិងប៉ូលីមែកម្ម បង្កើតបានជាប៉ូលីមែដោយម៉ូលេគុលភ្ជាប់គ្នាពីមួយទៅមួយ ។

### សង្ខេបមេរៀន

- អេស្ទែ ជាអង្គធាតុសរីរាង្គដែលបានពីប្រតិកម្មរវាងអាស៊ីតកាបុកស៊ីលិចនិងអាល់កុល ។ អេស្ទែភាគច្រើនមានក្លិនក្រអូប ដែលគេប្រើសម្រាប់ធ្វើទឹកអប់ ។

  រូបមន្តទូទៅរបស់អេស្ទែ : $R-C\begin{matrix}\nearrow O \\ \searrow O-R'\end{matrix}$

- ខ្លាញ់និងប្រេង គឺជាអេស្ទែដែលកើតឡើងពីគ្លីសេរ៉ុលនិងអាស៊ីតខ្លាញ់ ។ ខ្លាញ់(រឹង)បង្កឡើងពីអាស៊ីតឆ្អែត ឯប្រេង(រាវ)បង្កឡើងពីអាស៊ីតមិនឆ្អែត ។
- អ៊ីដ្រូលីសនៃខ្លាញ់និងប្រេង ក្នុងមជ្ឈដ្ឋានបាសបង្កើតបានសាប៊ូ ។
- សារធាតុជម្រះក្អែល (ឬសាប៊ូម្សៅ) មានលក្ខណៈសំអាតស្នាមប្រឡាក់ដូចសាប៊ូដែរ ប៉ុន្តែមានលក្ខណៈប្រសើរជាង ដោយគេអាចប្រើវាជាមួយទឹករឹងបាន ។ សារធាតុជម្រះក្អែលមិនបង្កើតកករជាមួយអ៊ីយ៉ុង $Ca^{2+}$ ឬ $Mg^{2+}$ របស់ទឹករឹងទេ ។
- ថ្នាំលាបមានសារធាតុបង្កបីសំខាន់គឺ : សារធាតុភ្ជាប់ ជាតិពណ៌ និងធាតុរំលាយ ។ សារធាតុភ្ជាប់ជាប្រេងដែលជាទ្រីគ្លីសេរីតនៃអាស៊ីតមិនឆ្អែត ។ នៅពេលប៉ះខ្យល់ថ្នាំលាបរងប្រតិកម្មអុកស៊ីតកម្មនិងប៉ូលីមែកម្មរបស់សម្ព័ន្ធពីរជាន់ នាំឱ្យមានការភ្ជាប់គ្នាពីម៉ូលេគុលមួយទៅមួយ ដែលធ្វើឱ្យថ្នាំលាបមានភាពជាប់ស្អិត ។

## សំណួរនិងលំហាត់

1. ចូរឱ្យនិយមន័យពាក្យ : សាប៊ូ អ៊ីដ្រូភីល អ៊ីដ្រូផូប ។
2. ចូរពន្យល់ពីអំពើរបស់សាប៊ូក្នុងការជម្រះខ្លាញ់ ឬប្រេង ។
3. ហេតុអ្វីបានជាសារធាតុជម្រះក្អែល មានលក្ខណៈល្អជាងសាប៊ូក្នុងការបោកគក់ ?
4. ចូរសរសេររូបមន្តរបស់ផលិតផលដែលកើតពីគ្លីសេរ៉ុលទ្រីអូលេអាតជាមួយ :

   ក. NaOH , ខ. $H_2$ (កាតាលីករ Ni )
5. ចូរគណនាម៉ាសម៉ូលរបស់អាស៊ីតខ្លាញ់ដែលបានពីអ៊ីដ្រូលីសខ្លាញ់ ឬប្រេងមួយដែលមានម៉ាសម៉ូល 884g ?

   ចូរកំណត់រូបមន្តរបស់អាស៊ីតខ្លាញ់នោះ បើគេដឹងថាម៉ូលេគុលវាមានសម្ព័ន្ធពីរជាន់មួយ ។

   ចម្លើយ : . $282g\ mol^{-1}$ , អាស៊ីតអូលេអ៊ិច $C_{17}H_{33}COOH$
6. អាស៊ីតអាសេទិចធ្វើប្រតិកម្មជាមួយអាល់កុលមួយបង្កើតបានអេស្ទែមួយដែល 0.4mol របស់វាមានម៉ាស 40.8g ។ តើអាល់កុលនោះមានម៉ាសម៉ូលប៉ុន្មាន ? ចម្លើយ : $60g\ mol^{-1}$
7. ចំហេះសព្វ 2.2g អេស្ទែមួយផ្តល់ឧស្ម័នកាបូនឌីអុកស៊ីត 4.4g ។ គេដឹងថា ផ្នែកអាល់កុលនិងផ្នែកអាស៊ីតដែលបង្កអេស្ទែនោះមានចំនួនអាតូមកាបូនស្មើគ្នា ហើយជាសមាសធាតុឆ្អែត ។ ចូរកំណត់រូបមន្តអេស្ទែនោះ ។ ចម្លើយ : $CH_3-COO-CH_2-CH_3$ អេទីលអាសេតាត

# 2 ស្រលាយអាលីផាទិចអាសូត

**ចប់មេរៀននេះ សិស្សអាច**

- ញែកសំគាល់ថ្នាក់ទាំងបីរបស់អាមីនតាមរយៈរូបមន្ត ។
- សរសេររូបមន្តនិងហៅឈ្មោះអាមីន អាមីតនិងអាស៊ីតអាមីណេ ។
- ពណ៌នាលក្ខណៈរូបរបស់អាមីន អាមីតនិងអាស៊ីតអាមីណេ ។
- សរសេរប្រតិកម្មគីមីសំខាន់ៗរបស់អាមីន អាមីតនិងអាស៊ីតអាមីណេ ។
- រៀបរាប់ទង្វើអាមីន អាមីតនិងអាស៊ីតអាមីណេ ។
- សរសេរទម្រង់ប៉ិបទីតនិងប្រូតេអ៊ីន ។

ស្រលាយអាលីផាទិចអាសូត ជាសមាសធាតុសរីរាង្គខ្សែបើកដែលម៉ូលេគុលវាមានធាតុអាសូត ។ សមាសធាតុសរីរាង្គអាសូតខ្លះមានសារៈសំខាន់ណាស់ចំពោះជីវិត ។

## 1. អាមីន

### 1.1. ទម្រង់និងនាមវលី

**ក. ទម្រង់**

អាមីនជាសមាសធាតុសរីរាង្គ ដែលបានពីការជំនួសអាតូមអ៊ីដ្រូសែនរបស់ម៉ូលេគុលអាម៉ូញ៉ាក់ដោយរ៉ាឌីកាល់អ៊ីដ្រូកាបួ ។




អាម៉ូញ៉ាក់ អាមីន

R ជារ៉ាឌីកាល់អ៊ីដ្រូកាបួខ្សែបើក។

បើ R ជារ៉ាឌីកាល់អ៊ីដ្រូកាបួឆ្អែត គេបានរូបមន្តទូទៅ $C_nH_{2n+3}N$ ។

## ខ. ចំណាត់ថ្នាក់អាមីន

គេចែកអាមីនជា3ថ្នាក់ ទៅតាមចំនួនអាតូមអ៊ីដ្រូសែនរបស់អាម៉ូញ៉ាក់ដែលត្រូវជំនួសដោយរ៉ាឌីកាល់ R ។

| $R_1-NH_2$ | $R_1-NH-R_2$ | $R_1-N(R_3)-R_2$ |
|---|---|---|
| អាមីនថ្នាក់ទី I | អាមីនថ្នាក់ទី II | អាមីនថ្នាក់ទី III |
| (ជំនួស H មួយ) | (ជំនួស H ពីរ) | (ជំនួស H បី) |

## គ. នាមវលី

- អាមីនថ្នាក់ទី I : ហៅឈ្មោះរ៉ាឌីកាល់ (R) រួចបន្ថែមបច្ឆិមបទអាមីន ។ អាតូម C លេខ 1 គឺជាអាតូម C ដែលភ្ជាប់ផ្ទាល់ទៅអាតូម N ។

*ឧទាហរណ៍ :*

ក. $CH_3-NH_2$ មេទីលឡាមីន

ខ. $CH_3-CH_2-NH_2$ អេទីលឡាមីន

គ. $\overset{4}{C}H_3-\overset{3}{C}H_2-\overset{2}{C}H(CH_3)-\overset{1}{C}H_2-NH_2$

2-មេទីល ប៊ុយទីលឡាមីន

ឃ. $CH_3-CH_2-\overset{1}{C}H(NH_2)-\overset{2}{C}H_2-\overset{3}{C}H_3$

1-អេទីល ប្រូពីលឡាមីន

- អាមីនថ្នាក់ទី II ឬ ថ្នាក់ទី III :

+ ទី1 ហៅឈ្មោះរ៉ាឌីកាល់ដែលមានខ្សែកាបូនខ្លី ដោយបញ្ជាក់ទីតាំង N– ឬ N,N– ក្នុងករណីមានរ៉ាឌីកាល់ពីរ ។

+ ទី2 ហៅឈ្មោះដូចអាមីនថ្នាក់1 ចំពោះរ៉ាឌីកាល់ដែលមានខ្សែកាបូនវែងឬសាំញ៉ាំ ឬសំខាន់ ។

*ឧទាហរណ៍ :*

$C_2H_5-NH-CH_3$ N– មេទីល អេទីលឡាមីន

$CH_3-NH-CH_3$ N – មេទីល មេទីលឡាមីន ឬ N– ឌីមេទីលឡាមីន

$C_2H_5-N(CH_3)-CH_3$ N,N – ឌីមេទីល អេទីលឡាមីន

$C_6H_5-N(CH_3)-C_2H_5$ N – អេទីល N – មេទីល ផេនីលឡាមីន

## លំហាត់អនុវត្តន៍

1. ចូរឱ្យឈ្មោះអាមីនដូចតទៅ :

ក. $CH_3-\underset{\displaystyle CH_3}{\underset{|}{N}}-CH_3$　　ខ. $C_2H_5-NH-C_2H_5$

គ. $CH_3-\underset{\displaystyle CH_3}{\underset{|}{CH}}-NH_2$　　ឃ. $CH_3-\underset{\displaystyle CH_3}{\underset{|}{CH}}-\underset{\displaystyle CH_3}{\underset{|}{CH}}-\underset{\displaystyle NH_2}{\underset{|}{CH}}-CH_3$ ។

2. ចូរធ្វើចំណាត់ថ្នាក់អាមីនខាងលើ (ថ្នាក់ទី I ថ្នាក់ទី II ឬ ថ្នាក់ទី III) ។

3. ចូរសរសេររូបមន្តសមាសធាតុដូចតទៅ :

ក. N– ឌីអេទីលឡាមីន　　ខ. 1– មេទីល ប៊ុយទីលឡាមីន

គ. ទ្រីអេទីលឡាមីន　　ឃ. N– មេទីល N– អ៊ីសូប្រូពីល អេទីលឡាមីន

## 1.2. លក្ខណៈរូប

តួដំបូងនៃអាមីន $C_nH_{2n+3}N$ ជាឧស្ម័នរលាយក្នុងទឹកបង្កើតបានជាសូលុយស្យុងបាស ។ អាមីនដែលមានភាពរូបជាឧស្ម័នមានក្លិនពុំសូវល្អ ព្រោះវាផ្សំដោយក្លិនអាម៉ូញ៉ាក់ ។ អាមីនដែលមានម៉ាសម៉ូលធំ (អាតូម C លើសពី 6 ) មិនរលាយក្នុងទឹកទេ ប៉ុន្តែរលាយក្នុងអង្គធាតុរំលាយសរីរាង្គ ។

តារាងទី 2.1 លក្ខណៈរូបរបស់អាមីនមួយចំនួនដែលជួបប្រទះញឹកញាប់ :

| ឈ្មោះ | រូបមន្ត | ចំណុចរលាយ | ចំណុចរំពុះ |
|---|---|---|---|
| អាម៉ូញ៉ាក់ | $NH_3$ | | –33°C |
| មេទីលឡាមីន | $CH_3-NH_2$ | –93°C | –6°C |
| អេទីលឡាមីន | $C_2H_5-NH_2$ | –81°C | + 17°C |
| ប្រូពីលឡាមីន | $CH_3-CH_2-CH_2-NH_2$ | –83°C | + 48°C |
| N – ឌីមេទីលឡាមីន | $(CH_3)_2NH$ | –47°C | + 3°C |

អាមីនមានចំណុចរំពុះខ្ពស់ជាងអាល់កាន ប៉ុន្តែទាបជាងអាល់កុលដែលមានម៉ាសម៉ូលប្រហែលគ្នា ។ នេះបណ្តាលមកពីវត្តមានសម្ព័ន្ធអ៊ីដ្រូសែនដែលកើតមានរវាងម៉ូលេគុល ចំពោះអាមីនថ្នាក់ទី I និងថ្នាក់ទី II (អាមីនថ្នាក់ទី III មិនអាចបង្កើតសម្ព័ន្ធនេះបានទេ) ។



សម្ព័ន្ធអ៊ីដ្រូសែនក្នុងអាមីនថ្នាក់ទី I



សម្ព័ន្ធអ៊ីដ្រូសែនក្នុងអាមីនថ្នាក់ទី II

| ឈ្មោះ | រូបមន្ត | ចំណុចរំពុះ (°C) | ម៉ាសម៉ូល $g\ mol^{-1}$ |
|---|---|---|---|
| ប្រូប៉ាន | $CH_3-CH_2-CH_3$ | –42 | 44 |
| អេទីលឡាមីន | $CH_3-CH_2-NH_2$ | 17 | 45 |
| អេតាណុល | $CH_3-CH_2OH$ | 78 | 46 |

ក្នុងចំណោមអ៊ីសូមែររបស់វា អាមីនថ្នាក់ទី I មានចំណុចរំពុះខ្ពស់ជាងគេ ហើយទាបជាងគេ គឺ អាមីនថ្នាក់ទី III ។ ***ឧទាហរណ៍*** អ៊ីសូមែនៃ $C_3H_9N$ :

| | $CH_3-CH_2-CH_2-NH_2$ | $CH_3-CH_2-NH-CH_3$ | $(CH_3)_3N$ |
|---|---|---|---|
| | ប្រូពីលឡាមីន | N – មេទីលអេទីលឡាមីន | ទ្រីមេទីលឡាមីន |
| ចំណុចរំពុះ | 50°C (ថ្នាក់ទី I) | 34°C (ថ្នាក់ទី II) | 3°C (ថ្នាក់ទី III) |

## 1.3. លក្ខណៈគីមី

អាមីនមានភាពស្រដៀងគ្នានិងអាម៉ូញ៉ាក់ ហើយមានលក្ខណៈរួមខ្លះទៀតផង ។

### ក. លក្ខណៈជាបាសនៃអាម៉ូញ៉ាក់

អាសូតមានលេខអាតូម Z = 7 របាយអេឡិចត្រុងរបស់វាគឺ $K^2\ L^5$ ។ អាសូតនៅខ្វះអេឡិចត្រុងចំនួន 3 ទៀត ដើម្បីឱ្យស្រទាប់ L ឆ្អែត ។ តាមវិធានអុកតេ អាសូតអាចចងសម្ព័ន្ធកូវ៉ាឡង់ជាមួយអាតូមអ៊ីដ្រូសែនបានបី ដើម្បីបង្កើតជាអាម៉ូញ៉ាក់និងនៅសល់មួយទ្វេតាអេឡិចត្រុងមិនសម្ព័ន្ធទៀត :

$$H-\ddot{N}(H)-H$$ ។

ទ្វេតាអេឡិចត្រុងមិនសម្ព័ន្ធនេះ អាចភ្ជាប់ជាមួយប្រូតុង $H^+$ បង្កើតបានជាអ៊ីយ៉ុងអាម៉ូញ៉ូម :

$$H-\ddot{N}(H)-H + H^+ \longrightarrow H-N^+(H)(H)-H$$

ឬ $NH_3 + H^+ \longrightarrow NH_4^+$ (អ៊ីយ៉ុងអាម៉ូញ៉ូម)

តាមប្រុងស្តេត បាសគឺជាប្រភេទគីមីដែលចាប់យកប្រូតុង ។

ដូច្នេះ $NH_3$ មានលក្ខណៈជាបាស ហើយអាស៊ីតឆ្លាស់របស់វាគឺ $NH_4^+$ ។ វាបង្កើតបានជាគូអាស៊ីត-បាស $NH_4^+/NH_3$ ។

$$NH_3 + H_2O \rightleftharpoons NH_4^+ + OH^-$$

## ១. លក្ខណៈជាបាសនៃអាមីន

អេទីលឡាមីន ($C_2H_5-NH_2$) ជាឧស្ម័នរលាយក្នុងទឹកនិងធ្វើឱ្យផេណុលផ្តាលេអ៊ីនឡើងពណ៌ក្កូឡាប បញ្ជាក់ថាសូលុយស្យុងនេះមានលក្ខណៈជាបាស ។ នៅសីតុណ្ហភាព 25°C សូលុយស្យុងអេទីលឡាមីនកំហាប់ $C = 0.1 mol\ L^{-1}$ មាន $pH = 11.9$ ។ ចំពោះសូលុយស្យុងបាសខ្លាំងដែលមានកំហាប់ដូចគ្នានេះមាន$pH = 13$ ។ ដូច្នេះសូលុយស្យុងអេទីលឡាមីនជាបាសខ្សោយ :

$$C_2H_5-\ddot{N}H_2 + H^+ \rightleftharpoons C_2H_5-NH_3^+$$

នៅក្នុងសូលុយស្យុង មានអត្ថិភាពនៃប្រភេទគីមីទាំងពីរគឺ $C_2H_5-NH_2$ និង $C_2H_5-NH_3^+$ ។ គូអាស៊ីត-បាសនេះ មានតម្លៃ $pK_a = 10.8$ ។

$$C_2H_5-NH_2 + H_2O \rightleftharpoons C_2H_5-NH_3^+ + OH^-$$ (អ៊ីយ៉ុងអេទីលឡាម៉ូញ៉ូម)

***ជាទូទៅ :***

- អាមីនទាំងអស់ (ថ្នាក់ទី I ថ្នាក់ទី II ថ្នាក់ទី III) សុទ្ធសឹងជាបាសខ្សោយ ។ លក្ខណៈជាបាសគឺបានមកពីទ្វេតាអេឡិចត្រុងមិនសម្ព័ន្ធរបស់អាសូតក្នុងបង្គុំអាមីន អាចចាប់យកប្រូតុង $H^+$ ដើម្បីក្លាយជាអាស៊ីតឆ្លាស់ ។

$$R_1-\ddot{N}(R_3)-R_2 + H^+ \rightleftharpoons R_1-N^+(H)(R_3)-R_2$$

បាស　　　　　　　　　　អាស៊ីតឆ្លាស់

- អាមីនជាបាសខ្លាំងជាងអាម៉ូញ៉ាក់ ។ តាមតម្លៃ $pK_a$ នៃគូអាស៊ីត-បាស កាលណា $pK_a$ កាន់តែធំលក្ខណៈបាសកាន់តែខ្លាំង ។ តាមតារាងបង្ហាញថា :
  - អាល់គីលឡាមីន ជាបាសខ្លាំងជាង $NH_3$
  - ផេនីលឡាមីន (អាមីនប្រហើរ) ជាបាសខ្សោយជាង $NH_3$ ។

| កំលាំងអាស៊ីតកើន ↓ | pKa ↑ | | កំលាំងបាសកើន ↑ |
|---|---|---|---|
| $(C_2H_5)_3NH^+$ | 11 | $(C_2H_5)_3N$ | |
| $C_2H_5\ NH_3^+$ | 10.8 | $C_2H_5\ NH_2$ | |
| $(CH_3)_2NH_2^+$ | 10.7 | $(CH_3)_2NH$ | |
| $CH_3\ NH_3^+$ | 10.7 | $CH_3\ NH_2$ | |
| $(C_2H_5)_2NH_2^+$ | 10.5 | $(C_2H_5)_2NH$ | |
| $(CH_3)NH^+$ | 9.8 | $(CH_3)_3N$ | |
| $NH_4^+$ | 9.3 | $NH_3$ | |
| $C_6H_5NH_3^+$ | 4.6 | $C_6H_5NH_2$ | |

តារាងទី 2.2 ***pKa*** របស់គូអាស៊ីត-បាសនៃអាមីនមួយចំនួន

### គ. ប្រតិកម្មរវាងអាមីននិងអង្គធាតុស្រលាយអាឡូសែន

អេទីលអ៊ីយ៉ូដួ ($C_2H_5-I$) ជាម៉ូលេគុលប៉ូលែ( $-\overset{|}{\underset{|}{C}}-\overset{|}{\underset{|}{C}}^{\delta+}-I^{\delta-}$ ) ។ បើគេដាក់អេទីលអ៊ីយ៉ូដួឱ្យរលាយក្នុងអេតាណុល បន្ទាប់មកឱ្យវាមានប្រតិកម្មជាមួយអាមីនថ្នាក់ទី III ប្រតិកម្មក៏កើតមានឡើងដោយសារទ្វេតាអេឡិចត្រុងមិនសម្ព័ន្ធរបស់អាសូតអាចអូសទាញបណ្តុំ $C_2H_5^{\delta+}$ និងបង្កើតជាអ៊ីយ៉ុងអ៊ីយ៉ូដួ :

$$R_1-\underset{\underset{R_3}{|}}{\ddot{N}}-R_2 + \overset{\delta+}{C}_2H_5-I^{\delta-} \longrightarrow I^- + R_1-\underset{\underset{R_3}{|}}{\overset{\overset{C_2H_5}{|}}{N^+}}-R_2$$

អ៊ីយ៉ុងអាម៉ូញ៉ូមថ្នាក់ទី IV

***ឧទាហរណ៍ :***

$$CH_3-\underset{\underset{CH_3}{|}}{\ddot{N}}-CH_3 + CH_3^{\delta+}-I^{\delta-} \longrightarrow (CH_3)_4N^+\ I^-$$

តេត្រាមេទីលឡាម៉ូញ៉ូមអ៊ីយ៉ូដួ

ទ្វេតាអេឡិចត្រុងសេរីរបស់អាសូតនៃបង្គុំអាមីន មានចំណូលខ្លាំងចំពោះមណ្ឌលដែលមានបន្ទុកវិជ្ជមាន ។ គេនិយាយថា អាមីនគឺជាប្រតិករ នុយក្លេអូភីល ។ ដូចគ្នានេះដែរក្នុងម៉ូលេគុល $CH_3-\overset{\delta+}{C}H_2-I^{\delta-}$ អាតូម $C^{\delta+}$ មានចំណូលខ្លាំងចំពោះអេឡិចត្រុង គេថា $CH_3-CH_2I$ ជាប្រតិករអេឡិចត្រូភីល ។

***ជាទូទៅ :***

- អាមីនថ្នាក់ទី I ឬថ្នាក់ទី II ធ្វើប្រតិកម្មជាមួយសមាសធាតុស្រលាយអាឡូសែន ( $R-X$ ដែល X អាចជាអាតូម F ឬ Cl ឬ Br ឬ I ) បង្កើតបានជា អាមីនថ្នាក់ខ្ពស់ជាង ។

$$R_1-NH_2 + R-X \longrightarrow R_1-NH-R + HX$$

$$R_1-NH-R_2 + R-X \longrightarrow R_1-\underset{\underset{R}{|}}{N}-R_2 + HX$$

- អាមីនថ្នាក់ទី III ធ្វើប្រតិកម្មជាមួយ $R-X$ បង្កើតបានជាអ៊ីយ៉ុងអាម៉ូញ៉ូមថ្នាក់ទី IV (មានន័យថាអ៊ីយ៉ុងអាម៉ូញ៉ូមដែលមានបណ្តុំជំនួស 4 ) ។

### ឃ. ប្រតិកម្មអាមីនថ្នាក់ទី I ជាមួយអាស៊ីលក្លរួ ($R-\underset{\underset{O}{\|}}{C}-Cl$)

អាមីន ជាប្រតិករនុយក្លេអូភីល ។ ទ្វេតាអេឡិចត្រុងសេរីរបស់អាសូត មានទំនាញជាមួយអាតូម $C^{\delta+}$ នៃបង្គុំកាបូនីលរបស់អាស៊ីលក្លរួ បង្កើតបានជាអាមីតនិងអ៊ីដ្រូសែនក្លរួ ។

$$R-\underset{\underset{O}{\|}}{C^{\delta+}}-Cl \quad + \quad \ddot{N}H-R_1 \ (\text{with } H \text{ on } N) \longrightarrow R-\underset{\underset{O}{\|}}{C}-\underset{\underset{H}{|}}{N}-R_1 \quad + \quad HCl$$

អាស៊ីលក្លរ — អាមីនថ្នាក់ទី I — អាមីត

## ង. ប្រតិកម្មបង្កើតអំបិល

អាមីនធ្វើប្រតិកម្មជាមួយអាស៊ីតរ៉ែ (អាស៊ីតខ្លាំង) បង្កើតបានជាអំបិល

$$R-NH_2 + H^+ + Cl^- \longrightarrow R-NH_3^+ + Cl^-$$

***ឧទាហរណ៍ :***

$$CH_3-CH_2-NH_2 + H^+ + Cl^- \longrightarrow CH_3-CH_2-NH_3^+ + Cl^- \quad \text{ឬ} \quad CH_3-CH_2-NH_3Cl$$

អេទីលឡាម៉ូញ៉ូមក្លរ

**លំហាត់អនុវត្តន៍**

សរសេរសមីការតាងប្រតិកម្មខាងក្រោម ព្រមទាំងឱ្យឈ្មោះផលិតផល :

ក. $CH_3-CH_2-NH_2 + HBr$

ខ. $(CH_3)_3N + HCl$

គ. $CH_3-CH_2-CH_2-NH_2 + CH_3I$

ឃ. $CH_3-CH_2-NH_2 + H-OH$

## 1.4. ចង្ក្រើអាមីន

- អាម៉ូញ៉ាក់ធ្វើប្រតិកម្មជាមួយអាល់គីលអាឡូសែនួ $(R-X)$ បង្កើតបានអាមីន :

$$R^{\delta+}-X^{\delta-} + 2\ddot{N}H_3 \longrightarrow R-NH_2 + NH_4X$$

អាល់គីលអាឡូសែនួ — អាម៉ូញ៉ាក់ — អាមីនថ្នាក់ទី I — អំបិលអាម៉ូញ៉ូម

អាមីនថ្នាក់ទី I ដែលទើបកកើតក៏ធ្វើប្រតិកម្មជាមួយ $R-X$ បង្កើតបានអាមីនថ្នាក់ទី II ហើយអាមីនថ្នាក់ទី II ក៏ធ្វើប្រតិកម្មបន្តជាមួយ $R-X$ បង្កើតបានជាអាមីនថ្នាក់ទី III ។ អាមីនថ្នាក់ ទី III ក៏ធ្វើប្រតិកម្មបន្តបង្កើតជាអំបិលអាម៉ូញ៉ូមថ្នាក់ IV :

$$R-X + NH_3 \longrightarrow R-NH_2 \xrightarrow{R-X} R-NH-R \xrightarrow{R-X} R_3N$$

អាល់គីលអាឡូសែនួ — អាមីនថ្នាក់ I — អាមីនថ្នាក់ II — អាមីនថ្នាក់ III

$$R_3\dot{N} + R-X \longrightarrow R_4N^+X^- \quad \text{ឬ} \quad R_4NX$$

គេប្រើលំនាំប្រតិកម្មខាងលើសម្រាប់សំយោគយកតែអាមីនថ្នាក់ទី I ប៉ុណ្ណោះ គឺនៅពេលប្រតិកម្មចាប់ផ្តើម គេញែកយកអាមីនថ្នាក់ទី I ចេញបានយ៉ាងងាយ ។

***ឧទាហរណ៍ :***

$$CH_3-CH_2-CH_2Br + 2NH_3 \longrightarrow CH_3-CH_2-CH_2-NH_2 + NH_4Br$$

ប្រូពីលប្រូមួ ... ប្រូពីលអាមីន

- ប្រតិកម្មរេដុកម្មនៃក្រុមនីទ្រីល ផ្តល់បានអាមីនថ្នាក់I :

$$R-C\equiv N + 4(H) \xrightarrow{Ni,t,1000atm} R-CH_2-NH_2$$

នីទ្រីល ... អាមីនថ្នាក់ទីI

$$CH_3-CH_2-CH_2-CH_2-C\equiv N + 4(H) \xrightarrow[t\ ,\ p]{Ni} CH_3-CH_2-CH_2-CH_2-CH_2-NH_2$$

ប៉ង់តានីទ្រីល ... ប៉ង់ទីលអាមីន

# 2. អាមីត

## 2.1. ទម្រង់និងនាមវលី

### ក. ទម្រង់

អាមីត គឺជាស្រលាយនៃអាស៊ីតកាបុកស៊ីលិច ($R-\underset{\Vert}{C}-OH$, C=O) ដែលក្នុងនោះបង្គុំ –OH របស់អាស៊ីតត្រូវបានជំនួសដោយបង្គុំអាមីន ($-NH_2$) ។

រូបមន្តទូទៅនៃអាមីត ($R-C(=O)-NH_2$)

អាតូមអ៊ីដ្រូសែនរបស់បង្គុំ ($-NH_2$) ជំនួសដោយរ៉ាឌីកាល់អ៊ីដ្រូកាបួ

| $R-C(=O)-NH_2$ | $R-C(=O)-NH-R_1$ | $R-C(=O)-N(R_2)-R_1$ |
|---|---|---|
| អាមីតថ្នាក់ទីI | អាមីតថ្នាក់ទីII | អាមីតថ្នាក់ទីIII |
| (ជំនួសH ចំនួន1) | (ជំនួសH ចំនួន2) | (ជំនួសH ចំនួន3) |

### ខ. នាមវលី (IUPAC)

ឈ្មោះរបស់អាមីតបានមកពីឈ្មោះអាស៊ីត ដោយប្តូរបច្ច័មបទ អូអ៊ិច របស់អាស៊ីតទៅជាអាមីត ។

***ឧទាហរណ៍ :***

| | $H-C(=O)-NH_2$ | $CH_3-C(=O)-NH_2$ | $CH_3-CH_2-C(=O)-NH_2$ |
|---|---|---|---|
| (IUPAC) | មេតាណាមីត | អេតាណាមីត | ប្រូប៉ាណាមីត |
| ឈ្មោះធ្លាប់ប្រើ | ផរម៉ាមីត | អាសេតាមីត | ប្រូប្យូណាមីត |



*រូបទី 2.1 គំរូម៉ូលេគុលអេតាណាមីត*

ដើម្បីហៅឈ្មោះអាមីតថ្នាក់ទី II ឬថ្នាក់ទី III  យើងត្រូវហៅឈ្មោះរ៉ាឌីកាល់ដែលតភ្ជាប់និងអាតូមអាសូត ។

***ឧទាហរណ៍ :***

$$CH_3-\underset{\underset{O}{\|}}{C}-NH-CH_3$$

N-មេទីលអេតាណាមីត

$$CH_3-CH_2-\underset{\underset{O}{\|}}{C}-\underset{\underset{CH_3}{|}}{N}-CH_3$$

N,N- ឌីមេទីលប្រូប៉ាណាមីត

**លំហាត់អនុវត្តន៍**

ចូរសរសេររូបមន្តអាមីតដូចតទៅ :

ក.  3 – មេទីលប៊ុយតាណាមីត

ខ.  N,N – ឌីអេទីលប្រូប៉ាណាមីត ។

## 2.2. លក្ខណៈ

- អាមីតមានចំណុចរំពុះខ្ពស់ ។  អាមីតភាគច្រើនគ្មានពណ៌ មានទម្រង់ជាគ្រាមរឹង ។  អាមីតរលាយក្នុងទឹកបានច្រើនជាងអាល់កុលបន្តិច ( កាលណាម៉ូលេគុលទាំងពីរមានចំនួនអាតូមកាបូនស្មើគ្នា ) ។
- ដោយដុតកម្តៅជាមួយទឹក អាមីតរងអ៊ីដ្រូលីសយឺតៗបង្កើតបានជាអាស៊ីតកាបុកស៊ីលិច ។

$$CH_3-\underset{\underset{O}{\|}}{C}-NH_2 + H_2O \xrightarrow{\text{ដាំពុះ}} CH_3-\underset{\underset{O}{\|}}{C}-OH + NH_3$$

អេតាណាមីត　　　　　អាស៊ីតអាសេទិច

## 2.3. ចង្វើអាមីត

អាមីតថ្នាក់ទី I អាចទទួលបានតាមប្រតិកម្ម :

### ក. អេស្ទែនិងអាម៉ូញ៉ាក់

$$CH_3-\underset{\underset{O}{\|}}{C}-O-C_2H_5 + NH_3 \longrightarrow CH_3-\underset{\underset{O}{\|}}{C}-NH_2 + C_2H_5OH$$

អេទីលអេតាណូអាត　　　　　អេតាណាមីត　　　　　អេតាណុល

### ខ. អាស៊ីលក្លរួនិងអាម៉ូញ៉ាក់

$$CH_3-\underset{\underset{O}{\|}}{C}-Cl + 2NH_3 \longrightarrow CH_3-\underset{\underset{O}{\|}}{C}-NH_2 + NH_4Cl$$

អេតាណូអ៊ីលក្លរួ　　　　　អេតាណាមីត　　　　　អាម៉ូញ៉ូមក្លរួ

### គ. អានីឌ្រីតអាស៊ីតនិងអាម៉ូញ៉ាក់

$$\underset{\text{អានីឌ្រីតអាសេទិច}}{CH_3-\underset{\underset{O}{\|}}{C}-O-\underset{\underset{O}{\|}}{C}-CH_3} + NH_3 \longrightarrow \underset{\text{អាសេតាមីត}}{CH_3-\underset{\underset{O}{\|}}{C}-NH_2} + \underset{\text{អាស៊ីតអាសេទិច}}{CH_3-\underset{\underset{O}{\|}}{C}-OH}$$

### ឃ. អាស៊ីតកាបុកស៊ីលិចនិងអាម៉ូញ៉ាក់

$$\underset{\text{អាស៊ីតអាសេទិច}}{CH_3-\underset{\underset{O}{\|}}{C}-OH} + NH_3 \longrightarrow \underset{\text{អាសេតាមីត}}{CH_3-\underset{\underset{O}{\|}}{C}-NH_2} + H_2O$$

**លំហាត់អនុវត្តន៍**

សរសេរសមីការនិងឱ្យឈ្មោះអាមីតដែលកកើតពីប្រតិកម្មរវាង :

ក. អាម៉ូញ៉ាក់និងអេទីលមេតាណូអាត

ខ. អាម៉ូញ៉ាក់និងអានីឌ្រីតផរមិច

គ. អាម៉ូញ៉ាក់និងបង់សូអ៊ីលក្លរួ ។



រូបទី 2.2 ដែកកេះធ្វើពីនីឡុង

នីឡុង គឺជាប៉ូលីអាមីត

***ឧទាហរណ៍ :*** នីឡុង 11 $\left[ NH-(CH_2)_{10}-\underset{\underset{O}{\|}}{C} \right]_n$

នីឡុងមិនរលាយក្នុងធាតុរំលាយសរីរាង្គទេ ប៉ុន្តែមានអំពើជាមួយអាស៊ីតខ្លាំងនិងមិនឆេះក្នុងខ្យល់ទេ (គឺឆេះហើយរលត់ដោយឯកឯង) ។

## 2.4. អាមីតពិសេស (អ៊ុយរ៉េ)

អ៊ុយរ៉េ គឺជាឌីអាមីតនៃអាស៊ីតកាបូនិច

$$\underset{\text{អាស៊ីតកាបូនិច}}{H-O-\underset{\underset{O}{\|}}{C}-O-H} \qquad \underset{\text{អ៊ុយរ៉េ}}{H_2N-\underset{\underset{O}{\|}}{C}-NH_2} \quad \text{ឬ} \quad O=C\begin{matrix}\diagup NH_2\\ \diagdown NH_2\end{matrix}$$

អ៊ុយរ៉េជាអង្គធាតុក្រាមរឹង គ្មានពណ៌រលាយក្នុងទឹក ។ វាគឺជាផលិតផលនៃមេតាបូលីសប្រូតេអ៊ីនក្នុងសារពាង្គកាយ ។ ក្នុងឧស្សាហកម្ម អ៊ុយរ៉េត្រូវបានផលិតឡើងតាមរយៈការដុតកម្តៅ $NH_3$ ជាមួយកាបូនឌីអុកស៊ីត ($CO_2$) នៅសីតុណ្ហភាពខ្ពស់និងសម្ពាធខ្ពស់ :

$$CO_2 + 2NH_3 \longrightarrow H_2N-CO-NH_2 + H_2O$$

បម្រើបម្រាស់ចម្បងរបស់អ៊ុយរ៉េ គឺជាជីសម្រាប់ដំណាំ ។

# 3. អាស៊ីតអាមីណេ

## 3.1. ទម្រង់ម៉ូលេគុលនិងនាមវលី

### ក. ទម្រង់ម៉ូលេគុល

អាស៊ីតអាមីណេ គឺជាសមាសធាតុសរីរាង្គដែលមានបង្គុំកាបុកស៊ីល (–COOH) មួយនិងបង្គុំអាមីន មួយ ។ កាលណាបង្គុំទាំងពីរភ្ជាប់និងអាតូមកាបូនតែមួយ គេបានអាស៊ីត α - អាមីណេ ។

រូបមន្តទូទៅនៃអាស៊ីត α - អាមីណេ $R-\underset{NH_2}{\underset{|}{\overset{\alpha}{C}H}}-\underset{O}{\underset{\|}{C}}-OH$

អាស៊ីត α - អាមីណេទាំងអស់មានគូអេណង់ទ្យូមែររបស់វា (អ៊ីសូមែអុបទិច) លើកលែងតែ អាស៊ីត α - អាមីណូអាសេទិច ( $H-\underset{NH_2}{\underset{|}{C}H}-COOH$ ) ដែលរ៉ាឌីកាល់ R– ជាអាតូម H ។

### ខ. នាមវលី

គេហៅអាស៊ីតអាមីណេតាមឈ្មោះដែលធ្លាប់ប្រើ ។ កាលណាបង្គុំនាទីអាមីនជាប់និងអាតូមកាបូន ក្នុងទីតាំង β ឬ γ ឈ្មោះអាស៊ីតអាមីណេត្រូវបន្ថែមបុព្វបទ β– អាមីណូ ឬ γ– អាមីណូទៅលើ ឈ្មោះអាស៊ីតកាបុកស៊ីលិច ។

***ឧទាហរណ៍ :***

$\underset{NH_2}{\underset{|}{\overset{\alpha}{C}H_2}}-COOH$

អាស៊ីត α– អាមីណូអាសេទិច ឬគ្លីស៊ីន (Gly)

$CH_3-\underset{NH_2}{\underset{|}{\overset{\alpha}{C}H_2}}-COOH$

អាស៊ីត α– អាមីណូប្រូប្យូនិច ឬអាឡានីន (Ala)



*រូបទី 2.3 គំរូម៉ូលេគុលអាស៊ីត α– អាមីណូប្រូប្យូនិច ឬអាឡានីន (Ala)*

$H_2N-\overset{\beta}{C}H_2-\overset{\alpha}{C}H_2-COOH$

អាស៊ីត β– អាមីណូប្រូប្យូនិច

$H_2N-\overset{\gamma}{C}H_2-\overset{\beta}{C}H_2-\overset{\alpha}{C}H_2-COOH$

អាស៊ីត γ– អាមីណូប៊ុយទីរិច

## 3.2. លក្ខណៈ

- អាស៊ីតអាមីណេ គឺជាអង្គធាតុក្រាមដែលរលាយ ឬបំបែកនៅសីតុណ្ហភាពខ្ពស់ ។ វាងាយរលាយក្នុងទឹក ប៉ុន្តែមិនរលាយក្នុងអង្គធាតុរំលាយសរីរាង្គដូចជា បង់សែន អាល់កុល អេទែ . . . ។

- ក្នុងម៉ូលេគុលអាស៊ីតអាមីណេ បង្គុំកាបុកស៊ីលមានលក្ខណៈជាអាស៊ីត ឯបង្គុំអាមីនមានលក្ខណៈជាបាស ។

នៅក្នុងភាពជាសូលុយស្យុងទឹក អាស៊ីតអាមីណេមានទម្រង់បីបែប :

$R-\underset{\substack{|\\ NH_3^+}}{CH}-COO^-$ ក្នុងសូលុយស្យុងណឺត

$R-\underset{\substack{|\\ NH_3^+}}{CH}-COOH$ ក្នុងសូលុយស្យុងអាស៊ីត

$R-\underset{\substack{|\\ NH_2}}{CH}-COO^-$ ក្នុងសូលុយស្យុងបាស

ប្រភេទទាំងបីស្ថិតនៅក្នុងគូអាស៊ីត- បាសពីរ :

$$R-\underset{\substack{|\\ NH_3^+}}{CH}-COOH \rightleftharpoons R-\underset{\substack{|\\ NH_3^+}}{CH}-COO^- + H^+$$

$$R-\underset{\substack{|\\ NH_3^+}}{CH}-COO^- \rightleftharpoons R-\underset{\substack{|\\ NH_2}}{CH}-COO^- + H^+$$

អាស៊ីតអាមីណេមានលក្ខណៈអំផូទែ គឺវាអាចចាប់យកប្រូតុង $H^+$ ពីអាស៊ីតខ្លាំង ឬក៏ផ្តល់ប្រូតុង $H^+$ ទៅបាសខ្លាំង ។

## ៣.៣. ចំរង្កើ

មានវិធីជាច្រើនដើម្បីបង្កើតអាស៊ីតអាមីណេ ។

### ក. វិធីទី 1

គេឱ្យអាស៊ីត $\alpha$ – អាឡូសែណូកាបុកស៊ីលិច មានប្រតិកម្មជាមួយអាម៉ូញ៉ាក់លើស គេទទួលបានអាស៊ីត $\alpha$ – អាមីណូកាបុកស៊ីលិច:

$$\underset{\substack{|\\ Cl}}{CH_2}-COOH + 2NH_3 \longrightarrow \underset{\substack{|\\ NH_2}}{CH_2}-COOH + NH_4Cl$$

អាស៊ីតក្លរ៉ូអាសេទិច → គ្លីស៊ីន

### ខ. វិធីទី 2

គេឱ្យអាល់ដេអ៊ីត មានអំពើជាមួយអ៊ីដ្រូសែនស្យានួ ចំពោះវត្តមានអាម៉ូញ៉ាក់បង្កើតបានអាមីណូនីទ្រីល ។ អ៊ីដ្រូលីសអាមីណូនីទ្រីលផ្តល់អាស៊ីតអាមីណេ :

$$CH_3-\underset{\substack{\|\\ O}}{C}-H \xrightarrow[NH_3]{HCN} CH_3-\underset{\substack{|\\ NH_2}}{CH}-C\equiv N \xrightarrow[H^+]{H_2O} CH_3-\underset{\substack{|\\ NH_2}}{CH}-COOH$$

អាសេតាល់ដេអ៊ីត → អាមីណូនីទ្រីល → អាឡានីន (Ala)

## 3.4. ប៉ិបទីតនិងប្រូតេអ៊ីន

### ក. សម្ព័ន្ធប៉ិបទីត

ម៉ូលេគុលអាស៊ីតអាមីណេចំនួនពីរអាចភ្ជាប់គ្នា ដោយមានការដកទឹកចេញចំនួន 1 ម៉ូលេគុល ។ ប្រតិកម្មនេះមានឈ្មោះថា កុងដង់កម្ម ហើយអង្គធាតុដែលទទួលបានមានឈ្មោះថា ឌីប៉ិបទីត ។ សម្ព័ន្ធដែលភ្ជាប់ម៉ូលេគុលទាំងពីរមានឈ្មោះថា សម្ព័ន្ធប៉ិបទីត ( $-\underset{\underset{O}{\|}}{C}-NH-$ ) ។

*ឧទាហរណ៍ :*

$$H_2N-CH_2-\underset{\underset{O}{\|}}{C}-\boxed{OH+H}-NH-\underset{\underset{CH_3}{|}}{CH}-\underset{\underset{O}{\|}}{C}-OH \longrightarrow H_2N-CH_2-\underset{\underset{O}{\|}}{C}-NH-\underset{\underset{CH_3}{|}}{CH}-COOH+H_2O$$

គ្លីស៊ីន (Gly) — អាឡានីន (Ala) — គ្លីស៊ីល ឡានីន (Gly-Ala)

### ខ. ប៉ិបទីតនិងប្រូតេអ៊ីន

ប៉ិបទីតដែលកើតឡើងពីអាស៊ីតអាមីណេចំនួន 3 , 4 ឬ 5 មានឈ្មោះថាទ្រីប៉ិបទីត តេត្រាប៉ិបទីត ប៉ង់តាប៉ិបទីត ។ ប៉ិបទីតដែលបង្កដោយអាស៊ីតអាមីណេច្រើន មានម៉ូលេគុល (តិចជាង 60 ) ហៅថា ប៉ូលីប៉ិបទីត ។

$$\underset{\underset{H}{|}}{NH}-\underset{\underset{R_1}{|}}{CH}-COOH + \underset{\underset{H}{|}}{NH}-\underset{\underset{R_2}{|}}{CH}-COOH + \underset{\underset{H}{|}}{NH}-\underset{\underset{R_3}{|}}{CH}-COOH + \ldots\ldots \longrightarrow$$

$$H_2N-\underset{\underset{R_1}{|}}{CH}-\underset{\underset{O}{\|}}{C}-NH-\underset{\underset{R_2}{|}}{CH}-\underset{\underset{O}{\|}}{C}-NH-\underset{\underset{R_3}{|}}{CH}-\underset{\underset{O}{\|}}{C}-\ldots\ldots$$

ប៉ូលីប៉ិបទីត

ប្រូតេអ៊ីនត្រូវបានគេហៅសម្រាប់ម៉ូលេគុលណាដែលបង្កដោយអាស៊ីតអាមីណេច្រើនជាង 60 ។ ប្រូតេអ៊ីនមានម៉ាសម៉ូលេគុលធំណាស់ អាចមានរហូតដល់ $4\times10^6\, g.mol^{-1}$ ។

*ឧទាហរណ៍ :* អេម៉ូគ្លូប៊ីន ជាប្រូតេអ៊ីនដែលមានសម្ព័ន្ធប៉ិបទីត 141 និងមានម៉ាសម៉ូល $66000 g\ mol^{-1}$ ។

រ៉ាឌីកាល់ R របស់អាស៊ីតអាមីណេដែលបង្កជាប្រូតេអ៊ីនមិនមែនជារ៉ាឌីកាល់ធម្មតាទេ ប៉ុន្តែនៅមានបង្គុំនាទីផ្សេងៗទៀតដូចជា បង្គុំកាបុកស៊ីល អាល់កុល អាមីត ឬអាតូមស្ពាន់ធ័រ... ។ បង្គុំទាំងនេះកំណត់លក្ខណៈជាក់លាក់ឱ្យអាស៊ីតអាមីណេនីមួយៗ ។



*រូបទី 2.4 សណ្តែកសៀងជាចញ្ចជាតិដែលសម្បូរទៅដោយប្រូតេអ៊ីន*

នៅពេលប្រូតេអ៊ីនត្រូវដុតកម្តៅជាមួយទឹក វារងអ៊ីដ្រូលីស ហើយផ្តល់ជាអាស៊ីត α – អាមីណោចំនួន 20 ប្រភេទ ។ ប្រូតេអ៊ីនខុសគ្នាពីមួយទៅមួយដោយចំនួនអាស៊ីតអាមីណោនិងការតម្រៀបរបស់វា ។

ក្នុងពេលរំលាយអាហារ ប្រូតេអ៊ីនសត្វឬរុក្ខជាតិរងអ៊ីដ្រូលីសជាអាស៊ីតអាមីណោដែលជ្រាបចូលក្នុងសរសៃឈាម ហើយត្រូវនាំទៅចែកចាយដល់ជាលិកា ។ បន្ទាប់មកក្រោមអំពើរបស់អង់ស៊ីម (ប្រូតេអ៊ីនដែលមានមុខងារជាក់លាក់) អាស៊ីតអាមីណោក៏រងកុងដង់កម្មសាជាថ្មី បង្កើតជាប្រូតេអ៊ីននៃសារពាង្គកាយវិញ ។



រូបទី 4.5 គំរូប្រូតេអ៊ីនមួយ

តារាងទី 2.3 អាស៊ីត α– អាមីណេសំខាន់ៗចំនួន 20

| ឈ្មោះ | អក្សរកាត់ | រូបមន្ត |
|---|---|---|
| គ្លីស៊ីន<br>Glycine<br>1 | Gly | $H-\underset{NH_2}{\underset{\mid}{CH}}-COOH$ |
| អាឡានីន<br>Alanine<br>2 | Ala | $CH_3-\underset{NH_2}{\underset{\mid}{CH}}-COOH$ |
| វ៉ាលីន*<br>Valinne<br>3 | Val | $\substack{CH_3 \\ CH_3}\!\!>\!CH-\underset{NH_2}{\underset{\mid}{CH}}-COOH$ |
| ឡឺស៊ីន*<br>Leucine<br>4 | Leu | $\substack{CH_3 \\ CH_3}\!\!>\!CH-CH_2-\underset{NH_2}{\underset{\mid}{CH}}-COOH$ |
| អ៊ីសូឡឺស៊ីន*<br>Isoleucine<br>5 | Ilu | $\substack{CH_3 \\ CH_3-CH_2}\!\!>\!CH-\underset{NH_2}{\underset{\mid}{CH}}-COOH$ |
| សេរីន<br>Sérine<br>6 | Ser | $CH_2OH-\underset{NH_2}{\underset{\mid}{CH}}-COOH$ |
| ត្រេអូនីន*<br>Thréonine<br>7 | Thr | $CH_3-CHOH-\underset{NH_2}{\underset{\mid}{CH}}-COOH$ |
| ស៊ីស្ទីន<br>Cystèine<br>8 | Cys | $HS-CH_2-\underset{NH_2}{\underset{\mid}{CH}}-COOH$ |
| មេត្យូនីន*<br>Méthionine<br>9 | Met | $CH_3-S-CH_2-CH_2-\underset{NH_2}{\underset{\mid}{CH}}-COOH$ |
| អាស៊ីតអាស្ប៉ាទិច<br>Aspartique<br>10 | Asp | $HOOC-CH_2-\underset{NH_2}{\underset{\mid}{CH}}-COOH$ |

| | | |
|---|---|---|
| អាស្ប៉ារ៉ាស៊ីន<br>Aspasragine<br>11 | Asn | $H_2N-C(=O)-CH_2-CH(NH_2)-COOH$ |
| អាស៊ីតគ្លុយតាមិច<br>Acide glutamique<br>12 | Glu | $HOOC-CH_2-CH_2-CH(NH_2)-COOH$ |
| គ្លុយតាមីន<br>Glutamine<br>13 | Gln | $H_2N-C(=O)-CH_2-CH_2-CH(NH_2)-COOH$ |
| លីស៊ីន*<br>Lysine<br>14 | Lys | $H_2N-CH_2-(CH_2)_3-CH(NH_2)-COOH$ |
| អាកស៊ីនីន<br>Arginine<br>15 | Arg | $H_2N-C(=NH)-NH-(CH_2)_3-CH(NH_2)-COOH$ |
| ផេនីឡាមីន*<br>Phènylanine<br>16 | Phe |  |
| ទីរ៉ូស៊ីន<br>Tyrosine<br>17 | Tyr |  |
| ទ្រីបតូផាន<br>Tryptophane<br>18 | Try |  |
| ហ៊ីស្ទីដីន<br>Histidine<br>19 | His |  |
| ប្រូលីន<br>Proline<br>20 | Pro |  |

(*)អាស៊ីត α – អាមីណេ* ចំនួន 8 ដែលមិនអាចខ្វះបានចំពោះសារពាង្គកាយ ព្រោះសរីរាង្គមនុស្សមិនអាចសំយោគវាបានទេ ។ យើងត្រូវតែផ្តល់វាតាមរយៈអាហារប្រមាណជា 1g ក្នុងមួយថ្ងៃ សម្រាប់អាស៊ីតអាមីណេនីមួយៗ ។

## មេរៀនសង្ខេប

ស្រលាយអាលីផាទិចអាសូត ជាសមាសធាតុសរីរាង្គដែលមានខ្សែកាបូនបើកនិងមានធាតុអាសូតក្នុងម៉ូលេគុល ។ សមាសធាតុទាំងនេះមាន អាមីន អាមីត ប៉ិបទីត និងប្រូតេអ៊ីន ។

- អាមីន ជាអង្គធាតុស្រលាយអាម៉ូញ៉ាក់ ដែលបានពីការជំនួសអាតូម H របស់ $NH_3$ ដោយរ៉ាឌីកាល់ R របស់អ៊ីដ្រូកាបួ ។

| $H-\underset{\overset{\vert}{H}}{N}-H$ | $R_1-\underset{\overset{\vert}{H}}{N}-H$ | $R_1-\underset{\overset{\vert}{H}}{N}-R_2$ | $R_1-\underset{\overset{\vert}{R_3}}{N}-R_2$ |
|---|---|---|---|
| អាម៉ូញ៉ាក់ | អាមីនថ្នាក់ទី I | អាមីនថ្នាក់ទី II | អាមីនថ្នាក់ទី III |

អាមីនទាំងអស់មានលក្ខណៈជាបាសខ្សោយដូចអាម៉ូញ៉ាក់ដែរ ។

- អាមីត គឺជាអង្គធាតុស្រលាយនៃអាស៊ីតកាបុកស៊ីលិច (R – COOH) ដែលបង្គុំ –OH ត្រូវជំនួសដោយបង្គុំអាមីន ($-NH_2$) ។ រូបមន្តទូទៅ $R-CO-NH_2$ ។

| $R-\underset{\overset{\Vert}{O}}{C}-OH$ | $R-\underset{\overset{\Vert}{O}}{C}-NH_2$ | $R-\underset{\overset{\Vert}{O}}{C}-NH-R_1$ | $R-\underset{\overset{\Vert}{O}}{C}-\underset{\overset{\vert}{R_2}}{N}-R_1$ |
|---|---|---|---|
| អាស៊ីតកាបុកស៊ីលិច | អាមីតថ្នាក់ទី I | អាមីតថ្នាក់ទី II | អាមីតថ្នាក់ទី III |

- អាស៊ីតអាមីណេ ជាសមាសធាតុសរីរាង្គដែលមានលក្ខណៈទ្វេ ព្រោះក្នុងម៉ូលេគុលវាមានបង្គុំនាទីពីរព្រមគ្នា គឺបង្គុំកាបុកស៊ីល –COOH ដែលនាទីជាអាស៊ីតនិងបង្គុំអាមីន $-NH_2$ ដែលនាទីជាបាស ។

រូបមន្តទូទៅ $R-\underset{\overset{\vert}{NH_2}}{CH}-COOH$ អាស៊ីត α – អាមីណេ

អាស៊ីតអាមីណេអាចភ្ជាប់គ្នាពីមួយទៅមួយ ដោយសម្ព័ន្ធប៉ិបទីត ( $-\underset{\overset{\Vert}{O}}{C}-NH-$ )

$$H_2N-\underset{\overset{\vert}{R_1}}{CH}-\underset{\overset{\Vert}{O}}{C}-OH+H-NH-\underset{\overset{\vert}{R_2}}{CH}-COOH \longrightarrow H_2N-\underset{\overset{\vert}{R_1}}{CH}-\underset{\overset{\Vert}{O}}{C}-NH-\underset{\overset{\vert}{R_2}}{CH}-COOH+H_2O$$

- អាស៊ីតអាមីណេអាចភ្ជាប់គ្នា ពីរ បី បួនឬច្រើន ហៅថា ឌីប៉ិបទីត ទ្រីប៉ិបទីត តេត្រាប៉ិបទីត និងប៉ូលីប៉ិបទីតតាមប្រតិកម្មកុងដង់កម្ម ។
- កាលណាមានអាស៊ីតអាមីណេភ្ជាប់គ្នាលើសពី 60 ទៅហៅថា ប្រូតេអ៊ីន ។ អ៊ីដ្រូលីសនៃប្រូតេអ៊ីនធម្មជាតិផ្តល់អាស៊ីត α – អាមីណេចំនួន 20 ប្រភេទ ដែលក្នុងចំណោមនោះមានអាស៊ីតអាមីណេចំនួន 8 ដែលមនុស្សត្រូវផ្តល់ឱ្យសារពាង្គកាយមិនអាចខ្វះបានតាមរយៈអាហារ ព្រោះសរីរាង្គមនុស្សមិនអាចសំយោគវាបាន ។

## ? សំណួរនិងលំហាត់

1. ចូរសរសេររូបមន្តទូទៅនៃ អាមីន អាមីត អាស៊ីតអាមីណេ ។
2. ហេតុអ្វីបានជាគេចាត់ទុកអាមីន ជាអង្គធាតុស្រលាយនៃអាម៉ូញ៉ាក់ ? ចូរពន្យល់ ។
3. ចូរសរសេរបណ្តុំអាតូមដែលសំគាល់ អាមីត អាមីន ។
4. ហេតុអ្វីបានជាគេថា អាស៊ីតអាមីណេមានលក្ខណៈទ្វេ ?
5. តើមានអាស៊ីតអាមីណេប៉ុន្មានប្រភេទដែលបង្កជាប្រូតេអ៊ីនធម្មជាតិ ?
6. ចូរសរសេររូបមន្តសមាសធាតុដូចតទៅ :

   ក. ប៊ុយតាណាមីត　　　ខ. N,N– ឌីមេទីលអាសេតាមីត

   គ. N,N– ឌីមេទីលផរម៉ាមីត　　　ឃ. អាស៊ីត 3– អាមីណូប៊ុយតាណូអ៊ិច
7. ចូរសរសេរសមីការបង្កើតទ្រីប៉ិបទីតពីអាស៊ីត $\alpha$– អាមីណូប្រូប្បនិច ឬអាឡានីន(Ala) ។
8. ការវិភាគម៉ូលេគុលអាមីនថ្នាក់ II មួយ បានលទ្ធផលដូចតទៅ :

   កាបូន 61.02 % អាសូត 23.73 % និងអ៊ីដ្រូសែន 15.25 % ។ តើអាមីននោះមានរូបមន្តដូចម្តេច ?

   ចម្លើយ : $CH_3-CH_2-NH-CH_3$
9. អាម៉ូញ៉ាក់និងឧស្ម័ន $CO_2$ ធ្វើប្រតិកម្មជាមួយគ្នានៅលក្ខខណ្ឌធម្មតាក្នុងមាឌប៉ុនគ្នា គេទទួលបាន អ៊ុយរ៉េ 6g ។ តើឧស្ម័នណាដែលនៅសល់មិនធ្វើប្រតិកម្ម ? មាឌប៉ុន្មាន ?

   ចម្លើយ : 2.24L　$CO_2$
10. 0.2mol ដែលត្រូវនឹង 24.5g អាស៊ីត $\alpha$– ក្លរ៉ូកាបុកស៊ីលិចឆ្អែតមួយ បង្កើតបាន 20.6g អាស៊ីត $\alpha$– អាមីណូកាបុកស៊ីលិចឆ្អែត ។ តើអាស៊ីតអាមីណេនោះមានរូបមន្តដូចម្តេច ?

    ចម្លើយ : $C_2H_5-\underset{\displaystyle NH_2}{\underset{|}{C}H}-COOH$

មេរៀនទី

# 3 សមាសធាតុប្រហើរ

**ចប់មេរៀននេះ សិស្សអាច**

- ពណ៌នាពីស្រឡាយនីត្រូនិងស្រឡាយអាមីណូរបស់បង់សែន ។
- ពណ៌នាពីផេណុលនិងអាល់កុលប្រហើរ ។
- ពណ៌នាពីអាស៊ីតប្រហើរ ។
- ពណ៌នាពីអាល់ដេអ៊ីតប្រហើរ ។

នៅថ្នាក់ទី 10 យើងបានសិក្សារួចហើយពីអ៊ីដ្រូកាបួប្រហើរមួយ គឺបង់សែន ($C_6H_6$) ។ ប្រតិកម្មសំខាន់ដែលកើតមានលើបង់សែននិងសមាសធាតុប្រហើរ គឺប្រតិកម្មជំនួស ។ នៅក្នុងប្រតិកម្មនេះ អាតូមអ៊ីដ្រូសែនមួយ ត្រូវបានជំនួសដោយអាតូម ឬបណ្តុំអាតូមផ្សេងៗ ដោយមិនប៉ះពាល់ដល់ណ្វៃយ៉ូបង់សែនទេ ។

ប្រតិកម្មជំនួសដែលគេជួបប្រទះនៅលើបង់សែនមាន :




ប្រតិកម្មក្លរកម្ម




ប្រតិកម្មប្រូមកម្ម




ប្រតិកម្មនីត្រកម្ម




ប្រតិកម្មស៊ុលផូកម្ម




ប្រតិកម្មអាល់គីលកម្ម

ប្រតិកម្មជំនួសលើសមាសធាតុប្រហើរ ត្រូវបានគេប្រើដើម្បីផលិតវត្ថុប្រើប្រាស់ជាច្រើនក្នុងជីវភាពរស់នៅ ។

# 1. ស្រឡាយនីត្រូនិងស្រឡាយអាមីណូរបស់បង់សែន

## 1.1. នីត្រូបង់សែននិងទ្រីនីត្រូតូលុយអែន

### ក. នីត្រូបង់សែន

ក្នុងប្រតិកម្មរវាងបង់សែនជាមួយអាស៊ីតនីទ្រិចដោយមានកាតាលីករអាស៊ីតស៊ុលផួរិចខាប់ អាតូមអ៊ីដ្រូសែនមួយនៃបង់សែនត្រូវបានជំនួសដោយបង្គុំនីត្រូ (–$NO_2$) ។ លំនាំនេះមានឈ្មោះថា នីទ្រកម្ម ។ ការបន្ថែមអាស៊ីតស៊ុលផួរិច គឺសម្រាប់ជួយសម្រួលដល់ការបង្កើតអ៊ីយ៉ុងនីត្រូញ៉ូម ។

$$H - \ddot{\underset{\cdot\cdot}{O}} - NO_2 + H^+ \longrightarrow H - \overset{\overset{H}{|}}{\underset{\cdot\cdot}{O}}{}^{+} - NO_2 \xrightarrow{-H_2O} \overset{+}{N}O_2 \text{ ឬ } \langle O = \overset{+}{N} = O \rangle$$

អាស៊ីតនីទ្រិច (បានពី $H_2SO_4$) អ៊ីយ៉ុងនីត្រូញ៉ូម




បង់សែន អ៊ីយ៉ុងនីត្រូញ៉ូម នីត្រូបង់សែន

វត្តមានបង្គុំ (–$NO_2$) មួយភ្ជាប់ទៅណ្វៃយ៉ូបង់សែន ធ្វើឱ្យសកម្មភាពណ្វៃយ៉ូថយចុះ សម្រាប់ការជំនួសបន្តទៀត ។ ការជំនួសទីពីរឬទីបីអាចប្រព្រឹត្តទៅបាន គេចាំបាច់ត្រូវបន្ថែមលក្ខខណ្ឌដល់ប្រតិកម្ម ។

ដូចនេះ ប្រតិកម្មជំនួសក្នុងទីតាំងណាក៏ដោយ របស់នីត្រូបង់សែនមានលក្ខណៈលំបាកជាងប្រតិកម្មជំនួសរបស់បង់សែន ។




នីត្រូបង់សែន ជាអង្គធាតុរាវ ពណ៌លឿង ធ្ងន់ជាងទឹក មានក្លិនគ្រអូបក្រពុល ។ នីត្រូបង់សែនមានគ្រោះថ្នាក់ចំពោះគោលិកាក្រហមនិងថ្លើម ។ ដូច្នេះយើងត្រូវប្រុងប្រយ័ត្នខ្ពស់នៅពេលប្រើប្រាស់និងមិនត្រូវស្រូបយកចំហាយវាទេ ។

នីត្រូបង់សែន ត្រូវបានគេយកទៅប្រើប្រាស់ក្នុងឧស្សាហកម្មសម្រាប់សំយោគអានីលីននិងសមាសធាតុសរីរាង្គដទៃទៀត ។

### ២. ទ្រីនីត្រូតូលុយអែន

ទ្រីនីត្រូតូលុយអែន ជាអង្គធាតុដែលបានពីប្រតិកម្មជំនួសជាច្រើនដំណាក់របស់តូលុយអែនជាមួយអាស៊ីតនីទ្រិច ។ គេប្រើទ្រីនីត្រូតូលុយអែនជាគ្រឿងផ្ទុះក្នុងវិស័យយោធា ។




2, 4, 6 - ទ្រីនីត្រូតូលុយអែន (TNT)

(ចំណុចរលាយ 80° C)

## ខ.២. ស្រឡាយអាមីណូរបស់បង់សែន : អានីលីន

អានីលីន ជាអាមីនប្រហើរដែលផលិតឡើងក្នុងឧស្សាហកម្ម តាមប្រតិកម្មរេដុកម្ម នីត្រូបង់សែនដោយដែកនិងចំហាយទឹក ។

នៅក្នុងទីពិសោធន៍គេប្រើអាស៊ីតក្លរីឌ្រិចជាប្រភពផ្តល់អ៊ីដ្រូសែនជំនួសចំហាយទឹក ហើយគេជំនួសដែកដោយប្រើស័ង្កសី ឬសំណប៉ាហាំង ។ ស័ង្កសីទៅរំដោះអ៊ីដ្រូសែនចេញពីអាស៊ីត ហើយអ៊ីដ្រូសែនដែលនៅក្នុងភាពជាអាតូមនេះក៏ធ្វើរេដុកម្មនីត្រូបង់សែនឱ្យទៅជាអានីលីន :




នីត្រូបង់សែន អានីលីន ឬផេនីឡាមីន

អានីលីនមានលក្ខណៈជាបាសដូចអាម៉ូញ៉ាក់ដែរ ប៉ុន្តែលក្ខណៈបាសនៃអានីលីនមានខ្សោយបំផុត (វាមិនបម្រែពណ៌ទួណឺសុលទេ) ។ អានីលីន មានប្រតិកម្មជាមួយអាស៊ីតក្លរីឌ្រិច បង្កើតបានជាអំបិល




អានីលីន អានីលីញ៉ូមក្លរ

អានីលីន មានប្រតិកម្មជំនួសយ៉ាងខ្លាំងគ្នាជាមួយទឹកប្រូម ។ បើគេត្រលុកអានីលីនជាមួយទឹកប្រូម វាកកើតទៅជា 2,4,6 – ទ្រីប្រូម៉ូអានីលីន :




អានីលីន ជាអង្គធាតុរាវដូចប្រេង គ្មានពណ៌ រលាយក្នុងទឹកតិចតួចនិងពុលខ្លាំង ។ នៅក្នុងខ្យល់ វាឡើងពណ៌ខ្មៅដោយបានរងអុកស៊ីតកម្ម ។

អានីលីន ជាសមាសធាតុមួយសំខាន់សម្រាប់ឧស្សាហកម្មគីមី ។ គេប្រើវាសម្រាប់ធ្វើជាល័ខ ថ្នាំពេទ្យ រូបធាតុប្លាស្ទិច និងសមាសធាតុប្រហើរជាច្រើនទៀត ។

## 2. សមាសធាតុប្រហើរអ៊ីដ្រុកស៊ី

សមាសធាតុប្រហើរដែលមានបង្គុំ (–OH) ក្នុងម៉ូលេគុល ជាសមាសធាតុប្រហើរអ៊ីដ្រុកស៊ី ។ សមាសធាតុនេះ មានពីរប្រភេទទៅតាមការភ្ជាប់នៃបង្គុំ (–OH) :

- កាលណាបង្គុំ (–OH) ភ្ជាប់ទៅអាតូមកាបូននៃណ្វៃយ៉ូបង់សែន គេបានក្រុមផេណុល ។
- កាលណាបង្គុំ (–OH) ភ្ជាប់ទៅអាតូមកាបូននៃខ្សែចំហៀង គេបានអាល់កុលប្រហើរ ។

*ឧទាហរណ៍ :*




### 2.1. ផេណុល

ផេណុល ជាស្រទ្បាយនៃអ៊ីដ្រូកាបួប្រហើរ ដែលមានបង្គុំ (–OH) មួយ ឬច្រើនទៅជំនួសអាតូមអ៊ីដ្រូសែននៃបង់សែន ។

គេក៏ប្រើពាក្យ ផេណុល សម្រាប់ហៅ ស្រឡាយបង់សែនដែលមានបង្គុំ (-OH) តែមួយភ្ជាប់ទៅអាតូមកាបូននៃណៃ្វយ៉ូបង់សែនផងដែរ ។ គេចាត់ទុកផេណុលដែលមានបណ្តុំអាតូមសាំញ៉ាំភ្ជាប់ទៅណៃ្វយ៉ូបង់សែនថា ជាស្រឡាយនៃផេណុលដែរ ។

***ឧទាហរណ៍ :***



ផេណុល   o-មេទីលផេណុល (ឬ o-គ្រេសុល)   p- មេទីលផេណុល (ឬ p-គ្រេសុល)   2,4,6- ទ្រីនីត្រូផេណុល (ឬ អាស៊ីតពីគ្រិច)

ក. ទង្វើ

ពីដើមគេទទួលបានផេណុលពីជ័រធ្យូងថ្ម(គូជ្រុងធ្យូងថ្ម) ។ ជ័រធ្យូងថ្មបានមកពីកូកេកម្មធ្យូងថ្ម ។ នៅក្នុងជ័រធ្យូងថ្មមានផ្ទុកទៅដោយផេណុល គ្រេសុលនិងណាប់តាឡែន ។ បច្ចុប្បន្ន ផេណុលត្រូវធ្វើឡើងតាមវិធីសំយោគ ។ ដំបូងគេបំលែងក្លរ៉ូបង់សែនឱ្យទៅជាអំបិល សូដ្យូមផេណូឡាត ( ឬសូដ្យូមផេណុកស៊ីត) ដោយសូលុយស្យុងអាល់កាលីនៅសីតុណ្ហភាពនិងសំពាធខ្ពស់ ។ បន្ទាប់មកអំបិលដែលកកើតត្រូវបំលែងជាផេណុលដោយទឹកនិងឧស្ម័នកាបូនិច :



ក្លរ៉ូបង់សែន   សូដ្យូមផេណូឡាត



ផេណុល

ខ. លក្ខណៈរូប

ផេណុលដែលកកើត ជាគ្រាម រាងដូចម្ទុលគ្រីស្តាល់ គ្មានពណ៌ ដែលប្រែជាពណ៌ផ្កាឈូកនៅពេលប៉ះខ្យល់(ទទួលអុកស៊ីតកម្ម) ។ គ្រាមផេណុលមានចំណុចរលាយ 42°C និងចំណុចរំពុះ 181°C ។ វាជាអង្គធាតុរលាយតិចក្នុងទឹក ។ គេប្រើសូលុយស្យុងរាវនៃផេណុលជាថ្នាំសម្លាប់សត្វល្អិតនិងជាថ្នាំ

សម្លាប់មេរោគ ( ដូចជា សំអាតឧបករណ៍វះកាត់មុនប្រើប្រាស់) ។ ផេណុលធ្វើឱ្យស្បែករលាកនៅពេលដែលប៉ះជាមួយវានិងពុលខ្លាំងណាស់ ប្រសិនបើលេបវាចូលទៅក្នុងខ្លួន ។ ដូចនេះ យើងត្រូវប្រុងប្រយ័ត្នបំផុតនៅពេលប្រើប្រាស់ផេណុល ។

### គ. លក្ខណៈគីមី

វត្តមាននៃបង្គុំ (–OH) ភ្ជាប់ទៅស្នៀយ៉ូបង់សែន ធ្វើឱ្យផេណុលមានលក្ខណៈគីមីខ្លះស្រដៀងគ្នាទៅនិងលក្ខណៈគីមីអាល់កុលនិងខ្លះទៀតខុសពីអាល់កុល ។

#### លក្ខណៈស្រដៀងនឹងអាល់កុល

ផេណុលដែលកម្តៅរហូតដល់ចំណុចរលាយមានប្រតិកម្មជាមួយលោហៈសូដ្យូម ដោយបំភាយអ៊ីដ្រូសែននិងកំណជាសូដ្យូមផេណូឡាត :


សូដ្យូមផេណូឡាត

#### លក្ខណៈខុសពីអាល់កុល

- ផេណុលមានលក្ខណៈជាអាស៊ីតខុសពីអាល់កុល ដោយវាធ្វើប្រតិកម្មជាមួយសូលុយស្យុងអាល់កាលី ។ លក្ខណៈនេះហើយ បានជាគេហៅផេណុលថា **អាស៊ីតផេនិច** ។


ផេណុល ឬអាស៊ីតផេនិច      សូដ្យូមផេណូឡាត

- ផេណុល អាចរងប្រតិកម្មជំនួស ។ ជាមួយទឹកប្រូម ផេណុលមានប្រតិកម្មជំនួសយ៉ាងរហ័សបង្កើតបានជា 2,4,6- ទ្រីប្រូម៉ូផេណុល ។



• ផេណុលមានប្រតិកម្មជាមួយ អាល់ដេអ៊ីតផរមិច ដោយមានកាតាលីករអាល់កាលី បង្កើតបានផលិតផលទីមួយជា o- ឬ p- អ៊ីដ្រុកស៊ីបង់ស៊ីលអាល់កុល :



ផេណុល   អាល់ដេអ៊ីតផរមិច   o- អ៊ីដ្រុកស៊ីបង់ស៊ីលអាល់កុល

បន្ទាប់មក o-អ៊ីដ្រុកស៊ីបង់ស៊ីលអាល់កុល ក៏ធ្វើប្រតិកម្មបន្តទៀតជាមួយផេណុល បង្កើតបានជាមេទីឡែន ($-CH_2-$) ដែលភ្ជាប់ណ្វៃយ៉ូបង់សែនទាំងពីរ :



o- អ៊ីដ្រុកស៊ីបង់ស៊ីលអាល់កុល   ផេណុល

ប្រតិកម្មក្នុងដង់កម្មនេះ ចេះតែបន្តទៅទៀតរហូតបង្កើតបានជាខ្សែប៉ូលីមែដ៏វែងមានឈ្មោះថា បាកេលីត ។



ផ្នែកមួយនៃរូបមន្តរបស់បាកេលីត

ប៉ូលីមែប្រភេទនេះ ប្រើសម្រាប់ឧបករណ៍ចាក់ពុម្ព ( ដូចជា គ្រឿងអគ្គិសនី ឧបករណ៍ផ្ទះបាយ ) ឧបករណ៍ដែលជាបន្ទះ (ដូចជា ផរមីកា ក្តារបន្ទះ)និងប្រើជាកាវសម្រាប់បិទបំណែកក្តារ ។

## 2.2. អាល់កុលប្រហើរ

ជាសមាសធាតុប្រហើរដែលមានបណ្តុំ (-OH) ភ្ជាប់ទៅអាតូមកាបូននៃខ្សែចំហៀង ។

អាល់កុលប្រហើរមានលក្ខណៈគីមីដូចគ្នាទៅនឹងអាល់កុលអាលីផាទិច (អាល់កុលខ្សែបើក) ដែលបានសិក្សារួចហើយនៅថ្នាក់ទី II ។

***ឧទាហរណ៍*** **:** បង់ស៊ីលអាល់កុល  ចំណុចរំពុះ 205°C

ចំណុចរលាយ –15°C

បង់ស៊ីលអាល់កុលធ្វើឡើងតាមប្រតិកម្មរវាងបង់ស៊ីលអាឡូសែនូនិងស៊ូតៈ



បង់ស៊ីលប្រូមួ  បង់ស៊ីលអាល់កុល

***ឧទាហរណ៍*** **:** ប្រតិកម្មរបស់ផេណុលនិងអាល់កុលប្រហើរ

***លំហាត់គំរូ*** **:** បើគេឱ្យល្បាយស្មើម៉ាសនៃបង់ស៊ីលអាល់កុលនិងផេណុល មានប្រតិកម្មជាមួយសូដ្យូម គេទទួលបានឌីអ៊ីដ្រូសែន 326mL នៅសីតុណ្ហភាព 27°C និងសម្ពាធ 1.5atm ។ ចូរគណនាម៉ាសផេណុលដែលមានក្នុងល្បាយ ។

***ចម្លើយ*** **:**

មាឌអ៊ីដ្រូសែន ដែលទទួលបាននៅលក្ខខណ្ឌធម្មតា

តាមទំនាក់ទំនង $\frac{PV}{T} = \frac{P_oV_o}{T_o}$

គេបាន $V_o = \frac{P}{P_o} \times \frac{T_o}{T} \times V$

$P = 1.5atm$ , $P_o = 1atm$ , $T_o = 273°K$ , $T = 27 + 273 = 300°K$

$V = 326mL = 0.326L$

$V_o = 0.326 \times \frac{1.5}{1} \times \frac{273}{300} = 0.445L$

ចំនួនម៉ូលឌីអ៊ីដ្រូសែន

$n = \frac{0.445}{22.4} = 0.02mol$

សមីការតាងប្រតិកម្មរវាងផេណុលនិងបង់ស៊ីលអាល់កុលជាមួយ Na

$$C_6H_5 - OH + Na \longrightarrow C_6H_5ONa + \frac{1}{2}H_2$$

xmol $\qquad\qquad\qquad\qquad\qquad \frac{x}{2}$mol

$$C_6H_5 - CH_2OH + Na \longrightarrow C_6H_5{-}CH_2ONa + \frac{1}{2}H_2$$

ymol $\qquad\qquad\qquad\qquad\qquad \frac{y}{2}$mol

ម៉ាសម៉ូល $M_{C_6H_5OH} = (12 \times 6) + 6 + 16 = 94g \cdot mol^{-1}$

ម៉ាសម៉ូល $M_{C_6H_5-CH_2OH} = (12 \times 7) + 8 + 16 = 108g \cdot mol^{-1}$

តាង x , y ជាចំនួនម៉ូលរៀងគ្នានៃផេណុលនិងបង់ស៊ីលអាល់កុល និង m ជាម៉ាសរបស់ $C_6H_5OH$ ឬ $C_6H_5CH_2OH$ ។

គេបានទំនាក់ទំនង :

ចំនួនម៉ូល $H_2$ កកើត $\frac{x}{2} + \frac{y}{2} = 0.02mol$

ឬ $x + y = 0.04mol$

ប៉ុន្តែ $x = \frac{m}{94}$ និង $y = \frac{m}{108}$

ដូច្នេះ $\frac{m}{94} + \frac{m}{108} = 0.04$

$108m + 94m = 0.04 \times 94 \times 108$ ឬ $202m = 406.08$

$$m = \frac{406.08}{202} = 2.01g$$

នៅក្នុងល្បាយមាន $C_6H_5OH = 2.01g$ ។

## 3. អាល់ដេអ៊ីតប្រហើរ

អាល់ដេអ៊ីតប្រហើរមានពីរប្រភេទ អាស្រ័យទៅតាមទីតាំងនៃបង្គុំនាទីអាល់ដេអ៊ីត (–CHO) ដែលភ្ជាប់ទៅអាតូមកាបូននៃណៃ្វយ៉ូបង់សែន ឬភ្ជាប់ទៅអាតូមកាបូននៃខ្សែចំហៀង :



បង់សាល់ដេអ៊ីត



ផេនីលអាសេតាល់ដេអ៊ីត

***បង់សាល់ដេអ៊ីត ឬអាល់ដេអ៊ីតបង់សូអ៊ិច :*** គឺជាអាល់ដេអ៊ីតប្រហើរ ដែលមានទម្រង់ងាយជាងគេនិងស្គាល់ច្រើនជាងគេ ។

## 3.1. ទង្វើ

ក្នុងឧស្សាហកម្ម គេធ្វើបង់សាល់ដេអ៊ីតតាមប្រតិកម្មក្លរកម្ម (ប្រតិកម្មជំនួស $Cl_2$ )ទៅលើតូលុយអែន ( $C_6H_5-CH_3$ ) ។ បន្ទាប់មកអង្គធាតុកកើតត្រូវរងអ៊ីដ្រូលីសក្លាយជាបង់សាល់ដេអ៊ីត :




តូលុយអែន　　　បង់សាល់ក្លរូ　　　បង់សាល់ដេអ៊ីត

## 3.2. លក្ខណៈរូប

បង់សាល់ដេអ៊ីត ជាអង្គធាតុរាវគ្មានពណ៌ មិនរលាយក្នុងទឹកទេ ។ វារលាយនៅ –17°C និងពុះនៅ 179°C ។

## 3.3. លក្ខណៈគីមី

វត្តមានបង្គុំនាទី (–CHO) បានធ្វើឱ្យសកម្មភាពជំនួសរបស់ណៃ្វយ៉ូថយចុះ ។ បង់សាល់ដេអ៊ីតមានប្រតិកម្មជំនួសពិបាកជាងបង់សែន ។ ឧទាហរណ៍ប្រតិកម្មជំនួសបង់សាល់ដេអ៊ីតជាមួយទឹកប្រូម :




បង់សាល់ដេអ៊ីត

m- ប្រូម៉ូបង់សាល់ដេអ៊ីត

បង់សាល់ដេអ៊ីត មានលក្ខណៈដូចអាល់ដេអ៊ីតខ្សែបើក គឺវាអាចរងអុកស៊ីតកម្មក្លាយជាអាស៊ីត ដោយអុកស៊ីតករ ដូចជា ប៉ូតាស្យូមប៊ីក្រូម៉ាតបន្ថែមអាស៊ីតស៊ុលផួរិច :



បង់សាល់ដេអ៊ីត អាស៊ីតបង់សូអ៊ិច

បង់សាល់ដេអ៊ីត មិនរងប្រតិកម្ម កុងដង់កម្ម ឬប៉ូលីមែកម្មទេ ។ ប៉ុន្តែវាអាចធ្វើរេដុកម្ម សូលុយស្យុង $AgNO_3$ ក្នុងទឹកអាម៉ូញ៉ាក់ (រ៉េអាក់ទីបតូឡង់) ប៉ុន្តែមិនមានប្រតិកម្មជាមួយទឹកផេលិញទេ ។

# 4. អាស៊ីតប្រហើរ

អាស៊ីតប្រហើរ ជាស្រឡាយអ៊ីដ្រូកាបួប្រហើរ ដែលអាតូមអ៊ីដ្រូសែនមួយ ឬច្រើនត្រូវបានជំនួសដោយក្រុម (–COOH) ។ អាស៊ីតប្រហើរសំខាន់ៗមាន :



អាស៊ីតបង់សូអ៊ិច



អាស៊ីតផ្តាលិច



អាស៊ីតតេរេផ្តាលិច

## 4.1. ទង្វើ

អាល់ដេអ៊ីតប្រហើរនិងបណ្តុំអាល់គីលដែលភ្ជាប់ទៅល្បែយ៉ូបង់សែនអាចទទួលអុកស៊ីតកម្មក្លាយជាបង្គុំកាបុកស៊ីល (–COOH) ដោយអុកស៊ីតករ ដូចជា $KMnO_4$ ឬ $K_2Cr_2O_7$ ។



អាល់ដេអ៊ីតបង់សូអ៊ិច អាស៊ីតបង់សូអ៊ិច



p- ក្លរ៉ូតូលុយអែន

អាស៊ីតតេរេផ្តាលិច ជាសមាសភាគមួយនៃប៉ូលីមែដាក្រុង។ ក្នុងឧស្សាហកម្ម អាស៊ីតតេរេផ្តាលិចត្រូវបានផលិតឡើងដោយធ្វើអុកស៊ីតកម្ម p- ស៊ីឡែន ដោយអុកស៊ីសែននៅសីតុណ្ហភាពខ្ពស់ ចំពោះមុខកាតាលីករកូបាល់ (Co) ។



p- ស៊ីឡែន                                        អាស៊ីតតេរេផ្តាលិច

ដាក្រុង (Dacron) គឺជាសរសៃសំយោគប៉ូលីអេស្ទែមួយ ដែលបានពីប្រតិកម្មនៃឌីមេទីលតេរេផ្តាឡាត ជាមួយអេតានឌីអុល (ឬគ្លីកុល) ។



ឌីមេទីលតេរេផ្តាឡាត    អេតានឌីអុល

អង្គធាតុកកើតនេះក៏ធ្វើប្រតិកម្មបន្តទៀតរហូតបង្កើតបានជាខ្សែប៉ូលីមែដ៏វែងហៅថា ដាក្រុង។



ដាក្រុង (ប៉ូលីមែ)

គេត្រូវបិតយកមេតាណុលចេញជាបណ្តើរៗពីមជ្ឈដ្ឋានប្រតិកម្ម។ សរសៃដែលផលិតចេញពីប៉ូលីអេស្ទែនេះ មានភាពយឺតពិសេសនិងស្រូបសំណើម ប៉ុន្តែលក្ខណៈរបស់វាមិនប្រែប្រួលទេ ទោះនៅក្នុងភាពសើមក៏ដូចជាភាពស្ងួត។

ប៉ូលីអេស្ទែនេះ អាចយកទៅធ្វើជាខ្សែម្យ៉ាងឈ្មោះមីឡា (Mylar) ដែលមានភាពជាប់មាំខ្លាំង ។

## មេរៀនសង្ខេប

សមាសធាតុប្រហើរសំខាន់ៗមាន :

- សមាសធាតុប្រហើរមានអាសូត ដែលបានមកពីការជំនួសបង្គុំ $-NO_2$ ឬបង្គុំ $-NH_2$ ទៅក្នុងបង់សែន ឬក្នុងសមាសធាតុប្រហើរ ។




នីត្រូបង់សែន




ទ្រីនីត្រូតូលុយអែន




អានីលីន

- សមាសធាតុប្រហើរអ៊ីដ្រុកស៊ី បានមកពីការជំនួសទៅអាតូមអ៊ីដ្រូសែននៃណ្វៃយ៉ូបង់សែន ឬ អាតូមអ៊ីដ្រូសែននៃខ្សែចំហៀងដោយ បង្គុំ $-OH$ ។







ក្រុមផេណុល







ក្រុមអាល់កុលប្រហើរ

- អាល់ដេអ៊ីតប្រហើរ មានពីរប្រភេទ គឺបង្គុំ $-CHO$ ភ្ជាប់ទៅអាតូមកាបូននៃណ្វៃយ៉ូបង់សែន ឬ ភ្ជាប់ទៅអាតូមកាបូននៃខ្សែចំហៀង ។







- អាស៊ីតប្រហើរ បានមកពីការជំនួសអាតូមអ៊ីដ្រូសែនមួយ ឬច្រើននៃណ្វៃយ៉ូបង់សែនដោយបង្គុំកាបុកស៊ីល ($-COOH$) ។









## សំណួរនិងលំហាត់

1. ផេណុលបង្ហាញលក្ខណៈជាអាស៊ីតមួយខ្សោយ ដែលមានលក្ខណៈខុសពីអាល់កុលអាលីផាទិច ។ តើដោយមូលហេតុអ្វី ?

2. ចូរបង្ហាញពីវិធីគីមី ដែលអាចសំគាល់គូសមាសធាតុដូចខាងក្រោម :

   ក. អេទីលអាល់កុលពីផេណុល ខ. អានីលីនពីបង់សែន ។

3. ចូរសរសេរទម្រង់ម៉ូលេគុលរបស់សមាសធាតុដូចតទៅ :

   ក. m – ក្លរ៉ូតូលុយអែន ខ. អាស៊ីត p – ប្រូម៉ូបង់សូអ៊ិច

   គ. 2,4 – ឌីក្លរ៉ូផេណុល ឃ. p – ប្រូម៉ូបង់សាល់ដេអ៊ីត

   ង. អាស៊ីត o – នីត្រូបង់សូអ៊ិច ច. ទ្រីផេនីលឡាមីន ។

4. ចូរឱ្យឈ្មោះសមាសធាតុដូចតទៅ :

   ក- 


   ខ- 


   គ- 


5. អង្គធាតុម្យ៉ាងមានរូបមន្ត 


   ចូរសរសេរសមីការតាងប្រតិកម្មរបស់សមាសធាតុនេះជាមួយ :

   ក. លោហៈសូដ្យូម ខ. ស៊ូតកាត់ ។

6. តើគេទទួលបានអានីលីនប៉ុន្មានក្រាម ពីនីត្រូបង់សែន 246g បើទិន្នផលប្រតិកម្មស្មើនិង 80 % ?

មេរៀនទី

# 4 កាបូនអ៊ីដ្រាតនិងលីពីត

**ចប់មេរៀននេះ សិស្សអាច**

- សរសេរបានពីទម្រង់កាបូនអ៊ីដ្រាតនិងពណ៌នាពីចំណែកថ្នាក់របស់វា ។
- រៀបរាប់ពីទម្រង់ម៉ូណូសាការីត ឌីសាការីត និងប៉ូលីសាការីត ។
- ពណ៌នាចំណែកថ្នាក់លីពីត លីពីតទោល និងលីពីតសាំញ៉ាំ ។

កាបូនអ៊ីដ្រាត ជាសមាសធាតុសរីរាង្គដែលមានច្រើនសន្ធឹកសន្ធាប់នៅក្នុងធម្មជាតិនិងមានមុខងារដ៏សំខាន់ក្នុងសកម្មភាពជីវិតរបស់សត្វនិងរុក្ខជាតិ ។

កាបូនអ៊ីដ្រាត ដែលគេស្គាល់ច្រើនជាងគេ គឺអាមីដុង ស្ករនិងសែលុយឡូស ។ អាមីដុងមាននៅក្នុងគ្រាប់ធម្មជាតិដូចជា ស្រូវ ពោត ក្នុងមើមដូចជា ដំឡូង. . . ។ រុក្ខជាតិមួយចំនួនដូចជា អំពៅ ផ្លែថាវស្ករ បានបង្កើតបរិមាណដ៏ច្រើនរបស់សាការ៉ូសឬស្ករស ។ សែលុយឡូសជាភ្នាសកោសិការុក្ខជាតិមាននៅក្នុងដើម ក្នុងសរសៃនិងជាលិការបស់ឈើ ។

## 1. កាបូនអ៊ីដ្រាត

គេអាចតាងរូបមន្តកាបូនអ៊ីដ្រាតដោយ $C_m(H_2O)_n$ គឺជាអ៊ីដ្រាតរបស់កាបូន ។ ក្រុមនេះមានបច្ច័យបទអូស ។ ***ឧទាហរណ៍*** គ្លុយកូស $C_6H_{12}O_6$ អាចសរសេរជា $C_6(H_2O)_6$ ។

កាបូនអ៊ីដ្រាតផ្សំដោយធាតុកាបូន អ៊ីដ្រូសែន និងអុកស៊ីសែន ។ នៅក្នុងកាបូនអ៊ីដ្រាត គេតែងជួបប្រទះបង្គុំនាទីអាល់កុល (–OH) អាល់ដេអ៊ីត $(-\underset{\underset{O}{\|}}{C}-H)$ និងសេតូន $(-\underset{\underset{O}{\|}}{C}-)$ ។

ដូច្នេះគេអាចឱ្យនិយមន័យកាបូនអ៊ីដ្រាតថា :

កាបូនអ៊ីដ្រាត គឺជាអង្គធាតុស្រឡាយប៉ូលីអ៊ីដ្រុកស៊ីអាល់ដេអ៊ីត ឬប៉ូលីអ៊ីដ្រុកស៊ីសេតូន ។

ស្ករដែលមានផ្ទុកបង្គុំនាទីអាល់ដេអ៊ីតហៅថា អាល់ដូស ។

ស្ករដែលមានផ្ទុកបង្គុំនាទីសេតូនវិញហៅថាសេតូស ។

## 2. ចំណែកថ្នាក់កាបូនអ៊ីដ្រាត

ជាញឹកញយគេធ្វើចំណែកថ្នាក់ កាបូនអ៊ីដ្រាតទៅតាមទម្រង់ខាងក្រោម :

តារាងទី 6.6 ចំណែកថ្នាក់កាបូនអ៊ីដ្រាតមួយចំនួន

| ម៉ូណូសាការីត | ឌីសាការីត | ប៉ូលីសាការីត |
|---|---|---|
| គ្លុយកូស | សាការ៉ូស | អាមីដុង |
| ហ្វ្រុចតូស | ឡាក់តូស | សែលុយឡូស |
| កាឡាក់តូស | ម៉ាល់តូស | គ្លីកូសែន |
| ម៉ាណូស | | ដិចទ្រីន |

### 2.1. ម៉ូណូសាការីត

កាបូនអ៊ីដ្រាតដែលមិនអាចរងអ៊ីដ្រូលីស ដើម្បីផ្តល់ជាកាបូនអ៊ីដ្រាតដែលតូចជាងហៅថា ម៉ូណូសាការីត ។

ម៉ូណូសាការីត ដែលគេស្គាល់ច្រើនជាងគេគឺ អិចសូស ដែលបង្កដោយអាតូមកាបូនចំនួន 6 ។ ក្រៅពីនេះ មានម៉ូណូសាការីតដែលបង្កដោយ :

អាតូមកាបូន 4 ហៅថា តេត្រូស

អាតូមកាបូន 5 ហៅថា ប៉ង់តូស

អាតូមកាបូន 7 ហៅថា អិបតូស

ខាងក្រោមនេះជាទម្រង់ម៉ូណូសាការីតមួយចំនួន :



តេត្រូស ប៉ង់តូស អិចសូស — អាល់ដូស (មានផ្នុកបង្គុំនាទីអាល់ដេអ៊ីត)

តេត្រូស ប៉ង់តូស អិចសូស — សេតូស (មានផ្នុកបង្គុំនាទីសេតូន)

គេបានស្គាល់ម៉ូណូសាការីតប្រមាណ 70 ដែលក្នុងនោះមាន 20 ជាស្ករទោល មាននៅក្នុងធម្មជាតិ ។ ស្ករទាំងនេះរលាយក្នុងទឹកដែលមានលក្ខណៈខុសពីសមាសធាតុសរីរាង្គផ្សេងៗទៀត ។ លក្ខណៈនេះបានមកដោយសារបង្គុំ (–OH) ក្នុងម៉ូលេគុលស្ករ បង្កើតសម្ព័ន្ធអ៊ីដ្រូសែនជាមួយម៉ូលេគុលទឹក ។

អាល់ដូសអិចសូសគឺជាម៉ូណូសាការីតដែលមានអាតូមកាបូន 6 និងមានបង្គុំនាទីអាល់ដេអ៊ីតមួយ ។ វាមានកាបូនអស៊ីមេទ្រីចំនួន 4 ដែលនាំឱ្យវាមានអ៊ីសូមែអុបទិចចំនួន 16 ។ យើងសិក្សា D– គ្លុយកូសគឺជាអ៊ីសូមែមួយដែលមានសារៈសំខាន់ជាងគេ ។

## ក. គ្លុយកូស

គេអាចតាងម៉ូលេគុល D– គ្លុយកូសដោយទម្រង់ខាងក្រោម :




(I)

D– គ្លុយកូស

(ទម្រង់ជាខ្សែត្រង់)




(II)

α–D– គ្លុយកូស

(បង្គុំ –OH នៃ C លេខ 1 និង 4 ស្ថិតក្នុងទម្រង់ Z )




(III)

β–D– គ្លុយកូស

(បង្គុំ –OH នៃ C លេខ 1 និង 4 ស្ថិតក្នុងទម្រង់ E )

គ្លុយកូសជាសារធាតុគ្រាម ងាយរលាយក្នុងទឹក មានរសផ្អែម (ពាក្យក្រិក " គ្លុយកូស " មានន័យថាផ្អែម) ។ វាមានច្រើនសន្ធិកសន្ធាប់នៅក្នុងពិភពមានជីវិត ។ គ្លុយកូសមាននៅស្ទើរតែក្នុងគ្រប់សរីរាង្គរុក្ខជាតិ : ក្នុងផ្លែ មើម ស្លឹក ផ្កា ។ បរិមាណដ៏ច្រើនជាងគេរបស់គ្លុយកូសមាននៅក្នុងទឹកដមផ្លែឈើទុំ ។ នៅក្នុងឈាមមនុស្សមានគ្លុយកូសប្រមាណ 0.1 % វាជាប្រភពថាមពលនៃថាមពលរបស់កោសិកា។

### លក្ខណៈគីមី

តាមសមាសភាពរបស់វា គ្លុយកូសមាននាទីគីមីពីរ គឺជាអាល់ដេអ៊ីតនិងជាអាល់កុល ។

- វត្តមាននៃបង្គុំនាទីអាល់កុល (–OH) ធ្វើឱ្យគ្លុយកូសរងប្រតិកម្មអេស្ទែកម្ម ។
- វត្តមាននៃបង្គុំនាទីអាល់ដេអ៊ីត (–CHO) ធ្វើឱ្យគ្លុយកូសរងអុកស៊ីតកម្មដោយទឹកផេលិញ ($Cu^{2+}$ ) ឬធាតុបន្ទាល់តូឡង់(សូលុយស្យុង $AgNO_3$ ក្នុងទឹកអាម៉ូញ៉ាក់)ក្លាយជាអាស៊ីតបាន ។

សមីការតាងប្រតិកម្មអុកស៊ីតកម្មគ្លុយកូសដោយទឹកផេលិញ :

$$\begin{array}{l}CHO\\ |\\ (CHOH)_4\\ |\\ CH_2OH\end{array} + 2Cu^{2+} + 4OH^- \longrightarrow \underset{\text{កករក្រហម (ពណ៌ឥដ្ឋ)}}{Cu_2O} + \underset{\text{អាស៊ីតគ្លុយកូនិច}}{\begin{array}{l}COOH\\ |\\ (CHOH)_4\\ |\\ CH_2OH\end{array}} + 2H_2O$$

គេប្រើទឹកផេលិញសម្រាប់រកអត្តសញ្ញាណគ្លុយកូស ដែលមាននៅក្នុងទឹកនោម ។

- បង្គុំនាទីអាល់ដេអ៊ីតរបស់គ្លុយកូសអាចរងរេដុកម្ម ដោយប្រតិករផ្សេងៗដូចជា $H_2$ (ដោយមានកាតាលីករ) ឬសូដ្យូមបូរ៉ូអ៊ីដ្រួ ($NaBH_4$) ដើម្បីក្លាយជាប៉ូលីអាល់កុលដែលមានបង្គុំ –OH ចំនួន6 ។

$$CH_2OH(CHOH)_4-CHO \xrightarrow[\text{ឬ } NaBH_4]{H_2 \text{ កាតាលីករ}} \underset{\text{D– គ្លុយស៊ីតុល ឬស៊របីតុល}}{CH_2OH-(CHOH)_4-CH_2OH}$$

- លក្ខណៈគីមីសំខាន់នៃគ្លុយកូស គឺល្បើងរបស់វាក្រោមអំពើនៃកាតាលីករសរីរាង្គ (អង់ស៊ីម) ។ ល្បើងនេះសាំញ៉ាំណាស់ ដែលគេតាងវាដោយសមីការ :

$$\underset{\text{គ្លុយកូស}}{C_{12}H_{12}O_6} \xrightarrow{\text{អង់ស៊ីម}} \underset{\text{អេទីលអាល់កុល}}{2C_2H_5OH} + 2CO_2$$

## ទង្វើនិងបម្រើបម្រាស់

គ្លុយកូសជាផលិតផលអាហារមួយដ៏មានតម្លៃ ។ អុកស៊ីតកម្មវាក្នុងសារពាង្គកាយផ្តល់នូវថាមពលចាំបាច់សម្រាប់ការហ៊ឹកហ្វឺនសាច់ដុំ ។

គេអាចតាងលំនាំនេះដោយ : $C_6H_{12}O_6 + 6O_2 \longrightarrow 6CO_2 + 6H_2O$

គេប្រើគ្លុយកូសសម្រាប់ធ្វើជាឱសថប៉ូវកម្លាំងសម្រាប់អ្នកជម្ងឺដែលខ្សោយ ជាសណ្ឋានឱសថគ្រាប់ ឬចាក់តាមសរសៃ ។ ក្នុងឧស្សាហកម្មគេធ្វើគ្លុយកូសចេញពីអាមីដុង ។

ខ. ព្រុចតូស $\underset{\text{រូបមន្តព្រុចតូស}}{CH_2OH-CHOH-CHOH-CHOH-\underset{\underset{O}{\|}}{C}-CH_2OH}$

ព្រុចតូស គឺជាម៉ូណូសាការីតដែលមានរូបមន្ត $C_6H_{12}O_6$ តែវាជា សេតូសអិចសូស : វាមានបង្គុំ –OH ចំនួនប្រាំនិងបង្គុំកាបូនីល ( $-\underset{\underset{O}{\|}}{C}-$ ) ចំនួនមួយ ។

ព្រុចតូសមានរសផ្អែមជាងគ្លុយកូសនិងស្ករស ។ វាមាននៅក្នុងផ្លែឈើប្រភេទខ្លះនិងមាននៅក្នុងទឹកឃ្មុំ ។

## 2.2. ឌីសាការីត

ឌីសាការរីត ជាលទ្ធផលនៃបន្សំរវាងអិចសូសពីរដោយមានការដកចេញនូវម៉ូលេគុលទឹកមួយ ។ វាមានរូបមន្តទូទៅ $C_{12}H_{12}O_{11}$ ។

ឌីសាការរីតសំខាន់ៗមាន : សាការរ៉ូស ឡាក់តូស ម៉ាល់តូស និងសែឡូប៊ីយ៉ូស ។

### ក. សាការរ៉ូស

ជាឌីសាការរីតដែលមានសារៈសំខាន់ជាងគេក្នុងពាណិជ្ជកម្ម ។ វាជាស្ករដែលយើងប្រើរាល់ថ្ងៃ ។ វាជាគ្រាមពណ៌ស រសផ្អែម ងាយរលាយក្នុងទឹក ។ សាការរ៉ូសមាននៅក្នុងរុក្ខជាតិជាច្រើន ដូចជាមើមការ៉ុតទឹកត្នោត ទឹកអំពៅ មើមនៃថាវស្ករ ។ ក្នុងឧស្សាហកម្ម គេផលិតវាចេញពីអំពៅ ឬនៃថាវស្ករ ។




ម៉ូលេគុលសាការរ៉ូសបានមកពីការភ្ជាប់រវាងម៉ូលេគុលគ្លុយកូសនិងព្រុចតូស ដោយមានការដកចេញនូវអាតូមខ្លះក្នុងម៉ូលេគុលទាំងពីរ ។

ទម្រង់ម៉ូលេគុលសាការរ៉ូស

**លក្ខណៈគីមី**

- សាការរ៉ូសមិនមានប្រតិកម្មជាមួយធាតុបន្ទាល់តូឡង់និងទឹកផេលិញទេ នេះបញ្ជាក់ថា សាការរ៉ូសមិនមានវត្តមានបង្គុំនាទីអាល់ដេអ៊ីតទេ ។
- សាការរ៉ូសអាចរងអ៊ីដ្រូលីស ដោយអាស៊ីត ឬដោយអង់ស៊ីមសាការរ៉ាសឱ្យផលជាគ្លុយកូសនិងព្រុចតូស ។

### ខ. ឡាក់តូស




D – កាឡាក់តូស

ជាស្ករដែលគេរកឃើញនៅក្នុងខ្លួនមនុស្សនិងក្នុងទឹកដោះសត្វគោ។វាត្រូវបានសំយោគចេញពីគ្លុយកូសដែលមាននៅក្នុងឈាម ដោយក្រពេញដោះរបស់សត្វ ។ ក្នុងពាណិជ្ជកម្មគេទទួលបានឡាក់តូសពីទឹកដោះ ។

ឡាក់តូសអាចរងអ៊ីដ្រូលីសដោយអង់ស៊ីមឡាក់តាស ឬដោយអាស៊ីតបង្កើតបានជាគ្លុយកូសនិងកាឡាក់តូស ។

ឡាក់តូស $\xrightarrow{\text{អ៊ីដ្រូលីស}}$ គ្លុយកូស + កាឡាក់តូស

### គ. ម៉ាល់តូស

គេទទួលបានម៉ាល់តូស នៅពេលអាមីដុងរងអ៊ីដ្រូលីសដោយភាគ ។ ម៉ូលេគុលម៉ាល់តូសបានមកពីការភ្ជាប់រវាងម៉ូលេគុលគ្លុយកូសពីរ ។

ម៉ាល់តូសអាចរងអុកស៊ីតកម្មដោយទឹកផេលីញបាន ។

### ឃ. សែឡូប៊ីយ៉ូស

ជាឌីសាការីត ដែលទទួលបាននៅពេលដែលសែលុយឡូសរងអ៊ីដ្រូលីសដោយភាគ ។ វាគឺជាអ៊ីសូមែមួយនៃម៉ាល់តូស ។

## 2.3. ប៉ូលីសាការីត

ប៉ូលីសាការីត ជាកាបូនអ៊ីដ្រាតដែលមានម៉ាសម៉ូលធំសម្បើម ។ វាមានរូបមន្តទូទៅ $(C_6H_{10}O_5)_n$ ។ វាមិនមានរសផ្អែមនិងជាទូទៅមិនរលាយក្នុងទឹកទេ ។

ប៉ូលីសាការីត រងអ៊ីដ្រូលីសសព្វ ផ្តល់ជាម៉ូណូសាការីត ។ ប៉ូលីសាការីតសំខាន់ៗមាន : អាមីដុង គ្លីកូសែន ឌិចទ្រីន និងសែលុយឡូស ។

### ក. អាមីដុង

ជាប៉ូលីសាការីតដែលមានសារៈសំខាន់ជាងគេ ។ អាមីដុងជាម្សៅពណ៌ស មិនរលាយក្នុងទឹក កាលណាគេដាក់វាក្នុងទឹកក្តៅអាមីដុងរីកហើយស្អិត (បាយម៉ានអាមីដុង) ។

អាមីដុង ជាទម្រង់ស្តុកទុកកាបូនអ៊ីដ្រាតនៅក្នុងរុក្ខជាតិ ។ កោសិកាស្លឹករុក្ខជាតិស្រូបយកឧស្ម័នកាបូនឌីអុកស៊ីត ($CO_2$) ពីក្នុងខ្យល់ ទឹកពីក្នុងដីនិងដោយសារថាមពលព្រះអាទិត្យដែលស្រូបដោយក្លរ៉ូភីល(ជាតិពណ៌បៃតង) បង្កើតបានជាអាមីដុង តាមសមីការ :

$$6nCO_2 + 5nH_2O + \text{ថាមពលព្រះអាទិត្យ} \longrightarrow (C_6H_{10}O_5)_n + 6nO_2$$

អាមីដុង

អាមីដុងច្រើនផ្ដុំនៅក្នុងមើមនិងក្នុងគ្រាប់ដូចជា ក្នុងដំឡូងបារាំងមាន 20 % ក្នុងគ្រាប់ពោត ឬក្នុងគ្រាប់ស្រូវសាលីមាន 70 % និងក្នុងគ្រាប់ស្រូវមាន 80 % ។

អាមីដុងជាប៉ូលីមែធម្មជាតិ $(C_6H_{10}O_5)_n$ ។ អាមីដុងក៏ដូចជាប៉ូលីមែផ្សេងៗទៀតដែរ ម៉ូលេគុលវាមានប្រវែងមិនស្មើគ្នាទេ គឺចំនួន n របស់វាខុសៗគ្នា។ អាមីដុងបង្កដោយប៉ូលីសាការីតពីរប្រភេទ គឺ អាមីឡូសនិងអាមីឡូសប៉ិចទីន ។




អាមីឡូស

(ទម្រង់ជាខ្សែត្រង់)




អាមីឡូសប៉ិចទីន

(ទម្រង់ខ្សែបែកខ្នែង)

## លក្ខណៈគីមី

- អាមីដុងមិនរងអុកស៊ីតកម្មដោយទឹកផេលិញទេ ។
- អាមីដុងរងអ៊ីដ្រូលីសសព្វ ឱ្យផលជាគ្លុយកូស ។
- អាមីដុងបង្កើតជាអង្គធាតុពណ៌ខៀវជាមួយអ៊ីយ៉ូត ។ គេប្រើប្រតិកម្មនេះសម្រាប់រកអត្តសញ្ញាណអាមីដុង ។

## ខ. គ្លីកូសែន

គឺជាទម្រង់ស្តុកទុកនៃកាបូនអ៊ីដ្រាតនៅក្នុងខ្លួនសត្វ ។ ជួនកាលគេហៅវាថា ជាអាមីដុងសត្វ ។ គេជួបប្រទះវានៅក្នុងថ្លើមនិងជាលិកាសាច់ដុំ ។ វារលាយក្នុងទឹកនិងបង្កើតបានជាពណ៌ក្រហមស្វាយ (red-purple) ជាមួយអ៊ីយ៉ូត ។

## គ. ដិចទ្រីន

គេជួបប្រទះដិចទ្រីននៅក្នុងពន្លកគ្រាប់ ប៉ុន្តែជាទូទៅគេទទួលបានវាតាមអ៊ីដ្រូលីសដោយភាគនៃអាមីដុង ។ វារលាយក្នុងទឹក ។ បរិមាណដ៏ច្រើននៃដិចទ្រីន ត្រូវបានប្រើក្នុងឧស្សាហកម្មផលិតការ ។

## ឃ. សែលុយឡូស

ជាអង្គធាតុសរីរាង្គ ដែលសម្បូណ៌ហូរហៀរនៅក្នុងធម្មជាតិ ។ វាចូលក្នុងសមាសភាពនៃគ្រប់រុក្ខជាតិ ។ កប្បាសមានសែលុយឡូសប្រមាណ 90 % ឯឈើមានប្រមាណ 50 % ។ ប៉ុន្តែសំបកផ្លែឈើនិងសំបកគ្រាប់រុក្ខជាតិគឺជាសែលុយឡូសសុទ្ធ ។ សែលុយឡូសដែលយកចេញពីសារធាតុធម្មជាតិ ជាសារធាតុរឹង មិនរលាយក្នុងទឹកនិងក្នុងអង្គធាតុរំលាយសរីរាង្គធម្មតា ។

សែលុយឡូសបង្កឡើងដោយប៉ូលីមែនៃ β– គ្លុយកូស ជាខ្សែត្រង់ប្រហាក់ប្រហែលនិងអាមីឡូសដែរ ។ វាមានរូបមន្ត $(C_6H_{10}O_5)_n$ ។



**ទម្រង់សែលុយឡូស**

ជាទូទៅ កម្រិតប៉ូលីមែកម្ម n របស់សែលុយឡូសធំជាងអាមីដុង ។ ដោយសែលុយឡូសមានទម្រង់ជាខ្សែទោល ដូច្នេះហើយបានជាវាមានលក្ខណៈជាសរសៃៗ ដូចជាកប្បាស ក្រចៅ . . . ដែលគេអាចយកទៅត្បាញជាសំពត់បាន ។

ដូចអាមីដុងដែរ សែលុយឡូសរងអ៊ីដ្រូលីសជាដំណាក់ៗបង្កើតបានជាគ្លុយកូស :

$$(C_6H_{10}O_5)_n + nH_2O \longrightarrow nC_6H_{12}O_6$$

បើគេឱ្យកប្បាសដែលស្ទើរតែជាសែលុយឡូសសុទ្ធមានអំពើជាមួយសូលុយស្យុងស៊ុលនិទ្រិច ហើយរងនូវប្រព្រឹត្តិកម្មជាបន្តបន្ទាប់ គេនិងទទួលបាននីត្រូសែលុយឡូស ដែលជាអេស្ទែមួយមានសារៈសំខាន់ក្នុងពាណិជ្ជកម្ម ។ នីត្រូសែលុយឡូសមួយប្រភេទដែលមានអាសូត 13 % ត្រូវបានគេប្រើនៅក្នុងការផលិតគ្រឿងផ្ទុះ ។

# 3. លីពីត

នៅក្នុងការសិក្សាពីគីមីសរីរាង្គ គេតែងធ្វើចំណែកថ្នាក់អង្គធាតុទៅតាមបង្គុំនាទីរបស់វា ។ ប៉ុន្តែចំពោះលីពីតវិញ គេធ្វើចំណែកថ្នាក់តាមភាពរលាយក្នុងទឹករបស់វា ។

លីពីត ជាសារធាតុដែលគេជួបប្រទះនៅក្នុងភាវៈរស់ ដែលមិនរលាយក្នុងទឹក ប៉ុន្តែរលាយក្នុងអង្គធាតុរំលាយសរីរាង្គ ។

លីពីត ជាសារធាតុដែលគេអាចទាញចេញពីកោសិកានិងជាលិកា ដោយប្រើធាតុរំលាយសរីរាង្គមិនប៉ូលែ ។

លីពីតរួមមានប្រភេទអង្គធាតុជាច្រើន ដែលមានផ្ទុកបង្គុំនាទីផ្សេងៗច្រើនបែបយ៉ាង ។

ដើម្បីសម្រួលដល់ការសិក្សា គេចែកលីពីតជាពីរក្រុមគឺ : លីពីតសាំញ៉ាំនិងលីពីតទោល ។

## 3.1. លីពីតសាំញ៉ាំ (Complex Lipids)

ជាលីពីតដែលរងអ៊ីដ្រូលីសផ្តល់ជាសារធាតុបង្ក ។ លីពីតសាំញ៉ាំភាគច្រើនជាអេស្ទែ ដែលមានខ្សែកាបូនវែងនៃអាស៊ីតកាបុកស៊ីលិចហៅថា អាស៊ីតខ្លាញ់ ។ អាស៊ីតខ្លាញ់បង្កើតអេស្ទែពីរក្រុមគឺ : ទ្រីគ្លីសេរីតនិងក្រមួន ។

ក. ក្រមួន (Waxes)

ជាអេស្ទែដែលកើតឡើងពីអាល់កុលដែលមានខ្សែកាបូនវែងជាមួយនឹងអាស៊ីតខ្លាញ់ ។ វាកើតមានក្នុងធម្មជាតិនិងមាននាទីងារប្លែកៗគ្នាទៅតាមប្រភេទរុក្ខជាតិនិងសត្វ ។ ដូចជាស្ពែម៉ាតេស៊ី ដែលរកឃើញនៅក្នុងក្បាលរបស់ស្ពែមត្រីបាឡែន វាហាក់ដូចជាមាននាទីងារជាអ្នកតម្រូវការហែលបណ្តែតខ្លួនឬការមុជទៅក្នុងជម្រៅទឹករបស់ត្រីបាឡែន ។

$$CH_3\cdot(CH_2)_{29}-O-\underset{\underset{O}{\|}}{C}-(CH_2)_{14}CH_3$$

សេរីត
(ភាគផ្សំមួយនៅក្នុងនៃក្រមួនឃ្មុំ)

$$CH_3-(CH_2)_{14}-\underset{\underset{O}{\|}}{C}-O-(CH_2)_{15}-CH_3$$

ស្ពែម៉ាតេស៊ី

$$CH_3-(CH_2)_{26}-\underset{\underset{O}{\|}}{C}-O-(CH_2)_{33}-CH_3$$

ភាគផ្សំមួយនៃក្រមួនកាណូបា

*សេរីត* ត្រូវបានប្រើដោយឃ្មុំដើម្បីធ្វើសំបុក ។

រុក្ខជាតិ កាណូបា បញ្ចេញក្រមួនម្យ៉ាងឈ្មោះកាណូបា ដែលពាសពីលើស្លឹក មាននាទីងារការពាររំហួតទឹកចេញពីស្លឹក ។

***សំគាល់*** **:** ខ្លាញ់គោ (ក្រមួនប៉ារ៉ាភីន) ដែលគេប្រើសម្រាប់លាបគ្រឿងខ្មៅខ្នងម៉ាស៊ីន មិនមែនជាក្រមួនពិតប្រាកដទេ វាគឺជាល្បាយនៃអាល់កានដែលមានម៉ាសម៉ូលច្រើន ។

ជាយូរមកហើយ ដែលគេប្រើក្រមួនធម្មជាតិសម្រាប់ធ្វើគ្រឿងសំអាង ការ វ៉ែរនីនិងរូបធាតុមិនជ្រាបទឹក ។ សព្វថ្ងៃរូបធាតុសំយោគជាច្រើនបានចូលទៅជំនួសផលិតផលធម្មជាតិ ។

## ១. ទ្រីគ្លីសេរីត

ជាអេស្ទែនៃអាស៊ីតខ្លាញ់និងគ្លីសេរ៉ុល ដែលក្នុងនោះបង្គុំ –OH ទាំងបីរបស់គ្លីសេរ៉ុលត្រូវរងអេស្ទែកម្មដោយអាស៊ីតខ្លាញ់ដូចជា :



**ទ្រីស្តេអារីន**

(ចំណុចរលាយ 72°C )



**ទ្រីអូលេអ៊ីន**

(ចំណុចរលាយ –4°C )

គេនិយមហៅទ្រីគ្លីសេរីតថាជាខ្លាញ់កាលណាវារឹងនិងជាប្រេងកាលណាវាជាអង្គធាតុរាវនៅសីតុណ្ហភាពបន្ទប់ ។ ទ្រីគ្លីសេរីតភាគច្រើនមានដើមកំណើតមកពីថនិកសត្វ ជាខ្លាញ់ ឧទាហរណ៍ខ្លាញ់ជ្រូក ។ ខ្លាញ់ទាំងនេះរឹងនៅសីតុណ្ហភាពបន្ទប់ ។ កំដៅខ្លួនរបស់សត្វ បានធ្វើឱ្យខ្លាញ់ស្ថិតក្រោមសណ្ឋានជាសន្ទនីយដែលទាក់ទងនៅនិងចលនារបស់រាងកាយ ។ នៅក្នុងរុក្ខជាតិនិងសត្វដែលមានឈាមត្រជាក់ជាទូទៅទ្រីគ្លីសេរីត ស្ថិតក្នុងភាពរាវដូចជា ប្រេងពោត ប្រេងដូង ប្រេងត្រី ។ ត្រីត្រូវការប្រេងក្នុងភាពរាវជាងរឹង ដោយវាពិបាកធ្វើចលនាជាមួយទ្រីគ្លីសេរីតរឹងនៅក្នុងទឹកត្រជាក់ ។

ភាគច្រើននៃទ្រីគ្លីសេរីតឆ្អែតជាខ្លាញ់និងជាប្រេងកាលណាវាជាទ្រីគ្លីសេរីតមិនឆ្អែត ។ ខ្លាញ់និងប្រេងដែលកើតមានក្នុងធម្មជាតិ គឺជាល្បាយចម្រុះនៃទ្រីគ្លីសេរីត ដែលផ្ទុកដោយអាស៊ីតខ្លាញ់ឆ្អែតនិងមិនឆ្អែត ។

តារាងទី 6.7 សមាសភាពភាគរយនៃអាស៊ីតខ្លាញ់ចំនួនប្រាំពីរនៅក្នុងទ្រីគ្លីសេរីតមួយចំនួន

| ប្រភេទ | អាស៊ីតខ្លាញ់ឆ្អែត | | | | អាស៊ីតខ្លាញ់មិនឆ្អែត | | |
|---|---|---|---|---|---|---|---|
| | ឡូរិច | មីរីស្ទិច | ប៉ាល់មីទិច | ស្តេអារិច | អូលេអ៊ិច | លីណូលេអ៊ិច | លីណូលេនិច |
| ខ្លាញ់គោ | 0 | 6 | 27 | 14 | 49 | 2 | 0 |
| ខ្លាញ់ជ្រូក | 0 | 1 | 24 | 9 | 47 | 10 | 0 |
| ខ្លាញ់មនុស្ស | 1 | 3 | 27 | 8 | 48 | 10 | 0 |
| ប្រេងពោត | 0 | 1 | 10 | 3 | 50 | 34 | 0 |
| ប្រេងអូលីវ | 0 | 0.1 | 7 | 2 | 84 | 5 | 0 |
| ប្រេងសណ្តែក | 0.2 | 0.1 | 10 | 2 | 29 | 51 | 7 |

ទ្រីគ្លីសេរីតប្រភេទខ្លះ មានអាស៊ីតផូស្វរិច ។ ទ្រីគ្លីសេរីតប្រភេទនេះហៅថា ផូស្វរគ្លីសេរីត ។ ផូស្វរគ្លីសេរីតដែលងាយជាងគេគឺ **អាស៊ីតផូស្វាទីឌិច** ដែលអាចបំបែកជាប្រូតុង $H^+$ បានក្នុងមជ្ឈដ្ឋានឈាម :



អាស៊ីតផូស្វាទីឌិច — ទម្រង់អ៊ីយ៉ុង

## គ. ផូស្វរលីពីត

ជាលីពីតដែលមានផ្ទុកស្រឡាយនៃអាស៊ីតផូស្វរិច ។ ផូស្វរលីពីតជាច្រើនបានមកដោយអាល់កុលធ្វើអេស្តែកម្មលើបង្គុំ -OH របស់អាស៊ីតផូស្វរិច ដូចជាករណីសេផាលីន (ដែលបង្គុំ-OH អេស្តែកម្មជាមួយអេតាណូឡាមីន)និងលេស៊ីទីន (ដែលបង្គុំ -OH អេស្តែកម្មជាមួយកូលីន) ។ សេផាលីននិងលេស៊ីទីនមានជាទូទៅនៅក្នុងកោសិកាសត្វនិងរុក្ខជាតិ ។

***ឧទាហរណ៍*** ផូស្វូលីពីត

$HO-CH_2-CH_2-NH_2$
អេតាណូឡាមីន

$HO-CH_2-CH_2-N^+(CH_3)_3$
កូលីន




សេផាលីន




លេស៊ីទីន

## 3.2. លីពីតទោល (Simple lipids)

លីពីតដែលពិបាករងអ៊ីដ្រូលីស ដោយសូលុយស្យុងអាស៊ីត ឬបាសហៅថា លីពីតទោល ។

លីពីតទោលមានបីក្រុមសំខាន់គឺ : ស្តេរ៉ូអ៊ីត   ប្រូស្តាក្លង់ឌីននិងទែរពីន ។

### ក. ស្តេរ៉ូអ៊ីត

គឺជាកុំផ្លិចពហុវង់ (ប៉ូលីស៊ីគ្លិច) ដែលគេជួបប្រទះនៅក្នុងរុក្ខជាតិនិងសត្វ ។ វាមានទម្រង់គ្រឹះជាវង់បួន (តេត្រាស៊ីគ្លិច) ។




គ្រោងអ៊ីដ្រូកាបួររបស់ស្តេរ៉ូអ៊ីត




ទម្រង់របស់កូលេស្តេរ៉ុល
(ជាស្តេរ៉ូអ៊ីតមួយ)

ស្តេរ៉ូអ៊ីត ជាលីពីតទោលដែលមិនរងអ៊ីដ្រូលីសដូចជាខ្លាញ់ ប្រេង ឬក្រមួនទេ ។

ស្តេរ៉ូអ៊ីតមានមុខងារច្រើនយ៉ាង ប៉ុន្តែមុខងារដែលមានសារៈសំខាន់ជាងគេ គឺស្តេរ៉ូអ៊ីតដែលមានមុខងារជាអរម៉ូនដូចជា អង់ដ្រូស្តេរ៉ូនដែលជាអរម៉ូនភេទប្រុស តេស្តូស្តេរ៉ូនជាអរម៉ូនដែលកំណត់លក្ខណៈភេទប្រុស អេស្ត្រាឌីអុលជាអរមូនដែលកំណត់លក្ខណៈភេទស្ត្រី ។




អង់ដ្រូស្តេរ៉ូន




តេស្តូស្តេរ៉ូន




អេស្ត្រាឌីអុល

នៅពេលដែលស្តេរ៉ូអ៊ីតទើបតែអាចញែកយកចេញបានពីសារពាង្គកាយគេយល់ថា មនុស្សមិនអាចសំយោគចេញជាស្តេរ៉ូអ៊ីតឡើយ ។ ម្ភៃឆ្នាំក្រោយមកគេបានសំយោគចេញនូវស្តេរ៉ូអ៊ីតជាច្រើនដែលស្តេរ៉ូអ៊ីតសំយោគទាំងនេះខ្លាំងជាងស្តេរ៉ូអ៊ីតធម្មជាតិរាប់រយពាន់ដង ។

## ១. ប្រូស្តាក្លង់ឌីន (Prostaglandins)

ប្រូស្តាក្លង់ឌីន ជាអង្គធាតុស្រឡាយនៃអាស៊ីតខ្លាញ់ ដែលជាអរម៉ូនមានអនុភាពជាងស្តេរ៉ូអ៊ីត ។ គេឱ្យឈ្មោះថា ប្រូស្តាក្លង់ឌីន ដោយសារគេញែកយកវាបានជាលើកដំបូងចេញពីអង្គធាតុរាវដែលបញ្ចេញដោយក្រពេញប្រូស្តាត (ក្រពេញនៅក្រោមប្លោកនោម) ។ ក្រោយមកគេបានរកឃើញវត្តមានវានៅគ្រប់ជាលិកានិងសន្ទនីយរបស់សារពាង្គកាយមនុស្ស ។

ប្រូស្តាក្លង់ឌីន មានអនុភាពលើប្រព័ន្ធជាច្រើនក្នុងសារពាង្គកាយដូចជា ប្រព័ន្ធប្រសាទ ប្រព័ន្ធបន្តពូជ . . . ។ វាជាអ្នករក្សាលំនឹងកត្តាជាច្រើនដូចជា សម្ពាធឈាម កំណកឈាម សកម្មភាពប្រព័ន្ធរំលាយអាហារ . . . ។

ជាទូទៅ ប្រូស្តាក្លង់ឌីនមានទម្រង់ជាខ្សែបិទប្រាំជ្រុងនិងមានខ្សែចំហៀងពីរដ៏វែង ដែលខ្សែមួយបញ្ចប់ដោយអាស៊ីតកាបុកស៊ីលិច ។

ភាគច្រើននៃប្រូស្តាក្លង់ឌីន មានអាតូមកាបូនចំនួន 20 ដែលមានរបៀបបង់លេខដូចខាងក្រោម ៖




ទម្រង់គ្រឹះនៃប្រូស្តាក្លង់ឌីន

គ. ទែរពីន (Terpenes)

ល្បាយនៃសារធាតុដែលមានក្លិនក្រអូប របស់រុក្ខជាតិហៅថា ប្រេងពិសេស (Essential oils) ។ ផ្នែកបង្កមួយនៃប្រេងពិសេសដែលឆាប់ហើរ ត្រូវនឹងក្រុមសារធាតុគីមីមួយគឺ ទែរពីន ។ ឧទាហរណ៍ មីរស៊ីន (Myrcene) ជាអ៊ីដ្រូកាបួដែលគេទាញចេញពីប្រេង bayberry គឺជាទែរពីនម្យ៉ាងសម្រាប់ផលិតទឹកអប់ ៖

$$(CH_3)_2C = CH-CH_2-CH_2-\underset{\underset{CH_2}{\|}}{C}-C = CH_2$$ ឬ




ទម្រង់ម៉ូលេគុលរបស់ Myrcene

ទម្រង់គ្រឹះដែលធ្វើឱ្យគេញែកសំគាល់ទែរពីន ពីផលិតផលធម្មជាតិផ្សេងទៀត គឺផ្នែកអ៊ីសូប្រែន ( $CH_2 = \underset{\underset{CH_3}{|}}{C}-CH = CH_2$ ឬ  ) ។ ក្រុមទែរពីនបង្កដោយផ្នែកអ៊ីសូប្រែនជាច្រើន ដូចជា Myrcene បង្កដោយផ្នែកអ៊ីសូប្រែនពីរផ្សំគ្នា ។ ចំនួនអាតូមកាបូនក្នុងទែរពីនជាពហុគុណនៃប្រាំ (10 , 15 , 20... ) ។

## មេរៀនសង្ខេប

- កាបូនអ៊ីដ្រាត ជាអង្គធាតុសរីរាង្គមានរូបមន្ត $C_m(H_2O)_n$ ដែលនៅក្នុងម៉ូលេគុលវាមានបង្គុំនាទីអាល់កុល (-OH) និងបង្គុំនាទីអាល់ដេអ៊ីត ឬបង្គុំនាទីអាល់កុលនិងបង្គុំនាទីសេតូន ។ ដូច្នេះហើយបានជាគេចាត់ទុកកាបូនអ៊ីដ្រាតថាជាអង្គធាតុស្រឡាយប៉ូលីអ៊ីដ្រុកស៊ីអាល់ដេអ៊ីត ឬប៉ូលីអ៊ីដ្រុកស៊ីសេតូន ។

  គេចែកកាបូនអ៊ីដ្រាត ជាម៉ូណូសាការីត ឌីសាការីត និងប៉ូលីសាការីត ។

  ម៉ូណូសាការីត : ជាកាបូនអ៊ីដ្រាតដែលមិនអាចរងអ៊ីដ្រូលីស ដើម្បីផ្ដល់ជាកាបូនអ៊ីដ្រាតដែលតូចជាង ។

  ឌីសាការីត : ជាកាបូនអ៊ីដ្រាត ដែលរងអ៊ីដ្រូលីសបានអិចសូសពីរ ។

  ប៉ូលីសាការីត : ជាប៉ូលីមែធម្មជាតិ ដែលមានរូបមន្ត $(C_6H_{10}O_5)_n$ ។ វារងអ៊ីដ្រូលីសផ្ដល់ជាម៉ូណូសាការីត ។

- លីពីត : ជាសារធាតុដែលគេជួបប្រទះក្នុងភាវៈរស់ ។ វាមិនរលាយក្នុងទឹក តែរលាយក្នុងអង្គធាតុរំលាយសរីរាង្គ ។

  ក្នុងម៉ូលេគុលលីពីតមានបង្គុំនាទីផ្សេងៗជាច្រើន ។

  លីពីតមានពីរក្រុម : លីពីតទោលនិងលីពីតសាំញ៉ាំ ។

  លីពីតទោល : ពិបាករងអ៊ីដ្រូលីស ដោយសូលុយស្យុងអាស៊ីត ឬបាស ។

  លីពីតសាំញ៉ាំ : ងាយរងអ៊ីដ្រូលីស ផ្ដល់ជាធាតុបង្ក ។

## សំណួរនិងលំហាត់

1. ចូរសរសេរសមីការអុកស៊ីតកម្មគ្លុយកូស ដោយធាតុបន្ទាល់តូឡង់ (សូលុយស្យុង $AgNO_3$ ក្នុងទឹកអាម៉ូញ៉ាក់) ។

2. គេមានសូលុយស្យុងសាការ៉ូសនិងគ្លុយកូស ។ តើតាមវិធីគីមីដូចម្តេចដែលអ្នកអាចស្គាល់សូលុយស្យុងនីមួយៗបាន ?

3. អ៊ីដ្រូលីសអាមីដុងនាំឱ្យបានជាគ្លុយកូស ។ អាមីដុងទាំងអស់បានប្លែងជាគ្លុយកូស ។ តើម៉ាសសរុបនៃគ្លុយកូសតិចជាង ឬច្រើនជាង ឬស្មើម៉ាសអាមីដុងដែលចូលធ្វើប្រតិកម្ម ? បញ្ជាក់អំណះអំណាងរបស់អ្នក ។

4. សរសេរសមីការប្រតិកម្មដែលនាំឱ្យមានកំណអេទីលអាល់កុល ដោយផ្តើមចេញពីអាមីដុង ។

5. គណនាចំនួនម៉ូណូមែ n ចំពោះសរសៃកប្បាស ដែល $M = 1750000 g\ mol^{-1}$ និងសរសៃខ្សែន ដែល $M = 5900000 g\ mol^{-1}$ ។

6. លីពីតទោលក៏មានម៉ូលេគុលសាញ៉ាំដែរ ប៉ុន្តែហេតុដូចម្តេចបានជាគេឱ្យឈ្មោះថា លីពីតទោល?

## ❓ សំណួរនិងលំហាត់ជំពូក 6

I. ចូរគូសសញ្ញា ✓ក្នុងប្រអប់ខាងមុខចម្លើយត្រឹមត្រូវដែលមានតែមួយគត់ ៖

1. ក្នុងចំណោមសារធាតុខាងក្រោម តើណាមួយជារូបមន្តអាមីត ?

☐ ក. $CH_3-\underset{NH_2}{\underset{|}{CH}}-CH_3$ ☐ ខ. $CH_3-CH_2-\underset{O}{\underset{\|}{C}}-NH_2$

☐ គ. $CH_3-\underset{NH_2}{\underset{|}{CH}}-COOH$ ☐ ឃ. $CH_3-\underset{O}{\underset{\|}{C}}-O-C_2H_5$

2. ក្នុងចំណោមលក្ខណៈខាងក្រោម តើណាមួយដែលមិនមែនជាលក្ខណៈរបស់អេស្ទែ ៖

☐ ក. មិនអាចបង្កើតសម្ព័ន្ធអ៊ីដ្រូសែនរវាងម៉ូលេគុលបាន

☐ ខ. មានក្លិនជាទីគាប់ចិត្ត

☐ គ. រងអ៊ីដ្រូលីសផ្ដល់ជាធាតុបង្ក

☐ ឃ. មានចំណុចរំពុះខ្ពស់ជាងអាស៊ីតបង្ក ។

3. ក្នុងចំណោមសារធាតុខាងក្រោម តើណាមួយដែលមិនមែនជាប៉ូលីសាការីត ?

☐ ក. អាមីដុង ☐ ខ. សែលុយឡូស

☐ គ. ព្រុចតូស ☐ ឃ. គ្លីកូសែន ។

4. អង្គធាតុមួយមានរូបមន្ត $CH_2OH-\underset{O}{\underset{\|}{C}}-CHOH-CH_2OH$ តើវាមានឈ្មោះដូចម្ដេច ?

☐ ក. អាល់ដូសតេត្រូស ☐ ខ. សេតូសតេត្រូស

☐ គ. គ្លុយកូស ☐ ឃ. អាល់ដូស ។

II. ចូរបំពេញល្បះខាងក្រោមឱ្យមានន័យត្រឹមត្រូវ ៖

1. កាបូនអ៊ីដ្រាត ផ្សំឡើងដោយធាតុ . . . . . . . . . . . . . ។

2. បង្គុំនាទីដែលគេជួបប្រទះក្នុងកាបូនអ៊ីដ្រាតមាន . . . . . . . . . . . . . . . . . . . . . . . . . និង . . . . . . . . . ។

3. ប្រភពថាមពលសម្រាប់រស្មីសំយោគគឺ . . . . . . . ។

**III. លំហាត់**

1. តេត្រាប៉ិបទីតមួយមានរូបមន្ត H – Phe – Ser – Gly – Ala – OH
ចូរសរសេររូបមន្តស្ទើរលាតរបស់តេត្រាប៉ិបទីតនេះ និងគណនាម៉ាសម៉ូលរបស់វា ។

2. អ៊ុយរ៉េ អាចធ្វើឡើងតាមប្រតិកម្មរវាងផូសែន ($COCl_2$) និងអាម៉ូញ៉ាក់តាមសមីការ :

$$Cl-\underset{\underset{O}{\|}}{C}-Cl + 2NH_3 \longrightarrow H_2N-\underset{\underset{O}{\|}}{C}-NH_2 + 2HCl$$

តេឱ្យអាម៉ូញ៉ាក់ 56L នៅលក្ខខណ្ឌធម្មតា ធ្វើប្រតិកម្មជាមួយបរិមាណគ្រប់គ្រាន់របស់ផូសែន ។គេរំលាយអ៊ុយរេ ដែលទទួលបានក្នុងទឹក 500g ។ ចូរគណនាកំហាប់ភាគរយនៃសូលុយស្យុងទទួលបាន ?

**ចម្លើយ** : 15 %

3. បើគេឱ្យអាស៊ីតអាសេទិច 12g មានប្រតិកម្មជាមួយបរិមាណគ្រប់គ្រាន់នៃអេទីលអាល់កុល គេទទួលបានអេទីលអាសេតាត 10.56g ។ ចូរគណនាទិន្នផលនៃប្រតិកម្ម ។ **ចម្លើយ** : 60 %

4. តើគេត្រូវប្រើសូលុយស្យុងស៊ូតកំហាប់ 20 % ប៉ុន្មានក្រាមដើម្បីបន្សាបអាស៊ីតខ្លាញ់ ដែលទទួលបានពីអ៊ីដ្រូលីសខ្លាញ់មួយបែបចំនួន 176.8g ។
គេឱ្យម៉ាសម៉ូលខ្លាញ់ 884g ។
**ចម្លើយ** : 120g

5. ការវិភាគ α – អាមីណូអាស៊ីតមួយបានលទ្ធផលដូចតទៅ : C = 40.45 % N = 15.72 % O = 35.98 % និង H = 7.56 % ។ តើ α – អាមីណូអាស៊ីតនេះមានរូបមន្តដូចម្តេច ?
**ចម្លើយ** : $CH_3-\underset{\underset{NH_2}{|}}{CH}-COOH$

6. ដើម្បីធ្វើអាសេតាមីត 14.75g គេត្រូវប្រើសូលុយស្យុងអាស៊ីតអាសេទិច 500mL ។ តើសូលុយស្យុងអាស៊ីតនេះមានកំហាប់ជាម៉ូលប៉ុន្មាន ? **ចម្លើយ** : $0.5 mol\ L^{-1}$

7. អាល់ដូសមួយមានរូបមន្តទូទៅ $C_nH_{2n}O_n$ ។ បើគេឱ្យអាល់ដូសនេះ 3.6g ធ្វើប្រតិកម្មជាមួយទឹកផេលីញ វាបង្កើតបានកករ $Cu_2O$ ចំនួន 2.86g ។ តើអាល់ដូសនោះមានរូបមន្តដូចម្តេច ?
**ចម្លើយ** : $C_6H_{12}O_6$

8. ក្នុងពេលល្បើងគ្លុយកូស 0.1mol បង្កើតបានឧស្ម័នកាបូនឌីអុកស៊ីតដែលត្រូវស្រូបដោយទឹកកំបោរថ្លា ។

ក. ចូរសរសេរសមីការតាងប្រតិកម្មដែលកើតមាន ។

ខ. គណនាម៉ាសកាល់ស្យូមកាបូណាតដែលកកើត ។

9. បើគេឱ្យល្បាយអាល់កុលនិងបង់ស៊ីលអាល់កុល ធ្វើប្រតិកម្មជាមួយលោហៈសូដ្យូម គេទទួលបានអ៊ីដ្រូសែន 7.38L នៅសីតុណ្ហភាព 27°C និងសម្ពាធ 0.5atm ។ ចូររកសមាសភាពភាគរយជាម៉ាសនៃផេណុលក្នុងល្បាយ ? ចម្លើយ : 30.3 %

10. តើគេត្រូវប្រើអាស៊ីតបង់សូអ៊ិចប៉ុន្មានក្រាម ដែលត្រូវរំលាយក្នុងទឹកបង្កើតបានសូលុយស្យុង 400mL ដែលមាន pH = 3 ?

គេឱ្យ : $K_a = 6.6 \times 10^{-5}$ ចម្លើយ : 0.785g